**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université royale de Droit et des Sciences économiques

Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# សុំកូននៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី ០៣ ខែមេសាឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០១៧


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ  កញ្ញា **រិន បូរី**

សាស្ត្រាចារ្យណែនាំ

លោក **គង សុីផាន់ណារ៉ា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៧

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេរសារណា ២០១៧

# លិខិតថ្លែងអំណរគុណ

៙

នាងខ្ញុំឈ្មោះ **រិន មុរី** ជានិស្សិតបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រទី៤ ជំនាន់ទី១៧ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាល័យសេដ្ឋកិច្ចក្នុងឆ្នាំសិក្សា ២០១៦ - ២០១៧ សូមថ្លែងអំណរគុណជូនចំពោះ ៖

ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមគ្រួសារជាពិសេសលោកឪពុក **រួន សារិន** អ្នកម្តាយ **សំ សោភ័ណ្ឌា** ដែលលោក ជាអ្នកមានគុណយ៉ាងលើសលុបបំផុត គ្មានថ្ងៃណាកូនបំភ្លេចបានឡើយ។

លោកឪពុកអ្នកម្តាយ ដែលលោកទាំងពីរមានគុណដ៏ឧដ្តុងឧត្តមជាទីបំផុតចំពោះកូនៗ ដែលលោកបានផ្តល់កំណើតដល់រូបយើងខ្ញុំ ហើយបានខិតខំលះបង់កម្លាំងញើសឈាមក្នុងការចិញ្ចឹមបីបាច់ថែរក្សាទំនុកបម្រុងរបស់រូបកូនៗ ទាំងស្មារតី និងសម្ភារៈជាពន់ពេក។ លើសពីនេះទៅទៀត លោកទាំងពីរបានអប់រំទូន្មានប្រៀនប្រដៅប្រកបដោយព្រហ្មវិហារធម៌គឺ មេត្តា ករុណា មុទិតា និងឧបេក្ខា ដ៏ល្អប្រពៃពេញមួយជីវិតស្ទើរតែក្លាយជាមហាសមុទ្រដែលរូបនាងខ្ញុំជាកូនៗ មិនអាចហែលឆ្លងបានឡើយ។ លោកទាំងពីរបានលះបង់ទ្រព្យធនទាំងឡាយដែលលោកទាំងពីរបានខិតខំស្វែងរកក្រោមកម្តៅព្រះអាទិត្យសម្រាប់ធ្វើការឧបត្ថម្ភ និងលើកទឹកចិត្តមកលើរូបយើងខ្ញុំចំពោះការសិក្សាអស់រយៈពេល១៦ឆ្នាំ ចាប់តាំងពីថ្នាក់បឋមសិក្សា រហូតដល់បញ្ចប់ថ្នាក់ឧត្តមសិក្សាប្រកបដោយភាពជោគជ័យត្រចះត្រចង់ដូចនេះ និងដើម្បីឱ្យរូបនាងខ្ញុំបានក្លាយបញ្ញាវ័ន្តមួយរូបដែលមានវិជ្ជាជីវៈ និងចំណេះជំនាញមួយច្បាស់លាស់ប្រកបដោយសីលធម៌ គុណធម៌ និងសច្ចធម៌សម្រាប់សង្គម។ ស្របពេលជាមួយគ្នានេះដែរ នាងខ្ញុំជាកូនៗ សូមធ្វើការក្រាបលំឱនកាយគោរពនូវមហាគុណាទិគុណដ៏មហិមាទាំងអស់នេះ ដែលបានធ្វើឱ្យរូបយើងខ្ញុំជាកូនៗនេះចងចាំជានិច្ចចំពោះការលះបង់គ្មានទីបញ្ចប់ និងដ៏ធំធេង ដើម្បីជួយជ្រោមជ្រែងជីវិតរបស់នាងខ្ញុំជាកូនៗបានទទួលនូវផ្លែផ្កាដែលជាលទ្ធផលដ៏វិសេសវិសាល សម្រាប់ជាទុនក្នុងការប្រកបរបរចិញ្ចឹមជីវិត ដ៏ដូចជា ជាសកម្មភាពយ៉ាងសកម្មសម្រាប់ជួយអភិវឌ្ឍប្រទេសជាតិ ឱ្យស្របទៅតាមកាលានុវត្តភាពនៃទិដ្ឋភាពសង្គមផងដែរ។

លោកនាយក នាយករង លោកគ្រូ អ្នកគ្រូ នៃសាលាបឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ ទាំងអស់ដែលបានបង្ហាត់បង្រៀន និងផ្តល់នូវចំណេះដឹងជាមូលដ្ឋានគ្រឹះ សម្រាប់រូបយើងខ្ញុំជាសិស្សក្រេបយកចំណេះវិជ្ជា ដែលជាមាគ៌ាឱ្យរូបនាងខ្ញុំបានសម្រេចបន្តឆ្ពោះមកកាន់សាកលវិទ្យាល័យ។

បន្ទាប់មក នាងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោកគ្រូ អ្នកគ្រូ ទាំងអស់ដែលបានបង្ហាត់បង្រៀនដល់រូបនាងខ្ញុំ តាំងពីបឋមសិក្សា រហូតដល់បញ្ចប់វិទ្យាល័យ ប្រកបដោយភាពជោគជ័យ។ ពិសេស ក៏សូមថ្លែងអំណរគុណផងដែរចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងលោកគ្រូ អ្នកគ្រូ** និងសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ទាំងអស់ដែលមានខិតខំអស់កំលាំង-កាយចិត្តក្នុងការផ្ទេរនូវចំណេះដឹងដល់និស្សិតគ្រប់រូប ពិសេសរូបនាងខ្ញុំរហូតចប់ មហាវិទ្យាល័យនីតិសាស្ត្រនេះ ។ លើសពីនេះទៅទៀត នាងខ្ញុំក៏សូមគោរព និងដឹងគុណយ៉ាងជ្រាលជ្រៅផងដែរចំពោះលោកសាស្ត្រាចារ្យ **កង ស៊ីផាន់ណារ៉ា** បានណែនាំសារណាបញ្ចប់ការសិក្សាលើចំណងជើងប្រធានបទមួយនេះ។ លោកបានផ្តល់នូវដំបូន្មានល្អៗ នូវរបៀបក៏ដូចជា គន្លឹះស្វែងរកឯកសារវិធីសាស្ត្រនិងការចងក្រងសារណា និងការកែលំអរឲ្យកាន់តែល្អថែមទៀត។ នាងខ្ញុំក៏ សូមអគុណចំពោះ លោក លោកស្រីបណ្ណារក្ស រាមច្បងនិស្សិតថ្នាក់នីតិសាស្ត្រ និងមិត្តរួមថ្នាក់ទាំងអស់ដែលបានជួយផ្តល់ជាមតិយោបល់ និងឯកសារដែលទាក់ទងទៅនឹងប្រធានបទនេះ សម្រាប់ជាទុនក្នុងការធ្វើសារណានេះ ដើម្បីបន្សល់ទុកជាឯកសារបន្តសម្រាប់មិត្តនិស្សិតជំនាន់ក្រោយ។

ជាទីបញ្ចប់យើងខ្ញុំទាំងអស់សូមធ្វើការខន្តីអភ័យទោសនូវរាល់ចំនុចអវិជ្ជមាន រួមមានពាក្យពេចន៍ អក្ខរាវិរុទ្ធដែលកើតមានឡើងដោយកំហុសអចេតនា ស្របពេលជាមួយគ្នានេះយើងខ្ញុំសូមបួងសួង ដល់វត្ថុស័ក្តសិទ្ធទាំងអស់នៅក្នុងលោក ព្រមទាំងទេវតាទាំងប្រាំបីទិស ប្រសិទ្ធពរជ័យ សិរីសួស្តី ជ័យមង្គល វិបុលសុខគ្រប់ប្រការកើតមានដល់ចំពោះលោកអ្នកមានគុណទាំងពីរ ព្រមទាំងលោក **ឯកឧត្តមសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងលោកគ្រូ អ្នកគ្រូ លោកសាស្ត្រាចារ្យ** ទាំងអស់ប្រកបដោយសេចក្តីសុខ និងសម្រេចនូវរាល់បំណងប្រាថ្នាទាំងពួង។

# អារម្ភកថា

៣៙៤

សារណាបញ្ចប់ឆ្នាំសិក្សា គឺជាគោលបំណងនាងខ្ញុំតាំងពីឆ្នាំទីមួយមកម្ល៉េះ ទោះបីជាពេលវេលាពុំទាន់អនុញ្ញាតអោយ នាងខ្ញុំអាចសំរេចចិត្តនៅឡើយអំពីការជ្រើសរើសប្រធានបទ។ ឥលូវឪកាសនេះបានមកដល់ហើយ ដែលជាហេតុតំរូវឲ្យនាងខ្ញុំផ្ទាល់ ធ្វើការសំរេចចិត្តជ្រើសរើសប្រធានបទសារណាអំពី **សុំកូននៅកម្ពុជា** ។ ប្រធានបទមួយនេះ គឺជាកម្មវត្ថុចំបងមួយផ្តោតទៅលើកុមារនៅកម្ពុជាយើង។ កុមារគ្រប់រូប ទោះបីជាកុមារកំព្រា កុមារងាយរងគ្រោះ ឬ ជាកូនសុំក្តី ត្រូវតែទទួលបាននូវការយកចិត្តទុកដាក់គាំពារថែរក្សាយ៉ាងកក់ក្តៅទាំងនៅក្នុងគ្រួសារ និងសហគមន៍ ។ ម្យ៉ាងទៀត វាបានផ្តោតសំខាន់ទៅលើឧត្តមប្រយោជន៍ និងអនាគតរបស់កុមារទាំងនោះ។ ទាំងនេះហើយជាហេតុធ្វើអោយរដ្ឋាភិបាល បណ្តាអង្គការក្រៅរាជរដ្ឋាភិបាលក្តី ខិតខំបង្កើត ច្បាប់ជាតិ អនុក្រឹត្យ និងបទដ្ឋានគតិយុត្ត ក្រសួង ដែលពាក់ព័ន្ធ នឹងការសុំកូន ពិសេសក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវតីសម្បទា ។

នាងខ្ញុំជឿជាក់ថា ការស្រាវជ្រាវនេះពិតជាអាចជួយជាជំនួយដល់អ្នកសិក្សាស្វែងយល់ ក៏ដូចជា អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយជាក់ជាពុំខាន ហើយការដែលនាងខ្ញុំ លើកយកប្រធានបទនេះឡើង គឺពឹងផ្អែកលើចំណេះដឹងផ្ទាល់ខ្លួន បូករួមឯកសារជាមូលដ្ឋានដទៃទៀតជាច្រើន ដើម្បីស្រាយជាចំងល់ដល់ខ្លួនឯង និង បំភ្លឺផ្លូវដល់បងប្អូននិស្សិត ក៏ដូចជា ប្រជាពលរដ្ឋខ្មែរ ដែលចង់យល់ច្បាស់ពីបញ្ហាសុំកូនស្របពេលដែលពួកគាត់មានបំណងសុំកូន និងធ្វើយ៉ាងណាលើកស្ទួយជីវិតដ៏ទន់ខ្សោយរបស់កុមារដែលជាកូនសុំបានទទួលជីវិតល្អថ្មីមួយទៀតដ៏ភ្លឺស្វាង។

គ្មានអ្វីដែលល្អឥតខ្ចោះនោះទេ កំហុសនៅតែបន្តមាន ដូច្នេះក្នុងនាមនាងខ្ញុំ ជាអ្នកចងក្រងឯកសារនេះ កំហុសឆ្គងទាំងឡាយណាដែលកើតឡើងដោយអចេតនា ទាំងអក្ខរាវិរុទ្ធ ទាំងការប្រើពាក្យពេជន៍ខ្លឹមសារ ឬអត្ថន័យក្នុងអត្ថបទក្តី ជៀសមិនផុតយកឡើយ។ ដូច្នេះ សូមមេត្តាអធ្យាស្រ័យនិងជួយកែតំរូវផងដើម្បីឲ្យស្នាដៃមួយនេះបានល្អប្រសើរជាងនេះ ហើយនាងខ្ញុំរង់ចាំទទួលនូវរាល់ការរិះគុណ និងស្លាបនាក្នុងន័យកែលំអដើម្បីឲ្យអត្ថបទនេះកាន់តែសុក្រឹត្យឡើង។

# មាតិកា


ទំព័រ

**សេចក្តីផ្តើម**……………………………………………………………………………………១

## ជំពូកទី១ ទ្រឹស្តីទូទៅ និង ស្នំកូនរវាងពលរដ្ឋខ្មែរ និង ពលរដ្ឋខ្មែរ

**ផ្នែកទី១ ទស្សនៈទានទូទៅនៃស្នំកូន** ………………………………………………………………៣

**កថាខណ្ឌទី១ និយមន័យនៃស្នំកូន**…………………………………………………………………៤

១. គោលបំណងនៃការស្នំកូន…………………………………………………………………………៤

២. ទិដ្ឋភាពទូទៅនៃស្នំកូន………………………………………………………………………………៤

៣. លក្ខណៈពិសេសនៃស្នំកូន…………………………………………………………………………៥

**កថាខណ្ឌទី២ ប្រភេទ និង សារៈសំខាន់នៃស្នំកូន**……………………………………………៥

១. ប្រភេទនៃស្នំកូន………………………………………………………………………………………៥

២. សារៈសំខាន់នៃស្នំកូន………………………………………………………………………………៦

**កថាខណ្ឌទី៣ វត្តមាននៃរបបស្នំកូននៅក្នុងប្រព័ន្ធគតិយុត្តកម្ពុជា**……………………………៧

១. ប្រព័ន្ធគតិយុត្តកម្ពុជា…………………………………………………………………………………៧

២. ការវិវត្តន៍នៃដំណើរគតិយុត្តស្នំកូន……………………………………………………………………៨

**កថាខណ្ឌទី៤ យុទ្ធសាស្រ្តដើម្បីការពារចំពោះការសុំ**………………………………………………១០

**ផ្នែកទី២ ស្នំកូនពេញលេញ**……………………………………………………………………………១០

**កថាខណ្ឌទី១ សញ្ញាណទូទៅនៃស្នំកូនពេញលេញ**……………………………………………………១០

១. គោលបំណងនៃការបង្កើតរបបស្នំកូនពេញលេញ……………………………………………………១០

១.១ ការពារផលប្រយោជន៍ស្នំកូនពេញលេញ…………………………………………………………១១

១.២ ការផ្តល់នូវគ្រួសារថ្មីដ៏ល្អ…………………………………………………………………………១១

២. ប្រវត្តិនៃរបបស្នំកូនក្នុងនីតិកម្មកម្ពុជា………………………………………………………………១១

**កថាខណ្ឌទី២ ល័ក្ខខ័ណ្ឌសារធាតុនៃសុំកូនពេញលេញ**……………………………..១២
១. ល័ក្ខខ័ណ្ឌទាក់ទងនឹងឪពុកម្ដាយចិញ្ចឹម……………………………………………..១២
១. ១ ភាពមានសហព័ទ្ធ និងការសហការ……………………………………………..១២
១.២ អាយុរបស់ឪពុកម្ដាយចិញ្ចឹម……………………………………………………..១៤
១.៣ ភាពដែលអាចធ្វើអោយទុកចិត្តបាននូវការផ្ដល់ការថែទាំកូនសុំ……………………..១៥
២. ល័ក្ខខ័ណ្ឌទាក់ទងនឹងកូនសុំ…………………………………………………………..១៦
២.១ អាយុរបស់កូនសុំ…………………………………………………………………..១៦
២.២ តម្រូវការ ការថែទាំជាពិសេស……………………………………………………..១៧
៣. លក្ខ័ខ័ណ្ឌទម្រង់នៃសុំកូនពេញលេញ…………………………………………………..១៨
៣.១ ភាគីនៃពាក្យសុំ……………………………………………………………………..១៨
៣.២ ចំណុចដែលត្រូវសរសេរក្នុងពាក្យសុំ……………………………………………..១៩
៣.៣ ការវិនិច្ឆ័យលើពាក្យសុំ ……………………………………………………………..២០
៣.៤ ការចាត់ចែងរក្សាការពារនៅមុខពេលដីការសម្រេចចាប់សុំកូនមានអានុភាព…២០
៣.៥ ការចេញដីកាសម្រេច………………………………………………………………..២១
**កថាខណ្ឌទី៣ អានុភាពនៃសុំកូនពេញលេញ**………………………………………..២២
១. ការបង្កើតទំនាក់ទំនងជាមួយឪពុកម្ដាយចិញ្ចឹម…………………………………………..២២
២. ការកាត់ផ្ដាច់ទំនាក់ទំនងញាតិ……………………………………………………………..២៣
៣. ការផ្ទេរអំណាចមេបា…………………………………………………………………..២៤
៤. ការកាត់កាល់សុំកូនពេញលេញ…………………………………………………………..២៥
៤.១.ល័ក្ខខ័ណ្ឌក្នុងការកាត់កាល់សុំកូនពេញលេញ………………………………………..២៥
៤.១.ក.ល័ក្ខខ័ណ្ឌសារធាតុ……………………………………………………………..២៥
៤.១.ខ. ល័ក្ខខ័ណ្ឌទម្រង់……………………………………………………………..២៥
៤.២.លក្ខណៈសម្បត្តិជាភាគី…………………………………………………………..២៥
៤ .២.ក.ការដាក់ពាក្យបណ្ដឹង និងចំណុចដែលត្រូវសរសេរ……………………..២៦
៤.២. ខ.ការវិនិច្ឆ័យលើបណ្ដឹងកាត់កាល់……………………………………..២៧
៥. អានុភាពនៃការកាត់កាល…………………………………………………………..២៧

**ផ្នែកទី៣ ស្មុំកូនធម្មតា**……………………………………………………………..២៨

**កថាខណ្ឌទី១ សញ្ញាណទូទៅនៃស្មុំកូនធម្មតា**…………………………………………..២៨

១. និយមន័យ……………………………………………………………………………..២៨

២. លក្ខណៈពិសេសនៃស្មុំកូនធម្មតា……………………………………………………..២៨

**កថាខណ្ឌទី២ លក្ខខណ្ឌនៃការបង្កើតស្មុំកូនធម្មតា**……………………………………..២៨

១. អាយុរបស់ឪពុកម្ដាយចិញ្ចឹម…………………………………………………………..២៩

២. អាយុរបស់កូនសុំ…………………………………………………………………….២៩

៣. ការចូលរួមរបស់សហព័ទ្ធក្នុងករណីជនដែលនឹងក្លាយជាឪពុកម្ដាយមានសហព័ទ្ធ..២៩

៤. ការចូលរួមរបស់ឪពុកម្ដាយបង្កើតរបស់កូនសុំ………………………………………..៣០

៥. មូលដ្ឋានវិនិច្ឆ័យដែលតុលាការនឹងពិចារណា…………………………………………..៣០

**កថាខណ្ឌទី៣ អានុភាពនៃស្មុំកូនធម្មតា**…………………………………………………..៣១

១. បង្កើតញាតិភាពជាមួយឪពុកម្ដាយចិញ្ចឹម……………………………………………..៣១

២. ការបន្តញាតិភាពជាមួយឪពុកម្ដាយបង្កើត…………………………………………….៣១

**កថាខណ្ឌទី៤ ការកាត់កាលស្មុំកូនធម្មតា**…………………………………………………..៣១

១. មូលហេតុ និងការវិនិច្ឆ័យនៃកាត់កាល់ស្មុំកូនធម្មតា…………………………………..៣១

២. ពាក្យសុំឲ្យកាត់កាល់ស្មុំកូនធម្មតា……………………………………………………..៣២

៣.ល័ក្ខខ័ណ្ឌនៃកាត់កាល់ស្មុំកូនធម្មតា……………………………………………………..៣២

៤. អានុភាពនៃកាត់កាល់កូនធម្មតា…………………………………………………………..៣៣

## ជំពូកទី២ ស្មុំកូនអន្តរប្រទេស

**ផ្នែកទី១ សញ្ញាណទូទៅនៃការស្មុំកូនអន្តរប្រទេស**……………………………………..៣៧

**កថាខណ្ឌទី១ គោលការណ៍ទូទៅនៃស្មុំកូនអន្តរប្រទេស** ……………………………..៣៧

**កថាខណ្ឌទី២ គោលបំណងនៃការបង្កើតស្មុំកូនអន្តរប្រទេស**………………………..៣៩

**កថាខណ្ឌទី៣ ដំណើរការវិវត្តន៍នៃនីតិសុំកូនអន្តរប្រទេស**……………………………………៤០

**កថាខណ្ឌទី៤ លក្ខខណ្ឌសម្រាប់សុំកូនអន្តរប្រទេស**……………………………………………៤១

១. អំពីកូនសុំ……………………………………………………………………………………………៤១

១.១.លក្ខខណ្ឌផ្សេងៗ ……………………………………………………………………………៤៣

១.១.១ ការព្រមព្រៀង ………………………………………………………………………៤៣

១.១.២ សមត្ថកិច្ចផ្តល់ទីប្រឹក្សា…………………………………………………………………៤៣

១.១.៣ ករណីកុមារកំព្រាយកទៅចិញ្ចឹមជាកូននៅបរទេស……………………………………៤៤

ក.លក្ខខណ្ឌចំពោះអ្នកសុំ…………………………………………………………………៤៤

ខ.លក្ខខណ្ឌចំពោះកូនសុំ…………………………………………………………………៤៤

គ.បែបបទនៃការស្នើរសុំ ………………………………………………………………៤៥

២. ឪពុកម្តាយបង្កើត ឬ អាណាព្យាបាល……………………………………………………………៤៦

៣.អំពីអ្នកសុំ………………………………………………………………………………………………៤៨

**ផ្នែកទី២ អាជ្ញាធរមានសមត្ថកិច្ចក្នុងកិច្ចការសុំកូនអន្តរប្រទេស**……………………………………៤៩

**កថាខណ្ឌទី១ អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស**……………………………………………………៤៩

១. ភារកិច្ចរបស់អាជ្ញាធររដ្ឋបាលកណ្តាលសុំកូនអន្តរប្រទេស…………………………………………៥០

២. គណៈកម្មាធិការកណ្តាលសុំកូនអន្តរប្រទេស……………………………………………………៥១

**កថាខណ្ឌទី២ រដ្ឋបាលសុំកូនអន្តរប្រទេស**………………………………………………………………៥១

១. សមាសភាព…………………………………………………………………………………………៥២

២. តួនាទី ភារកិច្ចរបស់រដ្ឋបាលសុំកូនអន្តរប្រទេស…………………………………………………៥២

**កថាខណ្ឌទី៣ អំពីទីភ្នាក់ងារសុំកូនអន្តរប្រទេស**…………………………………………………………៥៤

១. លក្ខណៈសម្បត្តិរបស់ទីភ្នាក់ងារសុំកូនអន្តរប្រទេស………………………………………………៥៤

២. ការដាក់ពាក្យសុំធ្វើប្រតិបត្តិការជាមួយទីភ្នាក់ងារសុំកូនអន្តរប្រទេស………………………………៥៥

**កថាខណ្ឌទី៤ អាជ្ញាធរផ្តល់អនុញ្ញាតឲ្យទីភ្នាក់ងារសុំកូនអន្តរប្រទេស** ………………………៥៥

**កថាខណ្ឌទី៥ ទោសប្បញ្ញត្តិ**……………………………………………………………………………៥៦

១. ការពិន័យជាប្រាក់……………………………………………………………………៥៧

២. ការពិន័យព្រហ្មទណ្ឌ…………………………………………………………………៥៩

**ផ្នែកទី៣ នីតិវិធីនៃការបង្កើតសុំកូនអន្តរប្រទេស**……………………………………………៦០

**កថាខណ្ឌទី១ បែបបទនៃការបង្កើតសុំកូនអន្តរប្រទេស**…………………………………៦០

១.ការដាក់ពាក្យ……………………………………………………………………………៦០

២.ការពិនិត្យពាក្យសុំ………………………………………………………………………៦១

៣.ការសម្រេចលើពាក្យសុំ…………………………………………………………………៦២

**កថាខណ្ឌទី២ ការស្នើសុំសេចក្តីសម្រេចបង្កើតសុំកូនអន្តរប្រទេស**…………………………៦៤

១.ស្ថាប័នអនុវត្ត……………………………………………………………………………៦៤

២.ការពិនិត្យភស្តុតាង………………………………………………………………………៦៥

៣. ដីកាសម្រេច……………………………………………………………………………៦៦

៤.សោហ៊ុយលើការសុំកូន……………………………………………………………………៦៧

**កថាខណ្ឌទី៣ កុមារក្រោយពេលទៅដល់ក្រៅប្រទេស**…………………………………………៦៨

**ផ្នែកទី៤ ផលវិជ្ជមាន និង អវិជ្ជមាននៃសុំកូនអន្តរប្រទេស**……………………………………៦៩

**កថាខណ្ឌទី១ ផលប្រយោជន៍នៃការសុំកូនអន្តរប្រទេស**……………………………………៧០

១. ផលប្រយោជន៍ចំពោះឪពុក និងម្តាយបង្កើត…………………………………………………៧០

២. ផលប្រយោជន៍ចំពោះកូនសុំ………………………………………………………………៧២

៣. ផលប្រយោជន៍ចំពោះអ្នកសុំ………………………………………………………………៧៣

**កថាខណ្ឌទី២ គុណវិបត្តិនៃសុំកូនអន្តរប្រទេស**………………………………………………៧៤

១. គុណវិបត្តិចំពោះឪពុក ឬនិងម្តាយបង្កើត……………………………………………………៧៤

២. គុណវិបត្តិចំពោះកូនសុំ……………………………………………………………………៧៥

៣. គុណវិបត្តិចំពោះអ្នកសុំ……………………………………………………………………៧៥

**កថាខ័ណ្ឌទី៣ អានុភាពនៃសុំកូនអន្តរប្រទេស**…………………………………………………៧៦

សេចក្តីសន្និដ្ឋាន……………………………………………………………………………………………………………..………៨០
អនុសាសន៍…………………………………………………………………………………………..…………………..……៨១
ឯកសារយោង
ឧបសម្ព័ន្ធ

# ឯកសារយោង

## ១. បទដ្ឋានគតិយុត្តជាតិ

- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ២០០៧
- ច្បាប់ស្តីពី  ស្មុំកូនអន្តរប្រទេស ២០០៩
- ច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើអាជីវកម្មលើកុមារ
- ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩
- ច្បាប់ស្តីពី  រឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ( NSCC
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ២០០៩

## ២.អនុក្រឹត្យ

- អនុក្រឹត្យស្តី  ពីការសុំទារកកំព្រា ឬ កុមារកំព្រាយកទៅចិញ្ចឹមជាកូននៅបរទេស ២០០១

## ៣.ប្រកាស

- ប្រកាសស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលស្មុំកូនអន្តរប្រទេស លេខ ១២៣០ អ.ស.យ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ ១០១៤
- ប្រកាសស្តីពី    ការរៀបចំ  និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្តាលស្មុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា ស.អ.យ ចុះថ្ងៃទី៣០ ខែ មេសា ឆ្នាំ ២០១៣
- ប្រកាសស្តីពី  នីតិវិធីផ្តល់ការរៀបចំ  និង  ការប្រព្រឹត្តទៅរបស់រដ្ឋបាលស្មុំកូនអន្តរប្រទេស លេខ ១៩៨០ របស់ ក្រសួង ស អ យ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤
- សេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់ស្មុំកូនអន្តរប្រទេសរបស់ក្រសួង ស . អ  . យ .(២៧ កញ្ញា ២០០៥)

- ១១. សេចក្តីណែនាំស្តីពីទម្រង់បែបបទ និងគំរូលិខិតបទដ្ឋានសម្រាប់អនុវត្តប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួស ចំពោះកុមារ (ក្រោមកិច្ចសហការជាមួយអង្គការយូនីសេហ្វកម្ពុជា ខែ ឧសភា ឆ្នាំ ២០១៣)

**៤.បទដ្ឋានគតិយុត្តិអន្តរជាតិ**

- អនុសញ្ញាក្រុងឡាអេស្តីពី ការការពារកុមារ និង សហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស ត្រូវបានផ្តល់សច្ចាប័នយល់ព្រមដោយព្រះរាជាចក្រកម្ពុជានៅថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៧

**៥.សារណាបញ្ចប់ការសិក្សា**

- សារណាបញ្ចប់ការសិក្សា " **សុំកូន** " ស្រាវជ្រាវពីថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០១៥ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៥ ណែនាំដោយសាស្ត្រាចារ្យ **ញឹក វុធ្ធី**
- សារណាបញ្ចប់ការសិក្សា " **សុំកូនអន្តរប្រទេស** "ស្រាវជ្រាវពីថ្ងៃទី ០១ ខែមេសា ឆ្នា ២០១៥ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៥ណែនាំដោយសាស្ត្រាចារ្យ **គង់ សុភក្រ័**

**៦.វចនានុក្រម**

- ១៨. វចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត បោះពុម្ពលើកទី៥ ឆ្នាំ ១៩៦៧
- សទ្ទានុក្រមបារាំងខ្មែរនៃពាក្យរបស់លោកសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចឆ្នាំ ១៩៩៦

**៧.សិក្ខាសាលា**

- សិក្ខាសាលា ស្តីពីការផ្សព្វផ្សាយលិខិតបទដ្ឋាននានារបស់អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស( ២៦ កុម្ភៈ ២០១៤ )
- សិក្ខាសាលាស្តីពី ទំនាក់ទំនងបុគ្គភាព ក្នុងនោះក៏មានការធ្វើបទបង្ហាញស្តីពី **សុំកូន** (ថ្ងៃទី ២៨ ខែមិនា ឆ្នាំ២០១៥) ឧទ្ទេសនាមដោយៈ **មេធាវី ឆេព ម្ចូផល**

## ផ.គេហទំព័រ

- hhttp://adoption.law.com/gay-adoption (LGBT)
- hhtp://www.**Haque Convention.com**
- hhtp://www.facebook.com ,VOA Khmer/ Facebook.

# អនុសាសន៍

# សេចក្ដីសន្និដ្ឋាន

# ជំពូកទី១

## ទ្រឹស្តីទូទៅ  និង ស្ទុំកូនរទាខ

## ពលរដ្ឋខ្មែរ និង ពលរដ្ឋខ្មែរ

# ជំពូកទី២

# សុំកូនអន្តរប្រទេស

# ឯកសារយោង

# ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

# ច្បាប់

# ស្តីពី

# សុំកូនអន្តរប្រទេស

# អនុក្រឹត្យ

## ស្តីពីការសុំទារកកំព្រា

## ឬ កុមារកំព្រាយកទៅចិញ្ចឹមជា

## កូននៅបរទេស

# ប្រកាស

## នានារបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

# ប្រកាស

## ស្ដីពីការរៀបចំ និងការ
## ប្រព្រឹត្តទៅរបស់រដ្ឋបាលស្រុក
## ក្នុងអន្តរប្រទេស

# ប្រកាស

## ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ
## របស់អាជ្ញាធរកណ្តាលសុំកូនអន្តរ
## ប្រទេសនៃព្រះរាជាណាចក្រកម្ពុជា

# សេចក្តីផ្តើម

ពីដើមឡើយមនុស្សរស់នៅតែម្នាក់ឯង ឬជាមួយគ្នាបានសុខសាន្តដូចសត្វដែរ ជាសម័យកាលមិនទាន់កកើតមានជារដ្ឋ ជាប្រទេស ជាក្រុមហ៊ុន មនុស្សចេះស្រលាញ់ និងយល់ធុរៈគ្នាទៅវិញទៅមក ហើយបើបានវត្ថុអ្វីមកមិនបានគិតរំលែកទុកសម្រាប់ដល់ថ្ងៃស្អែកឡើយនៅពេលដែលបានផលប្រយោជន៍មកចេះចែកគ្នាដោយគ្មានការកិបកេងប្រវ័ញ្ចដណ្តើមគ្នា និង មិនបង្កឲ្យមានជម្លោះវិវាទនោះដែរ។

កាលពីដើមមនុស្សរស់នៅក្នុងសភាពធម្មជាតិយូរៗទៅស្រាប់តែមានការប្រែប្រួលពីធម្មជាតិអាចធ្វើឲ្យ គេជួបផលវិបាកក្នុងការរស់នៅ និងចិញ្ចឹមជីវិតគេក៏ចាប់ផ្តើមរកមធ្យោបាយផ្សេងៗកែច្នៃឧបករណ៍នានា និងចេះចិញ្ចឹមសត្វដាំដំណាំហើយគ្រប់គ្រងអោយបានល្អប្រសើរ។ នៅពេលគំនិតរបស់មនុស្សមានការវិវត្តន៍ និងកត្តាសេដ្ឋកិច្ចរីកចំរើនក៏ចាប់ផ្តើមកើតនូវការ ចង់មានចង់បានចង់ល្អតែឯង ឬរស់តែឯង និងដោយសារកត្តានៃការបែងចែក វណ្ណៈ ពណ៌សម្បុរ ក្រុម ឬដោយសារហេតុផល នយោបាយ កត្តាជីវភាព សេដ្ឋកិច្ច ច្បាប់ បានធ្វើឲ្យមនុស្សមួយចំនួនមិនចាប់អារម្មណ៍ក្នុងការកសាងគ្រួសារពិសេស ការរួមរស់នៅជាមួយគ្នាដោយពុំយកកូន ឬដោយសារហេតុផលស៊ែនរបស់គូភាគី។ ក្រោយមកទើមនុស្សចេះរស់នៅមានការប្រមូលផ្តុំគ្នា ជាក្រុម ជាពួក ជាហ្វូងរហូតដល់មានការបង្កើតជារដ្ឋ ជាប្រទេស ហើយមនុស្សចេះរស់នៅតាមបែបកិច្ចសន្យាសង្គម ដែលជាហេតុធ្វើឲ្យគ្រួសារ ឬមនុស្ស មួយចំនួនចេះស្រលាញ់ និងចង់មានកូនរស់នៅជាមួយពួកគេ ហើយជារឿយៗគេតែងតែសង្កេតឃើញថា គ្រួសារដែលគ្មានកូនមួយចំនួន រមែងសុំកូនពីអ្នកដទៃមកធ្វើជាកូនរបស់ខ្លួនតាមទម្រង់ផ្សេងៗគ្នា ដោយខ្លះតាមបែបប្រពៃណីទំនៀមទំលាប់ ខ្លះតាម ច្បាប់ ឬទម្រង់បទដ្ឋានមួយចំនួនទៀត ព្រោះហេតុនេះហើយក្នុងទីនេះ នាងខ្ញុំលើកយក **សុំកូននៅកម្ពុជា** មកធ្វើការសិក្សាស្រាវជ្រាវដើម្បីវិភាគទៅលើសារណា។

សុំកូនជាយន្តការដែលពាក់ព័ន្ធនឹងកុមារដែលត្រូវការនូវកិច្ចការពារពិសេស ពីព្រោះវាបានលើកកម្ពស់សុខុមាលភាពកុមារនៅកម្ពុជា ហេតុដូច្នេះ បានជាកម្ពុជាមានបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិជាច្រើន សំរាប់គ្រប់គ្រងលើវិស័យនេះ ។ សុំកូន មានចំនុចសំខាន់ៗដូចជា ល័ក្ខខ័ណ្ឌ នៃការបង្កើត ដែលឈានទៅរកអានុភាពនៃការសុំ ហើយវាក៏អាចឈានទៅរកការបញ្ចប់ផងដែរ នៅពេលមានការកាត់កាល់នោះ ។ ទោះបីជាយ៉ាងណាក្តីសុំកូនធ្វើឡើងដើម្បីជាគោលការណ៍មនុស្សធម៌សុទ្ធសាធ ។

តើសុំកូន មានគោលបំណង និង សារៈសំខាន់យ៉ាងដូចម្តេចខ្លះទៅលើកុមារ ដែលត្រូវ ការកុមារជាទំពាំងស្នងឬស្សី កិច្ចការពារពិសេសនោះ? តើវិស័យសុំកូនមានតាំងពីពេលណាមក ហើយ

រយៈពេលកន្លង មកមានច្បាប់ណាខ្លះ អនុវត្តទៅវិស័យសុំកូននេះ? តើការសុំកូន មានពាក់ព័ន្ធនឹងក្រសួង និង ស្ថាប័នណាខ្លះ?

សុំកូន មានគោលបំណងក្នុងការធានាបាននូវឧត្តមប្រយោជន៍ និងការការពារសិទ្ធិជាមូលដ្ឋានរបស់ក្មេងដូចជា កុមារដែលមានឪពុកម្តាយក្រីក្រ ជាពិសេសកុមារ ដែលត្រូវការកិច្ចការពារពិសេស ដើម្បីឲ្យពួកគេបានរស់នៅមជ្ឈដ្ឋានសមស្រប ឬ ការអភិវឌ្ឍន៍ពេញលេញ ក្នុងបរិយាកាសគ្រួសារថ្មីប្រកបដោយសុវត្ថិភាព សុភមង្គល សេចក្តីស្រលាញ់ និង ការយោគយល់។ ពិសេសទទួលបានការអប់រំ ដោយផ្សារភ្ជាប់នូវការយកចិត្តទុកដាក់ពីសំណាក់ស្ថាប័នជាតិ អន្តរជាតិ និងរួមទាំងអង្គការនានាក្តី ជាហេតុជំរុញឲ្យកុមារកំព្រា បានរស់នៅក្នុងមជ្ឈដ្ឋានគ្រួសារថ្មីដែលពោរពេញដោយការអាណិត និង ទទួលបានអនាគតភ្លឺស្វាងដូច កុមារដ៏ទៃទៀតដែរ។ ថែមពីលើនេះ គឺដើម្បីការពារឲ្យរួចផុតពីការរំលោភបំពានផ្សេងៗ ពិសេសឲ្យជៀសផុតពីការការជួយដូរ ការកេងប្រវ័ញ្ចកំលាំងពលកម្ម ជាដើម។

សារណាមួយនេះ ពិតជាមានសារៈសំខាន់ណាស់ចំពោះវិស័យសុំកូននៅកម្ពុជា។ ពីព្រោះនីតិវិធីនៃដំណើរការសុំកូន អាចប្រព្រឹត្តទៅបានលុះត្រាតែរាល់អ្នកដែលជាប់ពាក់ព័ន្ធ និង អាជ្ញាធរដែលមានសមត្ថកិច្ច តម្រូវឲ្យមានចំណេះដឹងគ្រាប់គ្រាន់តាមរយៈ ការសិក្សាស្វែងយល់។ អាស្រ័យហេតុ នេះបានជារាល់លិខិតដ្ឋានដែលទាក់ទងនឹងវិស័យសុំកូន ក៏ដូចជាសារណានេះផ្ទាល់ គឺជា កត្តាលីករជំរុញឲ្យអ្នកដែលចង់ស្វែងយល់ទទួលបាននូវចំណេះដឹងនេះយ៉ាងទូលំទូលាយ។ និយាយជារួមអត្ថបទនេះពិតជាពន្លឺប្រទីប ក្នុងការបង្ហាញផ្លូវរាល់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធបានយល់ច្បាស់អំពីនីតិវិធីទាំងអស់ ដោយសារវាក៏បាន បំភ្លឺរាល់ចំងល់ដល់បុគ្គលដែលមានបំណងសុំកូនផងដែរ ។

ដើម្បីជាការដោះស្រាយគ្រប់រាល់ចំណងអំពី បញ្ហាសុំកូន នៃប្រធានបទខាងលើនេះទាំងប៉ុន្មាននាងខ្ញុំបានបែងចែកជា ២ ជំពូក។ ដោយ **ជំពូកទី១** និយាយអំពី **ទ្រឹស្តីទូទៅ និង សុំកូនរវាងពលរដ្ឋខ្មែរ និង ពលរដ្ឋខ្មែរ** ។ **ជំពូកទី២** ស្តីពី **សុំកូនអន្តរប្រទេស** វាមានលក្ខណៈតឹងរឹងជាងគេ ដោយសារនីតិវិធីសាំញ៉ាំ ជាប់ពាក់ព័ន្ធអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសអ្នកសុំទៀត។ ដូច្នេះ សូមធ្វើការអាននូវរាល់គ្រប់ជំពូកទាំងអស់គ្នា ដូចខាងក្រោមនេះ ៖

# ជំពូកទី១ ទ្រឹស្តីទូទៅ និង សុំកូនរវាងពលរដ្ឋខ្មែរ និង ពលរដ្ឋខ្មែរ

ឪពុកម្តាយ មានកាតព្វកិច្ចបីបាច់ ថែរក្សាកូនរបស់ខ្លួនប្រកបដោយជីវភាពគ្រប់គ្រាន់ដើម្បីធានាបាននូវសុខភាព និងសុខុមមាលភាពរបស់កូនដែលជាវ័យកុមារព្រោះ កុមារជាវ័យទន់ជ្រាយពុំមានភាពចាស់ទុំទាំងផ្នែករាងកាយ និងសតិបញ្ញា ។ចំណែកឯកុមារកំព្រាដែលពុំមានឪពុកម្តាយក៏មានសិទ្ធិទទួលបាននូវជំនួយ ការយកចិត្តទុកដាក់ និងការសង្គ្រោះ ហើយត្រូវបានការពារនិងថែរក្សាទាំពិសេសដោយច្បាប់របស់ប្រទេសក៏ដូចជាគោលការណ៍សង្គមជាតិទាំងមូល។

ក្រៅពីទំនាក់ទំនងបុត្តភាពតាមបែបធម្មជាតិ ក្រមរដ្ឋប្បវេណីក៏ទទួលស្គាល់ការបង្កើតឲ្យមានទំនាក់ទំនងបុត្តភាពតាមរយៈសុំកូន ហើយការបង្កើតឲ្យមានប្រព័ន្ធសុំកូននេះដែល គឺដើម្បីបង្កើតសន្តតិជន នៃទ្រព្យសម្បត្តិរបស់គ្រួសាររបស់ឪពុកម្តាយចិញ្ចឹម បង្កើតអោយមានកម្លាំងការពារ មើលថែរក្សា និងគិតគូដល់ផលប្រយោជន៍របស់កុមារដែលពុំមានស្ថានភាពនៃការថែរក្សាដោយសមរម្យពីឪពុកម្តាយបង្កើត។

ដើម្បីឲ្យការអនុវត្តការសុំកូនមានប្រសិទ្ធភាព និងភាពសុក្រឹត្យត្រូវតែអនុវត្តទៅតាមគោលការណ៍នៃបទបញ្ញត្តិ ដោយគោរពបែបបទ ល័ក្ខខ័ណ្ឌ នីតិវិធីនិង អានុភាពឲ្យបានត្រឹមត្រូវ។

## ផ្នែកទី១ ទស្សនៈទានទូទៅនៃសុំកូន

គោលគំនិតនៃការតាក់តែងបញ្ញត្តិស្តីពីការសុំកូនមានហេតុផល ជាច្រើន ដូចជាដើម្បីបន្តវង្សត្រកូលជាដើម ប៉ុន្តែចុងក្រោយ គឺដើម្បីផលប្រយោជន៍របស់កូនសុំមានន័យថា ចង់ឲ្យកូនសុំមានគ្រួសារថ្មី ដែលល្អជាងគ្រួសារពីមុន ។ ការទទួលស្គាល់ប្រព័ន្ធនេះគឺមានប្រយោជន៍ដល់កុមារដែលក្រគ្រី ឬកំព្រា មានឳកាសមានគ្រួសារថ្មី ដែលអាចជួយឲ្យជីវិតរបស់ពួកគេ បានប្រសើរឡើង។ហើយហេតុផលដែលគេបង្កើតឲ្យមានរបបសុំកូន គឺមានគោលបំណងបន្តពូជពង្សវង្សត្រកូលសំដៅទៅលើអ្នកអត់មានកូន ឬពួកគាត់អសមត្ថភាពក្នុងការដែលមានកូនខ្លួនឯង ប៉ុន្តែមូលហេតុនេះ មិនត្រូវបានបញ្ញត្តិនៅក្នុងច្បាប់ទេ ពីព្រោះច្បាប់កំណត់តែមូលហេតុផលប្រយោជន៍កុមារទេ ហេតុនេះពេលតុលាការ ពិចារណ តុលាការនឹងពិចារណាផ្អែកលើផលប្រយោជន៍ក្មេង។ ឧទាហរណ៍៖ បុគ្គលម្នាក់ គាត់មានកូន ៣នាក់រួចហើយ បន្ទប់មក គាត់ចង់សុំកូនគេទៅចិញ្ចឹមទៀត ចំណុចនេះ ច្បាប់មិនមានបញ្ញត្តិហាមឃាត់ទេ ក៏ប៉ុន្តែផ្តល់សិទ្ធិឲ្យតុលាការជាអ្នកសម្រេច តើគួរតែឲ្យគាត់បង្កើតសុំកូនដែរឬទេ? បើគាត់មានកូនច្រើនហើយ បើតុលារការយល់ឃើញថាស្ថានភាពទគ្រួសាររបស់គាត់មិនសូវមានជីវភាពធូរជាទេ តែគាត់នៅតែចង់សុំកូនយកទៅចិញ្ចឹមដើម្បីធ្វើជាអ្នក

បំរើក៏ថាបាន តែបើពិនិត្យទៅគ្រួសារនោះមានជីវភាពធូរធា មានទ្រព្យសម្បត្តិសមល្មមនិងមើល ថែទាំកូនសុំនោះ តុលាការអាចអនុញ្ញាតឲ្យចិញ្ចឹម នេះវាគ្រាន់តែជាផ្នែកមួយនៃការពិចារណាទេ ទេ ធាតុពិតអាស្រ័យលើស្ថានភាពជាក់ស្តែង។ រីឯ ចំពោះអ្នកអត់កូនសោះ តុលាការមានភាពជឿជាក់ច្រើនថា សុំក្នុងគោលបំណងធ្វើជាកូនពិតមែន។

## កថាខណ្ឌទី ១ និយមន័យនៃសុំកូន

**សុំកូន** ( Eng.Adopt Fr.Adopt ) គឺជាកិច្ចសន្យាយ៉ាងឱឡារិកដែលធ្វើឲ្យបុគ្គលពីរ នាក់ គឺ ឪពុកឬម្តាយ និងកូនចិញ្ចឹមមានទំនាក់ទំនងដូចគ្នានឹងឪពុកម្តាយជាមួយកូនបង្កើត។[1]

**សុំកូន** គឺជាកិច្ចសន្យា ដែលចងបុគ្គលពីរនាក់ គឺម្នាក់ហៅថាឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹម ហើយម្នាក់ទៀតហៅថាកូនចិញ្ចឹម អោយមានចំណងនឹងគ្នាដូចជាបុគ្គភាពមានខាន់ស្លា។

### ១. គោលបំណងនៃការសុំកូន

វត្ថុបំណងនៃសុំកូន គឺផ្តោតសំខាន់ចំបងទៅលើគោលការណ៍មនុស្សធម៌សុទ្ធសាធ ដោយ ផ្សារភ្ជាប់នូវការយកចិត្តទុកដាក់ចំពោះកុមារ ដើម្បីផ្តល់នូវការការពារកុមារឲ្យរួចផុតពីការរំលោភបំពាន ផ្សេងៗ ផ្តល់នូវការចិញ្ចឹមបីបាច់ថែរក្សា ផ្តល់សេវាសុខភាព ការអប់រំរៀនសូត្រ ជាពិសេសការគិត គូរទៅលើការគោរពសិទ្ធិជាមូលដ្ឋានរបស់កុមារ សិទ្ធិទទួលបានការការពារ សិទ្ធិទទួលបានការ រៀនសូត្រ ការអភិវឌ្ឍន៍ និងសិទ្ធិក្នុងការចូលរួម ដើម្បីឧត្តមប្រយោជន៍កុមារនៅពេលអនាគត ។

### ២ . និន្នាការទូទៅនៃសុំកូន

ដោយសារការចង់ជួយសង្គ្រោះ ការអាណិតដល់កុមារដែលមានឪពុកម្តាយក្រីក្រ ឬ កុមារ កំព្រា ទើបធ្វើឲ្យពលរដ្ឋខ្លះដែលគ្មានកូន សុំកុមារទាំងនោះយកមកធ្វើជាកូនចិញ្ចឹម។ មានកុមារមិន តិចទេដែលមានសំណាងដោយការសុំនេះ ពួកគេបានរស់នៅក្នុងគ្រួសារអ្នកមានស្តុកស្តម្ភ និងការ ថ្នាក់ថ្នមយ៉ាងកក់ក្តៅ ។ ផ្ទុយមកវិញ ក៏មានកុមារមួយចំនួនតូចដែរ ដែលគ្មានសំណាង ហើយត្រូវគេវាយដំធ្វើបាប ធ្វើអាជីវកម្មលើកំលាំងពលកម្ម ឬយកទៅជួញដូរជាដើម។

ដើម្បីជៀសវាងរាល់ការជួញដូរទាំងឡាយទៅលើកុមារ និងសំរាប់តំរង់ទិសទៅអ្នកដែល ពាក់ព័ន្ធ ឬអាជ្ញាធរមានសមត្ថកិច្ចលើវិស័យនេះ ឲ្យកាន់តែមានប្រសិទ្ធិភាពថែមទៀត ក្នុងក្រមរដ្ឋ-ប្បវេណី ២០០៧ បានបញ្ញត្តិអំពីសុំកូនមានចំនួន ២៧ មាត្រា ចាប់ពីមាត្រា១០០៧ ដល់មាត្រា ១០៣៣ ។ ក្នុងនោះមាត្រា ១០០៧ បានផ្តល់អំណាចពេញលេញដល់តុលាការក្នុងការពិចារណា និងសម្រេច

---

[1] សន្ទានុក្រមបារាំងខ្មែរនៃពាក្យរបស់លោកសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចឆ្នាំ ១៩៩៦

ឲ្យមានការសុំកូន ។ ដូចគ្នាផងដែរ នៅប្រទេសដទៃទៀតដូចជានៅអឺរ៉ុប កំណត់ថា ការសុំកូនពេញលេញមានសុពលភាព លុះត្រាមានការសម្រេចរបស់តុលាការ ឬអាជ្ញាធររដ្ឋបាល។ អនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា ២១ ក៏បានទាមទារឲ្យមានការពិចារណាជាអតិបរមា ទៅលើផលប្រយោជន៍របស់កុមារ ដែលធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ចដែរ[2]។ ដោយឡែក ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ២០០៩ បានបញ្ញត្តិចំនួន ១០ជំពូក និង ៥៨ មាត្រា។ ការតាក់តែងច្បាប់នេះឡើង ក៏អនុវត្តតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជាដំណាក់កាលទី២ សម្រាប់ នីតិកាលទី៤ នៃរដ្ឋសភា ដែលចែងជាអាទិ៍ថា រាជរដ្ឋាភិបាលប្តូរផ្តាច់ដាក់ចេញនូវវិធានការគ្រង់ បែបយ៉ាង ដើម្បីទប់ស្កាត់អំពើគាបសង្កត់ អំពើពេស្យាចារលើកុមារ ការជួញដូរកុមារ ការពង្រឹង អនុវត្តច្បាប់ ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។

### ៣. លក្ខណៈពិសេសនៃសុំកូន

យោងតាមក្រមរដ្ឋប្បវេណី សុំកូនក្នុងប្រទេសអាចជាសុំកូនពេញលេញ និងសុំកូនធម្មតា ។ ដោយឡែក រាល់ជនបរទេសដែលរស់នៅក្នុងប្រទេសកម្ពុជា ហើយមានបំណងសុំកុមារ កម្ពុជាយក ទៅចិញ្ចឹមនៅក្នុងប្រទេស ដែលខ្លួនមានលំនៅអចិន្ត្រៃយ៍ក្រៅពីប្រទេសកម្ពុជា ត្រូវអនុវត្តទៅតាម ច្បាប់សុំកូនអន្តរប្រទេស[3]។

ចំពោះលក្ខណៈពិសេសនៃសុំកូន គឺតំរូវឲ្យបំពេញនូវលក្ខខណ្ឌមួយចំនួន ដូចជាការបង្កើតដោយពាក់ព័ន្ធទៅលើលក្ខខណ្ឌចំពោះឪពុកម្តាយចំពោះកូនសុំ បន្ទាប់មកគឺអានុភាពទៅលើការសុំ ជាចុងក្រោយគឺការកាត់កាល់ ។ ចំនែកឯសុំកូនអន្តរប្រទេស ក៏មិនខុសពីសុំកូនក្នុង ប្រទេសប៉ុន្មានដែរ ដោយសារសុំកូនអន្តរប្រទេសធ្វើក្នុងទំរង់សុំកូនពេញលេញ ។ ម្យ៉ាងទៀតសុំកូនអន្តរប្រទេសទាមទារឲ្យមាននីតិវិធីច្បាស់លាស់ត្រឹមត្រូវបំផុតចំពោះដំណើរការនៃសុំនេះ ព្រោះមានអាជ្ញាធរដែលមានសមត្ថកិច្ចទាំងក្នុង និងក្រៅប្រទេសនៅអនុវត្តកិច្ចដំណើរការសុំនេះ ។

## កថាខណ្ឌទី២ ប្រភេទ និង សារៈសំខាន់នៃសុំកូន

### ១. ប្រភេទនៃសុំកូន

សុំកូនត្រូវបានបែងចែកជាពីរ គឺសុំកូនពេញលេញ និងសុំកូនធម្មតា ។ សុំកូនទាំងពីរ ប្រភេទនេះ មានលក្ខខណ្ឌ និងអានុភាពខុសគ្នា ដោយក្នុងនោះសុំកូនពេញលេញមានលក្ខខណ្ឌ ក្នុងការបង្កើតតឹងរឹងជាងសុំកូនធម្មតា ដូចជាករណីសុំកូនពេញលេញអាចបង្កើតបានចំពោះតែកុមារ តូចៗ

[2] មាត្រា ១០០៧ សេចក្តីកំណត់ចំពោះក្រមនីមួយៗនៃក្រមរដ្ឋប្បវេណី

[3] សេចក្តីណែនាំស្តីពីទម្រង់បែបបទ និងគំរូលិខិតបទដ្ឋានសម្រាប់អនុវត្តប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួស ចំពោះកុមារ (ក្រោមកិច្ចសហការជាមួយអង្គការយូនីសេហ្វកម្ពុជា ខែ ឧសភា ឆ្នាំ ២០១៣)

ដែលជាគោលការណ៍មានអាយុតិចជាង៨ឆ្នាំ និងអាចបង្កើតបានចំពោះតែបុគ្គល ដែលមាន សហព័ទ្ធប៉ុណ្ណោះ ហេតុនេះ បុគ្គលដែលមិនទាន់មានសហព័ទ្ធ មិនអាចបង្កើតសុំកូនពេញលេញ បានទេ តែអាចបង្កើតសុំកូនធម្មតាបាន ។ម្យ៉ាងវិញទៀត ចំណុចដែលខុសគ្នាទាំងស្រុងគឺ សុំកូន ពេញលេញមានអានុភាពបង្កើតនូវញាតិថ្មី ( ទំនាក់ទំនងញាតិរវាងកូនសុំ និងឪពុកម្តាយចិញ្ចឹម ព្រមទាំងញាតិលោហិតរបស់ឪពុកចិញ្ចឹម) ឲ្យកូនសុំ ដោយកាត់ផ្តាច់ទាំងស្រុងនូវទំនាក់ទំនងញាតិ រវាងកូនសុំ និងឪពុកម្តាយបង្កើតព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើត ។ ដោយឡែក សុំកូន ធម្មតាមានអានុភាពបង្កើតនូវញាតិថ្មី ដោយមិនផ្តាច់នូវទំនាក់ទំនងញាតិជាមួយនឹងឪពុកម្តាយបង្កើត ព្រម ទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើតទេ ពោលគឺញាតិភាពរវាងកូនសុំ និងឪពុកម្តាយបង្កើត នៅតែបន្ត[4]។

### ២. សារៈសំខាន់នៃសុំកូន

#### ❖សារៈសំខាន់នៃសុំកូនពេញលេញ

កូនសុំពេញលេញបានបង្កើតនូវទំនាក់ទំនងអចិន្ត្រៃយ៍ជាមួយឪពុកម្តាយចិញ្ចឹម គឺកូនសុំមានឋានៈ និងសិទ្ធិដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹម។ កូនសុំអាចគេចផុតពីភាពរស់នៅដោយជីវភាពក្រីក្រជាមួយឪពុកម្តាយបង្កើតទៀតហើយ ដោយជំនួសមកវិញដោយមជ្ឈដ្ឋានថ្មី ដែលមានឪពុកម្តាយចិញ្ចឹមផ្តល់អនាគតភ្លឺស្វាង។ពិសេសសុំកូនពេញលេញមានការសម្រេចដោយតុលា-ការដែលច្បាប់ទទួលស្គាល់។

#### ❖សារៈសំខាន់នៃសុំកូនធម្មតា

កូនសុំនិងឪពុកម្តាយបង្កើតមានសិទ្ធិទាមទារនិងករណីកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច។ មួយវិញទៀតកូនសុំនិងឪពុកម្តាយបង្កើតមានសិទ្ធិធ្វើសន្តតិកម្មគ្នាទៅវិញទៅមក។មានន័យថា ចំណងទំនាក់ទំនងរវាងកូនសុំ និងឪពុកម្តាយរបង្កើតមិនត្រូវបានកាត់ផ្តាច់ឡើយ ។ ម្យ៉ាងទៀត អាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬនាមត្រកូលមុនសុំកូនបាន។ ក្រោយពីបញ្ចប់នីតិវិធីសុំកូនធម្មតា កូនសុំបានរស់នៅក្នុងគ្រួសារសមរម្យ និងមានអធ្យាស្រ័យល្អពីឪពុកម្តាយ ពិសេស បានសិក្សារៀនសូត្រ ការថែទាំសុខភាពជាអចិន្ត្រៃយ៍។ ជាចុងក្រោយ ប្រព័ន្ធសុំកូនធម្មតាត្រូវបាន បង្កើតឡើងដោយតម្រូវឲ្យមានការពាក់ព័ន្ធពីតុលាកាដើម្បីបង្កើតអានុភាពញាតិលោហិតតាមផ្លូវច្បាប់ដូចជា សន្តតិកម្ម និងអាហារកិច្ចជាដើម។

---

[4] សិក្ខាសាលាស្តីពី ទំនាក់ទំនងបុគ្គភាព ក្នុងនោះក៏មានការធ្វើបទបង្ហាញស្តីពី **សុំកូន** (ថ្ងៃទី ២៨ ខែមិនា ឆ្នាំ ២០១៥) ឧទ្ទេសនាមដោយៈ **មេធាវី ទេព មុនផល**

❖**សារៈសំខាន់នៃសុំកូនអន្តរប្រទេស**

សុំកូនអន្តរប្រទេស បានផ្តល់ឲ្យកូនសុំធានាបាននូវសិទ្ធិ និងឧត្តមប្រយោជន៍គ្រប់បែបយ៉ាងក្នុងគ្រួសារបរទេស ដើម្បីគេចផុតពីការជួញដូរជាដើម ។ លុបបំបាត់ចោលនូវការរើសអើងពូជសាសន៍កុមារកម្ពុជា ពីឪពុកម្តាយដែលជាជនបរទេស ជាពិសេសកម្ពុជាផ្ទាល់ ក៏ទទួលបានការរឹតចំណងសាមគ្គីភាពជាមួយបណ្តាការទូតនៃប្រទេសអ្នកសុំ។ វាក៏ជាការធ្វើសមាហរណកម្មទៅតាមចរន្តនៃសកលភាវូបនីយកម្មនៃវិស័យកុមារ ពីព្រោះកម្ពុជាបានផ្តល់សច្ចាប័នអនុសញ្ញាពីសិទ្ធិកុមារ ដើម្បីឲ្យបណ្តាប្រទេសដទៃយល់ដឹងពីសិទ្ធិកុមារនៅកម្ពុជា និងជាយន្តការឲ្យរាជរដ្ឋាភិបាលកាន់តែយកចិត្តទុកដាក់ក្នុងការគាំពារកុមារទាំងនោះ។

## **កថាខណ្ឌទី៣ វត្តមាននៃរបបសុំកូននៅក្នុងប្រព័ន្ធគតិយុត្តកម្ពុជា**

សុំកូនត្រូវបានបញ្ញត្តិចាប់ពីមាត្រា ១០៨ ដល់មាត្រ១២២នៅក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ឆ្នាំ១៩៨៩ ប៉ុន្តែរបបសុំកូនតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារខុសគ្នាអំពីសុំកូនតាមក្រមរដ្ឋប្បវេណីដោយសុំកូនតាមច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារបង្កើតឡើងត្រឹមតែកិច្ចសន្យា រវាងភាគីតែប៉ុណ្ណោះ ពោលគឺសុំកូនមិនត្រូវបានបង្កើតឡើងតាមផ្លូវតុលាការនោះទេ។ ម្យ៉ាងទៀត សុំកូនត្រូវបានកម្រិតចំនួនកូន គឺជាគោលការណ៍មិនឲ្យលើសពីពីរនាក់ ។ ចំណែកឯក្រមរដ្ឋប្បវេណី ដើម្បីសុំកូនតាមផ្លូវច្បាប់បានលុះត្រាតែធ្វើតាមផ្លូវតុលាការ បើពុំដូច្នេះទេ សុំកូនមិនបង្កើតអានុភាព ឡើយ ហើយពុំមានកម្រិត អំពីចំនួនកូនសុំទេ ប៉ុន្តែការសម្រេចបង្កើតសុំកូនត្រូវវិនិច្ឆ័យដោយផ្តោតលើផលប្រយោជន៍របស់កុមារ[5]។

### **១. ប្រព័ន្ធគតិយុត្តកម្ពុជា**

ក្នុងវិស័យសុំកូនកម្ពុជាដំបូងឡើយ គឺបានអនុវត្តយកតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ប៉ុន្តែបច្ចុប្បន្នយកតាមក្រមរដ្ឋប្បវេណី ត្រូវបានរដ្ឋសភាអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ វិញ ដែលបញ្ញត្តិកថាខ័ណ្ឌទី១ អំពីសុំកូនពេញលេញ ( ចាប់ពីមាត្រា១០០៧ ដល់មាត្រា១០១៩ ) និងកថាខ័ណ្ឌទី២ ( ចាប់ពីមាត្រា១០២០ ដល់មាត្រា១០៤២ ) ។

ដោយឡែក ក្របខ័ណ្ឌច្បាប់ដែលគ្រប់គ្រងការសុំកូនយកទៅចិញ្ចឹមនៅបរទេសវិញ ដំបូងឡើយគឺមានអនុក្រឹត្យឆ្នាំ ២០០១ ស្តីពីការសុំទារកកំព្រា ឬកុមារកំព្រាទៅចិញ្ចឹមនៅបរទេស។ ក្រោយមកនៅឆ្នាំ ២០០៧ កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីការការពារកុមារ និងសហប្រតិបត្តិការ

---

[5] សិក្ខាសាលាស្តីពី ទំនាក់ទំនងបុគ្គភាព ក្នុងនោះក៏មានការធ្វើបទបង្ហាញស្តីពី **សុំកូន** (ថ្ងៃទី ២៨ ខែមិនា ឆ្នាំ ២០១៥) ឧទ្ទេសនាមដោយៈ **មេធាវី ទេព មុនផល**

ទាក់ទងនឹងសុំកូនអន្តរប្រទេស ( អនុសញ្ញាក្រុងឡាអេឆ្នាំ១៩៩៣ ) ហើយនៅថ្ងៃទី០៣ ខែ ធ្នូ ឆ្នាំ ២០០៩ រដ្ឋសភាកម្ពុជាក៏បានអនុម័តច្បាប់មួយទៀត គឺ " ច្បាប់ស្តីពីសុំកូនអន្តរប្រទេស " ដោយអនុលោមតាមរដ្ឋធម្មនុញ្ញ និងអនុលោមទៅតាមអនុសញ្ញាក្រុងស្តីពីការការពារកុមារ និងសហប្រតិ-បត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេសនោះ។

**២. ការវិវត្តនៃដំណើរការគតិយុត្តសុំកូន**

ការងារសុំកូននៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺមានចាប់តាំងពីឆ្នាំ១៩៨៧ ដោយមុនដំបូង គឺចាប់ផ្តើមអនុវត្តន៍ការផ្តល់កូនសុំជូនដល់បុគ្គលិកបរទេសរបស់អង្គការអន្តរជាតិ និងអង្គការក្រៅ រាជរដ្ឋាភិបាល ដែលមកបំពេញបេសកកម្មនៅក្នុងប្រទេសកម្ពុជា ហើយបន្ទាប់មកបានអនុវត្តន៍ ចំពោះប្រជាពលរដ្ឋបរទេស ដែលបានមកទំនាក់ទំនងសុំកូនពីកម្ពុជា។

បន្ទាប់ពីច្បាប់ស្តីពី សុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានអនុម័តឲ្យប្រើប្រាស់កាលពីថ្ងៃទី ០៣ ខែធ្នូ ឆ្នាំ២០០៩ កន្លងមក ដំណើរការសុំកូនអន្តរប្រទេសនៅកម្ពុជា នៅ មិនទាន់អាចបើកឲ្យដំណើរការឡើងវិញ ស្របទៅតាមច្បាប់នេះនៅឡើយទេ។ ដោយហេតុថា កម្ពុជា ត្រូវការពេលវេលាឲ្យបានគ្រប់គ្រាន់ សម្រាប់រៀបចំកសាងលិខិតបទដ្ឋានគតិយុត្តនានា សំដៅជំរុញ ការអភិវឌ្ឍន៍ច្បាប់ឲ្យបានល្អប្រសើរស្របតាមអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និងសហ-ប្រតិបត្តិការសទាក់ទងនឹងសុំកូនអន្តរប្រទេស ។ ជាមួយគ្នានេះដែរ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានបង្កើតនូវរដ្ឋបាលសុំកូនអន្តរប្រទេស ដែលជាសេនាធិការរបស់អាជ្ញាធរ កណ្តាលសុំកូនអន្តរប្រទេស ដើម្បីគ្រប់គ្រងចាត់ចែង និងតាមដានត្រួតពិនិត្យលើការងារសុំកូន អន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាថាការងារសុំកូនអន្តរប្រទេស ប្រព្រឹត្តទៅស្រប តាមគោលបំណងនៃគោលនយោបាយការពារសិទ្ធិនិងឧត្តមប្រយោជន៍របស់កុមារក៏តម្រូវឲ្យអនុលោម តាមលិខិតបទដ្ឋានជាតិនិងអន្តរជាតិដែលបានកំណត់។ ដំណើការសុំកូនអន្តរប្រទេស ត្រូវបាន ផ្អាកទៅវិញនៅឆ្នាំ ២០១១ បន្ទាប់ពីឃើញថា កុមារកម្ពុជាមួយចំនួនត្រូវរងគ្រោះ និងមានករណី ជួញដូរកុមារមួយចំនួនស្ថិតក្រោមស្លាកសុំកូនអន្តរប្រទេសនេះ ។ ការផ្អាកជាបណ្តោះអាសន្នរបស់ ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា គឺដើម្បីផ្តល់ឲ្យឱកាសឲ្យអាជ្ញាធរកម្ពុជារៀបចំនូវលិខិតបទដ្ឋានគតិយុត្តមួយចំនួនធានានិងការពារដល់ឧត្តមប្រយោជន៍របស់កុមារ។

រដ្ឋបាលសុំកូនអន្តរប្រទេសដូចជាអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសដែលស្ថិតក្រោម ចំណុះឲ្យក្រសួងសង្គមកិច្ចអតីតយុទ្ធជនអតីតយុទ្ធជននិងយុវនីតិសម្បទាបានជម្រាបជូន លទ្ធផលសំខាន់ៗដូចជា៖

១-ប្រកាសស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា

២-ប្រកាសស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់រដ្ឋបាលសុំកូនអន្តរប្រទេស

៣-ប្រកាសរួមស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិ-សម្បទា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៤-ប្រកាសរួមស្តីពីការកំណត់ចំនួនប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានា សម្រាប់សុំកូនអន្តរប្រទេស

៥-ប្រកាសរួម ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៦-ប្រកាសស្តីពីនីតិវិធីផ្តល់ការអនុញ្ញាតដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេស និងសេចក្តីណែ-នាំស្តីពីលក្ខណៈវិនិច្ឆ័យសម្រាប់ការផ្តល់ការអនុញ្ញាតដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេស ដើម្បីធ្វើប្រតិ- បត្តិការសុំកូនអន្តរប្រទេសនៅកម្ពុជា

៧-ប្រកាសស្តីពីការណែនាំអនុវត្តនីតិវិធីសុំកូនអន្តរប្រទេសដោយសាច់ញាតិ

៨-ប្រកាសស្តីពីការណែនាំអនុវត្តនីតិវិធីសុំកូនអន្តរប្រទេស ចំពោះកុមារដែលត្រូវបានថែទាំពិសេស និងកុមារមានតម្រូវការពិសេស

៩-ប្រកាសស្តីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រង និងចាត់ចែងប្រាក់វិភាគទានមនុស្សធម៌

១០-ប្រកាសស្តីពីការប្រើប្រាស់អក្សរកាត់ រូបសញ្ញា និងគំរូក្បាលលិខិតរបស់អាជ្ញាធរកណ្តាល សុំកូនអន្តរប្រទេស

១១-សៀវភៅណែនាំ ស្តីពីនីតិវិធីពិនិត្យសំណុំឯកសារសុំកូនអន្តរប្រទេស[6]។

លើសពីនេះទៀតរដ្ឋបាលសុំកូនអន្តរប្រទេសបានសហការយ៉ាងជិតស្និទ្ធ ជាមួយអង្គការ យូនីសេហ្វនិងអ្នកជំនាញការផ្នែកច្បាប់នៃការិយាល័យអចិន្ត្រៃយ៍អនុសញ្ញាក្រុងឡាអេ ស្តីពីការ ការពារកុមារនិងសហប្រតិបត្តិការសុំកូនអន្តរប្រទេសក្នុងការរៀបចំកសាងលិខិតបទដ្ឋាន បើកវគ្គ បណ្តុះបណ្តាលដល់មន្ត្រីជំនាញ ដើម្បីពង្រឹងសមត្ថភាព និងបង្កើននូវបទពិសោធន៍ថ្មីៗបន្ថែមទៀត ពាក់ព័ន្ធនឹងនីតិវិធីសុំកូនអន្តរប្រទេស។

[6] សិក្ខាសាលា ស្តីពីការផ្សព្វផ្សាយលិខិតបទដ្ឋាននានារបស់អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស( ២៦ កុម្ភៈ ២០១៤ )

**កថាខណ្ឌទី៤៖ យុទ្ធសាស្រ្តដើម្បីការពារចំពោះការសុំ**

ក្នុងយុទ្ធសាស្រ្តនេះជាវិធានការមួយដើម្បីឲ្យកាន់តែល្អប្រសើរដល់កុមារដោយទាំងអង្គការ ក៏ដូចជាក្រសួងទទួលបន្ទុករួមទាំងរដ្ឋាភិបាលបានរួមដៃគ្នារិះរកផែនការទប់ស្កាត់ហេតុការណ៍ផ្សេងៗ ចំពោះជនទុច្ចរិតដែលមានបំណងយកការសុំកូនអន្តរប្រទេសធ្វើជាជំនួញក្នុងការរកស៊ីដើម្បីជា ប្រយោជន៍ផ្ទាល់របស់ពួកគេ។

ដើម្បីផ្តល់ភាពងាយស្រួល និងសុវត្ថិភាពដល់កុមារឲ្យរួចពីការកេងប្រវ័ញ្ចគ្រប់រូបភាព ដោយគិតតែប្រយោជន៍ផ្ទាល់ខ្លួនហេតុនេះហើយបានជាច្បាប់ស្តីពីសុំកូនអន្តរ ប្រទេសបានកំណត់នូវ យន្តការការពារចំពោះកូនសុំ ដើម្បីធានាថាកុមារកូនសុំនោះទទួលបាននូវកិច្ចគាំពារ និងជំនួយ ឧបត្ថម្ភដ៏សមស្របពីឪពុកម្តាយចិញ្ចឹម ដូចដែលមានចែងនៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ និងឯក- សារអន្តរជាតិនានាឯទៀតស្តីពីសិទ្ធិកុមារ និងមនុស្សធម៌។

ដើម្បីជាយន្តការក្នុងការទប់ស្កាត់ចំពោះការសុំត្រូវធានាថាកុមារដែលជាកូនសុំត្រូវមាន សិទ្ធិទទួលបាននូវការការពារសិទ្ធិការពារពីការរំលោភបំពាន។ពិសេសពួកគេត្រូវទទួលបានសិទ្ធិ ការពារពីការជិះជាន់កិច្ចគាំពារផ្នែកសេដ្ឋកិច្ចការថែទាំផ្នែកសុខភាពការអប់រំជាដើម។ រដ្ឋក៏ត្រូវទប់ស្កាត់នូវការជិះជាន់លើផ្លូវភេទការពង្រាត់ការលក់ដូរនិងការជួញដូរកុមារគ្រប់រូបភាព។

## ផ្នែកទី២ សុំកូនពេញលេញ

### កថាខណ្ឌទី១ សញ្ញាណទូទៅនៃសុំកូនពេញលេញ

#### ១. គោលបំណងនៃការបង្កើតរបបសុំកូនពេញលេញ

ការសុំកូន គឺជាការបង្កើតទំនាក់ទំនងញាតិតាមផ្លូវច្បាប់រវាងបុគ្គលដែលជាឪពុកម្តាយ និងកូនសុំ។ទំនាក់ទំនងនេះក៏មានគោលបំណងបង្កើតអោយមាននូវការទទួលបន្តមត៌កតាមរយៈសន្តតិកម្ម និងករណីកិច្ចរវាងភាគីនៃសុំកូន ដែលដូចគ្នាទៅនឹងទំនាក់ទំនងញាតិលោហិតផងដែរ[7]( មាត្រា ៩៤០នៃ ក្រមរដ្ឋប្បវេណី )។

យោងតាមក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ ២០០៧ របបសុំកូនត្រូវបានបែងចែកជាពីរ គឺសុំកូនពេញលេញនិងសុំកូនធម្មតា។ ដោយពិនិត្យលើលក្ខណៈទូទៅ របបសុំកូនទាំងពីរមានគោលបំណងដូចគ្នាគឺ ការបង្កើតអោយមានទំនាក់ទំនងញាតិ រវាងឪពុកម្តាយចិញ្ចឹម និងឪពុកម្តាយបង្កើត។ ប៉ុន្តែក្រៅពីលក្ខណៈដូចគ្នានេះគោលបំណងនៃការបែងចែករបបសុំកូនមានដូចខាងក្រោម៖

[7] មាត្រា ៩៤០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

### ១.១ ការពារផលប្រយោជន៍របស់កូនសុំ

របបសុំកូនពេញលេញត្រូវបានបង្កើតដោយយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការការពារ ផលប្រយោជន៍របស់កូនសុំ។ រាល់ល័ក្ខខ័ណ្ឌនីមួយៗមានភាពតឹងរឹងដើម្បីធានាការបង្កើតរបបសុំកូនអាចធ្វើអោយអនាគតរបស់កូនសុំមានភាពប្រសើរជាងការរស់នៅជាមួយគ្រួសារបង្កើត។ ដោយឡែករបបសុំកូនធម្មតវិញ យើងពុំឃើញមានល័ក្ខខ័ណ្ឌតឹងរឹងដូចសុំកូនធម្មតាឡើយ។

យោងតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ ( UNCRC ) មាត្រា៩ កថាខណ្ឌទី១[8] ឧត្តមប្រយោជន៍របស់កុមារត្រូវគិតគូជាចម្បង។ ក្រៅពីល័ក្ខខ័ណ្ឌផ្សេង១ទៀត ប្រសិនបើគោលបំណងនៃការសុំកូននោះពុំមែនជាការការពារផលប្រយោជន៍កុមារ សុំកូនពេញលេញមិនត្រូវអនុញ្ញាឡើយ។ ផ្ទុយពីនេះ របបសុំកូននោះពុំតម្រូវអោយមានស្ថានភាពចាំបាច់ដើម្បីផលប្រយោជន៍កូនសុំទេ។ កូនសុំក្នុងរបបនេះអាចជានីតិជន ឬអនីតិជនហើយកូនសុំធម្មតានៅតែរក្សាទំនាក់ទំនងរវាងឪពុកម្តាយបង្កើត និងកូនសុំដដែលហេតុនេះករណីកិច្ចរវាងកូនសុំ និងឪពុកម្តាយបង្កើត ព្រមទាំងញាតិភាពពុំត្រូវបានការកាត់ផ្តាច់ទេ។

### ១.២ ការផ្តល់នូវគ្រួសារថ្មីដ៏ល្អ

ថ្វីត្បិតតែទំនាក់ទំនងសុំកូន ត្រូវបានបង្កើតឡើងក្រោមផ្លូវច្បាប់សារធាតុនៃនីតិជន ប៉ុន្តែទំនាក់ទំនងនេះអាចធ្វើអោយមានផលប៉ះពាល់ដល់សណ្តាប់ធ្នាប់របៀបរៀបរយសារធាណៈ ដែលត្រូវយកចិត្តទុកដាក់។ របបសុំកូនពេញលេញត្រូវបានបង្កើតឡើងតាមផ្លូវតុលាការដើម្បីតុលាការអាចវិនិច្ឆ័យអំពីភាពសមសម្របនៃការសុំកូន ចៀសវាងការអនុញ្ញាតអោយភាគីបង្កើតទំនាក់ទំនងសុំកូនឯកជន ដោយគ្មានការត្រួតពិនិត្យ ។

គ្រួសារថ្មីជាទីបង្អែងរបស់កុមារ ត្រូវបានពិចារណាយ៉ាងហ្មត់ចត់ដោយតុលាការ អំពីលទ្ធភាពផ្នែកសេដ្ឋកិច្ច ភាពចាស់ទុំក្នុងការអប់រំថែរក្សាកូន។ហេតុនេះ កុមារនឹងទទួលបានគ្រួសារមួយកក់ក្តៅ ថ្វីត្បិតតែវាពុំមែនជាគ្រួសារបង្កើតរបស់កុមារយ៉ាងណាក្តី។

## ២. ប្រវត្តិនៃរបបសុំកូនក្នុងនីតិកម្ពុជា

នៅមុនកាលបរិច្ឆេកនៃការអនុវត្តក្រុមរដ្ឋប្បវេណី សុំកូនត្រូវបានបង្កើតឡើងដោយតាមមាត្រា១៦៦ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ។ សញ្ញាណគតិយុត្តនៃសុំកូននេះ ស្ថិតក្រោមនីតិរូមនៃកិច្ចសន្យាពោលគឺគ្រាន់តែតម្រូវអោយមានការព្រមព្រៀង និងបំពេញល័ក្ខខ័ណ្ឌការចុះ

---

[8] « រដ្ឋភាគីត្រូវធានាថា កុមារមិនត្រូវបានបំបែកចេញពីឪពុកម្តាយ ផ្ទុយពីឆន្ទៈរបស់កុមារឡើយ លើកលែងតែអាជ្ញាធរមានសមត្ថកិច្ច ដែលស្ថិតក្រោមការពិនិត្យរបស់តុលាការ សម្រេចស្របតាមច្បាប់ និងនីតិវិធីថា ការបំបែកនេះគឺចាំបាច់សម្រាប់ផលប្រយោជន៍ល្អបំផុតរបស់កុមារ ( Best interest of the Child )។ ការសម្រេចនេះអាចចាំបាច់តែក្នុងករណីពិសេស មានជាអាទិ៍ ឪពុកម្តាយធ្វើបាប ឬទុកចោល ឬឪពុកម្តាយលែងរស់នៅជាមួយ ហើយសេចក្តីសម្រេចនេះត្រូវធ្វើដោយគិតពីកន្លែងស្នាក់នៅរបស់កុមារ។»

បញ្ញើរបបសុំកូននឹងត្រូវបានបង្កើត។ ការធ្វើបែបនេះពុំអាចធានាការពារផលប្រយោជន៍របស់កុមារបានឡើយ។ អាស្រ័យហេតុនេះរបបសុំកូនថ្មីត្រូវបានបញ្ញាត្តិនៅក្នុងក្រមរដ្ឋប្បវេណី ២០០៧ ដែលដកស្រង់ភាគច្រើនចេញពីគោលគំនិតក្រមរប្បវេណីជប៉ុន ដើម្បីធ្វើអោយមានភាពល្អប្រសើរជាងមុន ។

## កថាខណ្ឌទី២ ល័ក្ខខ័ណ្ឌសារធាតុនៃសុំកូនពេញលេញ

ធម្មជាតិនៃសុំកូនពេញលេញគឺជាការ ធ្វើអោយល្អប្រសើរដល់ការរស់នៅរបស់កុមារ។ ខុសពីរបបសុំកូនដែលបញ្ញាត្តិនៅក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ ១៩៨៩ របបសុំកូនពេញលេញដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ត្រូវបង្កើតឡើងដោយគិតពិចារណាយ៉ាងជិតដល់ពីផលប្រយោជន៍របស់កូនសុំ ( Best Interest of the Child )ហេតុនេះវាត្រូវការល័ក្ខខ័ណ្ឌយ៉ាងតឹងរឹងដូចមានចែងក្នុងមាត្រា ១០០៧ នៃក្រមរដ្ឋប្បវេណី ៖

### ១. ល័ក្ខខ័ណ្ឌទាក់ទងនឹងឪពុកម្តាយចិញ្ចឹម

#### ១.១ ភាពមានសហព័ទ្ធ និងការសហការ

បុគ្គលដែលនឹងក្លាយទៅជាឪពុក ឬម្តាយចិញ្ចឹមចាំបាច់ត្រូវតែជាបុគ្គលដែលមានសហព័ទ្ធ (មាត្រា **១០០៨** នៃក្រមរដ្ឋប្បវេណី)។ ការបញ្ញាត្តិបែបនេះ គឺដោយសារតែរបបសុំកូនពេញលេញត្រូវបានបង្កើតឡើងក្នុងគោលបំណងផ្តល់គ្រួសារថ្មីដល់កូនសុំ និងប្រឌិតស្ថានភាពអោយដូចទៅឪពុកម្តាយបង្កើតរបស់កូនសុំ។ បញ្ញាត្តិនេះក៏ចេញមកដើម្បីបង្ការដល់ការបង្កើតសុំកូនរវាង បុគ្គលដែលមានភេទដូចគ្នានិងសុំកូន ដោយគេគិតថា កម្ពុជាពុំទាន់អាចស្គាល់ភាពស្របច្បាប់នៅឡើយចំពោះអាពាហ៍ពិពាហ៍រវាងបុគ្គលដែលមានភេទដូចគ្នា ដោយផ្អែកលើប្រពៃណីទំនៀមទំលាប់ ដែលប្រកាន់តាំងពីដើមមក ស្របពេលបណ្តាប្រទេសមួយចំនួនទទួលស្គាល់ការបង្កើតសុំកូនដោយបុគ្គលមានភេទដូចគ្នា (LGBT ) ជាអាទិ៍ចក្រភពអង់គ្លេសនិងអេស្ប៉ាញ)[9]។

ដោយឡែកការសុំកូនក៏ជាគោលការណ៍ត្រូវសម្រេចអោយបានឆន្ទៈជាឯកឆន្ទៈរបស់សហព័ទ្ធផងដែរ។ ក្រមរដ្ឋប្បវេណីពុំបានប្រើពាក្យចំទេអំពីការឯកភាពនោះ។ ប៉ុន្តែយោងតាមការសំយោគមាត្រា ១០០៨ កថាខណ្ឌទី២ « **ប្តី ឬប្រពន្ធតែម្ខាង ពុំអាចក្លាយជាឪពុក ឬម្តាយចិញ្ចឹមបានឡើយ ប្រសិនបើសហព័ទ្ធម្ខាងទៀតមិនក្លាយជាម្តាយ ឬឪពុកចិញ្ចឹម។ ប៉ុន្តែបញ្ញាត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលប្តីប្រពន្ធណាម្ខាង ក្លាយជាឪពុក ឬម្តាយចិញ្ចឹមរបស់កូនបង្កើតនៃសហព័ទ្ធម្ខាងទៀត។**» អាចអោយយើងធ្វើការសន្និដ្ឋានជាទិដ្ឋភាពដីដូចខាងក្រោម ៖

[9] hhtp://adoption.law.com/gay-adoption

- ប្រសិនបើសហព័ទ្ធណាម្ខាង ចង់បង្កើតសុំកូន ត្រូវមានការឯកភាពពីសហព័ទ្ធម្ខាងទៀត។
- ប្រសិនបើសហព័ទ្ធម្ខាង ចង់សុំកូនរបស់សហព័ទ្ធម្ខាងទៀតមកធ្វើជាកូនសុំ ពុំចាំបាច់មានការយល់ព្រមពី សហព័ទ្ធម្ខាងទៀតឡើយ ។
- បើសហទ័ព្ធណាម្ខាង ធ្លាប់ត្រូវបានដកហូតអំណាចមេបា ហើយបានរៀបអាពាហ៍ពិពា

  ហ៍ជាមួយបុគ្គលដែលមានបំណងចង់សុំកូន ៖ ចំណុចនេះ ត្រូវការ ការបកស្រាយ ៖ តើសមស្របដែរឬទេ ដែលត្រូវទទួលស្គាល់ការបង្កើតសុំកូនពេញលេញរវាងកូនសុំ និងភាគីម្ខាងទៀតនៃសហព័ទ្ធដែលត្រូវបានដកហូតអំណាចមេបា? ប្រសិនបើទទួលស្គាល់ការបង្កើតបែបនេះ តើសហព័ទ្ធដែលត្រូវបានដកហូតអំណាចមេបាអាចទទួលបានអំណាចមេបាមកវិញទេ អនុឡោមតាម អានុភាពនៃមាត្រា ១០១៥ ៣» លក្ខខ័ណ្ឌទម្រង់នៃសុំកូនពេញលេញ ?

បញ្ហាជាបន្ទាន់មកទៀត នឹងធ្វើការចោទឡើងថា តើអនីសង្វាសជន អាចបង្កើតរបបសុំកូនពេញលេញបានដែរឬទេ?

បើយើងព្យាយាមធ្វើការប្រៀបធៀបអនីតិសង្វាស និងអាពាហ៍ពិពាហ៍តាមលក្ខណ:ជារូបភាព វាពុំមានភាពខុសប្លែកគ្នាទេ។ អនីសង្វាស និងអាពាហ៍ពិពាហ៍ មានលក្ខណ:ខុសគ្នាត្រឹមតែទម្រង់ ( ការចុះសំបុត្រអាពាហ៍ពិពាហ៍)។ យ៉ាងនេះក៏ដោយ ក្នុងរឿងទាក់ទងនឹងឋាន:បុគ្គល បទបញ្ញាត្តិនីមួយត្រូវបកស្រាយដោយតឹងរឹង។ មូលហេតុដែលបទបញ្ញាត្តិនៃក្រមរដ្ឋប្បវេណីតម្រូវអោយបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមគឺជាសហព័ទ្ធ ពោលគឺបានរៀបអាពាហ៍ពិពាហ៍តាមបទបញ្ញាតច្បាប់ ព្រោះគេពិចារណាដល់ភាពឋិតថេរនៃទំនាក់ទំនងគតិយុត្តរបស់បុគ្គលដែលធនឹងក្លាយជាឪពុកម្តាយចិញ្ចឹម។ អនីសង្វាសពុំបង្កើតជាស្ថានភាពដែលធ្វើអោយទុកចិត្តបាននូវគ្រួសារឋិតថេរ និងល្អមួយនៅឡើយ។ អនីតិសង្វាសពុំចងដោយករណីកិច្ចមួយចំនួនជាអាទិ៍ ករណីសង្គ្រោះ ករណីកិច្ចរស់នៅដោយចុះសម្រុងគ្នាហិង្សាដូចអាពាហ៍ពិពាហ៍ស្របច្បាប់ឡើយ។ ហេតុនេះ ដើម្បីធានាភាពល្អប្រសើរនៃគ្រួសារថ្មីរបស់កូនសុំ បុគ្គលដែលអាពាហ៍ពិពាហ៍ទៅជាឪពុកម្តាយចិញ្ចឹមត្រូវតែជាបុគ្គលដែលមានសហព័ទ្ធ ពោលគឺមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់។

### ១.២ អាយុរបស់ឪពុកម្ដាយចិញ្ចឹម

ឪពុកម្ដាយចិញ្ចឹមត្រូវមានអាយុចាប់ពី២៥ឆ្នាំឡើងទៅ ហើយត្រូវមានអាយុច្រើនជាងកូនសុំយ៉ាងតិច ២០ឆ្នាំ[10] ( មាត្រា ១០០៩ ) ។ ស្ដីពីល័ក្ខខ័ណ្ឌអាយុនេះ ក៏មាននៅភាពប្រហាក់ប្រហែលនឹង ល័ក្ខខ័ណ្ឌខាងលើដែរ។ របបសុំកូនត្រូវតែធានាអោយបាននូវគ្រួសារថ្មីមួយសម្រាប់កុមារដែលជាកូនសុំ ហេតុនេះវាជាភាពចាំបាច់ដើម្បីអោយគ្រួសារថ្មីបង្កើតនូវស្ថានភាពអោយដូចទៅនឹងគ្រួសារធម្មតាដទៃទៀតដែរ។

ប្រសិនបើអាយុរបស់ឪពុកម្ដាយចិញ្ចឹមតិចពេកលទ្ធភាព និងបទពិសោធន៍ក្នុងការថែទាំកូនសុំក៏មានកម្រិតដែលវាអាចនឹងបណ្ដាលអោយកូនសុំពុំអាចទទួលបានថែទាំដែលត្រឹមត្រូវ ។ម្យ៉ាងវិញទៀត យើងគប្បីចោទជាចម្ងល់ពីមូលហេតុដែលបុគ្គលដែលមានអាយុតិចមានបំណងចង់សុំកូន។ តើពួកគេមាមបញ្ហាទាក់ទងនឹងលទ្ធភាពនៃការបង្កកំណើតឬទេ?ហេតុនេះហើយតាមរយៈការពិចារណាលើស្ថានភាពខាងលើច្បាប់បានកំណត់អាយុអប្បរមារបស់ឪពុកម្ដាយចិញ្ចឹមត្រឹម ២៥ឆ្នាំ និងមានគម្លាតអាយុរវាងកូនសុំ យ៉ាងតិច២០ឆ្នាំ។

បទបញ្ញាត្តិនៃ **មាត្រា១០០៩** នៃក្រមរដ្ឋប្បវេណីបានចែងធ្វើធ្វើអោយមានភាពមិនច្បាស់លាស់ទាក់ទងនឹងល័ក្ខខ័ណ្ឌអាយុនេះ។

តើពាក្យថាឪពុកម្ដាយចិញ្ចឹមត្រូវមានអាយុចាប់ពី ២៥ឆ្នាំ សំដៅដល់សហព័ន្ធទាំងពីរ ឬតែម្ខាង?និមិត្តថាឪពុកចិញ្ចឹមមានអាយុ២៥ឆ្នាំម្ដាយចិញ្ចឹមមានអាយុ១៨ឆ្នាំ។ តើរបបសុំកូនអាចត្រូវបានបង្កើតឡើងដែរឬទេ?

ដោយសារតែ បុគ្គលដែលនឹងបុគ្គលដែលនឹងក្លាយជាឪពុកម្ដាយ នឹងទទួលបានអំណាចមេបាលើកូនសុំ និងករណីកិច្ចបីបាច់ថែរក្សា និងផ្ដល់នូវគ្រួសារដែលល្អប្រសើរដល់កូនសុំ ហេតុនេះគប្បីបកស្រាយអំពីបញ្ហាអាយុនេះមានភាពតឹងរឹង ពោលគឺសហព័ន្ធទាំងសងខាងត្រូវមានអាយុយ៉ាងតិច ២៥ ។

**បញ្ហា** ៖ តើបុគ្គលដែលនឹងក្លាយទៅជាឪពុកម្ដាយចិញ្ចឹមត្រូវមានអាយុ យ៉ាងតិច២៥ឆ្នាំ រាប់ចាប់ពីពេលដាក់ពាក្យសុំ ឬយ៉ាងណា។

ក្រមរដ្ឋប្បវេណីពុំបានចែងអោយច្បាស់ពីស្ថាននេះទេ។ ប៉ុន្តែយើងអាចបកស្រាយប្រដូចនឹងវិសាលភាពអាជ្ញាអស់ជំនុំផ្នែកពេលវេលាក្នុងបណ្ដឹងអង្គសេចក្ដី។ តុលាការការធ្វើការសម្រេចសេចក្ដីផ្អែកលើសិទ្ធិឬទំនាក់ទំនងគតិយុត្ត ដែលកើតមាននៅមុនពេលបញ្ចប់ការទាញហេតុផលផ្ទាល់មាត់ [11]

[10] មាត្រា ១០០៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[11] មាត្រា ១៩៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី

(មាត្រា ១៩៩៤ កថាខណ្ឌទី២ )។ ហេតុនេះអង្គហេតុដែលកើតក្រោយពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ពុំស្ថិតក្នុងចំណុចដែលតុលាការផ្អែកដើម្បីចេញសេចក្តីសម្រេចឡើយ។ ចំណែកនីតិវិធីសុំកូនពេញលេញវិញ តាមរយៈការបកស្រាយខាងលើ យើងអាចសន្និដ្ឋានបានថា តុលាការធ្វើការសម្រេចសេចក្តីដោយផ្អែកលើល័ក្ខខ័ណ្ឌសារធាតុនៃក្រមរដ្ឋប្បវេណី ទោះបីវាត្រូវបានបំពេញក្រោយពេលដាក់ពាក្យសុំ ក៏វាពុំធ្វើអោយខុសនឹងល័ក្ខខ័ណ្ឌដែលអាចចេញដីកាសម្រេចចាប់ផ្តើមសុំកូនពេញលេញបានដែរ។ ហេតុនេះឪពុកម្តាយចិញ្ចឹមត្រូវបំពេញពុំមែននៅពេលដាក់ពាក្យសុំទេ គឺនៅពេលដែលតុលាការបញ្ចប់ការវិនិច្ឆ័យអំពីភាពត្រឹមត្រូវនៃល័ក្ខខ័ណ្ឌសុំកូន ពោលគឺនៅមិនពេលតុលាការចេញដីការសម្រេចចាប់ផ្តើមរបបសុំកូន។

### ១.៣ ភាពដែលអាចធ្វើអោយទុកចិត្តបានខ្ទង់ការផ្តល់ការថែទាំកូនសុំ

ដោយសារតែបង្កើតរបបសុំកូន ត្រូវមានជាចាំបាច់នូវការត្រួតពិនិត្យរបស់តុលាការ ( មាត្រា ១០០៧ នៃក្រមរដ្ឋប្បវេណី )ដើម្បីធានាអោយបាននូវផលប្រយោជន៍របស់កូនសុំ ហេតុនេះបុគ្គលដែលនឹងក្លាយទៅជាឪពុកម្តាយចិញ្ចឹមត្រូវបង្ហាញអោយតុលាការមានជំនឿទុកចិត្តថា ការបង្កើតរបបសុំកូនរវាងខ្លួន និងកូនសុំ អាចនឹងបញ្ចៀសស្ថានភាពពិបាកខ្លាំង ឬមិនសមរម្យ ក្នុងការគ្រប់គ្រងថែរក្សាកូនរបស់ឪពុកម្តាយបង្កើត ឬស្ថានភាពផ្សេងៗទៀត ដែលមានភាពចាំបាច់ដើម្បីផលប្រយោជន៍របស់កូននោះ (មាត្រា ១០១២ នៃក្រមរដ្ឋប្បវេណី )។ល័ក្ខខ័ណ្ឌនេះអាចនឹងសម្រេចបាននៅពេលដែលតុលាការបង្គាប់អោយបុគ្គលដែលតុលាការនឹងក្លាយទៅជាឪពុកម្តាយចិញ្ចឹមធ្វើការគ្រប់គ្រងថែរក្សា ក្នុងដំណាក់ការគ្រប់គ្រងថែរក្សា ក្នុងដំណាក់កាលនៃអំឡុងពេលសាកល្បងចិញ្ចឹម (មាត្រា ១០១៣ នៃក្រមរដ្ឋប្បវេណី)។

ពាក្យសុំចាប់ផ្តើមរបបសុំកូនពេញលេញ ស្ថិតនៅក្នុងវិសាលភាពច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។ យោងតាមច្បាប់ស្តីពី**រឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង**( NSCC, ***None Suit Civil Case***) មាត្រា ៣ កថាខណ្ឌទី១ បានបង្ហាញថានីតិវិធីប្រភេទនេះ គឺជានីតិវិធីដែលការសម្រេចសេចក្តី ស្ថិតក្រោម សិទ្ធិអំណាចរបស់តុលាការ[12]។ តុលាការមានឆន្ទានិសិទ្ធក្នុងការបដិសេធអង្គហេតុដែលភាគីបានអះអាងនិងភស្តុតាងដែលភាគីបានដាក់ ហើយមានឆន្ទានុសិទ្ធក្នុងការស្រាវជ្រាវអង្គហេតុនិងភស្តុតាង។ ហេតុនេះ ទោះបីជាភាគីបានដាក់ភស្តុតាង ដែលលបញ្ជាក់ពីការចិញ្ចឹមថែរក្សាកូនសុំបានល្អនៅពេលកន្លងមកក៏ដោយ ក៏តុលាការមានឆន្ទានុសិទ្ធក្នុងការដែលមិនទទួលយកអង្គហេតុ និងភស្តុតាងនោះជាមូលដ្ឋានក្នុងការចេញដីកាសម្រេចដែរ (មាត្រា ២៧ និង មាត្រា ២៨ នៃ NSCC )។

---

12 មាត្រា ៣ ច្បាប់ស្តីពី **រឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង** ( NSCC )

## ២. ល័ក្ខខ័ណ្ឌទាក់ទងនឹងកូនសុំ

យោងតាមគោលគំនិតនៃលិខិតបទដ្ឋានអន្តរជាតិមួយចំនួន ជាអាទិ៍អនុសញ្ញាស្តីពីសិទ្ធិកុមារ អនុសញ្ញាអឺរ៉ុបស្តីពីសុំកូន និងអនុសញ្ញា ហាហ្គ ( Hague Convention )[13] ស្តីពីការសុំកូនអន្តរប្រទេស គោលគំនិតនៃការបង្កើតរបបសុំកូនគឺជា ការផ្តល់អោយកុមារដែលពុំមានការបីបាច់ថែរក្សាពីឪពុកម្តាយបង្កើតនូវគ្រួសារជានិរន្តមួយដែលផ្តល់នូវល័ក្ខខ័ណ្ឌល្អប្រសើរជាមុន។ របបសុំកូនត្រូវបង្កើតឡើងដោយឈរលើការការពារផលប្រយោជន៍កុមារជាចម្បង ហើយចំណុចបន្ទាប់បន្សំដែលត្រូវពិចារណាគឺតម្រូវការកូនរបស់ឪពុកម្តាយចិញ្ចឹម។ ដើម្បីធានានូវការបង្កើតរបបសុំកូនដើម្បីផលប្រយោជន៍កុមារ របបសុំកូនត្រូវបង្កើតឡើងដោយពិចារណាលើ (១) អាយុកូនសុំ (២) តម្រូវការ ការថែទាំជាពិសេស។

### ២.១ អាយុរបស់កូនសុំ

ក្រមរដ្ឋប្បវេណីនៃព្រះរាជាចក្រកម្ពុជាមាត្រា ១០១០ (អាយុកូនសុំ) បានសម្តែងថា ជាគោលការណ៍កូនសុំត្រូវមានអាយុតិចជាង៨ឆ្នាំ។ សុំកូនពេញលេញគឺជារបបសុំកូនដែលបង្កើតឡើងរវាងឪពុកម្តាយចិញ្ចឹម និង កុមារតូចដែលចាំបាច់ត្រូវការការផ្តល់នូវល័ក្ខខ័ណ្ឌគ្រួសារល្អប្រសើរមួយ។ គោលគំនិតនេះមានភាពខុសគ្នានឹងសុំកូនធម្មតាដោយសុំកូនធម្មតាមានគោលបំណងបង្កើតទំនាក់ទំនងញាតិតែប៉ុណ្ណោះ។

ពាក្យថា ជាគោលការណ៍ បង្ករអោយមានការបកស្រាយថា៖

តើការសុំកូនដែលមានអាយុ ៨ឆ្នាំឬលើសពីនេះធាចប្រព្រឹត្តទៅបានទេ? ក្នុងល័ក្ខខ័ណ្ឌអ្វី?

ទោះបីជាមាត្រានេះបានបញ្ញត្រជាគោលការណ៍យ៉ាងណាក្តី ក៏ពុំអាចបកស្រាយអោយផ្ទុយនឹងគោលគំនិតដើមនៃការតាក់តែងបទបញ្ញាត្តិនេះដែរ។ ដោយសារតែការសម្រេចរបស់តុលាការមានគោលបំណងសម្រេចពីភាពត្រឹមត្រូវនៃការសុំកូនពេញលេញ ហេតុនេះបើសិនការចិញ្ចឹមកូនសុំឡើងមុនពេលវេលាជាមូលដ្ឋាន (៨ឆ្នាំ) ក៏គប្បីអនុញ្ញាតអោយបង្កើតសុំកូនបានដែរ ទោះបីជាបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមបានដាក់ពាក្យសុំក្រោយពេលកូនសុំមានអាយុ៨ឆ្នាំយ៉ាងណាក្តី។ការសុំកូនពេញលេញនៅប្រទេសជប៉ុនត្រូវបានអនុញ្ញាតទោះបីជាកូនមានអាយុ៨ឆ្នាំយ៉ាងណាក្តី។ ការសុំកូនពេញលេញនៅប្រទេសសជប៉ុន ត្រូវបានអនុញ្ញាតទោះបីជាកូនសុំមានអាយុ

[13] The **Hague Convention** on the Protection of Children and Co-operation in Respect of Intercountry Adoption (Convention) is an international agreement to safeguard intercountry adoptions. Concluded on May 29, 1993 in The Hague, the Netherlands, the Convention establishes international standards of practices for intercountry adoptions. The United States signed the Convention in 1994, and the Convention entered into force for the United States on April 1, 2008. Read the **full text** of the Convention.

លើសពីគោលការណ៍ក្នុងករណីដែលបុគ្គលដែលនឹងក្លាយជាឪពុកម្តាយបានចិញ្ចឹម ឬបានផ្គត់ផ្គង់ជីវភាពដល់កូនសុំនៅមុនសុំចម្រើនវ័យដល់អាយុជាគោលការណ៍។ អាយុគោលការណ៍របស់កូនសុំប្រទេសជប៉ុនកំណត់យក ៦ឆ្នាំ។

ការដកស្រង់បទបញ្ញត្តិនៃក្រមរដ្ឋប្បវេណីជប៉ុន ពុំមែនជាមូលដ្ឋានដាច់ខាត ក្នុងការបកស្រាយបទបញ្ញត្តិអាយុគោលការណ៍នេះទេ ប៉ុន្តែវាជាទស្សនទានមួយនៃការការពារផលប្រយោជន៍របស់កុមារ។ ចំពោះការបកស្រាយបញ្ហាអាយុជាគោលការណ៍នេះមានភាពខុសប្លែកគ្នារវាងមជ្ឈដ្ឋានអ្នកច្បាប់យ៉ាងនេះក្តី ការបកស្រាយដែលអាចទទួលយកបានគឺជាការបកស្រាយដែលការពារផលប្រយោជន៍របស់កូនសុំ។

### ២.២ តម្រូវការ ការថែទាំជាពិសេស

ប្រសិនបើកុមារមានលទ្ធភាពអាចទទួលបានការថែទាំពីឪពុកម្តាយបង្កើតរបស់ពួកគេហើយ របបសុំកូនពេញលេញនេះ ពុំមានភាពចាំបាច់ដើម្បីស្រោចស្រង់កុមារឡើយ។ របបស្តីពីសុំកូនពេញលេញបានបញ្ញត្តិនូវល័ក្ខខ័ណ្ឌយ៉ាងតឹងរឹងដើម្បីការពារឧត្តមប្រយោជន៍របស់កុមារ ព្រោះប្រសិនបើរបបសុំកូនអាចត្រូវបានបង្កើតតាមនីតិរូមនៃកិច្ចសន្យា ដោយពុំឆ្លងកាត់ការវិនិច្ឆ័យរបស់តុលាការផលប្រយោជន៍របស់កុមារអាចនឹងត្រូវបានបំពាន ពោលគឺយើងពុំអាចធានាបានថាឪពុកម្តាយចិញ្ចឹមអាចមានលទ្ធភាពធ្វើអោយល្អប្រសើរនូវកិច្ចថែទាំកុមារនោះឡើយ ហើយពេលខ្លះវាអាចឈានដល់ការជួញដូរកុមារក្រោមរូបភាពនៃការសុំកូននេះផងដែរ។

ដើម្បីចេញដីការសម្រេចចាប់ផ្តើមរបបសុំកូនពេញលេញ តុលាការត្រូវធ្វើការស្រាវជ្រាវដោយឆន្ទានុសិទ្ធិនូវអង្គហេតុដូចខាងក្រោម៖

- តើមានភាពលំបាកខ្លាំងក្នុងការថែរក្សាកូនរបស់ឪពុកម្តាយបង្កើតនោះទេ?
- តើមានការបោះបង់ចោលដោយមិនត្រឹមត្រូវឬដោយគំនិតទិច្ចរិតរបស់ឪពុកម្តាយបង្កើតដែរឬទេ?
- តើមានភាពធ្វើបាប ជាអាទិ៍ហិង្សា លើកុមារដែរឬទេ?
- តើរបបសុំកូនដែលនឹងបង្កើតឡើង អាចស្រោចសស្រង់ស្ថានភាពទាំងបីខាងលើនេះដែរឬទេ? ទាំងអស់ខាងលើនេះគឺជាមូលដ្ឋានដើម្បីអោយតុលាការធ្វើការធ្វើការវិនិច្ឆ័យ ពីភាពសមស្របនៃការចាប់ផ្តើមសុំកូនពេញលេញ។

## ៣. លក្ខខ័ណ្ឌទម្រង់នៃសុំកូនពេញលេញ

របបសុំកូនពេញលេញដែលបានបញ្ញត្តិក្រមរដ្ឋប្បវេណី២០០៧ ពុំត្រឹមតែបានកំណត់ល័ក្ខខ័ណ្ឌសារធាតុយ៉ាងតឹងរឹងប៉ុណ្ណោះទេ វាថែមទាំងតម្រូវអោយមានការសម្រេចពីតុលាការដោយឆ្លងកាត់ការវិនិច្ឆ័យពិនិត្យយ៉ាងជិតដល់នូវល័ក្ខខ័ណ្ឌសារធាតុនីមួយៗ ដើម្បីការពារផលប្រយោជន៍របស់កុមារ ផ្ទុយស្រលះអំពីល័ក្ខខ័ណ្ឌទម្រង់ដែលកំណត់ក្នុងច្បាប់ស្តីពិអាពាហ៍ពិពាហ៍ និង គ្រួសារ ដែលចាត់ទុកទំនាក់ទំនងសុំកូនជានិច្ចសន្យា។ ល័ក្ខខ័ណ្ឌទម្រង់នៃសុំកូនពេញលេញដែលត្រូវបំពេញគឺលក្ខណៈសម្បត្តិជាភាគីទម្រង់នៃពាក្យសុំការវិនិច្ឆ័យ និងការចេញដីកាសម្រេចចាប់ផ្តើមសុំកូន ដែលជាចំណុចចាប់ផ្តើមអានុភាពនៃសុំកូនពេញលេញ។

### ៣.១ ភាគីនៃពាក្យសុំ

យោងតាមមាត្រា១៦នៃ **រឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង** ( NSCC ) បុគ្គលដែលអាចដាក់ពាក្យសុំ នៅក្នុងនីតិវិធីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងត្រូវតែជាជនពាក់ព័ន្ធ ដែលអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ១០០៧ បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមគឺជាបុគ្គលដែលមានសិទ្ធិតាមបញ្ញត្តិសារធាតុក្នុងការដាក់ពាក្យសុំ[14]។ នៅក្នុងពាក្យសុំចាប់ផ្តើមរបបសុំកូន ពុំចាំបាច់មានការដាក់ពាក្យរួមគ្នាជាមួយឪពុកម្តាយបង្កើតរបស់កូនសុំទេ។ ចំណែកឯល័ក្ខខ័ណ្ឌនៃការព្រមព្រៀងតាមមាត្រា ១០១១ (ការយល់ព្រមរបស់ឪពុកម្តាយ) នៃក្រមនេះនៅក្នុងដំណើរការនៃការជំនុំជម្រះលើពាក្យសុំ តុលាការនឹងសាកសួរឪពុកម្តាយបង្កើត ក្នុងនាមជាជនពាក់ព័ន្ធ អំពីការឯកភាពអោយបង្កើតរបបសុំកូនពេញលេញ(មាត្រា ២៩ នៃNSCC)។

ជាគោលលការណ៍របបសុំកូន មិនអាចបង្កើតបានឡើយប្រសិនបើពុំមានការឯកភាពពីឪពុកម្តាយបង្កើត ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន របស់កូនសុំ (មាត្រា ១០១១ វាក្យខណ្ឌ១) ។ជាវិធានសីលធម៌ការយកកុមារចេញពីគ្រួសារបង្កើតរបស់ពួកគេ ត្រូវមានការឯកភាពពីបុគ្គលដែលមានករណីកិច្ចត្រួតពិនិត្យ។ ប៉ុន្តែដើម្បីការពារឧត្តមប្រយោជន៍របស់កុមារ កាលបើឪពុកម្តាយបង្កើតឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ពុំមានសមត្ថភាពក្នុងការបង្ហាញឆន្ទៈ ឬ បានធ្វើបាបឬបង់ចោលកុមារចោលដោយគំនិតទុច្ចរិត ឬមូលហេតុផ្សេងទៀត របបសុំកូនពេញលេញត្រូវបង្កើតឡើងដោយពុំចាំបាច់មានការឯកភាពពីជនទាំងនោះឡើយ (មាត្រា ១០១១ វាក្យខណ្ឌ២) ។

បទបញ្ញត្តិខាងលើគាំទ្រអោយទស្សនទាននៃអនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា ៩ ។ គោលគំនិយនេះមានន័យថាគ្មានការដកហូតណាមួយអាចបានធ្វើឡើងចំពោះកុមារ ពីឪពុកម្តាយបង្កើតរបស់ពួកគេ ដោយមិនឆ្លុះបញ្ចាំងឆន្ទៈពិតរបស់កុមារលើកលែងតែការធ្វើនេះ ធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ច ហើយវាចាំបាច់ដើម្បីការពារឧត្តមប្រយោជន៍របស់កុមារ។

---

[14] មាត្រា ១០០៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

យោងតាមមាត្រា ១០១១ វាក្យខណ្ឌទី១នៃក្រមរដ្ឋប្បវេណី ដើម្បីអាចចាប់ផ្តើមរបបសុំកូន បានបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមត្រូវមានការឯកភាពពីឪពុកម្តាយបង្កើតរបស់កូនសុំ។

ប៉ុន្តែប្រសិនបើការសុំកូន ចូលល័ក្ខខ័ណ្ឌនៃវក្យខណ្ឌ២ នៃមាត្រា១០១១ បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមអាចដាក់ពាក្យសុំ ដោយពុំចាំបាច់មានការយល់ព្រមពីឪពុកម្តាយបង្កើតរបស់កូនសុំឡើយ ប៉ុន្តែនៅក្នុងពាក្យសុំ ត្រូវបញ្ជាក់នូវអង្គហេតុដែលបង្ហាញអោយតុលាការការឃើញនូវស្ថានភាពអំពើហឹង្សាលើកូនសុំ ឬការបោះបង់កូនសុំចោលដោយគំនិតទុច្ចរិត តាមមាត្រា ១០១១វាក្យខណ្ឌទី២ (មាត្រា ២៦ កថាខណ្ឌទី ២ចំណុច ខ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង)។

សកម្មភាពដាក់ពាក្យសុំដាក់ពាក្យសុំក៏តម្រូវអោយអ្នកដាក់ពាក្យមានសមត្ថភាពនៅក្នុងការធ្វើសកម្មភាពស្របតាមច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងដែរ។ ក្នុងករណីដែលសហាព័ទ្ធណាម្ខាងគឺជាជនដែលស្ថិតនៅក្រោមរបបអាណាព្យាបាលទូទៅ សកម្មភាពដាក់ពាក្យសុំរបស់សហាព័ទ្ធនោះក៏ត្រូវបានទទួលស្គាល់ដែរ យោងតាមមាត្រា១៧ នៃ NSCC ។ ប៉ុន្តែប្រសិនបើនៅពេលដាក់ពាក្យសុំ សហាព័ទ្ធនោះពុំមានសមត្ថភាពក្នុងការបង្ហាះឆន្ទៈទេ (មាត្រា ១៤ នៃCC)ពោលគឺ ពុំអាចយល់ដឹងបានអំពីលទ្ធផលតាមផ្លូវច្បាប់នៃអំពើរបស់ខ្លួន សហាព័ទ្ធនោះពុំមានលក្ខណៈសម្បត្តិជាអ្នកដាក់ពាក្យសុំឡើយហើយវិធានការតំណាងពិសេស មិនអាចយកមកអនុវត្តឡើយក្នុងនីតិវិធីនេះព្រោះរបបអ្នកតំណាងពិសេសអនុវត្តតែចំពោះជនដែលខ្វះសមត្ថភាពក្នុងការធ្វើសកម្មភាព។

### ៣.២ ចំណុចដែលត្រូវសរសេរក្នុងពាក្យសុំ

នីតិវិធីសុំកូន ត្រូវធ្វើដោយអនុឡោមតាមច្បាប់ស្តីពីនីតិវិធីរឿងរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។ ពាក្យសុំអោយតុលាការចេញដីកាសម្រេចចាប់ផ្តើមសុំកូនត្រូវសរសេរចំណុចនីមួយៗដូចខាងក្រោម ៖

- អត្តសញ្ញាណជនពាក់ព័ទ្ធ ៖ ឈ្មោះនិង អាស័យដ្ឋានអ្នកដាក់ពាក្យសុំ (របស់ឪពុកម្តាយចិញ្ចឹម) និងភាគីម្ខាងទៀត (ឪពុកម្តាយបង្កើត និងកូនសុំ)
- ខ្លឹមសារនៃដីការសម្រេច ៖ សុំអោយតុលាការចេញដីការសម្រេចចាប់ផ្តើមរបបសុំកូនឪពុកម្តាយចិញ្ចឹមឈ្មោះ………និង កូនសុំឈ្មោះ………
- អង្គហេតុដែលជាមូលហេតុនៃការទាមទារ ៖ ត្រូវបង្ហាញអោយតុលាការយល់អំពីស្ថានភាពលំបាករបស់កុមារនៅគ្រួសារបង្កើតរបបសុំកូនពិតជាអាចធ្វើអោយស្ថានភាពរស់នៅរបស់កុមារ មានភាពល្អប្រសើរជាងមុន។

- ឧបសម្ព័ន្ធពាក្យសុំ ៖ សេចក្តីចម្លងសំបុត្រកំណើតរបស់ឈ្មោះ អ្នកដាក់ពាក្យសុំ និងកូនសុំ

### ៣.៣ ការវិនិច្ឆ័យលើពាក្យសុំ

នីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងជាប្រភេទនៃនីតិវិធីដែលត្រូវធ្វើការសម្រេចអំពីចំណុចដែលជាសិទ្ធិអំណាចរបស់តុលាការ។ គោលការណ៍ចំពោះមុខ និងគោលការណ៍សេរីភាពចាត់ចែង មិនត្រូវយកមកអនុវត្តឡើយក្នុងនីតិវិធីប្រភេទនេះ ជំនួសមកវិញនូវគោលការណ៍ការពិតជាក់ស្តែង ( substandtive truth) ។ហេតុនេះដើម្បីចេញដីការសម្រេច តុលាការពុំចាំបាច់ឆ្លងកាត់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ទេ។ ករណីដែលតុលាការសម្រេចមិនធ្វើនីតិវិធីទាញហេតុផលតុលាការត្រូវកំណត់កាលបរិច្ឆេទ និងកោះហៅអ្នកដាក់ពាក្យសុំ ( ឪពុកសុំចិញ្ចឹម) និងជនផ្សេងទៀតដែលពាក់ព័ន្ធ ដូចជាឪពុកម្តាយបង្កើត មកធ្វើការសាកសួរ (មាត្រា ២៩នៃ NSCC)[15]។

ដើម្បីការពារផលប្រយោជន៍សាធារណៈ ព្រះរាជអាជ្ញាតាំងនាមស្ថាប័នអយ្យការ អាចចូលរួមក្នុងនីតិវិធីទាញហេតុផល ឬកាលបរិច្ឆេទនៃការសាកសួរភាគីបាន។អយ្យការ អាចសម្តែងជាមតិយោបល់កាលបើខ្លួនយល់ឃើញថាចាំបាច់ដើម្បីការពារប្រយោជន៍សារធាណៈ (ផលប្រយោជន៍របស់កូនសុំ)។

ចំណុចដែលតុលាការត្រូវធ្វើការវិនិច្ឆ័យគឺ ៖

- តើបុគ្គលដែលបានដាក់ពាក្យសុំ ពិតជាមានលក្ខណៈសម្បត្តិតាមផ្លូវច្បាប់ដើម្បីក្លាយជាឪពុកម្តាយចិញ្ចឹមដែរឬទេ ?( មានសហព័ទ្ធដែរឬទេ? (មានសហព័ទ្ធឬទេ? ទទួលការឯកភាពពីសហព័ទ្ធឬទេ?)
- តើការសុំកូននេះមានការឯកភាពពីឪពុកម្តាយបង្កើតឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កូនសុំដែរឬទេ? បើពុំមានការឯកភាព តើមានការវាយធ្វើបាប ឬការបោះបង់អនីតិជនចោលដោយគំនិតទុច្ចរិតឬទេ?
- តើការបង្កើតរបបសុំកូនពេញលេញនេះអាចធ្វើអោយកុមារជៀសផុតពីស្ថានភាពលំបាកខ្លាំងដែរឬទេ?

### ៣.៤ ការចាត់ចែងរក្សាការពារនៅមុខពេលដីការសម្រេចចាប់សុំកូនមានអានុភាព

ដើម្បីអាចសម្រេចនូវល័ក្ខខ័ណ្ឌនៃការចិញ្ចឹមសាកល្បងឪពុកម្តាយចិញ្ចឹមត្រូវទទួលការគ្រប់គ្រប់គ្រងកូន។ ប្រសិនបើឪពុកម្តាយបង្កើតពុំជំទាស់នឹងនឹងការចិញ្ចឹមសាកល្បងនេះទេ អ្នកដាក់

[15] មាត្រា ២៩ ច្បាប់ស្តីពី រឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ( NSCC )

ពាក្យសុំអាចគ្រប់គ្រងកូនដោយសន្តិវិធី។ ប៉ុន្តែក្នុងករណីដែលមានការបដិសេធមិនអោយគ្រប់គ្រង វិធានខាងក្រោមនេះនឹងត្រូវយកមកអនុវត្ត។

យោងតាមមាត្រា៩៨នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង (NSCC) (មាត្រា១៦៦ នៃច្បាប់ចេញដីការក្សាការពារព្យួរជាបណ្តោះអាសន្ននូវអំណាចមេបារបស់ឪពុកម្តាយបង្កើតឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន និងកំណត់អំពីអ្នកដែលមានអំណាចមេបាជំនួស[16]។ ប៉ុន្តែដីការសម្រេចរក្សាការពារត្រូវតែមានមូលហេតុត្រឹមត្រូវដើម្បីការពារផលប្រយោជន៍របស់កុមារ។ ប្រសិនបើតុលាការយល់ឃើញថាការបដិសេធនេះមិនប៉ះពាល់ដល់ប្រយោជន៍របស់កូនសុំទេ ពោលគឺពុំចូលស្ថានភាពនៃមាត្រា១០១១ នៃCC ឆន្ទៈយល់ព្រមរបស់ឪពុកម្តាយបង្កើតត្រូវអោយមានជាចាំបាច់។ ការបដិសេធការប្រគល់កូននេះ បានបង្ហាញពីឆន្ទៈរបស់ឪពុកម្តាយបង្កើត ថាពុំយល់ព្រមក្នុងការបង្កើតរបបសុំកូននេះឡើយ។ ហេតុនេះប្រសិនបើមានស្ថានភាពដូចបានរៀបរាប់ខាងលើតុលាការនឹងចេញដីកាសម្រេចច្រានចោល ការទាមទាររបស់អ្នកដាក់ពាក្យសុំដោយមូលហេតុខ្វះល័ក្ខខ័ណ្ឌយល់ព្រម។

### ៣.៥ ការចេញដីកាសម្រេច

យោងតាមមាត្រា ១០០៧ នៃក្រមរដ្ឋប្បវេណី ដើម្បីចេញសេចក្តីសម្រេចចាប់ផ្តើមពីរបបសុំកូន តុលាការត្រូវធ្វើការវិនិច្ឆ័យអំពី ៖

(១) ឆន្ទៈព្រមព្រៀងរវាងសហព័ន្ធជាឪពុកម្តាយចិញ្ចឹមមុំ

(២) អាយុរបស់កូនសុំ និងឪពុកម្តាយចិញ្ចឹម

(៣) ការឯកភាពរបស់ឪពុកម្តាយបង្កើត

(៤) លទ្ធភាពដែលអាចធ្វើអោយកុមារមានការថែទាំប្រសើរជាងមុន។

ដើម្បីអាចចេញដីកាសម្រេចចាប់ផ្តើមសុំកូន ចាំបាច់ឆ្លងកាត់ការចិញ្ចឹមសាកល្បង (មាត្រា ១០១៣)។ ប៉ុន្តែប្រសិនបើអ្នកដាក់ពាក្យសុំបានធ្វើការចិញ្ចឹមកូនមុនពេលដាក់ពាក្យសុំកន្លងមក ហើយបើយល់ឃើញថាគ្មានភាពចាំបាច់ក្នុង ការចិញ្ចឹមសាកល្បងទេ តុលាការអាចចេញដីកាសម្រេចចាប់ផ្តើម របបសុំកូនដោយសរសេរបន្ថែមត្រង់ផ្នែកសំអាងហេតុ ថាអ្នកដាក់ពាក្យសុំបានចិញ្ចឹមកូនសុំពេលកន្លងមកហើយតុលាការទទួលស្គាល់ការចិញ្ចឹមនេះ។

ក្នុងករណីដែលឪពុកម្តាយចិញ្ចឹមមានបំណងដកពាក្យសុំ មុនពេលដែលតុលាការចេញសេចក្តីសម្រេចការធ្វើនេះអាចត្រូវបានអនុញ្ញាត ដោយសារមូលហេតុ បុគ្គលដែលបានដាក់ពាក្យសុំបាត់បង់ឆន្ទៈក្នុងការសុំកូនពេញលេញ។ ប៉ុន្តែបើការធ្វើនេះ នៅក្រោយពេលតុលាការចេញដីកា

[16] មាត្រា១៦៦ច្បាប់ស្តីពី រឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ( NSCC )

សម្រេចពោលគឺអំឡុងពេលបណ្តឹងជំទាស់ ជាចំណុចដែលចាំបាច់ត្រូវធ្វើការបកស្រាយ ព្រោះ NSCCពុំបានចែងពីបញ្ហានេះ។ តាមច្បាប់ស្តីពីនីតិវិធីទាក់ទងនឹងទំនាក់ទំនងគ្រួសាររបស់ប្រទេសជប៉ុនមានតែដីការសម្រេចច្រានចោលពាក្យសុំទេ ដែលភាគីដាក់ពាក្យសុំអាចប្តឹងជំទាស់។ បន្ថែមពីនេះទៀត មាត្រា ៨២ នៃច្បាប់ដដែលបានសម្តែងថា ៖ «លើកលេងតែមានបទបញ្ញត្តពិសេសចែងពីផ្ទុយពីនេះអ្នកដាក់ពាក្យសុំអាចដកពាក្យសុំមួយផ្នែក ឬទាំងមូល មុនពេលតុលាការចេញដីកាសម្រេចលើពាក្យសុំ។» យោងតាមគោលគំនិតនៃមាត្រានេះ រាល់ការដកពាក្យសុំ ក្រោយពេលតុលាការចេញដីកាសម្រេចចាប់ផ្តើមសុំកូនពេញលេញ មិនត្រូវអនុញ្ញាតអោយធ្វើឡើយ។ ដោយឡែកច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង របស់កម្ពុជាវិញ ការដកពាក្យបណ្តឹង និង បណ្តឹងឧបាស្រ័យចំពោះដីកាសម្រេចច្រានចោលពាក្យសុំ ពុំមានចែងទេ ហើយវាអាស្រ័យលើការបកស្រាយរបស់ភាគី កម្ពុជាចំពោះបញ្ហាខាងលើនេះ។

**កថាខណ្ឌទី៣ ៖ អានុភាពនៃសុំកូនពេញលេញ**

របបសុំកូន បង្កើតអានុភាពនៅពេលដីកាសម្រេចចាប់ផ្តើមរបបសុំកូនចូលជាស្ថាពរ។ សម្របពេលនឹងការចូលជាស្ថាពរនៃពីដីកាសម្រេចផ្តើមនេះ វាបានបង្កើតអោយមានអនុភាពគតិយុត្តមួយចំនួនដូចជា ៖ (១) ការបង្កើតទំនាក់ទំនងញាតិ (២) ការកាត់ផ្តាច់ទំនាក់ទំនងញាតិ (៣) ការផ្ទេរអំណាចមេបា។

**១. ការបង្កើតទំនាក់ទំនងជាមួយឪពុកម្តាយចិញ្ចឹម**

គោលបំណងសខាន់បន្ទាប់ពីការផ្តល់នូវការថែទាំដូចនឹងគ្រួសាររបស់កូនសុំ គឺជាការបង្កើតអោយមានទំនាក់ទំនងញាតិថ្មីមួយក្នុងទំនាក់ទំនងរវាងកូនសុំ និងគ្រួសាររបស់ឪពុកម្តាយ។នៅពេលដីការសម្រេច ចាប់ផ្តើមសុំកូនមានអនុភាព ត្រូវបង្កើតទំនាក់ទំនងញាតិដូចគ្នានឹងញាតិលោហិតរវាងបុគ្គលជាកូនសុំនិង ឪពុកម្តាយចិញ្ចឹមព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយ[17] ។ វិសាលភាពនៃទំនាក់ទំនងញាតិដែលត្រូវបង្កើតតាមរយៈសុំកូន មានត្រឹមត្រូវតែក្នុង ទំនាក់ទំនងរវាងកូនសុំនឹងឪពុកម្តាយចិញ្ចឹម ព្រមទាំងញាតិលោហិត របស់ឪពុមម្តាយចិញ្ចឹមតែប៉ុណ្ណោះ។ញាតិលោហិត ឬញាតិពន្ធរបស់កូនសុំដែលបានកើតមុនទំនាក់ទំនងសុំកូន ពុំស្ថិតក្នុងវិសាលភាពនៃអនុភាពសុំកូនឡើយ។ដូចនេះ ក្នុងទំនាក់ទំនងរវាង បុព្វញាតិរបស់កូនសុំ នឹងឪពុកម្តាយចិញ្ចឹម និងញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹមពុំមានទំនាក់ទំនងញាតិនឹងគ្នាឡើយ។

ដីកាសម្រេចចាប់ផ្តើមសុំកូនពុំមានអានុភាពប្រតិសកម្ម។ នៅពេលដែលដីកាសម្រេចនេះបង្កើតអានុភាព អានុភាពទាក់ទងនឹងញាតិកើតឡើងរាប់ចាប់ពីពេលដែលដីកាសម្រេចនេះចូលជា

[17] មាត្រា ៩៤០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ស្ថាពរ។ ហេតុនេះអានុភាពទំនាក់ទំនងញាតិ ចំពោះបច្ឆាញាតិ ឬសហព័ទ្ធរបស់កូនស្មុំ វាអាស្រ័យថាតើទំនាក់ទំនងញាតិរវាងកូនសុំ និងបច្ឆាញាតិនោះកើតឡើង មុនឬក្រោយទំនាក់ទំនងស្មុំកូន។

តើកូនសុំអាចទទួលឋានៈជាសន្តតិជនលំដាប់ទី៣ដែរឬទេ ក្នុងទំនាក់ទំនងជាមួយកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹម?

យោងតាមមាត្រា ១០១៥ នៃក្រមរដ្ឋប្បវេណី «ដោយបង្កើតស្មុំកូន កូនសុំត្រូវទទួលបានឋានៈដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹម និងត្រូវទទួលសិទ្ធិ និងករណីកិច្ចដូចគ្នានឹងកូនបង្កើតក្នុងទំនាក់ទំនងជាមួយឪពុកម្តាយ។» មាត្រានេះបានកំណត់វិសាលភាពនៃ សិទ្ធិ និងកាតព្វកិច្ច ក្នុងទំនាក់ទំនងជាមួយឪពុកម្តាយចិញ្ចឹម[18]។ ពាក្យថាសិទ្ធិ និងករណីកិច្ចកិច្ចដូចគ្នា ពុំសំដៅលើការធ្វើអោយកូនសុំ ក្លាយទៅជាកូនបង្កើតទេ។ វាមានគោលបំណងកំណត់អំពីដូចគ្នា រវាង សិទ្ធិ និងកាតព្វកិច្ចដែលឪពុកម្តាយចិញ្ចឹមមានចំពោះកូនបង្កើតរបស់ខ្លួន និងចំពោះកូនសុំ។ ម្យ៉ាងទៀតមាត្រា ៩៤០ក៏ធ្វើអោយយើងគិតថា ការបង្កើតស្មុំកូន ធ្វើអោយកូនសុំក្លាយទៅជាកូនបង្កើត។ប៉ុន្តែមាត្រានេះ ពុំគោលបំណងកំណត់បែបនេះទេ។ មាត្រា៩៤០ គ្រាន់តែកំណត់អំពីអានុភាពនៃការស្មុំកូន ដែលបង្កើត ទំនាក់ទំនងញាតិលោហិតរបស់ឪពុកម្តាយបង្កើត។ គិតពីថ្នាក់ញាតិ កូនសុំ និងកូនបង្កើតរបស់ឪពុកម្តាយបង្កើតរបស់ឪពុកម្តាយចិញ្ចឹម មានលក្ខណៈដូចគ្នា នឹង ថ្នាក់ញាតិនៃទំនាក់ទំនង ញាតិលោហិតរវាងកូនបង្កើត និងកូនបង្កើត ប៉ុន្តែពុំបានន័យថា កូនសុំក្លាយទៅជាបងប្អូនបង្កើត ជាមួយនឹងកូនបង្កើតឡើយ។ ហេតុនេះកូនសុំពុំមែនជាបងប្អូនបង្កើតរបស់កូនបង្កើតនៃឪពុក

ម្តាយចិញ្ចឹម ហើយមិនមានលក្ខណៈសម្បត្តិជាសន្តតិជនលំដាប់ទី៣ ក្នុងទំនាក់ទំនងជាមួយកូនបង្កើតនៃឪពុកម្តាយចិញ្ចឹម។

**ឧទាហរណ៍ជាក់ស្តែង ៖** A និង B បានលែងលះគ្នា C ស្ថិតក្រោមអំណាចមេបាររបស់ A ។ A បានរៀបអាពាហ៍ពិពាហ៍ថ្មីជាមួយ D បន្ទាប់មក D មានបំណងចង់សុំ C ធ្វើជាកូនសុំ។ ក្នុងករណីនេះ អ្នកមានអំណាចមេបារួមលើ C គឺ A និង D។ ប៉ុន្តែបើ C ស្ថិតក្រោមអំណាចមេបាររបស់ B ក្នុងករណី D បានស្មុំ C អ្នកដែលមានអំណាចមេបាលើ C គឺ A និង D ។

### ២. ការកាត់ផ្តាច់ទំនាក់ទំនងញាតិ

តាមរយៈអានុភាពនៃដីកាសម្រេចចាប់ផ្តើមស្មុំកូនពេញលេញ ទំនាក់ទំនងញាំតិរវាងកូនសុំ និងឪពុកម្តាយបង្កើតត្រូវបានកាត់ផ្តាច់ (មាត្រា ១០១៤នៃ CC) វាស្របទៅនឹងគោលបំណងនៃការបង្កើតរបបស្មុំកូនពេញលេញដែលជាការបង្កើតគ្រួសារប្រឌិតមួយ និងបង្កើតស្ថានភាពដូចគ្រួសារពី

[18] មាត្រា ១០១៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ធម្មជាតិរបស់កូនសុំ។ ការកាត់ផ្តាច់នេះ ក៏ធ្វើអោយកូនសុំ បាត់បង់នូវលក្ខណៈសម្បត្តិជាសន្តតិជន ក្នុងទំនាក់ទំនងរវាងឪពុកម្តាយបង្កើតផងដែរ។

ក្នុងករណីមួយចំនួនការផ្តាច់ទំនាក់ទនងទាំងស្រុងរវាងឪពុកម្តាយបង្កើតរបស់កូនសុំ អាចនឹងធ្វើអោយកូនពុំសូវមានលទ្ធភាពអាចដឹងអំពីសាវតាជាតិពិតប្រាកដរបស់ខ្លួន ដោយសារមូលហេតុ ៖ ការសុំកូនបង្កើតនៅពេលកូនសុំមានអាយុតិចពេក (១ឆ្នាំ ឬ ២ឆ្នាំ )និងភាពថ្មីសន្លាងនៃសំបុត្រកំណើតរបស់កូនសុំ [19] ។ ជាលក្ខណៈសីលធម៌ កូនសុំគប្បីមានសិទ្ធិអាចដឹងអំពីកំណើតរបស់ខ្លួនហេតុនេះច្បាប់បានអនុញ្ញាតអោយកូនសុំនៅពេលដល់នីតិភាព អាចដាក់ពាក្យសុំ ទៅតុលាការដែលរក្សាសំណុំរឿងដើម្បីផ្តល់នូវពត៌មានស្តីពីកំណើតរបស់ខ្លួន។ ប៉ុន្តែការស្នើរសុំនេះ ពុំត្រូវអនុញ្ញាតឡើយប្រសិនបើពុំមានមូលហេតុត្រឹមត្រូវ (មាត្រា ១០១៩ )។

**៣. ការផ្ទេរអំណាចមេបា**

អានុភាពនៃដីកាសម្រេចចាប់ផ្តើមសុំកូន ពុំត្រឹមត្រូវតែកាត់ផ្តាច់ទំនាក់ទំនងញាតិរវាងកូនសុំ និងឪពុកម្តាយបង្កើតទេ ប៉ុន្តែវាថែមទាំងផ្ទេរអំណាចមេបា ពីឪពុកម្តាយបង្កើត ទៅឪពុកម្តាយចិញ្ចឹមផងដែរ (មាត្រា ១០៣៥នៃ ក្រមរដ្ឋប្បវេណី )។ឪពុកម្តាយចិញ្ចឹមដែលជាអ្នកទទួលអំណាចមេបាតាមរយៈអានុភាពនៃដីកាសម្រេចខាងលើ ត្រូវមានសិទ្ធិ និងករណីកិច្ចបីបាច់ថែរក្សារូបកាយរបស់កូនសុំជាអនីតិជន និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូនដូចជា៖ ការអប់រំ ផ្តល់ទីសំណាក់ ដាក់ទណ្ឌកម្មកូន និងសិទ្ធិអំណាចគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន ។

ក្នុងករណីដែលដីកាសម្រេចចាប់ផ្តើមសុំកូនបង្កើតអានុភាព អំណាចមេបាត្រូវបានផ្ទេរ។ ហេតុនេះប្រសិនបើឪពុកម្តាយបង្កើត ពុំយល់ព្រមក្នុងការប្រគល់កូនអោយឪពុកម្តាយចិញ្ចឹម ឪពុកម្តាយចិញ្ចឹមអាចអនុវត្តសិទ្ធិទាមទារអោយប្រគល់កូនផ្អែកលើអំណាចមេបា [20] តាមមាត្រា ១០៤៧ កថាខណ្ឌទី១។ ការទាមទារអោយប្រគល់កូន ជាប្រភេទនៃបណ្តឹងទាមទារអោយផ្តល់តាវកាលិក ហើយការអនុវត្តដោយបង្ខំអោយប្រគល់កូនត្រូវអនុវត្តតាមវិធីបង្ខំដោយប្រយោល ( ស្រដៀងនឹងការទាមទារអោយប្រគល់កូនផ្អែកលើដីកាសម្រេច ឬ សាលក្រមលែងលះ ដែលកំណត់អំពីអំណាចមេបាដែរ )។

---

[19] មាត្រា ១០១៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[20] មាត្រា ១០៤៧ ត្រង់ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

### ៤. ការកាត់កាល់សុំកូនពេញលេញ

ការកាត់កាល់គឺជាការបញ្ចប់ទំនាក់ទំនងញាតិរវាងកូនសុំ បច្ឆាញាតិរបស់កូនសុំ ឬសហព័ទ្ធរបស់បច្ឆាញាតិនោះនឹងឪពុកម្តាយចិញ្ចឹម ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹម។ ការកាត់កាល់កូនសុំពេញលេញ ក៏ត្រូវបំពេញដូចគ្នានូវល័ក្ខខ័ណ្ឌយ៉ាងតឹងរឹង ដើម្បីការពារផលប្រយោជន៍របស់កូនសុំ។

#### ៤.១.ល័ក្ខខ័ណ្ឌក្នុងការកាត់កាល់សុំកូនពេញលេញ

##### ៤.១.ក ល័ក្ខខ័ណ្ឌសារធាតុ

ចំណុចដែលសំខាន់ក្នុងការបង្កើតសុំកូនពេញលេញគឺផលប្រយោជន៍របស់កុមារចំណែកឯចំណុចសំខាន់ដើម្បីជាមូលហេតុក្នុងការកាត់កាល់ ក៏ត្រូវតែជាផលប្រយោជន៍របស់កុមារដែរ។ យោងតាមមាត្រា ១០១៦នៃក្រមរដ្ឋប្បវេណី ដើម្បីអាចកាត់កាល់កូនសុំពេញលេញ ល័ក្ខខ័ណ្ឌខាងក្រោមត្រូវតែបំពេញ៖

- បើមានការធ្វើបាបដោយឪពុកម្តាយចិញ្ចឹម បោះបង់កូនសុំចោលដោយគំនិតទុច្ចរិតឬហេតុផលផ្សេងៗទៀត ដែលបំពានផលប្រយោជន៍របស់កូនសុំយ៉ាងធ្ងន់ធ្ងរ។
- បើឪពុកម្តាយបង្កើតអាចគ្រប់គ្រងថែរក្សាដោយសមរម្យ។

នៅក្នុងមាត្រា ១០១៦ ត្រង់ កថាខណ្ឌទី២ បានសង្កត់ន័យអោយកាន់តែធ្ងន់ថា រាល់ការកាត់កាល់ដែលពុំធ្វើឡើងស្របតាមល័ក្ខខ័ណ្ឌពីរខាងលើ ពុំអាចធ្វើឡើយ។

ប្រសិនបើការកាត់កាល់កូនសុំពេញលេញដែលជានីតិជនដោយយកមូលហេតុនៃការបោះបង់ចោលដោយគំនិតទុច្ចរិត ពុំត្រូវបានទទួលស្គាល់ថាសមស្របទេ ដោយសារតែមាត្រា ១០១៦ចែងមកក្នុងស្ថានភាពដែលកូនសុំនៅត្រូវការចិញ្ចឹមកាន់តែថយ ករណីកិច្ចមើលថែរក្សាក៏កាន់តែតិចដែរ។ ហេតុនេះ ស្ថានភាពដែលកូនជានីតិជន កាត់កាល់ឪពុកម្តាយ ត្រូវបានសន្មត់ថា ពុំអាចធ្វើទៅបានឡើយ យោងតាមមាត្រា ១០១៦ កថាខណ្ឌទី២។

##### ៤.១.ខ ល័ក្ខខ័ណ្ឌទម្រង់

ការកាត់កាលត្រូវធ្វើឡើងតាមនីតិវិធីបណ្តឹងឋានៈបុគ្គល ហើយតុលាការធ្វើការសម្រេចសេចក្តីដោយចេញសាលក្រម។

##### ៤.២. លក្ខណៈសម្បត្តិជាភាគី

យោងតាមមាត្រា ៨ (ការអនុវត្តដូចគ្នានឹងមាត្រា ៣២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ក្នុងនីតិវិធីបណ្តឹងកាត់កាល់ ដើមចោទអាចជា ៖ កូនសុំ ឪពុកម្តាយបង្កើត ឬតំណាងអយ្យការ។ ចុងចម្លើយគឺ

ជាឪពុកម្តាយចិញ្ចឹម។ ប្រសិនបើដើមចោទ ជាឪពុកម្តាយ បង្កើតឬតំណាងអយ្យការចុងចម្លើយគឺជា កូនសុំនិងឪពុកម្តាយចិញ្ចឹម (មាត្រា៧ នៃច្បាប់ស្តីពីបណ្តឹងឋានៈបុគ្គល)។

ទោះបីតាមផ្លូវច្បាប់សារធាតុ កូនសុំដែលជាអនីតិជនពុំអាចធ្វើសកម្មភាពដោយឯករាជក៏ដោយ ក៏នៅក្នុងបណ្តឹងឋានៈបុគ្គល ច្បាប់ទទួលស្គាល់អោយ អនីតិជនអាចធ្វើសកម្មភាពបណ្តឹងដោយពុំចាំបាច់អ្នកតំណាងតាមច្បាប់កំណត់ (មាត្រា ៨ នៃច្បាប់ស្តីពីបណ្តឹងឋានៈបុគ្គល)។

**៤.២.ក ការដាក់ពាក្យបណ្តឹង និងចំណុចដែលត្រូវសរសេរ**

មាត្រាខាងលើបានសម្តែងថា ការកាត់កាលត្រូវធ្វើតាមពាក្យសុំ ប៉ុន្តែយោងតាមមាត្រា ៣ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង និងតារាឧបសម្ព័ន្ធពុំមានចែងអំពីនីតិវិធីកាត់កាល់ទេ។ដោយឡែករសត្រូវបានឃើញនៅក្នុងច្បាប់ស្តីពីបណ្តឹងឋានៈបុគ្គលមាត្រា ៣ ចំណុច ជ ទៅវិញ។ វាអាចជាកំហុសផ្នែកបញ្ចេកទេសក្នុងការបកប្រែសេចក្តីព្រាង ពីក្រមរដ្ឋប្បវេណីជប៉ុន។

យោងតាមមាត្រា ១ នៃច្បាប់ស្តីពីបណ្តឹងឋានៈបុគ្គល « ច្បាប់នេះមានគោលដៅបញ្ញត្តិជាករណីពិសេស នៃក្រមនីតិវិធីរដ្ឋប្បវេណី ចំពោះបណ្តឹងទាក់ទងនឹងឋានៈបុគ្គល[21]។ » លើកលែងតែមានករណីពិសេសកំណត់ក្នុងច្បាប់នេះ បទបញ្ញត្តិនៃច្បាប់គោល (ក្រមនីតិវិធីរដ្ឋប្បវេណី) ត្រូវយកមកអនុវត្ត។

ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹងកាត់កាល់ ត្រូវអនុឡោមតាមមាត្រា៧៥ កថាខណ្ឌទី២នៃក្រមនីតិវិធីដែលមានដូចខាងក្រោម៖

- ឈ្មោះ និងអាសយដ្ឋាន របស់ភាគី (ដូចបានកំណត់ក្នុងចំណុចក.១ ខាងលើ)៖ ករណីរឿងក្តីបណ្តឹងឋានៈបុគ្គល ពុំតម្រូវអោយមានអ្នកតំណាងដែលច្បាប់កំណត់ទេ។
- ខ្លឹមសារនៃសាលក្រម ៖ ទាមទារអោយតុលាការអោយតុលាការចេញសាលក្រមដែលមានខ្លឹមសារដូចខាងក្រោម៖
  - លុបចោលការប្រកាសសុំពេញលេញកូនរវាង ភាគីនៃទំនាក់ទំនងសុំកូនដែលត្រូវបានចាប់ផ្តើមដោយដីការសម្រេចចាប់សុំកូនពេញលេញលេខ......របស់សាលដំបូង....។
  - ទាមទារសំណងការខូចខាតជាទឹកប្រាក់ចំនួន ៖ ក្នុងបណ្តឹងឋានៈបុគ្គល ភាគីអាចធ្វើការទាមទារសំណងការខូចខាត ដែលកើតឡើងដោយអង្គហេតុជាមូលហេតុនៃការទាមទារបាន (មាត្រា ១១នៃ ច្បាប់ស្តីពីនីតិវិធីបណ្តឹងឋានៈបុគ្គល)។
  - អង្គហេតុដែលជាមូលហេតុនៃការទាមទារ ៖ ត្រូវរៀបរាប់អំពីអង្គហេតុនៃការកកើតឡើងនូវសិទ្ធិទាមទារកាត់កាល់រវាងភាគីនៃទំនាក់ទំនងសុំកូន

[21] មាត្រា ១ នៃច្បាប់ស្តីពីបណ្តឹងឋានៈបុគ្គល នៃក្រមនីតិវិធីរដ្ឋប្បវេណី

### ៤.២.ខ ការវិនិច្ឆ័យលើបណ្តឹងកាត់កាល់

នីតិវិធីឋានៈបុគ្គល និងនីតិវិធីរឿងរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងមានលក្ខណៈដូចគ្នាជារួមមួយគឺ ការជំនុំជម្រះក្តីដោយឆន្ទានុសិទ្ធិ។ តុលាការនៅក្នុងរឿងក្តីបណ្តឹងឋានៈបុគ្គល មានឆន្ទានុសិទ្ធិក្នុងការស្រាវជ្រាវអង្គហេតុ និងភស្តុតាង និងយកអង្គហេតុដែលភាគីមិនអះអាងធ្វើជាមូលដ្ឋានក្នុងការចេញសាលក្រម[22]។ គោលការណ៍ជម្រះក្តីផ្អែកលើអង្គហេតុដែលបានលើកឡើង (មាត្រា ៩៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ពុំត្រូវយកមកអនុវត្តឡើយ (មាត្រា ១៤ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងឋានៈបុគ្គល)។

លក្ខណៈដូចគ្នាអាចស្តែងចេញជាការមិនគោរពគោលការណ៍សេរីភាពក្នុងការចាត់ចែងសិទ្ធិ និងគោលការណ៍ចំពោះមុខ ប៉ុន្តែយ៉ាងនេះក្តីនីតិវិធីកាត់កាលតុលាការត្រូវធ្វើការទាយហេតុផលដោយផ្ទាល់មាត់។ ការទាញហេតុផល ពុំមែនជាការទទួលស្គាល់ទាំងស្រុងនូវសិទ្ធិចាត់ចែងរបស់ភាគី ជាអាទិ៍ការសារភាព ការទទួលស្គាល់ការទាមទារ ឬការផ្សះផ្សា របស់ភាគីទេ ( មាត្រា ១៣ នៃ PLS )។ តុលាការមិនចង់ដោយករណីទទួលស្គាល់អង្គហេតុតាមរយៈភស្តុតាង (មាត្រា១២៣ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដូចនីតិវិធីបណ្តឹងធម្មតាទេ។

ក្នុងរឿងក្តីកាត់កាល់ តុលាការអាចប្រើអំណាចឆន្ទានុសិទ្ធិគ្រប់មធ្យោបាយនៅក្នុងការទទួលបានធនធានភស្តុតាង ដើម្បីធ្វើការវិនិច្ឆ័យ គឺជាអង្គហេតុដែលមានចែងក្នុងមាត្រា ១០១៦ កថាខណ្ឌទី ១ ចំណុច **ក** និង **ខ**។

### ៥.អានុភាពនៃការកាត់កាល

អានុភាពនៃការបង្កើតសុំកូនពេញលេញ ក៏ធ្វើអោយទំនាក់ទំនាក់ញាតិ ក៏ធ្វើអោយទំនាក់ទំនងញាតិរវាងឪពុកម្តាយបង្កើត និងកូនសុំ កាត់ផ្តាច់ដែរ។ ដូចបានបកស្រាយនៅចំនុចខាងលើ ស្តីពីអានុភាពបង្កើតទំនាក់ទំនងញាតិ។ ក្នុងទំនាក់ទំនងរវាងកូនសុំ និង ឪពុកម្តាយចិញ្ចឹម ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹមត្រូវបង្កើតទំនាក់ទំនងញាតិ ដូចទៅនឹងញាំញតិលោកហិតចាប់តាំងពីពេលបង្កើតសុំកូន ។ ទំនាក់ទំនង នឹងត្រូវបញ្ចប់ទៅវិញ ក្រោយពេលកាត់កាល់។ ញាតិភាពរវាង កូនសុំ សហព័ទ្ធរបស់កូនសុំបច្ឆាញាតិផ្ទាល់ ព្រមទាំងសហព័ទ្ធរបស់បច្ឆាញាតិ និង ឪពុកម្តាយចិញ្ចឹម ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹម នឹងត្រូវកាត់ផ្តាច់ទំនាក់ទំនងញាតិនឹងគ្នា ដោយការកាត់ផ្តាច់សាខាញាតិ គឺដោយសារ

[22] មាត្រា ៩៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី) & (មាត្រា ១៤ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងឋានៈបុគ្គល)។

តែ មានគ្រា ៩៨០ ការបង្កើតទំនាក់ទំនងញាតិតាមរយៈសុំកូន។ បង្កើតអានុភាពតែរវាងកូនសុំ និង គ្រួសារឪពុកម្តាយចិញ្ចឹម ហេតុនេះ ពុំអាចមានស្ថានភាពកូនសុំមានសាខាញាតិទេក្នុងករណីនេះ។

អានុភាពនៃសាលក្រម ឬសាលដីកាសម្រេចកាត់កាល់សុំកូនពេញលេញ នឹងធ្វើអោយកាត់ផ្តាច់ទំនាក់ទំនងញាតិរវាងឪពុកម្តាយចិញ្ចឹម និង កូនសុំ និងបង្កើតឡើងវិញនូវ ទំនាក់ទំនងញាតិជាមួយឪពុកម្តាយបង្កើត ។ បើកូនសុំដែលបានកាត់កាល់គឺជាអនីតិជន អំណាចមេបាត្រូវធ្លាក់លើឪពុកម្តាយបង្កើត។

# ផ្នែកទី ៣ សុំកូនធម្មតា

## កថាខណ្ឌទី១ សញ្ញាណទូទៅនៃសុំកូនធម្មតា

សុំកូនធម្មតា អាចហៅម្យ៉ាងទៀតបានថា សុំកូនសាមញ្ញ គឺទម្រង់មួយដែលបានសម្រួល ពីសុំកូនពេញលេញ។ របបដែលដាក់កូនសុំទៅក្នុងការគ្រប់គ្រង ទាំងស្រុងរបស់គ្រួសារឪពុកម្តាយ ចិញ្ចឹម ហើយមិនមានការកាត់ផ្តាច់នូវចំណងទំនាក់ទំនងរវាងកូនសុំ និងឪពុកម្តាយបង្កើត។ ប្រព័ន្ធ សុំកូនធម្មតានេះត្រូវបានបង្កើតឡើង ដោយតម្រូវឲ្យមានការពាក់ព័ន្ធពីតុលាការ ដើម្បីបង្កើតអានុភាព ញាតិលោហិតតាមផ្លូវច្បាប់ដូចជាសន្តតិកម្ម និងអាហារកិច្ចជាដើម។

### ១. និយមន័យ

សុំកូនធម្មតា សំដៅដល់ការសុំកូនដែលកូននោះអាចជាអនីតិជន ឬនីតិជនដោយមិនកាត់ផ្តាច់ញាតិភាពពីឪពុកម្តាយបង្កើត ហើយការសុំនេះត្រូវសម្រេចដោយតុលាការ។

### ២. លក្ខណៈពិសេសនៃសុំកូនធម្មតា

សុំកូនធម្មតា មិនមានលក្ខណៈតឹងរឹងដូចសុំកូនពេញលេញនោះទេ ។ ញាតិភាពរវាងកូនសុំ និងឪពុកម្តាយបង្កើតត្រូវបន្តអត្ថិភាពរហូត ហើយកូនសុំ និងឪពុកម្តាយបង្កើតមានសិទ្ធិធ្វើសន្តតិកម្ម គ្នាទៅវិញទៅមកបាន។ កូនសុំ និងឪពុកម្តាយបង្កើតក៏មានសិទ្ធិទាមទារ និងមានករណីកិច្ចត្រូវ ផ្គត់ផ្គង់អាហារកាតព្វកិច្ចផងដែរ។ លើសពីនេះ កូនសុំត្រូវទទួលបាននូវឋានៈដូចគ្នានឹងកូនបង្កើត របស់ឪពុកម្តាយចិញ្ចឹម និងត្រូវទទួលបាននូវសិទ្ធិ និងករណីកិច្ចដូចគ្នានឹងកូនបង្កើតនៅក្នុងទំនាក់ទំនងជាមួយនឹងឪពុកម្តាយចិញ្ចឹម។

## កថាខណ្ឌទី២ លក្ខខណ្ឌនៃការបង្កើតសុំកូនធម្មតា

មានលក្ខខណ្ឌជាច្រើនសម្រាប់ការបង្កើតសុំកូនធម្មតា ហើយលក្ខខណ្ឌទាំងនោះមានដូចជាអាយុរបស់ឪពុកម្តាយចិញ្ចឹម និងកូនសុំការចូលរួមរបស់សហព័ទ្ធម្ខាងរបស់បុគ្គលដែលនឹងក្លាយជាឪពុក ឬម្តាយចិញ្ចឹមក្នុងករណីបុគ្គលនោះមានសហព័ទ្ធ និងកូនសុំជាអនីតិជន ការចូលរួមរបស់ឪពុកម្តាយបង្កើតក្នុងករណីកូនសុំជាអនីតិជន និងមូលដ្ឋានដែលតុលាការនឹងពិចារណា។

**១. អាយុរបស់ឪពុកម្ដាយចិញ្ចឹម**

បុគ្គលដែលមានអាយុចាប់ពី ២៥ ឆ្នាំឡើងទៅ អាចបង្កើតសុំកូនធម្មតាបាន ប៉ុន្តែសុំកូន ធម្មតាមិនអាចបង្កើតបានឡើយក្នុងករណីបុគ្គលដែលនឹងក្លាយជាកូនចិញ្ចឹម មានអាយុច្រើនជាង បុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម។ ម្យ៉ាងវិញទៀត ការបង្កើតសុំកូនធម្មតាមិនហាមឃាត់ ចំពោះបុគ្គលដែលជាញាតិនឹងគ្នានោះទេ ប៉ុន្តែសុំកូនមិនអាចបង្កើតបានឡើយ ក្នុងករណីបុគ្គល ដែលនឹងក្លាយជាកូនសុំជាបុព្វញាតិរបស់បុគ្គល ដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម។ តាមការបក ស្រាយក្នុងក្រមរដ្ឋប្បវេណី អាយុ២៥ឆ្នាំ ត្រូវគិតចាប់ពីពេលដាក់ពាក្យសុំ ហេតុនេះករណីអ្នកដាក់ ពាក្យសុំមានអាយុ ២៤ឆ្នាំ នៅពេលដាក់ពាក្យសុំ តុលាការមិនអាចបង្កើតសុំកូនធម្មតាបានទេ។

**២. អាយុរបស់កូនសុំ**

អាយុរបស់កូនសុំធម្មតាពុំត្រូវបានកម្រិតទេ ហេតុនេះ កូនសុំអាចជាអនីតិជន ឬនីតិជន ហើយមានអាយុប៉ុន្មានក៏បានដែរ លើកលែងតែកូនសុំមានអាយុច្រើនជាងបុគ្គលដែលនឹងក្លាយជា ឪពុកម្ដាយចិញ្ចឹម ឬកូនសុំនោះជាបុព្វជាតិរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម។

**៣ . ការចូលរួមរបស់សហព័ទ្ធ ក្នុងករណីជនដែលនឹងក្លាយជាឪពុកម្ដាយ ចិញ្ចឹមមានសហព័ទ្ធ**

សុំកូនធម្មតា អាចបង្កើតបានទោះបីជាបុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹមមាន ឬគ្មានសហព័ទ្ធក៏ដោយ។ ប៉ុន្តែក្នុងករណីបុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹមមានសហព័ទ្ធ ដើម្បីបង្កើតសុំកូនធម្មតាបានលុះត្រាតែមានការយល់ព្រមរបស់សហព័ទ្ធ។ ប៉ុន្តែប្រសិនបើម្ខាងបានដាក់ ពាក្យជាមួយសហព័ទ្ធម្ខាងទៀត ឬសហព័ទ្ធម្ខាងមិនអាចបង្ហាញឆន្ទៈយល់ព្រមបាន សុំកូនធម្មតា អាចបង្កើតបាន។ ផ្ទុយទៅវិញ ក្នុងករណីកូនសុំជាអនីតិជន ហើយបុគ្គលដែលនឹងក្លាយជាឪពុក ម្ដាយចិញ្ចឹមមានសហព័ទ្ធ ការយល់ព្រមរបស់ភាគីម្ខាងមិនគ្រប់គ្រាន់ទេ ពោលគឺត្រូវដាក់ពាក្យសុំ រួមគ្នា ( សុំកូនដោយសហការ ) ទើបអាចបង្កើតសុំកូនធម្មតាបាន។ ប៉ុន្តែ ក្នុងករណីយកកូនរបស់ សហព័ទ្ធមកធ្វើជាកូនសុំ ឬសហព័ទ្ធម្ខាងទៀតមិនអាចបង្ហាញឆន្ទៈបាន សុំកូនអាចបង្កើតឡើង បានត្រឹមការដាក់ពាក្យសុំតែម្នាក់ឯងរបស់សហព័ទ្ធម្ខាង។

គួរបញ្ជាក់ថា ការដាក់ពាក្យសុំរួមគ្នា និងការដាក់ពាក្យសុំដោយមានការយល់ព្រមពីហាព័ទ្ធ មានភាពខុសគ្នាត្រង់ថា៖ ការដាក់ពាក្យសុំរួមគ្នា ( ដូចមានចែងក្នុងមាត្រា១០២១ ) សហព័ទ្ធទាំងពីរ នឹងក្លាយជាឪពុកម្ដាយចិញ្ចឹម ប៉ុន្តែ ក្នុងករណីពាក្យសុំត្រូវបានដាក់ដោយសហព័ទ្ធម្ខាង ដោយមាន ការ

យល់ព្រមរបស់សហព័ទ្ធម្ខាងទៀត ( ដូចមានចែងនៅក្នុងមាត្រា ១០២២ ) អ្នកដែលក្លាយជា ឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹម គឺសហព័ទ្ធម្ខាងដែលបានដាក់ពាក្យសុំ[23]។

**៤. ការចូលរួមរបស់ឪពុកម្តាយបង្កើតរបស់កូនសុំ**

ក្នុងករណីបុគ្គលដែលនឹងក្លាយជាកូនសុំជានីតិជន ការដាក់ពាក្យបង្កើតសុំកូនធ្វើឡើងត្រឹមតែបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម និងបុគ្គលដែលនឹងត្រូវក្លាយជាកូនសុំនោះមានភាពគ្រប់គ្រាន់ ដោយមិនពិចារណាអំពីឆន្ទៈរបស់ឪពុកម្តាយបង្កើតឡើយ។ ម្យ៉ាងវិញទៀត ទោះបីជាកូន សុំមានសហព័ទ្ធក៏ដោយ សុំកូនត្រូវបានបង្កើតឡើងត្រឹមឆន្ទៈរបស់កូនសុំ ដោយមិនពិចារណាអំពី ឆន្ទៈរបស់សហព័ទ្ធនៃកូនសុំឡើយ។

ក្នុងករណីកូនសុំជាអនីតិជន សុំកូនអាចបង្កើតបានលុះត្រាតែមានការចូលរួម ( ដាក់ពាក្យ ) ពីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កូនសុំ ក្នុងនាមជាអ្នកមានអំណាចមេបា។ បើកូនសុំជាអនីតិជនមានអាយុដល់១៥ ឆ្នាំ ដើម្បីបង្កើតសុំកូនបាន លុះត្រាតែមានការយល់ព្រមពីអនីតិជននោះ ហេតុនេះ ក្នុងករណីអនីតិជនមិនយល់ព្រម សុំកូនមិនអាចបង្កើត ឡើងបានទេ។

**៥ . មូលដ្ឋានវិនិច្ឆ័យដែលតុលាការនឹងពិចារណា**

តុលាការធ្វើការវិនិច្ឆ័យអំពីបង្កើតសុំកូនធម្មតា ដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម៖

១-មានការបញ្ជាក់អំពីឆន្ទៈពិតប្រាកដរបស់ភាគី ក្នុងការបង្កើតទំនាក់ទំនងរវាងឪពុកម្តាយនិងកូន។

២-សុំកូនត្រូវបានបំពានក្នុងគោលបំណងអាពាហ៍ពិពាហ៍ រវាងភេទផ្សេងគ្នា ឬដូចគ្នា ឬក្នុង គោលបំណងមិនត្រឹមត្រូវផ្សេងទៀត។

៣-ក្នុងករណី កូនសុំជាអនីតិជន តុលាការអាចឲ្យបង្កើតសុំកូនបានលុះត្រាតែយល់ឃើញថា មានភាពចាំបាច់ពិសេស ដើម្បីផលប្រយោជន៍របស់កូនសុំដែលជាអនីតិជននោះ។ តុលាការ ត្រូវពិចារណាអំពីឆន្ទៈរបស់អនីតិជន កាលបើអនីតិជនមានអាយុដល់១៥ឆ្នាំ ហើយទោះបីជាពុំមាន អាយុដល់១៥ឆ្នាំ ក៏ដោយ ក៏តុលាការអាចសួរយោបល់របស់អនីតិជនបានដែរ។ ម្យ៉ាងទៀត ក្នុង ករណីឪពុកម្តាយបង្កើតលែងលះគ្នា មុននឹងសម្រេចបង្កើតសុំកូនធម្មតា តុលាការក៏ត្រូវសួរយោបល់ ឪពុក ឬម្តាយបង្កើតដែលមិនមែនជាអ្នកមានអំណាចមេបា។

---

[23]មាត្រា ១០២១ និង ១០២២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

## កថាខណ្ឌទី៣ អានុភាពនៃសុំកូនធម្មតា

### ១. បង្កើតញាតិភាពជាមួយឪពុកម្តាយចិញ្ចឹម

ក្រោយបង្កើតសុំកូន ញាតិភាពរវាងឪពុកម្តាយចិញ្ចឹម និងកូនសុំត្រូវបានបង្កើតឡើងកូន សុំមានឋានៈដូចគ្នានឹងកូនបង្កើត មានសិទ្ធិធ្វើសន្តតិកម្មចំពោះគ្នាទៅវិញទៅមក និងកាតព្វកិច្ច ចំពោះគ្នាទៅវិញទៅមកផងដែរ ហើយកូនសុំអាចប្រើប្រាស់នាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬ នាមត្រកូលរបស់ខ្លួនមុនពេលបង្កើតសុំកូនបាន។ ក្នុងករណី កូនសុំជាអនីតិជន កូនសុំត្រូវស្ថិត ក្រោមអំណាចមេបារបស់ឪពុកម្តាយចិញ្ចឹម ឪពុក ឬម្តាយចិញ្ចឹម ប៉ុន្តែ ក្នុងករណីយកកូនបង្កើត របស់សហព័ទ្ធមកធ្វើជាកូនសុំ កូនសុំនោះត្រូវស្ថិតក្រោមអំណាចមេបារួមរបស់ឪពុក ឬម្តាយចិញ្ចឹម និងសហព័ទ្ធនោះ។

**កូនសុំ** មានន័យថា គឺយកតែកូនប៉ុណ្ណោះ ហេតុនេះញាតិរបស់កូនមិនត្រូវបានមកជា មួយទេ។ **ឧទាហរណ៍៖** លោក B ជាកូនសុំ ហើយមានប្រពន្ធ C និងកូនម្នាក់ D ក្នុងករណីនេះ មានតែ B ទេ ដែលជាញាតិរបស់ឪពុកម្តាយចិញ្ចឹម រីឯប្រពន្ធ និងកូនរបស់ B មិនមែនជាញាតិជា មួយឪពុកម្តាយចិញ្ចឹមទេ ប៉ុន្តែក្រោយបង្កើតសុំកូន លោក B មានកូនម្នាក់ទៀត ក្នុងករណីនេះ កូនទី២របស់ B គឺជាញាតិជាមួយឪពុកម្តាយចិញ្ចឹម។

### ២. ការបន្តញាតិភាពជាមួយឪពុកម្តាយបង្កើត

ទោះបីជាសុំកូនត្រូវបានបង្កើតឡើងក៏ដោយ ញាតិភាពរវាងឪពុកម្តាយបង្កើត និងកូនសុំនៅតែបន្ត ហេតុនេះកូនសុំ និងឪពុកម្តាយបង្កើតមានសិទ្ធិធ្វើសន្តតិកម្មឲ្យគ្នាទៅវិញទៅមក ហើយ មានក៏មានសិទ្ធិទាមទារ និងករណីកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមកដែរ។

ជាទូទៅ សុំកូនធម្មតា កូនសុំនោះមានឪពុកម្តាយបង្កើតផង និងឪពុកម្តាយចិញ្ចឹមផង ហេតុនេះ សិទ្ធិក្នុងការធ្វើសន្តតិកម្ម ក៏មានចំពោះគ្នាទៅវិញទៅមកដែរ មានន័យថា មានទាំងទំនាក់ ទំនងជាមួយឪពុកម្តាយចិញ្ចឹម និងឪពុកម្តាយបង្កើត ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក្នុងករណី កូនសុំជាអនីតិជន អ្នកដែលមានអំណាចមេបាលើកូនសុំ គឺឪពុកម្តាយចិញ្ចឹម ។

## កថាខណ្ឌទី៤ ៖ ការកាត់កាលសុំកូនធម្មតា

### ១. មូលហេតុ និង ការវិនិច្ឆ័យនៃការកាត់កាល់កូនធម្មតា

ការកាត់កាល គឺត្រូវបានប្រើលើគ្រប់សុំកូនបានទាំងអស់ឲ្យតែអនុវត្តតាមច្បាប់ ដែលបានបញ្ញត្តិជាធរមាន។ ការកាត់កាល់ គឺជាការបោះបង់លែងរាប់អានតទៅទៀត មានន័យថា បើមានពាក្យសុំកាត់កាលសុំកូនធម្មតា តុលាការអាចសម្រេចឲ្យកាត់កាល់បាន លុះត្រាតែបានបញ្ជាក់ថាភាគីសងខាងមានបំណងពិតប្រាកដក្នុងការរំលាយទំនាក់ទំនងរវាងឪពុកម្តាយ និងកូន។ បុគ្គលដែល

អាចដាក់ពាក្យបណ្ដឹងទាមទារឲ្យកាត់កាលបាន លុះត្រាតែភាគីម្ខាងទៀតបានប្រព្រឹត្តដូចបញ្ញត្តិក្នុងមាត្រា១០៣១នៃក្រមរដ្ឋប្បវេណី២០០៧[24] ។ ឧទាហរណ៍ ដូចជាឪពុកម្ដាយចិញ្ចឹមបានបោះបង់ កូនចិញ្ចឹមដោយមានគំនិតទុច្ចរិត ឬបើភាគីខាងឪពុកម្ដាយចិញ្ចឹម ឬកូនចិញ្ចឹមមិនដឹងថារស់ ឬ ស្លាប់ក្នុងរយៈពេលយ៉ាងតិច១ឆ្នាំ ជាដើម។

**២. ពាក្យសុំឲ្យកាត់កាលសុំកូនធម្មតា**

ភាគីនៃសុំកូន អាចដាក់ពាក្យសុំទៅតុលាការឲ្យកាត់កាល់សុំកូនធម្មតាបាន ក្នុងករណីដែល ភាគីទាំងសងខាងព្រមព្រៀងអំពីការកាត់កាល់នោះ តែប្រសិនបើក្នុងករណីដែលកូនសុំជាអនីតិជន ពាក្យកាត់កាល់ដែលបានធ្វើឡើងដោយមានការព្រមព្រៀងគ្នានោះ ត្រូវធ្វើឡើងដោយឪពុកម្ដាយចិញ្ចឹម និងបុគ្គលដែលនឹងត្រូវក្លាយជាអ្នកតំណាង ដែលច្បាប់បានកំណត់ក្រោយពេលកាត់កាល់ តែបើកូនសុំដល់អាយុ ១៥ ( ដប់ប្រាំ ) ឆ្នាំ ហើយត្រូវទទួលការយល់ព្រមពីកូនសុំនោះ។ តែទោះបីជាយ៉ាងណាក៏ដោយ អនីតិជននោះមិនទាន់ដល់អាយុ១៥ឆ្នាំក៏ដោយ បើអនីតិជននោះអាចបង្ហាញ ឆន្ទៈរបស់ខ្លួន តុលាការត្រូវសួរយោបល់របស់អនីតិជននោះ។ ក្នុងករណីដែលឪពុកម្ដាយបង្កើត របស់កូនសុំបានលែងលះគ្នាហើយ ឪពុកម្ដាយរបស់កូនសុំនោះត្រូវពិភាក្សា និងកំណត់ថា ឪពុក ឬម្ដាយបង្កើតជាបុគ្គលដែលត្រូវក្លាយជាអ្នកមានអំណាចមេបានៅក្រោយពេលកាត់កាល់ បើសិនជា ការពិភាក្សាខាងលើពុំបានសម្រេច ឬពុំអាចពិភាក្សាបានទេ តុលាការត្រូវកំណត់បុគ្គលដែលត្រូវ ក្លាយជាអ្នកមានអំណាចមេបា ដោយគិតពិចារណាទៅលើផលប្រយោជន៍របស់កូនសុំ។

**៣. លក្ខខ័ណ្ឌនៃការកាត់កាល់សុំកូនធម្មតា**

ដើម្បីឲ្យការកាត់កាល់សុំកូនធម្មតាប្រព្រឹត្តទៅបានលុះត្រាតែមានមូលហេតុដូចខាងក្រោម៖

-ភាគីម្ខាងនៃសុំកូន អាចដាក់ពាក្យបណ្ដឹងទាមទារឲ្យកាត់កាល់បាន លុះត្រាតែ៖

❖បើត្រូវបានបោះបង់ចោលដោយភាគីម្ខាងទៀតដោយទុច្ចរិត។

❖បើមិនច្បាស់ ក្នុងអំឡុងពេលយ៉ាងតិច ១ ( មួយ ) ឆ្នាំ ថាភាគីម្ខាងទៀតនៅរស់ ឬទទួលមរណភាព។

❖បើមានហេតុធ្ងន់ធ្ងរផ្សេងទៀត ដែលបណ្ដាលឲ្យមានការពិបាកក្នុងការបន្តសុំកូន

-ក្នុងអំឡុងពេលដែលកូនសុំពុំទាន់ក្លាយជានីតិជន ឪពុកម្ដាយចិញ្ចឹមមិនអាចដាក់ពាក្យបណ្ដឹងសុំកាត់កាល់ចំពោះកូនសុំបានឡើយ។

-ទោះបីក្នុងករណីកូនសុំជាអនីតិជនក៏ ដោយ ក៏កូនសុំអាចដាក់ពាក្យបណ្ដឹងចំពោះឪពុកម្ដាយចិញ្ចឹមបានដែរ ឲ្យតែបានគោរពលក្ខខណ្ឌដូចដែលបានកំណត់ខាងលើ។

[24] មាត្រា១០៣១នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

### ៤. អានុភាពនៃការកាត់កាលកូនធម៌តា

អានុភាពទាំងឡាយនៃសុំកូនធម៌តា ត្រូវបញ្ចប់ទៅអនាគតដោយការកាត់កាល់ ហើយក្រោយ ការកាត់កាល់ កូនសុំអាចទទួលបានវិញនូវនាមត្រកូលមុនសុំកូនក៏បាន ឬអាចប្រើត្រកូលរបស់ ឪពុកម្តាយចិញ្ចឹមក៏បាន។

# សេចក្តីផ្តើម

នៅក្នុងប្រទេសភាគច្រើននៅក្នុងពិភពលោក ការខ្វះខាតផ្នែកជីវភាព និងភាពក្រីក្រនៅតែបន្តមាន តែអ្វីដែលសំខាន់ គឺវិធីសាស្ត្រនៃការលុបបំបាត់ មិនសូវបានយកចិត្តទុកដាក់ដោយរដ្ឋាភិបាល ឬការអនុវត្តនោះនៅតែមានលក្ខណៈយឺតយ៉ាវ ដែលជាហេតុធ្វើឲ្យគំលាតពីអ្នកមាន អ្នកក្រីក្រនៅដាច់ឆ្ងាយពីគ្នា។ មុខរបរចិញ្ចឹមជីវិត និងថវិកា គឺជាទុនដ៏សំខាន់ក្នុងការបន្តជីវិតរស់នៅក្នុងសង្គម និងកែលំអរស្ថានភាពជីវភាពរបស់ខ្លួនកាន់តែប្រសើរ ជាពិសេសទៅទៀតនោះ គឺ ផ្គត់ផ្គង់នូវតំរូវការរបស់ខ្លួនឯង។ ការផ្គត់ផ្គង់តំរូវការ មិនមែនមានតែម្នាក់ឯងទេ គឺសំដៅទៅលើក្រុមគ្រួសារទាំងមូល អាចរាប់បញ្ចូលទាំងមនុស្សធំ និងក្មេង ដែលជាបន្ទុកក្នុងគ្រួសារ ទាមទារឲ្យមេគ្រួសារត្រូវមានការទទួលខុសត្រូវ និងត្រូវមានការសម្រេចចិត្តឲ្យបានដោយត្រឹមត្រូវ ។ នាពេលដែលបញ្ហាថវិការបានកើតឡើង ធ្វើឲ្យការផ្គត់ផ្គង់ទាំងអស់គ្នានោះត្រូវបានកាត់បន្ថយ។ ប៉ុន្តែតំរូវការរបស់កុមារមិនអាចកាត់បន្ថយនោះទេ ពួកគេត្រូវការលូតលាស់ទាំងផ្នែករាង្គកាយ និងស្មារតី ជាពិសេសគឺការសិក្សាអប់រំ ដែលមិនអាចខ្វះបានចំពោះកុមារ ។ ក្នុងករណីដែលដឹងថា ខ្លួនមិនអាចផ្តល់ ឲ្យកុមារដែលជា កូនរបស់ខ្លួនបាន គឺមានតែពឹងទៅលើជំនួយឧបត្ថម្ភផ្សេងៗ ។ កត្តានេះហើយ ដែលធ្វើអោយប្រទេសកម្ពុជា បានបង្កើតឲ្យមាន ការសុំកូនអន្តរប្រទេស ដើម្បីផ្តល់នូវឱកាសបរិយាកាសថ្មីដល់កុមារ និងជួយ សម្រួលបន្ទុកគ្រួសារ ប៉ុន្តែបែរជាកើនឡើងនូវការជួញដូរកុមារ ដែលផ្ទុយពីកម្មវត្ថុនៃសុំកូនអន្តរប្រទេសទៅវិញ ហើយធ្វើឲ្យដំណើរការនេះផ្អាកមួយរយៈក្នុងឆ្នាំ ២០០៣ ។ ដូច្នេះដើម្បីធានាសុវត្ថិភាព និងរារាំងនូវការជួញដូរកុមារនេះ រដ្ឋាភិបាលបានបង្កើតនូវសមត្ថកិច្ច និងផ្នែកបទដ្ឋានគតិយុត្តមួយចំនួនដូចជា បានផ្តល់សច្ចាប័នលើអនុសញ្ញាក្រុងឡាអេស៊្តីពី « ការការពារកុមារ និង សហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស » ក្នុងឆ្នាំ ២០០៧ ។

**សុំកូនអន្តរប្រទេស** គឺជាការសុំអនីតិជន ដែលមានអាយុក្រោម ៨ឆ្នាំយកធ្វើជាកូនចិញ្ចឹម ដោយបញ្ចប់ញាតិភាពជាមួយ និងញាតិលោហិតនៃឪពុកម្តាយបង្កើត ហើយការសុំនេះត្រូវសម្រេចដោយតុលាការពីប្រទេសដែលសុំកូននោះ។ ដោយធ្វើដំណើរទៅរស់នៅជាអចិន្ត្រៃយ៍ ក្នុងប្រទេសអ្នកសុំ។ ម្យ៉ាងទៀត ការសុំកូនជាលក្ខណៈអន្តរប្រទេសនេះ ជាការសុំពីប្រទេសមួយដែលជាកន្លែងកំណើតរបស់កូនសុំ សុំយកទៅរស់នៅប្រទេសមួយផ្សេងទៀត ដោយបំពេញតាមលក្ខខណ្ឌនៃ នីតិវិធីសុំកូនអន្តរប្រទេស។

ជារួម សុំកូនអន្តរប្រទេសគឺជាការសុំទារក ឬកុមារកំព្រាសញ្ជាតិកម្ពុជាមានលំនៅអចិន្ត្រៃយ៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយប្តីប្រពន្ធដែលរស់នៅប្រទេសដទៃ ដើម្បីយកទៅចិញ្ចឹមជាកូន ហើយនឹងទទួលស្គាល់ដោយច្បាប់របស់ប្រទេសនោះ។

ការបង្កើត និងទទួលស្គាល់នូវបទដ្ឋានទាំងអស់នេះ គឺចង់កំណត់ពីគោលការណ៍ លក្ខខណ្ឌ នីតិវិធី ទម្រង់បែបបទ និងអានុភាពនៃសុំកូនអន្តរប្រទេស ហើយជាពិសេសជាងនេះទៅទៀតគឺមាន គោលបំណងធានាឲ្យបាននូវឧត្តមប្រយោជន៍ និងការពារសិទ្ធិជាមូលដ្ឋានរបស់កុមារ ដែលជាកម្មវត្ថុនៃសុំកូនអន្តរប្រទេស។ ក្រៅពីនេះទៅទៀតគឺមានគោលបំណងធានាឲ្យបាននូវឧត្តមប្រយោជន៍ និងការពារសិទ្ធិជាមូលដ្ឋានរបស់កុមារ ដែលជាកម្មវត្ថុនៃសុំកូនអន្តរប្រទេស។ ក្រៅពីនេះទៅទៀតគឺ បង្កើតប្រព័ន្ធសហប្រតិបត្តិការក្នុងចំណោមរដ្ឋជាភាគីដើម្បីធានាថា មធ្យោបាយការពារទាំងនេះត្រូវបានគោរព ហើយតាមរយៈប្រព័ន្ធនោះ គឺទប់ស្កាត់ការចាប់ពង្រត់ ការលក់ ឬការជួញដូរកុមារ។

**ដំណើរការណ៍នៃសុំកូនអន្តរប្រទេសគឺ ត្រូវតែផ្តល់នូវឧត្តមប្រយោជន៍របស់កុមារ ដោយឈរលើគោលការណ៍ដូចជា៖**

1. កុមារត្រូវចម្រើនធំធាត់នៅក្នុងបរិយាកាសគ្រួសារ បរិយាកាសសុភមង្គល សេចក្តីស្រលាញ់ និងការយោគយល់ ដើម្បីឲ្យមានការអភិវឌ្ឍពេញលេញ និងយ៉ាងសុខដុម នូវបុគ្គលិកលក្ខណៈរបស់ខ្លួន។ សុំកូនអន្តរប្រទេស អាចអនុញ្ញាតបាន ក្រោយពីអស់លទ្ធភាពផ្តល់ការឧបត្ថមគាំទ្រ ដើម្បីឲ្យកុមាររស់នៅក្នុងគ្រួសារកំណើត និងក្រោយពីបានធ្វើពីការពិចារណអំពីសុំកូននៅក្នុងព្រះរាជាណាចក្រកម្ពុជា។
2. សុំកូនអន្តរប្រទេស អាចប្រព្រឹត្តទៅបានលុះត្រាតែជា សុំកូនពេញលេញដែលបង្កើតនូវទំនាក់ទំនងរវាងអ្នកសុំ និងកូនសុំជាអចិន្ត្រៃយ៍ និងដែលផ្តល់ដល់កុមារនូវឋានៈសិទ្ធិ និងកាតព្វកិច្ចដូចជាកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹមនោះ។
3. រាល់ការសម្រេច និងសកម្មភាពទាក់ទងនឹងដំណើរការសុំកូនអន្តរប្រទេស ត្រូវគិតគូរឲ្យបានច្រើនលើសលប់ដល់ឧត្តមប្រយោជន៍របស់កុមារ។
4. កុមារទាំងឡាយណាដែលបំពេញបាននូវលក្ខខណ្ឌបានគ្រប់គ្រាន់ អាចធ្វើជាកម្មវត្ថុនៃសុំកូនអន្តរប្រទេសបានដោយមិនមានការរើសអើងអំពីពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើត ជាតិកំណើត ឋានៈក្នុងសង្គម ធនធាន ពិការភាពឬស្ថានភាពផ្សេងៗទៀតរបស់កុមារ ឬរបស់ឪពុក ឬរបស់និងម្តាយ ឬរបស់អ្នកអាណាព្យាបាល។
5. ហាមការធ្វើអាជីវកម្ម ឬ ធ្វើសកម្មភាពយកកម្រៃពីសុំកូនអន្តរប្រទេស។
6. តុលាការ និងអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធក្នុងដំណើរការសុំកូនអន្តរប្រទេសត្រូវធានាថា នៅពេលកំពុងដំណើរការនីតិវិធីសុំកូន កុមារដែលមានសមត្ថភាពអាចដឹងខុសត្រូវបានពិគ្រោះយោបល់ និងពន្យល់ណែនាំឲ្យបានត្រឹមត្រូវអំពី

អានុភាពនានា ដែលកើតចេញពីសុំកូននេះដោយគិតគូរដល់សេចក្តីប្រាថ្នា និងមតិរបស់កុមារដើម្បីឧត្តមប្រយោជន៍របស់កុមារ។

7. អាជ្ញាធរមានសមត្ថកិច្ច ដែលពាក់ព័ន្ធក្នុងនីតិវិធីនេះ ត្រូវធានាថាដំណើរការសុំកូនអន្តរប្រទេស មិនបណ្តោយឲ្យមានការទទួលផលកម្រៃផ្នែកហិរញ្ញវត្ថុដោយមិនស្របច្បាប់ និងមិនឲ្យមានការចាប់ពង្រត់ ការលក់ និង ការជួយដូរកុមារក្នុងពេលកំពុងដំណើរសុំកូនអន្តរប្រទេស។[25]

[25] មាត្រា៥នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេសឆ្នាំ ២០០៩

# ជំពូកទី២ ស្មុំកូនអន្តរប្រទេស

## ផ្នែកទី១ សញ្ញាណទូទៅនៃការស្មុំកូនអន្តរប្រទេស

ការបង្កើតគោលការណ៍អោយមានស្មុំកូនអន្តរប្រទេស គឺដើម្បីលើកកម្ពស់ល័ក្ខខ័ណ្ឌរស់នៅរបស់កុមារនៅក្នុងប្រទេសនីមួយៗជាពិសេសក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ ដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចដែលកំណត់ដោយអនុលោមតាមច្បាប់ និងនីតិវិធីដែលអាចអនុវត្តបាន និងឈរលើមូលដ្ឋាននៃពត៌មានត្រឹមត្រូវគួរអោយទុកចិត្តបាន ហើយនឹងធានាថាការស្មុំកូននោះអាចអនុញ្ញាតអោយបាន អាស្រ័យលើស្ថានភាពរបស់កុមារទាក់ទិនទៅនឹងឪពុកម្តាយសាច់ញាតិ និងអ្នកអាណាព្យាបាលស្របច្បាប់ ហើយបើសិនជាចាំបាច់បុគ្គលទាំងឡាយដែលមានការទាក់ទិនត្រូវបានផ្តល់ការយល់ព្រមរបស់ខ្លួនលើការសុំកូនចិញ្ចឹមនេះ ដោយមានការយល់ដឹងយ៉ាងច្បាស់លាស់ពី អត្ថប្រយោជន៍នៃសិទ្ធិ និងកាតួកិច្ចរបស់ខ្លួន និងក្រោយពីបានទទួលការបំភ្លឺជាចាំបាច់រួចមក។

ជាទូទៅ ការបង្កើតស្មុំកូនអន្តរប្រទេសត្រូវគោរពទៅតាមគោលការណ៍ ល័ក្ខខ័ណ្ឌ នីតិវិធីទម្រង់បែបបទ និងអានុភាពនៃស្មុំកូនអន្តរប្រទេសគឺ ដើម្បីធានាថាស្មុំកូនអន្តរប្រទេស ធ្វើឡើងក្នុងឧត្តមប្រយោជន៍របស់កុមារ និងដោយសេចក្តីគោរពសិទ្ធមូលដ្ឋានរបស់កុមារធានាថា កុមារដែលត្រូវបានស្មុំកូនទៅចិញ្ចឹមទទួលបាននូវការថែទាំ ការចិញ្ចឹមបីបាច់ថែរក្សាយ៉ាងពិតប្រាកដ។

### កថាខណ្ឌទី១ គោលការណ៍ទូទៅនៃស្មុំកូនអន្តរប្រទេស

ភាពជាក់លាក់នៃការទទួលបានស្មុំកូនអន្តរប្រទេស ត្រូវតែឆ្លងកាត់តាមនីតិវិធីជាធរមាន និងតាមទម្រង់លក្ខខណ្ឌមួយប្រាកដប្រជាទើបអាចទទួលបានដោយស្របច្បាប់។

ច្បាប់ស្តីពីការស្មុំកូនអន្តរប្រទេស បានកំណត់នូវគោលការណ៍ទូទៅមួយចំនួនទាក់ទងនឹងការសុំកូនទៅនៅឯបរទេស។ នៅក្នុងគោលការណ៍ទាំងនេះអ្នកទាក់តែងច្បាប់ បានគិតដល់ឧត្តមប្រយោជន៍ របស់កុមារជាចំបង ដែលបានកំណត់ដូចតទៅៈ

➢កុមារត្រូវចំរើនការធំធាត់នៅក្នុងបរិយាកាសគ្រួសារ ដែលមានសុភមង្គល មានសេចក្តីស្រលាញ់ និងការយោគយល់ ដើម្បីឲ្យពួកគេមានការអភិវឌ្ឍន៍ពេញលេញនូវបុគ្គលិកលក្ខណៈរបស់ពួកគេ។

➢ស្មុំកូនអន្តរប្រទេស អាចអនុញ្ញាតបានក្រោយពីអស់លទ្ធភាពផ្តល់ក្នុងការឧបត្ថម្ភគាំទ្រ ដើម្បីឲ្យកុមារ រស់នៅក្នុងគ្រួសារកំណើត។

➢ស្មុំកូនអន្តរប្រទេសអាចប្រព្រឹត្តទៅបាន លុះត្រាជាស្មុំកូនពេញលេញ ដែលបង្កើតទំនាក់ទំនងរវាងអ្នកសុំ និងកូនសុំជាអចិន្ត្រៃយ៍ដែលអាចផ្តល់នូវឋានៈ សិទ្ធិ និងកាតព្វកិច្ចដូចកូនបង្កើតរបស់ខ្លួន។

➢រាល់សេចក្តីសម្រេច និងសកម្មភាពទាក់ទងនឹងដំណើរការស្មុំកូនអន្តរប្រទេស ត្រូវគិតគូរឲ្យបានច្រើនចំពោះឧត្តមប្រយោជន៍របស់កុមារ ។

➢តុលាការ និងអាជ្ញាធរមានសមត្ថកិច្ច ដែលពាក់ព័ន្ធក្នុងដំណើរការស្មុំកូនអន្តរប្រទេសត្រូវធានាថា នៅកំពុងដំណើរការនីតិវិធីស្មុំកូន កុមារដែលមានសមត្ថភាពអាចដឹងខុសត្រូវបានពិគ្រោះយោបល់ និងពន្យល់ណែនាំឲ្យបានត្រឹមត្រូវអំពីអានុភាពនានាដែលកើតចេញពីស្មុំកូននេះ ដោយគិតគូរដល់សេចក្តីប្រាថ្នា និងមតិរបស់កុមារ ដើម្បីឧត្តមប្រយោជន៍របស់កុមារ។

➢ហាមធ្វើអាជីវកម្ម ឬធ្វើសកម្មភាពយកកំរៃពីស្មុំកូនអន្តរប្រទេស ក្នុងករណីដូចខាងក្រោម៖

- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកំរៃ ញុះញង់ដោយផ្ទាល់ដល់ឪពុកម្តាយ ឬឪពុក ឬម្តាយឲ្យបោះបង់ទារកដែលកើតមកហើយ ឬដែលនឹងកើត ដើម្បីឲ្យប្រគល់កូនតាមរយៈស្មុំកូនអន្តរប្រទេស។
- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកំរៃ ធ្វើជាអន្តរការីរវាងប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈស្មុំកូនអន្តរប្រទេស និងឪពុកឬ ម្តាយដែលចង់បោះបង់កូនដែលកើតមកហើយ ឬ ដែលនឹងកើត។
- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកំរៃ ធ្វើជាអន្តរការីរវាងប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈស្មុំកូនអន្តរប្រទេសនិង ស្រីម្នាក់យល់ព្រមពពោះ ដើម្បីនឹងប្រគល់កូននោះទៅឲ្យអ្នកសុំ។

➢អាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធក្នុងនីតិវិធីស្មុំកូនអន្តរប្រទេស ត្រូវធានាថា ដំណើរការស្មុំកូនអន្តរប្រទេស មិនបណ្តោយឲ្យមានការទទួលផលកំរៃផ្នែកហិរញ្ញវត្ថុ ដោយមិនស្របច្បាប់ និងត្រូវបង្ការមិនឲ្យមានការចាប់ពង្រត់ ការលក់ និង ការជួញដូរកុមារក្នុងពេលកំពុងដំណើរការ ស្មុំកូនអន្តរប្រទេស។ មានតែប្រាក់ចំនេញ សោហ៊ុយ និង វិភាគទាន ដែលកំណត់ដោយបទប្បញ្ញត្តិ នៃច្បាប់នេះដែលត្រូវបង់[26]។

[26] មាត្រា ៥ នៃច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស ២០០៩

**កថាខណ្ឌទី២ គោលបំណងនៃការបង្កើតសុំកូនអន្តរប្រទេស**

ប្រទេសកម្ពុជា បានឆ្លងកាត់នូវក្នុងសង្គ្រាមជាច្រើនលើកច្រើនសារ ដែលជាកត្តានាំឲ្យប្រជាជនកម្ពុជាធ្លាក់ទៅក្នុងភាពក្រីក្រ ទុរគត និងមានគ្រួសារខ្លះព្រាត់ប្រាស់ឪពុកម្តាយបងប្អូនដែលបន្សល់ទុកនូវកុមារកំព្រា ជាច្រើនឲ្យរស់នៅក្នុងគ្មានទីពឹង ខ្វះភាពកក់ក្តៅ ពុំទទួលបានការអប់រំគ្រប់គ្រាន់ដែលស្ថិតនៅក្នុងស្ថានភាពលំបាកវេទនា ។ ដោយមើលឃើញអំពីស្ថានភាពលំបាក ដូច្នេះហើយទើបរាជរដ្ឋាភិបាលកម្ពុជាបានចូលរួមយ៉ាងសកម្ម ដើម្បីដំណើរការរៀបចំសេចក្តីព្រាងច្បាប់សុំកូនអន្តរប្រទេសដែលស្របទៅតាម អនុសញ្ញាស្តីពីសិទ្ធិកុមារនិងអនុសញ្ញាទីក្រុងឡាអេ ដោយគោលបំណងជួយស្តារស្ថានភាពលំបាកកុមារទាំងនេះ។

ដោយអនុលោមស្តីពីអនុសញ្ញាទីក្រុងឡាអេបានបង្កើតនូវគោលបំណងដូចខាងក្រោមះ

- បង្កើតមធ្យោបាយការពារដើម្បីធានាថា ការសុំកូនអន្តរប្រទេស ធ្វើឡើងក្នុងឧត្តមប្រយោជន៍របស់កុមារ និងដោយសេចក្តីគោរពចំពោះសិទ្ធជាមូលដ្ឋានរបស់កុមារដូចបានទទួលស្គាល់នៅក្នុងច្បាប់អន្តរជាតិ។
- បង្កើតប្រព័ន្ធសហប្រតិបត្តិការក្នុងចំណោមរដ្ឋជាភាគីដើម្បីធានាថា មធ្យោបាយការពារទាំងនោះត្រូវបានគោរពហើយតាមរយៈប្រព័ន្ធនោះទប់ស្កាត់ការចាប់ពង្រត់ ការលក់ ឬការជួញដូរកុមារ។
- ធានាអោយមានការទទួលស្គាល់នៅក្នុងរដ្ឋភាគី សុំកូនត្រូវប្រព្រឹត្តទៅស្របតាមអនុសញ្ញានេះ។
- អនុសញ្ញានេះត្រូវអនុវត្តនៅក្នុងករណីកុមារម្នាក់មានទីលំនៅជាទៀងទាត់នៅក្នុងរដ្ឋជាភាគីមួយ( រដ្ឋដើម )ត្រូវបានកំពុងឬនឹងត្រូវបានយករដ្ឋជាភាគីមួយទៀត (រដ្ឋទទួល) ក្រោយពីការសម្រេចសុំកូនដោយសហព័ទ្ធឬដោយជនម្នាក់ដែលមានទីលំនៅទៀងទាត់នៅក្នុងរដ្ឋទទួលបានប្រព្រឹត្តទៅនៅក្នុងរដ្ឋដើម ឬក្នុងគោលបំណងសុំកូន ការសម្រេច សុំកូនធ្វើឡើងនៅក្នុងរដ្ឋទទួលក្តី ឬរដ្ឋដើមក្តី។
- សុំកូនដោយអន្តរប្រទេសអាចផ្តល់អត្ថប្រយោជន៍នៃគ្រួសារអចិន្ត្រៃយ៍ដល់កុមារ ដោយសារគេមិនអាចរកគ្រួសារមួយសមស្របនៅក្នុងប្រទេសដើមរបស់កុមារនោះ។

**កថាខណ្ឌទី៣ ដំណើរការវិវត្តន៍នៃនីតិសុំកូនអន្តរប្រទេស**

ការសុំទារកកំព្រា ឬកុមារកំព្រានៅកម្ពុជាបានអនុវត្តចាប់ពីឆ្នាំ១៩៨៧ តាមសេចក្តី សម្រេច របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីលេខ៧៩ សសរ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៨៧។ អ្នកស្នើសុំកុមារ កម្ពុជា ពេលនោះភាគច្រើនជាបុគ្គលិករបស់អង្គការអន្តរជាតិ ឬអង្គការមិនមែនរដ្ឋាភិបាល ដែល បំពេញ បេសកកម្មនៅកម្ពុជា ដោយចិត្តអាណិតស្រលាញ់ទារក ឬកុមារកំព្រា ដូច្នេះហៅពេលចប់ បេសកកម្ម ត្រលប់ទៅវិញគេបានសុំទារក និងកុមារកំព្រាយកទៅចិញ្ចឹម ដោយអនុវត្តតាមនីតិវិធីជាធរមាន។

នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៨៩ ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ត្រូវបានរដ្ឋសភា កម្ពុជាអនុម័ត និងដាក់ឲ្យប្រើប្រាស់។ រដ្ឋាភិបាលបានចេញសេចក្តីណែនាំលេខ ៥៩៩ សជណ ផក ចុះថ្ងៃទី២៥ ខែមិនា ឆ្នាំ១៩៩១ ស្តីពីនីតិវិធីការងារសុំកូនចិញ្ចឹម តាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ។

ចាប់ពីឆ្នាំ ១៩៩៧ - ២០០០ ការងារសុំកូនចិញ្ចឹមពីកម្ពុជា ត្រូវបានចាប់អារម្មណ៍កាន់តែខ្លាំងឡើងៗ ពីពលរដ្ឋនៃប្រទេសនានាមួយចំនួនរួមមាន អាមេរិក បារាំង កាណាដា អូស្ត្រាលី អាល្លឺម៉ង់ អ៊ីតាលី...។ រដ្ឋាភិបាល បានពង្រឹងនីតិវិធីសុំកូន ហើយចាប់ពីឆ្នាំ១៩៩៨ ដល់២០០៥ កុមារកំព្រាសរុប២៦៣៣នាក់ ក្នុងនោះកុមារី ចំនួន១៤៥៧នាក់ ត្រូវបានសុំយកទៅចិញ្ចឹមនៅ ប្រទេស។ ដើម្បីពង្រឹងបន្ថែមនីតិវិធីសុំកូនអន្តរប្រទេស រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ២៩ អនុក្រ បក ចុះថ្ងៃទី០៤ ខែមិនា ឆ្នាំ២០០១ ប្រគល់ភារៈកិច្ចឲ្យក្រសួងសង្គម មានសមត្ថកិច្ច មួយចំនួន រួមមាន **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងទីស្តីការគណៈរដ្ឋមន្ត្រីអនុវត្តនីតិវិធី និងបែបបទសុំកូនអន្តរ ប្រទេស។**

ប៉ុន្តែ ផ្អែកតាមបទដ្ឋានអង្គការសហប្រជាជាតិ និងអនុសញ្ញាក្រុងឡាអេ តម្រូវឲ្យមានច្បាប់ស្តីពីសុំកូនអន្តរប្រទេស ។ ដោយរង់ចាំច្បាប់នេះ និងដោយមានពត៌មានស្តីពីការជួញដូរកុមារ រួមនឹងសកម្មភាពខុសច្បាប់របស់ទីភ្នាក់ងារបរទេសមួយចំនួននៅប្រទេសខ្លះ បានធ្វើឲ្យប្រទេសមួយចំនួនព្យួរដំណើរការសុំកូនអន្តរប្រទេសជាមួយកម្ពុជាដោយឯកតោភាគី ។ ទន្ទឹមនឹងនេះ នៅមានប្រទេសជាច្រើនកំពុងបន្តការសុំកូនពីកម្ពុជា ដូច្នេះយើងមិនបានបិទទ្វារចំពោះប្រទេសណាមួយឡើយ ហើយស្វាគមន៍ចំពោះកិច្ចសហការលើការងារសុំកូនអន្តរប្រទេស ជាមួយប្រទេសទាំងអស់។ ច្បាប់នេះមិនតម្រូវចិត្តប្រទេសណាមួយទេ តែនេះជាតម្រូវការចាំបាច់នៃនីតិវិធីសុំកូនអន្តរប្រទេស និងដើម្បីឧត្តមប្រយោជន៍នៃកុមារកម្ពុជា[27]។

[27] សេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់សុំកូនអន្តរប្រទេសរបស់ក្រសួង ស . អ . យ .(២៧ កញ្ញា ២០០៥)

### កថាខណ្ឌទី៤ ល័ក្ខខ័ណ្ឌសម្រាប់សុំកូនអន្តរប្រទេស

**សុំកូន** គឺដើម្បីបង្កើននូវអនុភាពគតិយុត្តតាមផ្លូវច្បាប់រវាងកូនសុំនិងឪពុកម្តាយចិញ្ចឹមដូចជាឪពុកម្តាយបង្កើតដែរ។ កូនសុំនិងអ្នកសុំត្រូវមានអត្តសញ្ញាណច្បាស់លាស់និងត្រូវមានការយល់ព្រមពីឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអាណាព្យាបាល។

ល័ក្ខខ័ណ្ឌសម្រាប់សុំកូនអន្តរប្រទេស ត្រូវបានកំណត់យ៉ាងច្បាស់នៅក្នុងច្បាប់ស្តីពីសុំកូនអន្តរប្រទេសដែលមានទាំងលក្ខខណ្ឌចំពោះកូនសុំ ល័ក្ខខ័ណ្ឌចំពោះឪពុកម្តាយចិញ្ចឹម ឬអាណាព្យាបាល និងល័ក្ខខ័ណ្ឌចំពោះអ្នកសុំ។

**១ អំពីកូនសុំ**

កុមារដែលជាកម្មវត្ថុនៃការសុំ ជាកុមារដែលត្រូវការនូវការថែទាំពិសេស ឬ កុមារដែលបានគេបោះបង់ចោល ឬ កុមារដែលអ្នកអាណាព្យាបាលឬ អ្នកមានអំណាចមេបាមានភាពខ្វះខាត។

**កុមារមានអត្តសញ្ញាណត្រឹមត្រូវ អាចជាកម្មវត្ថុនៃការសុំកូនអន្តរប្រទេសបាន ដែលក្នុងនោះតម្រូវឲ្យ៖**

➢កុមារសញ្ជាតិខ្មែរ ដែលមានលំនៅឋានអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា។

➢កុមារអាយុក្រោម ៨ (ប្រាំបី)ឆ្នាំ គិតត្រឹមថ្ងៃទទួលពាក្យសុំ លើកលែងតែក្នុងករណីកុមារត្រូវការនូវការថែទាំពិសេស ដែលអនុញ្ញាតបានដល់អាយុក្រោម ១៨ ( ដប់ប្រាំបី ) ឆ្នាំ ។

➢ក្នុងករណីមានបងប្អូនបង្កើតច្រើននាក់ ហើយម្នាក់មានអាយុក្រោម ៨ ( ប្រាំបី ) ឆ្នាំ អាចអនុញ្ញាតឲ្យសុំកុមារនោះ រួមជាមួយនឹងបងប្អូនបង្កើត ដែលមានអាយុក្រោម ១៨ ឆ្នាំ ។

➢កុមារកំពុងរស់នៅក្នុងមណ្ឌលកុមារកំព្រា ឬ រស់នៅក្រោមការទុកដាក់សមស្របផ្សេងទៀតដែលត្រួតពិនិត្យដោយក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច។

➢កុមារទាំងនោះស្ថិតក្រោមអាណាព្យាបាលសំរាប់អនីតិជន ឬកុមារដែលស្ថិតនៅក្រោម អំណាចមេបា ដែលមានស្ថានភាពលំបាកបំផុត។

➢កុមារទាំងអស់នោះត្រូវបានប្រកាសថា អាចសុំជាកូនចិញ្ចឹមបានដោយអនុលោមតាមមាត្រា ១៣ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/របក/១២០៩/០២៤។

➢ក្នុងករណីសុំកូនដោយសាច់ញាតិ សុំកូនអាចអនុញ្ញាតបានចំពោះកុមារមានអាយុក្រោម ១៨ឆ្នាំ ដែលរស់នៅក្នុង ឬក្រៅមណ្ឌលកុមារកំព្រា[28]។

[28] មាត្រា ១០នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ២០០៩

ករណីកុមារដែលពុំត្រូវបានគេស្គាល់អត្តសញ្ញាណ ដូចជា កុមារត្រូវបានរកឃើញ និងបញ្ជូនមក ហើយរកមិនឃើញឪពុកម្ដាយ ឬសាច់ញាតិ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ប្រធានកុមារកំព្រាត្រូវជូនដំណឹងទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានីខេត្ត អំពីអវត្តមានរបស់កុមារ ដែលបានចូលរួមមកស្នាក់នៅក្នុងមណ្ឌលយ៉ាងយូរបំផុតរយៈពេល ៧ថ្ងៃ នៃថ្ងៃធ្វើការគិត ពីពេលដែលកុមារមកដល់មណ្ឌលកំព្រា។ មន្ទីរទទួលបន្ទុកវិស័យសេដ្ឋកិច្ចរាជធានី/ខេត្ត ត្រូវជូនដំណឹង ជាបន្ទាន់ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីបញ្ចូលកុមារទៅក្នុងបញ្ជីពីកុមារដែលបានរាយការណ៍ថា ត្រូវបានគេបោះបង់ចោល។

មន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី/ខេត្ត ត្រូវប្រឹងប្រែងគ្រប់លទ្ធភាព ដើម្បីស្វែងរកឪពុកម្ដាយ ឬឪពុក ឬម្ដាយ ឬសាច់ញាតិ និងអ្នកអាណាព្យាបាលសម្រាប់អនីតិជនជាមុននៅ ទូទាំងព្រះរាជាណាចក្រកម្ពុជា ដោយប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយជាសាធារណៈទៅតាមលទ្ធភាព។ ជនណាដែលអះអាងថាខ្លួន ជាឪពុកម្ដាយ ឬឪពុក ឬម្ដាយ ឬសាច់ញាតិ និងអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ជននោះត្រូវបង្ហាញភស្តុតាងផ្សេងៗ ដែលបញ្ជាក់ថាខ្លួនមានជាប់ទាក់ទងជាសាច់ញាតិ ឬអ្នកអាណា ព្យាបាលសំរាប់អនីតិជន ជាមួយកុមារស្របទៅតាមបទបញ្ញត្តិ ច្បាប់ជាធរមាន[29]។

បន្ទាប់ពីផ្សព្វផ្សាយដំណឹងរយៈពេលប្រាំខែ នៅតែរកមិនឃើញឪពុកម្ដាយ ឬឪពុក ឬម្ដាយ ឬសាច់ញាតិ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនមុននោះ មន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី/ខេត្ត ត្រូវធ្វើរបាយការណ៍ស្ដីពីការខិតខំប្រឹងប្រែងស្រាវជ្រាវនេះ ហើយត្រូវផ្ញើរសារមួយច្បាប់ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីចុះឈ្មោះកុមារទៅក្នុងសៀវភៅកត់ត្រាកុមារដែលត្រូវបោះ បង់ចោល។

ចាប់ពីពេលដែលកុមារត្រូវបានរកឃើញ រហូតដល់តុលាការបានជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ប្រធានមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី/ខេត្ត គឺអ្នកអាណាព្យាបាលសម្រាប់អនីតិជនបណ្ដោះអាសន្ន។

ប្រសិនបើកុមារកំព្រាដែលមានអ្នកមានអំណាចមេបាក្រលំបាក ឬមានជីវភាពមិនអាចចិញ្ចឹមកុមារបាន ហើយបានធ្វើការទុកដាក់កុមារឲ្យនៅក្រោមការថែទាំរបស់ក្រសួងទទួលបន្ទុកនោះ គឺត្រូវ តែបញ្ជូនឈ្មោះ កុមារទៅក្នុងសៀវភៅកត់ត្រាកុមារ ដែលត្រូវបានធ្វើការទុកដាក់ឲ្យនៅក្រោមការថែទាំរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច។

[29] មាត្រា ១១ នៃច្បាប់ស្ដីពីសុំកូនអន្តរប្រទេស ២០០៩

### ១.១.ល័ក្ខខ័ណ្ឌផ្សេងៗ

ដើម្បីបង្កើតនូវសុំកូនបានត្រូវគោរពល័ក្ខខ័ណ្ឌជាចាំបាច់មិនត្រឹមតែចំពោះអ្នកសុំ និងកូនសុំប៉ុណ្ណោះទេ ល័ក្ខខ័ណ្ឌផ្សេងៗទៀតដូចជា ការព្រមព្រៀង និង ការពិគ្រោះយោបល់ពីភ្នាក់ងារសមត្ថកិច្ច។

#### ១.១.១ ការព្រមព្រៀង

ក្រៅពីអាយុកូនសុំនិងអ្នកសុំ ការយល់ព្រមរបស់ឪពុកម្តាយឬ ឪពុក ឬម្តាយ អ្នកអាណាព្យាបាលរបស់អនីតិជន ជាល័ក្ខខ័ណ្ឌចាំបាច់មួយដែរក្នុងចំណោមល័ក្ខខ័ណ្ឌកូនសុំ និងអ្នកសុំក្នុងដំណើរការប្រព្រឹត្តទៅនៃសុំកូនព្រោះឪពុកម្តាយមានទំនាក់ទំនងជ្រាលជ្រៅជាមួយនឹងកូនសុំរបស់គាត់ដូច្នេះល័ក្ខខ័ណ្ឌនៃការយល់ព្រមនៃដំណើរការសុំកូនរបស់ច្បាប់គឺទាមទារអោយមាន៖

- ក្នុងករណីមានចំណងបុត្តភាពជាមួយឪពុកម្តាយ និងម្តាយការយល់ព្រមត្រូវផ្តល់ដោយឪពុក និងម្តាយរបស់កុមារ។
- ក្នុងករណីដែលឪពុកម្តាយ ឬម្តាយណាមួយរបស់កុមារបានស្លាប់ ឬស្ថិតក្នុងស្ថានភាពមិនអាចបង្ហាញឆន្ទៈបាន ឬត្រូវបានដកហូតពីអំណាចមេបា ការយល់ព្រមត្រូវផ្តល់ដោយឪពុកម្តាយឬ ម្តាយតែម្ខាង ដែលមានអំណាចមេបាជាការគ្រប់គ្រាន់។
- ក្នុងករណីដែលឪពុកម្តាយរបស់កុមារបានស្លាប់ ឬស្ថិតក្នុងស្ថានភាពមិនអាចបង្ហាញឆន្ទៈបាន ឬត្រូវបានដកហូតអំណាចមេបាយល់ព្រមត្រូវផ្តល់ដោយអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ[30]។

#### ១.១.២ សមត្ថកិច្ចផ្តល់ទីប្រឹក្សា

**សមត្ថកិច្ចរបស់ភ្នាក់ងារសង្គមកិច្ចក្នុងការពិគ្រោះយល់បល់ ៖**

- ឪពុកម្តាយ ឬ ឪពុក ឬម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារត្រូវទទួលនូវការពិគ្រោះយោបល់ពីភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ច ដែលបានទទួលការអនុញ្ញាតជាមុនសិនមុននឹងផ្តល់ការយល់ព្រម។ ភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ចត្រូវប្រាប់យ៉ាងច្បាស់លាស់ដល់អ្នក ដែលត្រូវផ្តល់ការយល់ព្រមការបញ្ចប់នូវបុត្តភាពព្រមទាំងបញ្ចប់សិទ្ធ និង កាតព្វកិច្ចជាអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន និង ត្រូវប្រាប់ពីបែបបទ និងរយៈពេលបញ្ឈប់ការយល់ព្រមដូចមានចែងក្នុងមាត្រា ១៧នៃច្បាប់នេះ។ ភ្នាក់ងារសង្គមកិច្ចត្រូវធ្វើកំណត់ជាលាយលក្ខណ៍

[30] មាត្រា ២១ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ ២០០៩

អក្សរ អំពីការសំភាសន៍របស់ខ្លួនជាមួយឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសំរាប់អនីតិជនរបស់កុមារ។

- ទោះបីក្នុងករណីណាក៏ដោយ ការយល់ព្រមត្រូវផ្តល់សក្ខីកម្មជាលាយលក្ខណ៍អក្សរនៅចំពោះមុខមេឃុំឬ ចៅសង្កាត់ខាងទីលំនៅរបស់ឪពុកម្តាយ ឬឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អាណាព្យាលបាលសម្រាប់អនីតិជនរបស់កុមារ។
- មេឃុំ ឬចៅសង្កាត់ និងភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ចត្រូវធានាថា រាល់ការយល់ព្រមរបស់ឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាល សម្រាប់អនីតិជនជាការយលព្រមដែលគោរពទៅតាមឆន្ទៈដោយសេរី និង ច្បាស់លាស់ដែលបានកំណត់ខាងលើ។
- មេឃុំ ឬចៅសង្កាត់ត្រូវចាត់ចែងធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរអំពីការយល់ព្រមនេះហើយពីបានពិនិត្យថាភ្នាក់ងារសង្គមកិច្ច មានសង្គមកិច្ចបានពិគ្រោះយោបល់ជាមុនជាមួយឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារនិងបានប្រាប់យ៉ាងត្រឹមត្រូវអំពីអនុភាពនៃការយល់ព្រមនេះ[31]។

### ១.១.៣ ករណីកុមារកំព្រាយកទៅចិញ្ចឹមជាកូននៅបរទេស

#### ក.ល័ក្ខខ័ណ្ឌចំពោះអ្នកសុំ

សាមីអ្នកស្នើសុំជាប្តីប្រពន្ធដែលបានរៀបអាពាហ៍ពិពាហ៍នឹងមានអាយុ២៥ឆ្នាំដល់ឆ្នាំដល់៥០ឆ្នាំ។ ចំពោះអ្នកនៅលាវអាចអនុញ្ញាតអោយសុំបានតែអ្នកនៅលូវដែលមានអាយុចាប់ពី ៤០ ឆ្នាំ ដល់៥០ឆ្នាំ ចំពោះសាមីអ្នកស្នើរសុំមិនអាចសុំកូនយកទៅចិញ្ចឹមលើសពី ២នាក់បានហើយ ។ត្រូវបានអនុញ្ញាតអោយសុំកូនបាន លុះត្រាតែអ្នកស្នើសុំ គ្មានកូន ឬមានកូនមិនលើសពី ២នាក់[32]។

#### ខ.ល័ក្ខខ័ណ្ឌចំពោះកូនសុំ

ទារកកំព្រា ឬកុមារកំព្រា ដែលត្រូវបានអនុញ្ញាតអោយសុំយកទៅចិញ្ចឹមត្រូវមានលក្ខណៈវិនិច្ឆ័យ និងសំណុំលិខិតដូចខាងក្រោមៈ

- មានអាយុក្រោម ៨ ឆ្នាំ

[31] មាត្រា ១៦ នៃច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស ឆ្នាំ ២០០

[32] មាត្រា ៣ នៃច្បាប់ស្តីពីការសុំទារកកំព្រា ឬកុមារកំព្រាយកទៅចិញ្ចឹមជាកូននៅបរទេស

- រស់នៅក្រោមការថែទាំរបស់មជ្ឈមណ្ឌលកុមារកំព្រារដ្ឋ ឬ មណ្ឌលឯទៀតគ្រប់គ្រងដោយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាវិជ្ជាជីវៈ និងយុវនីតិសម្បទា ។រស់នៅក្នុងមណ្ឌលអស់រយៈពេល ៣ខែ យ៉ាងតិចមិនពេលស្នើសុំ។
- ត្រូវមានសំបុត្រកំណើតដែលចេញអោយដោយមន្ត្រីអាត្រានុកូនដ្ឋាន
- ត្រូវមានវិញ្ញាបនប័ត្រពីសុខភាពកាយសម្បទា ដែលចេញដោយវេជ្ជបណ្ឌិតមានសមត្ថកិច្ចធ្វើការក្នុងមន្ត្រីពេទ្យរដ្ឋ ឬគ្លីនិចផ្សេងទៀតដែលរដ្ឋទទួលស្គាល់[33]។

### គ.បែបបទនៃការស្នើរសុំ

សាមីអ្នកស្នើសុំត្រូវសរសេរពាក្យសុំទៅក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវៈនីតិសម្បទាតាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដោយមានភ្ជាប់ឯកសារដូចខាងក្រោមៈ

- ទំរង់ពាក្យសុំ
- លិខិតអនុញ្ញាតិអោយសុំកូនចិញ្ចឹមពីអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសសាមីរបស់សាមីអ្នកសុំ។
- របាយការណ៍ស្តីពីស្ថានភាពគ្រួសារ ដោយមានបញ្ជាក់ពីចំនួនសមាជិកគ្រួសារ ដែលធ្វើដោយភ្នាក់ងារមានជំនាញលើការងារនេះ ហើយមានការទទួលស្គាល់ពីក្រសួងមានសមត្ថកិច្ចនៃប្រទេសសាមីរបស់សាមីអ្នកស្នើសុំ។
- សេចក្តីចម្លងសំបុត្រកំណើតឬ បរិញ្ញាបនប័ត្រកំណើតរបស់អ្នកសុំ
- សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬលិខិតលែងលះគ្នា ឬលិខិតបញ្ជាក់ថានៅលីវ
- លិខិតបញ្ជាក់អំពីសុខភាពរបស់សាមីអ្នកស្នើរសុំ
- របាយការណ៍ស្តីពីចិត្តវិទ្យាធ្វើឡើងដោយគ្រូពេទ្យចិត្តវិទ្យា ដែលទទួលស្គាល់ដោយរដ្ឋាភិបាលនៃប្រទេសសាមីរបស់សាមីអ្នកស្នើសុំ។
- លិខិតបញ្ជាក់ថា គ្មានទោស ចេញដោយអាជ្ញាធរក្នុងប្រទេសកំណើតថាគ្មានទោស ឬកន្លែងដែលសាមីអ្នកស្នើសុំបានរស់នៅ ឬសំបុត្រថ្កោលទោសចេញដោយក្រសួងមានសមត្ថកិច្ច។

[33] មាត្រា ៥ នៃច្បាប់ស្តីពីការសុំទារកកំព្រា ឬកុមារកំព្រាយកទៅចិញ្ចឹមជាកូននៅបរទេស

- សេចក្តីបញ្ជាក់អំពីស្ថានភាពហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់សាមីអ្នកស្នើសុំ ចេញដោយអាជ្ញាមានសមត្ថកិច្ច
- កិច្ចសន្យាគោរពសិទ្ធជាកូន និងផ្តល់ការសិក្សា ព្រមទាំងសិទ្ធទទួលមរតកដូចជាកូន បង្កើតរបស់ខ្លួន។
- រូបថតរបស់សាមីអ្នកស្នើសុំ យកក្នុងអំឡុងពេលពីរខែចុងក្រោយ
- កិច្ចសន្យារបស់សាមីអ្នកស្នើសុំ ស្តីពីការផ្តល់ពត៌មានលើការចិញ្ចឹមកូនចាប់ពីពេលដែលកូនចិញ្ចឹមចេញពីប្រទេសកម្ពុជាមួយឆ្នាំម្តង១ រហូតដល់អាយុ ១៨ (ដប់ប្រាំបី) ឆ្នាំ មកក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ហើយរបាយការនោះត្រូវបានត្រួតពិនិត្យ និងបញ្ជាក់ពីភាពត្រឹមត្រូវដោយក្រសួងមានសមត្ថកិច្ចខាងការងារសុំកូនចិញ្ចឹម នៃប្រទេសសាមីអ្នកស្នើសុំហើយចម្លងជូនទៅស្ថានទូតខ្មែរប្រចាំ នៅប្រទេសសាមីអ្នកស្នើសុំ។
- សេចក្តីចំលងលិខិតឆ្លងដែនសាមីអ្នកស្នើសុំ
- លិខិតបញ្ជាក់ពីស្ថានទូតនៃប្រទេសរបស់អ្នកស្នើសុំ ចំពោះឯកសារទាំងអស់ខាងលើភាពត្រឹមត្រូវ[34]។

## ២. ឪពុកម្តាយបង្កើត ឬ អាណាព្យាបាល

### ❖ការយល់ព្រមរបស់ឪពុកម្តាយបង្កើត ឬអាណាព្យាបាល

ដំណើរការសុំកូនអន្តរប្រទេស អាចប្រព្រឹត្តទៅបានលុះត្រាតែមានការយល់ព្រមច្បាស់លាស់ និងពិតប្រាកដពីឪពុកម្តាយ ឬសាច់ញាតិ និងអ្នកអាណាព្យាបាល សម្រាប់អនីតិជនរបស់កុមារ តាមករណីដូចជា៖

-ក្នុងករណីកុមារមានចំណងបុត្តភាពជាមួយឪពុក និងម្តាយការយល់ព្រមត្រូវបានផ្តល់ដោយឪពុក និងម្តាយរបស់កុមារនោះ។

-ក្នុងករណីដែលឪពុក ឬម្តាយណាមួយរបស់កុមារបានស្លាប់ ឬស្ថិតក្នុងស្ថានភាពដែលមិនអាចបង្ហាញឆន្ទៈបាន ឬត្រូវបានដកហូតអំណាចមេបាការយល់ព្រមត្រូវបានផ្តល់ដោយឪពុក ឬម្តាយតែម្ខាងដែលមានអំណាចមេបាជាការគ្រប់គ្រាន់។

[34] មាត្រា ៤ នៃច្បាប់ស្តីពីការសុំទារកកំព្រា ឬកុមារកំព្រាយកទៅចិញ្ចឹមជាកូននៅបរទេស

-ក្នុងករណីដែលឪពុកម្ដាយរបស់កុមារបានស្លាប់ ឬស្ថិតក្នុងស្ថានភាពដែលមិនអាចបង្ហាញឆន្ទៈបាន ឬត្រូវដកហូតអំណាចមេបា ការយល់ព្រមត្រូវផ្ដល់ដោយអ្នកអាណាព្យាបាលសម្រាប់ អនីតិជនរបស់កុមារនោះ។ ការយល់ព្រមខាងលើត្រូវផ្ដល់ដោយសេរី និងច្បាស់លាស់ ដោយមិន ត្រូវមានវិការៈណាមួយដូចជា ការបង្ខិតបង្ខំ ការឆបោក ឬ ការបញ្ចុះបញ្ចូលតាមរយៈការផ្ដល់ ឬ ការសន្យាផ្ដល់ប្រាក់រង្វាន់សំរាប់ជាសំណងផលប្រយោជន៍ណាមួយ និងដោយបានដឹងច្បាស់ពីផលវិបាកនៃការយល់ព្រមរបស់ខ្លួនចំពោះសុំកូនអន្តរប្រទេស។ ឪពុកម្ដាយ ឬឪពុក ឬម្ដាយ ឬអ្នកអាណាព្យាបាល សម្រាប់អនីតិជនរស់កុមារត្រូវទទួលនូវការពិគ្រោះយោបល់ពីភ្នាក់ងារសង្គមកិច្ចមានសមត្ថភាពដែលបានទទួលការអនុញ្ញាតជាមុននឹងផ្ដល់ការយល់ព្រម។ ភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ច ត្រូវប្រាប់យ៉ាងច្បាស់លាស់ដល់អ្នកដែលត្រូវផ្ដល់ការយល់ព្រមអំពីអានុភាព នៃការយល់ព្រមនូវការបញ្ចប់នូវបុត្តភាពព្រមទាំងបញ្ចប់សិទ្ធិ និងកាតព្វកិច្ចជាអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន និងត្រូវប្រាប់អំពីបែបបទ និងរយៈពេលបញ្ឈប់ការយល់ព្រមនេះ។ ភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ចត្រូវធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ អំពីការសម្ភាសន៍របស់ខ្លួនជាមួយឪពុកម្ដាយ ឬឪពុក ឬម្ដាយ ឬអ្នកមានអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ។

ទោះបីក្នុងករណីណាក៏ដោយ ការយល់ព្រមត្រូវផ្ដល់សក្ខីកម្មជាលាយលក្ខណ៍អក្សរនៅចំពោះមុខមេឃុំ ឬចៅសង្កាត់ខាងទីលំនៅរបស់ឪពុកម្ដាយ ឬឪពុក ឬម្ដាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនជាការយល់ព្រមដោយសេរី និងច្បាស់លាស់ និងដោយមិនត្រូវមានវិការៈណាមួយឡើយ។ ម្យ៉ាងទៀត មេឃុំ ឬចៅសង្កាត់ត្រូវចាត់ចែងធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរអំពីការយល់ ព្រមនេះក្រោយពីបានពិនិត្យថា ភ្នាក់ងារសង្គមកិច្ចបានពិគ្រោះយោបល់ជាមុនជាមួយឪពុកម្ដាយ ឬឪពុក ឬម្ដាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារនោះ និងបានគ្រប់យ៉ាងត្រឹម ត្រូវអំពីអានុភាពនៃការយល់ព្រមនេះ។

❖**ការបញ្ឈប់ការយល់ព្រមលើសុំកូន**

ឪពុកម្ដាយ ឬឪពុក ឬម្ដាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារអាចបញ្ឈប់ ការយល់ព្រមរបស់ខ្លួនវិញបាន រហូតដល់មានសេចក្ដីសម្រេចរបស់តុលាការស្ដីអំពីការសុំកូន ជាស្ថាពរ។ ការបញ្ឈប់ការយល់ព្រមឪពុកម្ដាយ ឬឪពុក ឬម្ដាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជននេះអាចត្រូវធ្វើជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់នៅចំពោះមុខមេឃុំ ឬចៅសង្កាត់ខាងលំនៅឋានរបស់ខ្លួន។ មេឃុំ ឬចៅសង្កាត់ខាងលំនៅឋានរបស់ឪពុកម្ដាយ ឬឪពុក ឬម្ដាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនកុមារ ត្រូវធ្វើកំណត់ហេតុអំពីកិច្ចការនេះ ហើយត្រូវបញ្ជូនកំណត់ហេតុនេះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី/ខេត្ត ប្រធានមណ្ឌលកុមារកំព្រា ដែលពាក់ព័ន្ធ

នឹងត្រូវប្រគល់កំណត់ហេតុចម្លង ដែលមានសេចក្តីបញ្ជាក់នៅលើកំណត់ហេតុនោះទៅឲ្យឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ។

**❖ការដកហូតអំណាចមេបាដោយមានការយល់ព្រមពីតុលាការ**

ករណីឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារបដិសេធការយល់ព្រម ឬបញ្ឈប់ការយល់ព្រមរបស់ខ្លួន ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចអាចប្តឹងឲ្យតុលាការប្រកាសការដកហូតអំណាចមេបាពីឪពុកម្តាយ ឬឪពុក ឬម្តាយ ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ និងជ្រើសតាំងអ្នកអាណាព្យាបាលថ្មីសម្រាប់អនីតិជនរបស់កុមារ ក្នុងករណីពិនិត្យឃើញថា ការបដិសេធ ឬបញ្ឈប់ការយល់ព្រមនេះ ធ្វើឲ្យប៉ះពាល់ផលប្រយោជន៍របស់កុមារ ឬបណ្តាលឲ្យប៉ះពាល់ដល់សុខភាព ឬសីលធម៌របស់កុមារ។

ពាក្យបណ្តឹងទៅតុលាការត្រូវធ្វើក្នុងរយៈពេល ៦០ថ្ងៃ នៃថ្ងៃធ្វើការក្រោយពីឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនកុមារបដិសេធ ឬបញ្ឈប់ការយល់ព្រមរបស់ខ្លួន។

**៣.អំពីអ្នកសុំ**

ចំពោះជនបរទេសដែលអនុញ្ញាតឲ្យសុំទារក ឬកុមារកំព្រាយកទៅចិញ្ចឹមជាកូន នៅឯបទេសបានត្រូវឆ្លើយតបនឹងលក្ខខណ្ឌមួយចំនួនដែលមានដូចតទៅ៖

➢អ្នកសុំជាប្តីប្រពន្ធត្រូវមានអាយុពី៣០ ( សាមសិប ) ឆ្នាំ និងមានអាយុលើសកូនសុំយ៉ាងតិច ២២ (ម្ភៃពីរ) ឆ្នាំ និងយ៉ាងច្រើនបំផុត ៤៥ (សែសិបប្រាំ) ឆ្នាំ គិតត្រឹមកាលបរិច្ឆេទដាក់ពាក្យសុំកូន។

➢ក្នុងករណីដែលអ្នកសុំមិនបានបំពេញតាមចំណុចដូចបានរៀបរាប់ខាងលើ ហើយក្នុងករណី សុំកូនឆ្លើយតបនឹងឧត្តមប្រយោជន៍របស់កុមារ សុំកូនអាចអនុញ្ញាតឲ្យបានក្នុងស្ថានភាពដូចតទៅ៖

- អ្នកសុំមានដើមកំណើតជាជនជាតិខ្មែរ សុំកុមារដែលជាសាច់ញាតិរបស់ខ្លួន ឬអ្នកសុំជាសហព័ទ្ធដែលសុំកូននៃសហព័ទ្ធម្ខាងទៀត។
- អ្នកសុំអាចសុំកុមារដែលត្រូវការថែទាំពិសេស ឬស្ថានភាពផ្សេងទៀតដែលបម្រើឧត្តមប្រយោជន៍របស់កុមារ។

➢ក្នុងករណីអ្នកសុំមានប្តី ឬប្រពន្ធការសុំកូនត្រូវធ្វើដោយសហព័ទ្ធទាំងពីររួមគ្នាលើកលែងតែករណីដែលសហព័ទ្ធណាម្ខាងសុំបង្កើតនៃសហព័ទ្ធម្ខាងទៀត។

➢ច្បាប់ជាតិរបស់អ្នកសុំនីមួយៗ និងច្បាប់ប្រទេសនៃលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំបានទទួលស្គាល់ និងអនុញ្ញាតនូវបុគ្គភាពនៃសុំកូនពេញលេញ។

➢ប្រទេសនៃសញ្ជាតិ ឬប្រទេសនៃលំនៅឋានអចិន្ត្រៃយ៍នៃអ្នកសុំ ត្រូវតែជាប្រទេសមានទំនាក់ទំនងការទូតជាមួយព្រះរាជាណាចក្រកម្ពុជា។

➢អ្នកសុំត្រូវមានលក្ខណៈសម្បត្តិ និងលក្ខខណ្ឌជាសារវន្តសុំកូនស្របទៅតាមច្បាប់ប្រទេសនៃលំនៅឋានអចិន្ត្រៃយ៍។

➢អ្នកសុំត្រូវតែជាជនពុំធ្លាប់ត្រូវបានផ្តន្ទាទោស ឬត្រូវកំពុងបានប្តឹងអំពីកំហុសទាក់ទងទៅនឹងកិរិយាមាយាទ ឬការប្រព្រឹត្តបទឧក្រិដ្ឋកម្ម ឬមជ្ឈឹមណាមួយនៅក្នុងប្រទេសនៃសញ្ជាតិរបស់ខ្លួន ឬប្រទេសលំនៅឋានអចិន្ត្រៃយ៍ ឬក្នុងប្រទេសណាមួយដែលខ្លួនបានស្នាក់នៅចុងក្រោយ។

➢អ្នកសុំត្រូវតែអ្នកមានសមត្ថភាពផ្តល់ការថែទាំសមស្រប និងការគាំទ្រយ៉ាងចាំបាច់ ដល់កូន។

➢អ្នកសុំត្រូវបានអនុញ្ញាតឲ្យសុំកូនបានលុះត្រាតែអ្នកសុំកូនគ្មានកូន ឬមានកូនតែម្នាក់នៅក្នុងបន្ទុក។ អ្នកសុំកូនអាចសុំកូនបានតែម្នាក់ប៉ុណ្ណោះ លើកលែងតែកុមារដែលមានបងប្អូនបង្កើតច្រើនទើបអ្នកសុំអាចសុំបានលើសពីមួយ ឬច្រើននាក់បាន[35]។

## ផ្នែកទី២ អាជ្ញាធរមានសមត្ថកិច្ចក្នុងកិច្ចការសុំកូនអន្តរប្រទេស

ជាទូទៅក្នុងដំណើរនីតិវិធីណាក៏ដោយគឺត្រូវមានអង្គការ ឬភ្នាក់ងារដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រងដោះស្រាយ និងជាយន្តការសម្របសម្រួលដើម្បីឲ្យស្ថាប័នមានដំណើរការបានល្អ។ ជាក់ស្តែង ក្នុងកិច្ចការសុំកូនអន្តរប្រទេសមានអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដូចជា៖ អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស រដ្ឋបាលសុំកូនអន្តរប្រទេស ភ្នាក់ងារសុំកូនអន្តរប្រទេស ដែលត្រូវបានបែងចែកចំនួនបីកថាខ័ណ្ឌដូចខាងក្រោម៖

### កថាខណ្ឌទី១ ៖ អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស

អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស គឺជាសមត្ថកិច្ចចម្បងមួយដ៏សំខាន់ សម្រាប់ការអនុវត្តន៍ដំណើរការទាំងឡាយចំពោះបញ្ហាសុំកូនអន្តរប្រទេស ដូច្នេះអាជ្ញាធរទាំង អស់ដោយផ្ទាល់ក្តី ឬតាមអាជ្ញាធរសាធារណៈក្តី ត្រូវចាត់វិធានការដើម្បីទប់ស្កាត់ការកេងយកចំនេញមិនត្រឹមត្រូវផ្នែកហិរញ្ញវត្ថុ ឬការយកចំនេញដទៀតដែលទាក់ទងនឹងសុំកូន និងដើម្បីទប់ស្កាត់ការអនុវត្តន៍ទាំងអស់ដែលផ្ទុយនឹងគោលបំណងនៃអនុសញ្ញានៃទីក្រុងឡាអេ ស្តីពីការការពារកុមារនិងសហប្រតិបត្តិការដែលទាក់ទងនឹងសុំកូនអន្តរប្រទេស[36]។ អាជ្ញាធរកណ្តាលទាំងអស់ ត្រូវសហប្រតិបត្តិការជាមួយគ្នាទៅវិញទៅ

---

[35] មាត្រា ២១ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ២០០៩

[36] មាត្រា ៨ នៃអនុសញ្ញាក្រុងឡាអេស្តីពី ការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស ១៩៩៣

មក ហើយត្រូវលើកស្ទួយសហប្រតិបត្តិការ ក្នុងចំណោមអាជ្ញាធរមានសមត្ថកិច្ចនៅក្នុងរដ្ឋរបស់ខ្លួន ដើម្បីការពារកុមារ និងដើម្បីធ្វើឲ្យបានសម្រេចគោលបំណងដទៃទៀតនៃអនុសញ្ញាទីក្រុងឡាអេ។

**១. ភារៈកិច្ចរបស់អាជ្ញាធររដ្ឋបាលកណ្តាលសុំកូនអន្តរប្រទេស**

អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស មានភារៈកិច្ចរៀបចំ និងត្រួតពិនិត្យការអនុវត្តគោលនយោបាយ ច្បាប់ បទបញ្ញា និងនីតិវិធីទាក់ទងនឹងការសម្រេចលើកិច្ចការសុំកូនអន្តរប្រទេស។ ពិសេស ធ្វើកិច្ចសហប្រតិបត្តិការ ក៏ដូចជាសម្របសម្រួលលើការប្រាស្រ័យទាក់ទងទៅនឹងកិច្ចការ សុំកូនអន្តរប្រទេសជាមួយ ក្រសួង ស្ថាប័ន និងទីភ្នាក់ងារដែលមានសមត្ថកិច្ចដោះស្រាយកិច្ចការសុំកូនអន្តរប្រទេស នៅក្នុងព្រះរាជា- ណាចក្រកម្ពុជា និងជាមួយអាជ្ញាធរកណ្តាល និងអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស នៃប្រទេសទទួល។

រៀបចំបណ្តុះបណ្តាលជំនាញកិច្ចការសុំកូនអន្តរប្រទេសដល់មន្ត្រីពាក់ព័ន្ធ និងពិនិត្យលើសំណើរបស់ រដ្ឋបាលសុំកូនអន្តរប្រទេសដែលទាក់ទងនឹងករណីសុំកូនអន្តរប្រទេសនីមួយៗតាមការចាំបាច់។ ធ្វើអធិការកិច្ច លើការងារទាំងឡាយដែលពាក់ព័ន្ធជាមួយសុំកូនអន្តរប្រទេស និងចាត់វិធានការសមស្រប ដើម្បីប្រមូល រក្សាការពារ និងផ្លាស់ប្តូរពត៌មានអំពីស្ថានភាពរបស់កុមារ និងរក្សាទុកពត៌មានទាក់ទងនឹងប្រភពកំណើតរបស់ កុមារ អត្តសញ្ញាណរបស់កុមារ ឪពុកម្តាយកុមារ និងប្រវត្តិសុខភាពកុមារ ។

លើសពីនេះ អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសផ្តោត សំខាន់លើការចាត់វិធានការសមស្រប ដើម្បី បង្ការ និងទប់ស្កាត់ការទទួលផលកម្រៃផ្នែកហិរញ្ញវត្ថុដោយមិនសមស្រប ឬផលចំនេញផ្សេងៗទាក់ទងនឹងសុំកូន អន្តរប្រទេស ។ រក្សា និងផ្តល់ស្ថិតិទាក់ទងនឹងសុំកូនអន្តរប្រទេស ដល់ប្រទេសនានាតាមសំណើ។ បន្ថែម លើនេះ ទទួលប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានា ពីអ្នកសុំកូនត្រូវបង់តាមរយៈទីភ្នាក់ងារសុំ កូនអន្តរប្រទេស និងធ្វើរបាយការណ៍ស្តីពីស្ថានភាពប្រាក់ចំណាយ ការប្រមូលវិភាគទាន និងការបង់ចូលក្នុង គណនីប្រាក់បញ្ញើនៅរតនាគាជាតិជារៀងរាល់ខែ បូករួមចាត់ចែងប្រាក់វិភាគទានមនុស្សធម៌។

ពិនិត្យ ផ្តល់អនុសាសន៍ និងបញ្ជូនសំណុំឯកសារសុំកូនអន្តរប្រទេសនីមួយៗទៅតុលាការ។ ហើយ បំពេញភារៈកិច្ចផ្សេងៗទៀត ដែលក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា យល់ថាចាំបាច់ សម្រាប់អនុវត្តកិច្ចការសុំកូនអន្តរប្រទេស ដោយអនុលោមទៅតាមច្បាប់ និងបទបញ្ញាជាធរមាននៃព្រះរាជាណាចក្រកម្ពុជា[37]។

[37] មាត្រា ៣ នៃប្រកាសរបស់ក្រសួង ស អ យ លេខ១៩៤ ចុះថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ ២០១៣

**២. គណៈកម្មាធិការកណ្តាលសុំកូនអន្តរប្រទេស**

គណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស មានសមាសភាពដូចតទៅ[38]៖

- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប្រធាន
- រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា អនុប្រធាន ទទួលបន្ទុកវិស័យសុខុមាលភាពកុមារ។
- អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា សមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ សមាជិក
- នាយកឧទ្ទកាល័យរដ្ឋមន្ត្រី សមាជិក
- តំណាងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សមាជិក
- អ្នកជំនាញការជាតិលើវិស័យសុខុមាលភាពកុមារ សមាជិក
- ប្រធាននាយកដ្ឋានសុខុមាលភាពកុមារ សមាជិក
- ប្រធានរដ្ឋបាលសុំកូនអន្តរប្រទេស អគ្គលេខាធិការ

គណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស មាននីតិវិធីធ្វើការដូចជា បើកសម័យប្រជុំ ដើម្បីពិនិត្យឲ្យយោបល់លើករណីសុំកូននីមួយៗ និងពិនិត្យផ្តល់យោបល់ក្នុងការរៀបចំត្រួត ពិនិត្យការអនុវត្តគោលនយោបាយ ច្បាប់ បទបញ្ញា និងនីតិវិធីទាំងឡាយទាក់ទងនឹងសុំកូនអន្តរប្រទេស និងអនុវត្តភារៈកិច្ចខាងលើ។

ការប្រជុំ និងការសម្រេចរបស់គណៈកម្មាធិការអាជ្ញាធរកណ្តាល សុំកូនអន្តរប្រទេសអាចយកបាន លុះត្រាតែមានសមាជិកចូលរួមយ៉ាងតិច ៥០%+១ នៃសមាជិកគណៈកម្មាធិការទាំងអស់។ ការប្រជុំត្រូវដឹកនាំដោយប្រធានគណៈកម្មាធិការ ក្នុងករណីប្រធានអវត្តមាន អាចប្រគល់សិទ្ធិឲ្យ អនុប្រធានដឹកនាំជំនួស។ ការសម្រេចរបស់អង្គប្រជុំ ត្រូវអនុម័តដោយសំឡេងភាគច្រើននៃសមាជិក អង្គប្រជុំករណីមានសំលេងស្មើគ្នា សំឡេងប្រធានមានឧត្តមានុភាព[39]។

**កថាខ័ណ្ឌទី២ រដ្ឋបាលសុំកូនអន្តរប្រទេស**

រដ្ឋបាលសុំកូនអន្តរប្រទេស អាចចាត់ទុកថាជាភ្នាក់ងារដែលតូចជាងគេក្នុងក្រសួងសង្គមកិច្ច ទាក់ទងនឹងដំណើរការសុំកូនអន្តរប្រទេសក៏ពិតមានតែរដ្ឋបាលនេះត្រូវមានការងារជាច្រើន ដែល ត្រូវធ្វើ ព្រមទាំងទំនួលខុសត្រូវ ដែលសមាជិកទាមទារ ប្រកបទៅដោយចំនេះដឹង និងជំនាញ បូករួម

[38] ប្រការ ៤ នៃប្រកាសរបស់ក្រសួង ស អ យ លេខ១៩៤ ចុះថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ ២០១៣

[39] ប្រការ៨ នៃប្រកាសរបស់ក្រសួង ស អ យ លេខ១៩៤ ចុះថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ ២០១៣

ទាំងបែងចែកឲ្យបានត្រឹមត្រូវតាមរចនាសម្ព័ន្ធ ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងដំណើរការ សុំកូនអន្តរប្រទេស។

**១. សមាសភាព**

រដ្ឋបាលសុំកូនអន្តរប្រទេសដឹងនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនតាម ការចាំបាច់[40]។

សមាសភាពថ្នាក់ដឹកនាំ និងមន្ត្រីបម្រើការងារនៅរដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវមានលក្ខណសម្បត្តិ ដូចមានបទពិសោធន៍លើការងារសង្គមកិច្ច ផ្នែចិត្តសាស្ត្រ ជាពិសេសការងារសុខុមាភាពកុមារ និងបានទទួលការបណ្តុះបណ្តាលវគ្គសេវាសង្គមកិច្ច។ មិនតែប៉ុណ្ណោះ ត្រូវមានចំណេះដឹងជាមូលដ្ឋានលើផ្នែកច្បាប់ ជាពិសេសច្បាប់ស្តីពីសុំកូនអន្តរប្រទេស និងអនុសញ្ញាអន្តរជាតិននានាដែលពាក់ព័ន្ធនឹងសុំកូនអន្តរប្រទេស។

សមាសភាពថ្នាក់ដឹងនាំ និងមន្ត្រីបម្រើការងារនៅរដ្ឋបាល ត្រូវតម្រូវឲ្យមានសមត្ថភាពខាងផ្នែកពតិមានវិទ្យា និងភាសាបរទេសជាពិសេសភាសាអង់គ្លេស។ ជាមន្ត្រីក្របខណ្ឌរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬជាមន្ត្រីជាប់កិច្ចសន្យា។ រដ្ឋបាលសុំកូនអន្តរប្រទេស ក៏អាចប្រើប្រាស់ទីប្រឹក្សាតាមការចាំបាច់[41]។

**២. តួនាទី ភារៈកិច្ចរបស់រដ្ឋបាលសុំកូនអន្តរប្រទេស**

រដ្ឋបាលសុំកូនអន្តរប្រទេស សរសេរកាត់ថា រ.ស.អ ជាភាសាអង់គ្លេស Inter-Country Adoption Administration ( I.C.A.A )។

រដ្ឋបាលសុំកូនអន្តរប្រទេស មានភារៈកិច្ចដូចខាងក្រោម៖

➢រៀបចំ ថែរក្សា និងធ្វើបច្ចុប្បន្នភាពបញ្ជីសម្ងាត់ និងសំណុំឯកសាររបស់កុមារដែលមានលក្ខណសម្បត្តិសមស្របសម្រាប់សុំកូនអន្តរប្រទេស ។

➢ធ្វើការប៉ាន់ប្រមាណស្ថានភាពកុមារទាំងអស់ដែលមានឈ្មោះក្នុងបញ្ជីសម្ងាត់ ដើម្បីកំណត់ទម្រង់នៃការចិញ្ចឹមថែទាំសមស្របបំផុតសម្រាប់កុមារ និងធានាថាកុមារទាំងនោះទទួលបានការចិញ្ចឹមថែទាំតាមតម្រូវការ។

---

[40] ប្រការ ៣ នៃប្រកាសរបស់ក្រសួង ស អ យ លេខ១២៣០ ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០១៣

[41] ប្រការ៥ នៃប្រកាសរបស់ក្រសួង ស អ យ លេខ១២៣០ ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០១៣

➢ធ្វើការផ្ទៀងផ្ទាត់អំពីការខិតខំប្រឹងប្រែង ដោយអស់ពីលទ្ធភាពក្នុងដំណោះស្រាយនៅក្នុងប្រទេសតាមរយៈការថែទាំជាអចិន្ត្រៃយ៍នៅតាមគ្រួសារ ឬជាមួយអ្នកអាណាព្យាបាលមុនដាក់សំណើរការសុំកូនអន្តរប្រទេស។

➢ទទួលពិនិត្យ និងចាត់ការពាក្យសុំកូនអន្តរប្រទេស និងឯកសារពាក់ព័ន្ធផ្សេងៗទៀតរបស់ អ្នកសុំ។

➢ផ្គូរផ្គងកុមារដែលមានលក្ខណសម្បត្តិសមស្របសម្រាប់សុំកូនអន្តរប្រទេស ជាមួយអ្នកសុំដែលអាចបំពេញតម្រូវការដ៏ល្អបំផុតរបស់កុមារ ស្របតាមគោលការណ៍ នៃឧត្តមប្រយោជន៍របស់កុមារ ហើយលើកយោបល់ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ពិនិត្យសម្រេច។

➢ជូនដំណឹងអំពីនីតិវិធីសុំកូន និងការវិវឌ្ឍន៍នៃករណីសុំកូនទៅអាជ្ញាធរកណ្តាល ឬអាជ្ញាធរមាន សមត្ថកិច្ចនៃប្រទេសទទួល ឬទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាតពីប្រទេសទទួល។

➢រៀបចំពិធីប្រគល់កុមារឲ្យទៅអ្នកសុំ និងរៀបចំឯកសារដើម្បីឲ្យកុមារធ្វើដំណើរចូលទៅប្រទេសរបស់អ្នកសុំ។

➢ផ្តល់ ឬសម្របសម្រួលការផ្តល់សេវាក្រោយសុំកូនសមស្របដល់កុមារ គ្រួសារអ្នកសុំ និងគ្រួសារបង្កើត តាមការចាំបាច់។

➢ផ្តល់យោបល់ជូនគណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស ទាក់ទងនឹងការអនុញ្ញាត ឬដកហូតការអនុញ្ញាតដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេស ដែលធ្វើសហប្រតិបត្តិការសុំកូនអន្តរប្រទេស នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

➢អនុវត្តគោលការណ៍ណែនាំរបស់គណៈកម្មាធិការអាជ្ញាធរកណ្តាល ដើម្បីធ្វើអធិការកិច្ចលើកិច្ចសុំកូនអន្តរប្រទេស ។ គ្មានជនណាអាចរារាំង បង្អាក់ បំភិតបំភ័យ ឬជ្រៀតជ្រែកក្នុងការងារអធិការកិច្ចដែលបានធ្វើឡើងត្រឹមត្រូវតាមច្បាប់បានឡើយ។

➢លើកសំណើសុំការសម្រេចពីគណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស ដើម្បីចាត់វិធានការព្រមាន ដាក់កំហិត ឬផាកពិន័យចំពោះបុគ្គល ឬអង្គភាពដែលប្រព្រឹត្តល្មើសនឹងច្បាប់ ស្តីពីសុំកូនអន្តរប្រទេស ព្រមទាំងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមានផ្សេងៗទៀត។

➢ពិនិត្យឯកសារទាក់ទងនឹងសុំកូនអន្តរប្រទេស និងផ្តល់យោបល់សមស្របជូនប្រធានគណៈ កម្មាធិការ អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស និងជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ដើម្បីសម្រេច។

➢រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុរាល់ការប្រជុំរបស់គណៈកម្មាធិការ អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស។

➢គ្រប់គ្រងថវិកាចំណូលរបស់រដ្ឋបាលសុំកូនអន្តរប្រទេស រៀបចំធ្វើផែនការចំណាយ និងធ្វើរបាយការណ៍ហិរញ្ញវត្ថុស្តីពីស្ថានភាពប្រើប្រាស់ថវិកាជារៀងរាល់ខែ ត្រីមាស និងប្រចាំឆ្នាំជូនអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស។

➢រៀបចំផែនការ កម្មវិធី និងសកម្មភាពបណ្តុះបណ្តាលជំនាញដល់មន្ត្រី ធ្វើការងារសុំកូនអន្តរប្រទេស និងអ្នកពាក់ព័ន្ធផ្សេងទៀត។

➢ចាត់វិធានការសមស្របក្នុងការប្រមូល ថែរក្សា និងផ្លាស់ប្តូរពត៌មានស្តីពីស្ថានភាពកុមារ ពត៌មានដើមកំណើតកុមារ អត្តសញ្ញាណឪពុកម្តាយ និងប្រវត្តិសុខភាពកុមារ។

➢បំពេញភារកិច្ចចាំបាច់ផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេស ដោយអនុលោមតាមច្បាប់ និង បទប្បញ្ញត្តិផ្សេងៗទៀត តាមការប្រគល់ភារកិច្ចរបស់គណៈកម្មាធិការ អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស[42]។

**កថាខណ្ឌទី៣ អំពីទីភ្នាក់ងារសុំកូនអន្តរប្រទេស**

ទីភ្នាក់ងារ ដែលមានបំណងចង់ធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅកម្ពុជា ត្រូវមានការអនុញ្ញាតពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងពីស្ថាប័នមានសមត្ថកិច្ច នៃប្រទេសរបស់ទីភ្នាក់ងារស្របតាមច្បាប់ស្តីពីសុំកូនអន្តរប្រទេស។ មានន័យថា ទីភ្នាក់ងារសុំកូនអន្តរប្រទេសអាចដំណើរការទៅបាន លុះត្រាតែបំពេញលក្ខណសម្បត្តិនៅក្នុងច្បាប់ស្តីពីសុំកូនអន្តរប្រទេស ហើយដាក់ពាក្យសុំធ្វើប្រតិបត្តិការជាទីភ្នាក់ងារសុំកូនអន្តរប្រទេស និងប្រតិបត្តិការតាមការកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច។

**១. លក្ខណៈសម្បត្តិរបស់ទីភ្នាក់ងារសុំកូនអន្តរប្រទេស**

ដើម្បីសុំការអនុញ្ញាតធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅកម្ពុជា ទីភ្នាក់ងារនោះត្រូវមានលក្ខណសម្បត្តិ ដូចជាមានការបញ្ជាក់ទទួលស្គាល់ពីអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសរបស់ទីភ្នាក់ងារ ហើយបន្តអនុញ្ញាតឲ្យធ្វើប្រតិបត្តិការសុំកូនអន្តរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ទីភ្នាក់ងារផ្ទាល់ត្រូវមានអ្នកដឹងនាំ និងមានបុគ្គលិក ដែលមានសមត្ថភាពប្រកបដោយគុណធម៌ និងសីលធម៌ដែលបញ្ជាក់ដោយអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ច។ មិនស្វែងរកផលចំនេញ និងបានបំពេញនូវលក្ខខណ្ឌដែលមានចែងក្នុងបទប្បញ្ញត្តិច្បាប់ទាក់ទងនឹងនីតិបុគ្គលមិនយកចំនេញ ហើយក៏មិនមានបើកមណ្ឌលកុមារកំព្រាផងដែរ។

[42] ប្រការ២ នៃប្រកាសរបស់ក្រសួង ស អ យ លេខ១២៣០ ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០១៣

**២. ការដាក់ពាក្យសុំធ្វើប្រតិបត្តិការជាមួយទីភ្នាក់ងារសុំកូនអន្តរប្រទេស**

ការសុំការអនុញ្ញាតធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេស នៅក្នុងព្រះរាជាណាចក្រកម្ពុជាទីភ្នាក់ងារត្រូវមានសំណុំឯកសារដូចតទៅ៖

➢ ពាក្យស្នើសុំត្រូវចុះហត្ថលេខាដោយប្រធានទីភ្នាក់ងារ និងមានបទតែមសារពើពន្ធតម្លៃ ៥០០០ ( ប្រាំពាន់ ) រៀល។

➢ច្បាប់ចម្លងលិខិតអនុញ្ញាតឲ្យបើកទីភ្នាក់ងារ ដែលមានទិសដៅមិនស្វែងរកផលចំនេញដោយមានការបញ្ជាក់ត្រឹមត្រូវ និងច្បាប់ចម្លងលិខិតបញ្ជាក់ទទួលស្គាល់គុណវុឌ្ឍិរបស់ទីភ្នាក់ងារ (នៅមានសុពលភាព) ចេញដោយអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរស់ទីភ្នាក់ងារ។

➢លិខិតរបស់អាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់ទីភ្នាក់ងារ ដែលអនុញ្ញាតឲ្យទីភ្នាក់ងារធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេស នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

➢លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ទីភ្នាក់ងារ។

➢ឯកសារសង្ខេបអំពីប្រវត្តិ សកម្មភាព កម្មវិធី និងសេវារបស់ទីភ្នាក់ងារ បញ្ជីរាយនាមបុគ្គលិក និងលក្ខណសម្បត្តិរបស់បុគ្គលិកទាំងនោះ រួមទាងភស្តុតាងដែលបង្ហាញអំពីបទពិសោធន៍ក្នុងវិស័យសុំកូនអន្តរប្រទេសយ៉ាងតិច ០៥ (ប្រាំ) ឆ្នាំ។

➢របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំចុងក្រោយ ដែលបានធ្វើសវនកម្មឯករាជ្យរួមមានប្រភពមូលនិធិសោហ៊ុយសុំកូន និងថ្លៃចំណាយនានាទាក់ទងនឹងសុំកូនអន្តរប្រទេស។

➢ជីវប្រវត្តិសង្ខេបមានបិទរូបថតទំហំ ៤ស.មx៦ស.ម របស់សមាជិកក្រុមប្រឹក្សាភិបាល ឬ គណៈគ្រប់គ្រងទីភ្នាក់ងារ និងរូបថតរបស់បុគ្គលិកមួយនាក់ ឬពីរនាក់ដែលបានទទួលការអនុញ្ញាតឲ្យធ្វើជាអ្នកតំណាងទីភ្នាក់ងារលើការងារសុំកូនអន្តរប្រទេស នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

➢ច្បាប់ចម្លងឯកសារកិច្ចព្រមព្រៀងពីអតីតកាល ឬបច្ចុប្បន្នកាលជាមួយក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាស្តីពីការផ្តល់ជំនួយមនុស្សធម៌ ឬការជួយឧបត្ថម្ភដល់កុមារកំព្រានានានៅក្នុងព្រះរាជាណាចក្រកម្ពុជា។

➢ច្បាប់ចម្លងកិច្ចព្រមព្រៀងទ្វេភាគី ស្តីពីកិច្ចសហប្រតិបត្តិការសុំកូនអន្តរប្រទេសរវាងព្រះរាជាណាចក្រកម្ពុជា ( ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ) និងប្រទេសរបស់ទីភ្នាក់ងារប្រសិនបើប្រទេសនេះមិនមែនជាប្រទេសភាគីអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស[43]។

[43] ប្រការ៦ ប្រកាសរបស់ក្រសួង ស អ យ លេខ១៩៨០ ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ ២០១៤

**កថាខណ្ឌទី៤ អាជ្ញាធរផ្តល់ការអនុញ្ញាតឲ្យទីភ្នាក់ងារស្នុំកូនអន្តរប្រទេស**

ចំនួនទីភ្នាក់ងារមកពីប្រទេសទទួលនីមួយៗ ដែលអនុញ្ញាតឲ្យផ្តល់សេវានេះនៅកម្ពុជាត្រូវបានកំណត់ដោយកិច្ចព្រមព្រៀងរួមគ្នារវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាជាមួយនឹងអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទទួលនោះ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានិងស្ថាប័នមានសមត្ថកិច្ច នៃប្រទេសទទួល គឺជាសមត្ថកិច្ចក្នុងការអនុញ្ញាតឲ្យទីភ្នាក់ងារស្នុំកូនអន្តរប្រទេសមាន សិទ្ធិធ្វើប្រតិបត្តិការស្នុំកូនអន្តរប្រទេសនៅក្នុងប្រទេសកម្ពុជា។

ករណីមានបទប្បញ្ញត្តិពិសេសដូចមានចែងក្នុងច្បាប់នេះ។ ដូចនេះនីតិវិធីរបស់តុលាការគឺ ពិនិត្យទៅលើសំណុំឯកសារ និងធ្វើការសម្រេចសេចក្តីព្រមទាំងកំណត់អំពីការប្តឹងទាស់។

**កថាខណ្ឌទី៥ ទោសប្បញ្ញត្តិ**

ជាទូទៅទោសប្បញ្ញត្តិ តែងតែភ្ជាប់មកជាមួយច្បាប់ដែលរៀបចំសណ្តាប់ធ្នាប់នៅក្នុងសង្គម និងដើម្បីបង្កើននូវប្រសិទ្ធិភាព និងអានុភាពនៃច្បាប់នោះ។ ការធ្វើបែបនេះគឺសុទ្ធតែបង្ការ និង បញ្ចៀសនូវវិការៈណាមួយកើតក្នុងដំណើរការនៃច្បាប់។ ទោសប្បញ្ញត្តិ គឺទាមទារស្វែងរកនូវយុត្តិធម៌ និងព្រមានជៀសវាងអំពើផ្គាំផ្គងម្តង ហើយម្តងទៀត ព្រមទាំងធ្វើយ៉ាងណាដើម្បីឲ្យការអនុវត្តក្នុងដំណើរស្របទៅតាមច្បាប់ដែលចូលជាធរមាន។

ជាគោលការណ៍ នៅគ្រប់ករណីនៃបទល្មើសទាំងឡាយនឹងទទួលរងនូវទោសព្រហ្មទណ្ឌ ឬទោសរដ្ឋប្បវេណី ឬអាចទាំងទោសព្រហ្មទណ្ឌផង និងទោសរដ្ឋប្បវេណីផង និងសំណងរដ្ឋប្បវេណីផង ឬការប្រកាសនូវទោសផ្សេងៗទៀត អាស្រ័យទៅតាមស្ថានទម្ងន់របស់ជនល្មើស។

➢ទោសព្រហ្មទណ្ឌ៖ ទោសដាក់ពន្ធនាគារ

➢ទោសរដ្ឋប្បវេណី៖ ទោសពិន័យជាប្រាក់

➢ទោសដាក់ពន្ធនាគារផង និងទោសពិន័យជាប្រាក់ ហើយរួមទាំងការប្រកាសនូវទោសបន្ថែម[44]គឺ៖

- ការដកសិទ្ធិខ្លះជាពលរដ្ឋ សម្រាប់រយៈពេលយ៉ាងច្រើន៥ឆ្នាំ។
- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេលយ៉ាងច្រើន២ខែ[45]។
- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស នៅក្នុងទំព័រសារពត៌មាន។

---

[44] មាត្រា ៥៣ នៃក្រមព្រហ្មទណ្ឌ ២០០៩

[45] មាត្រា ៦៨ នៃក្រមព្រហ្មទណ្ឌ ២០០៩

•ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសតាមគ្រប់មធ្យោបាយ ទូគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ ថ្ងៃយ៉ាងច្រើន។

**១.ការពិន័យជាប្រាក់**

ដោយមិនទាន់គិតដល់ទោសប្បញ្ញត្តិ ដែលមានចែងនៅក្នុងច្បាប់ជាធរមានមាន ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចអាចព្យួរ ឬដកហូតការទទួលស្គាល់ ឬបដិសេធការទទួលស្គាល់ទីភ្នាក់ងារ សុំកូនអន្តរប្រទេសសាជាថ្មី ប្រសិនបើមានភស្តុតាងបង្ហាញឲ្យឃើញថា ទីភ្នាក់ងារសុំកូនអន្តរប្រទេស ជាប់ពាក់ព័ន្ធនឹងអំពើណាមួយដូចខាងក្រោមៈ

-អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ញុះញង់ដោយផ្ទាល់ឲ្យឪពុកម្តាយ ឬឪពុក ឬម្តាយបោះបង់ទារកដែលកើតហើយ ឬដែលនឹងកើត ដើម្បីឲ្យដឹងប្រគល់កូនតាមរយៈសុំកូនអន្តរប្រទេស។

-អំពើប្រព្រឹត្តក្នុងគោលដៅបង់បានកម្រៃ ធ្វើជាអន្តរការីរវាងប្តីប្រពន្ធ ដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និងឪពុកម្តាយ ឬឪពុក ឬម្តាយដែលចង់បោះបង់កូនដែលកើតមកហើយ ឬដែលនឹងកើត ។

-អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ធ្វើជាអន្តរការីរវាងប្តីប្រពន្ធ ដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និងស្ត្រីម្នាក់យល់ព្រមពពោះ ដើម្បនឹងប្រគល់កូននោះទៅឲ្យអ្នកសុំ។

-អំពើក្លែងបន្លំ ឬសមគំនិតក្លែងបន្លំស្ថានភាពលំបាកបំផុត ដើម្បីទទួលបានការយល់ព្រមពី ឪពុកម្តាយបង្កើត ឬឪពុកបង្កើត ឬម្តាយបង្កើត ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ។

-អំពើរៀបចំឲ្យមានការយល់ព្រមរបស់ឪពុកម្តាយ ឬឪពុក ឬម្តាយ ឬរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារដោយការបង្ខិតបង្ខំ ការគំរាមគំហែង ការឆបោក ឬការបញ្ចុះបញ្ចូលតាមរយៈការផ្តល់ ឬសន្យាផ្តល់ប្រាក់រង្វាន់ សំណង ឬផលប្រយោជន៍ណាមួយ។

-ការបញ្ចេញសំណុំឯកសារ និងកំណត់ហេតុទាំងអស់ ឬមួយផ្នែកទាក់ទងនឹងករណីសុំកូនអន្តរប្រទេសជាក់លាក់ណាមួយ ដោយគ្មានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ឬតុលាការមានសមត្ថកិច្ច។

-ការបង្គាប់ ឬការទទួលដោយផ្ទាល់ ឬដោយប្រយោល នូវថ្នូរប្រាក់កាស ទំនិញ ឬសេវាដោះដូរនឹងការបម្រុងទុកកុមារណាមួយសម្រាប់សុំកូន។

-ការផ្តល់ប្រាក់កាស ទំនិញ ឬសេវាទៅឲ្យមន្ត្រី ឬអ្នកតំណាងណាមួយនៃរដ្ឋបាលសុំកូនអន្តរប្រទេស ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អាជ្ញាធរកណ្តាលទទួលខុសត្រូវកិច្ចការសុំកូន

អន្តរប្រទេស ឬមន្ត្រីពាក់ព័ន្ធផ្សេងទៀត ដើម្បីឲ្យផ្តល់នូវសិទ្ធិជាអាទិ៍ភាពនៅក្នុងនីតិវិធីសុំកូនអន្តរប្រទេសដល់អ្នកសុំ។

-ការផ្សាយពាណិជ្ជកម្ម ឬការបោះពុម្ពផ្សាយនូវអត្តសញ្ញាណ ឬរូបថតរបស់កុមារណាមួយដែលជាកម្មវត្ថុសុំកូន ក្នុងគោលបំណងបញ្ចុះបញ្ចូលបុគ្គលណាមួយឲ្យដាក់ពាក្យសុំកូន។

-ការតែងតាំង ឬចាត់តាំងអ្នកតំណាងណាមួយដោយមិនមានការឯកភាពពីក្រសួងទទួលបន្ទុក វិស័យសង្គមកិច្ច។

-ការចូលរួមក្នុងការរៀបចំការផ្គូរផ្គង ឬការទាក់ទងគ្នារវាងអ្នកសុំ និងឪពុកម្តាយបង្កើត ឬឪពុកបង្កើត ឬម្តាយបង្កើត ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារក្នុងគោលបំណងកំណត់ទុកជាមុននូវកុមារណាមួយដែលនឹងត្រូវសុំ។

-ការរំលោភបំពានដល់បទប្បញ្ញត្តិនៃច្បាប់នេះ បទដ្ឋានអប្បបរមានៃការថែទាំជំនួសចំពោះកុមារ និងបទប្បញ្ញត្តិផ្សេងទៀតជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា[46]។

គ្មាននរណាម្នាក់អាចទាញយកផលកម្រៃផ្នែកហិរញ្ញវត្ថុ ឬផលកម្រៃដទៃទៀតពីសុំកូនអន្តរប្រទេសនោះទេ សូម្បីតែនាយកអភិបាល និងនិយោជិតនៃអង្គការដែលពាក់ព័ន្ធក្នុងរឿងសុំកូនមិន ត្រូវទទួលលាភ ដែលខ្ពស់មិនសមរម្យទាក់ទងនឹងសេវាកម្មដែលខ្លួនបានផ្តល់ទេ គឺមានតែសោហ៊ុយ និងប្រាក់ចំណាយ រួមមានប្រាក់ឈ្នួលវិជ្ជាជីវៈសមរម្យរបស់ជន ដែលពាក់ព័ន្ធក្នុងរឿងសុំកូនប៉ុណ្ណោះ ទើបអាចយកបាន ឬចំណាយបាន[47]។

ទីភ្នាក់ងារដែលធ្វើប្រតិបត្តិការក្នុងដំណើរការសុំកូនអន្តរប្រទេស នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវតែជាភ្នាក់ងារ ដែលបានទទួលការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចនៃ ព្រះរាជាណាចក្រកម្ពុជា និងពីស្ថាប័នមានសមត្ថកិច្ច នៃប្រទេសទទួលព្រមទាំងមានទិសដៅមិន ស្វែងរកផលចំនេញ និងបានបំពេញនូវលក្ខខណ្ឌដែលមានចែងក្នុងបទប្បញ្ញត្តិច្បាប់ ដែលទាក់ ទងនឹងនីតិបុគ្គលមិនយកចំនេញ សមាគមន៍ ឬអង្គការក្រៅរាជរដ្ឋាភិបាល ឬបទប្បញ្ញត្តិពាក់ព័ន្ធ ផ្សេងទៀតទាក់ទងនឹងលក្ខណៈនៃទីភ្នាក់ងារនេះ។ បើមិនដូច្នេះទេ ទីភ្នាក់ងារនោះត្រូវពិន័យជា អន្តរការណ៍ជាប្រាក់ពី ១.០០០.០០០(មួយលាន)រៀល ទៅ១០.០០០.០០០(ដប់លាន)រៀល។ ការ ដាក់ពិន័យអន្តរការណ៍ ជាសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច។ ប្រាក់ពិន័យអន្តរ ការណ៍

[46] មាត្រា ៥៩ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ២០០៩

[47] មាត្រា ៣២នៃអនុសញ្ញាទីក្រុងឡាអេស្តីពីការការពារកុមារ និង សហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស ១៩៩៣

នេះ ត្រូវបង់ចូលក្នុងមូលនិធិសម្រាប់ទ្រទ្រង់វិស័យសុខុមាលភាពកុមារ[48]។ ក្នុងករណី ទីភ្នាក់ងារ មិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍នេះទេ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចអាចបញ្ជូនសំណុំរឿង ទៅតុលាការ។

**២.ការពិន័យព្រហ្មទណ្ឌ**

នៅក្នុងច្បាប់ស្តីពីការបង្ក្រាប់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានចូលជាធរមាននៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ក៏បានចែងនូវទោសប្បញ្ញត្តិ មួយចំនួនផងដែរ ទៅលើទង្វើដែលមិនស្របច្បាប់ទាក់ទងទៅនឹងសុំកូនអន្តរប្រទេសចំពោះការនាំ ចេញដោយមិនស្របច្បាប់សម្រាប់ឆ្លងដែន និងអំពើលក់ - ដូរមនុស្សសម្រាប់ឆ្លងដែនជាដើម។ ច្បាប់នេះមានអានុភាពអនុវត្តទៅលើបទល្មើស ដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងព្រះរាជាណាចក្រ កម្ពុជា ឬប្រព្រឹត្តឡើងនៅក្រៅដែនដីដោយពលរដ្ឋខ្មែរ ឬប្រព្រឹត្តឡើងនៅក្រៅដោយជនបរទេស ហើយជនរងគ្រោះ គឺជាពលរដ្ឋខ្មែរនៅពេលដែលបទល្មើសកើតឡើង។

ការនាំយកចេញដោយមិនស្របច្បាប់មានន័យថា៖

-ការធ្វើឲ្យមនុស្សម្នាក់ផ្លាស់ទីពីទីកន្លែងមួយ ដែលគេកំពុងរស់នៅទៅកាន់ទីកន្លែងដទៃ ដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ខ្លួន ឬរបស់តតិយជនតាមមធ្យោបាយបង្ខិតបង្ខំគម្រាមគំហែង បោកបញ្ឆោតបំពានដោយអំណាច ឬលួងលោម។

-ការនាំយកអនីតិជន ឬជនដែលនៅក្រោមអាណាព្យាបាលទូទៅ ឬនៅក្រោមហិតូបត្ថម្ភ ឬនៅក្រោមអ្នកគ្រប់គ្រងស្របច្បាប់ ដោយគ្មានអំណាចតាមផ្លូវច្បាប់ ឬយុត្តិកម្មតាមផ្លូវច្បាប់ចេញ ពីការគ្រប់គ្រងស្របច្បាប់នៃឪពុកម្តាយ អ្នកថែរក្សា ឬអ្នកអាណាព្យាបាលរបស់គេ[49] ។

ចំពោះអំពើលក់-ដូរមនុស្ស មានន័យថា ការប្រគល់ឲ្យដោយខុសច្បាប់ នូវការគ្រប់គ្រងលើជនណាម្នាក់ទៅជនដទៃ ឬទទួលយកដោយខុសច្បាប់ នូវការប្រគល់ការគ្រប់គ្រងលើជនណាម្នាក់ពីជនដទៃ ដោយដោះដូរទៅនឹងរបស់មានតម្លៃអ្វីមួយ ដោយរាប់បញ្ចូលទាំងសេវា និងមនុស្សផង។ អំពើធ្វើជាភ្នាក់ងារកណ្តាលនៃការលក់-ដូរមនុស្ស ត្រូវផ្តន្ទាទោសដូចគ្នានឹងចារីដែរ[50]។

ចំពោះជនដែលយកជនដទៃ ដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន ឬធ្វើការលក់-ដូរជនដទៃក្នុងគោលដៅប្រគល់ ឬនាំយកទៅក្រៅព្រះរាជាណាចក្រកម្ពុជា ដើម្បីស្វែងរកប្រយោជន៍

[48] មាត្រា ៥៥ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ២០០៩

[49] មាត្រា ៨ នៃច្បាប់ស្តីពីការបង្ក្រាអំពីជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ

[50] មាត្រា ១៣ នៃច្បាប់ស្តីពីការបង្ក្រាអំពីជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ

ឈ្លានពានខាងផ្លូវភេទ ផលិតរូបភាពអាសអាភាស ដែលផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះសុំកូន ឬទម្រង់ណាមួយនៃការកេងប្រវ័ញ្ចផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ឆ្នាំ ដល់១៥ឆ្នាំ។

ជាពិសេសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ឆ្នាំ ដល់២០ឆ្នាំ ក្នុងករណីៈ

-ជនរងគ្រោះជាអនីតិជន

-អំពើល្មើសប្រព្រឹត្តឡើងដោយមន្ត្រីសាធារណៈ ដែលបំពានដោយអំណាចរបស់ខ្លួន

-អំពើល្មើសប្រព្រឹត្តឡើង ដោយក្រុមមានការចាត់តាំង[51]។

## ផ្នែកទី៣ នីតិវិធីនៃការបង្កើតសុំកូនអន្តរប្រទេស

### កថាខណ្ឌទី១ បែបបទនៃការបង្កើតសុំកូនអន្តរប្រទេស

សុំកូនអន្តរប្រទេស សាមីសុំត្រូវបំពេញទម្រង់ទៅតាមបទបញ្ញាត្តិច្បាប់ស្តីពីសុំកូនអន្តរប្រទេស។

អ្នកសុំត្រូវដាក់ពាក្យសុំទៅអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស និងដោយមានការអនុញ្ញាតអោយកូនសុំនោះចូលទៅរស់នៅជាអចិន្ត្រៃយ៍នៃប្រទេសសាមីសុំ។

#### ១.ការដាក់ពាក្យ

ការដាក់ពាក្យសុំកុមារមកជាកូនចិញ្ចឹម គឺដើម្បីទទួលបានសិទ្ធនិងករណីកិច្ចក្នុងការថែទាំកុមារជំនួសឪពុកម្តាយបង្កើតឬអាណាព្យាបាលលើកុមារដែលងាយរងគ្រោះ ឬកុមារដែលត្រូវបោះបង់ចោល។ ប្តីប្រពន្ធដែលដាក់ពាក្យសុំអន្តរប្រទេស ទោះបីជាសាច់ញាតិឬមិនមែនជាសាច់ញាតិនៃកូនសុំគឺមានសិទ្ធស្នើសុំកុមារជាកូនចិញ្ចឹមរបស់ខ្លួនបាន។

ពាក្យសុំត្រូវបញ្ជូនមកក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិតាមរយៈអាជ្ញាធរកណ្តាល ស្ថានទូត ឬ ស្ថានតំណាងនៃប្រទេសទទួលប្រចាំនៅព្រះរាជាណាចក្រកម្ពុជាដែលបានបញ្ជាក់ពីភាពត្រឹមត្រូវនៃឯកសារទាំងនោះ។

ក្នុងរយៈពេល១៥ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីទទួលបានឯកសារស្នើសុំ ក្រសួងការបរទេស និងការសហប្រតិបត្តិការអន្តរជាតិត្រូវ ពិនិត្យផ្តល់យោបល់នឹងត្រូវបញ្ជូនទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ហើយក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចបន្ទាប់ពីបានទទួលឯកសារពីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិក្នុងរយៈពេលយ៉ាងយូរបំផុត១៥ថ្ងៃនៃថ្ងៃធ្វើការរដ្ឋបានសុំកូនអន្តរប្រទេសត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរទៅអ្នកមានសុំកូនដោយបញ្ជាក់ថាខ្លួនបានទទួលពាក្យសុំកូននេះតាមរយៈអាជ្ញាធរកណ្តាលនៃប្រទេសដើមរបស់អ្នកសុំ ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសឬតាមរយៈទីភ្នាក់ងារសុំកូនអន្តរប្រទេស នៃប្រទេសលំនៅឋានអ

[51] មាត្រា ១១ និង មាត្រា ១៦ នៃច្បាប់ស្តីពីការបង្ក្រាអំពីជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ

ចិន្ត្រៃយ៍ (សំដៅដល់ប្រទេសដែលជនណាមួយកំពុងរស់នៅដោយមានបំណង យកប្រទេសនោះធ្វើជាលំនៅឋានអចិន្ត្រៃយ៍នៅក្នុងប្រទេសនោះ)[52]។

អ្នកសុំត្រូវដាក់ពាក្យសុំទៅអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស នៃព្រះរាជាណាចក្រកម្ពុជា ដោយភ្ជាប់មកជាមួយចំនួនដូចដែលមានចែងក្នុងច្បាប់ ហើយដែលឯកសារទាំងនោះត្រូវបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំ។ ឯកសារច្បាប់ដើមទាំងអស់ត្រូវភ្ជាប់មកជាមួយនូវការបកប្រែជាភាសារអង់គ្លេស ឬភាសាបារាំងមានបញ្ជាក់ត្រឹមត្រូវ[53]។

រាល់កុមារដែលជាកម្មវត្ថុនៃការសុំគឺ កុមារដែលមានសញ្ជាតិខ្មែរ ហើយកំពុងរស់នៅជាអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា[54] និង មានអត្តសញ្ញាណភាព សារតាជាតិ បរិយាកាសសង្គមរបស់កុមារ ប្រវត្តិសុខភាព ប្រវត្តិគ្រួសារ និងសេចក្តីត្រូវការរបស់កុមារ អាចសុំជាកូនចិញ្ចឹមបាន។ ប៉ុន្តែក្នុងករណីដែលកុមារនោះត្រូវគេបោះបង់ចោលក៏អាចក្លាយជាកម្មវត្ថុ នៃការសុំកូនអន្តរប្រទេសបានដែរ[55]។

អ្នកសុំត្រូវបង់ប្រាក់ចំណាយសោហ៊ុយ និងវិភាគទាននានាសម្រាប់ជួយឧបត្ថម្ភដល់ជម្រើសនានា នៃការថែទាំជំនួស និងការឧបត្ថម្ភទៅដល់កុមារកំព្រារបស់រដ្ឋទូទាំងប្រទេសនិងកម្រៃសេវាចាំបាច់ផ្សេងៗ ទាក់ទងទៅនឹងសុំកូនអន្តរប្រទេសដែលនឹងកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច[56]។

**២.ការពិនិត្យពាក្យសុំ**

ក្រោយពីបានទទួលពាក្យសុំ រដ្ឋបាលសុំកូនអន្តរប្រទេសដែលជាសេនាធិការរបស់អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច [57] ត្រូវត្រួតពិនិត្យលើពាក្យសុំកូនអន្តរប្រទេស។

រដ្ឋបាលសុំកូនអន្តរប្រទេសមានតួនាទីត្រួតពិនិត្យពីលក្ខណៈគ្រប់គ្រាន់ និងភាពត្រឹមត្រូវនៃសំណុំលិខិតស្នើរសុំក្នុងរយៈពេល ៦០( ហុកសិប) ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីថ្ងៃដែលក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចទទួលសំណុំលិខិតសុំកូននោះ។ ក្នុងករណីការពិនិត្យលើសំណុំឯកសាររបស់

[52] មាត្រា ២៤ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩
[53] មាត្រា ២៣ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩
[54] មាត្រា ៣ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

[55] មាត្រា ២២ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩
[56] មាត្រា ២៥ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩
[57] មាត្រា ២៦ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

អ្នកសុំមិនទាន់គ្រប់គ្រង ឬមិនត្រឹមត្រូវរដ្ឋបាលសុំកូនអន្តរប្រទេសត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីឯកសារដែលនៅខ្វះ ឬ មិនទាន់គ្រប់គ្រាន់តាមរយៈអាជ្ញាធរកណ្ដាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសត្រូវត្រួតពិនិត្យឯកសារដែលស្នើរសុំអោយកែតម្រូវនោះដូចគ្នានឹងរយៈពេលខាងលើដែរ។ ប៉ុន្តែការស្នើសុំនេះត្រូវទុកជាមោឃៈករណីដែលអ្នកសុំខកខានផ្តល់នូវឯកសារដែលខ្វះ ឬមិនទាន់ត្រឹមត្រូវក្នុងរយៈពល៦០ (ហុកសិប) ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃរដ្ឋបាល សុំកូនអន្តរប្រទេសបានជូនដំណឹងអំពីឯកសារដែលមិនគ្រប់គ្រាន់ឬមិនត្រឹមត្រូវហើយការបដិសេធ នេះក្រសួងទទួលបន្ទុកសង្គមកិច្ចត្រូវបញ្ជាក់អំពីមូលហេតុជាលាយលក្ខណ៍អក្សរ[58]។

**៣.ការសម្រេចលើពាក្យសុំ**

ក្រោយពីបានពិនិត្យលើសំណុំលិខិតឃើញថា មានភាពត្រឹមត្រូវទៅតាមល័ក្ខខ័ណ្ឌ នៃច្បាប់រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវពិនិត្យពិចារណាទៅលើសំណុំឯកសាររបស់កុមារទាំងឡាយដែលមានលក្ខណៈសម្បត្តិសម្រាប់សុំកូនអន្តរប្រទេសបាន និងផ្ទួរផ្គង់លក្ខណៈសម្បត្តិដែលត្រូវគ្នាល្អបំផុតរវាងអ្នកសុំនិងកុមារដែលត្រូវសុំទាំងឡាយ ដោយត្រូវគិតគូរដល់ឧត្តមប្រយោជន៍របស់កុមារ អត្ថប្រយោជន៍នៃការបន្តអោយមានការបីបាច់ថែរក្សាកុមារ សាវតា ជាតិពន្ធុ សាសនា និងវប្បធម៌របស់កុមារ [59]។

បន្ទាប់ពីធ្វើការផ្ទួរផ្គង់ពីលក្ខណៈសម្បត្តិនៃភាគីសុំកូន និងកូនសុំ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវផ្ញើរសំណុំឯកសាររបស់កុមារនោះទៅអាជ្ញាធរកណ្ដាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬទីភ្នាក់ងារសុំកូនអន្តរប្រទសនៃប្រទេសដើម្បីពិនិត្យនិងបញ្ជូនទៅអ្នកសុំដោយមិនចាំបាច់ជូនដំណឹងអំពីអត្តសញ្ញាណរបស់ឪពុកម្ដាយ ឬឪពុក ឬម្ដាយ ឬអ្នកអាណាព្យាបាលសម្រាប់ អនីតិជនឡើយលើកលែងតែករណីសុំកូនដោយសាច់ញាតិ[60]។

នៅពេលដែលបានទទួលឯកសាររបស់កុមារដែលជាកូនសុំនោះ ពីរដ្ឋបាលសុំកូនអន្តរប្រទេសអ្នកសុំត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរអមពីការយល់ព្រមរបស់ខ្លួនក្នុងការទទួលយកកុមារនោះទៅរដ្ឋបាលសុំកូនអន្តរប្រទេសវិញ។ ប៉ុន្តែក្នុងករណីដែលអ្នកសុំមិនឆ្លើយតបទៅរដ្ឋបាលសុំកូនអន្តរប្រទេសក្នុងរយៈពេល ៦០ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលបានផ្ញើរឯកសារមកសាមីសុំនោះរដ្ឋបាលសុំកូនអន្តរប្រទេសអាចចាត់ទុកថា អ្នកសុំបានបញ្ឈប់ពាក្យសុំរបស់ខ្លួន។ បើអ្នកសុំធ្វើ

[58] មាត្រា ២៤ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

[59] មាត្រា ២៧ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

[60] មាត្រា ២៨ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

ការឆ្លើយតបថាមិនទទួលយកកុមារដែលបានផ្គូរផ្គងអោយខ្លួននោះទេ អ្នកសុំអាចស្នើរសុំអោយរដ្ឋបាលសុំកូនអន្តរប្រទេសផ្គូរផ្គងកុមារជាលើកទី២បាន។ អ្នកសុំនៅពេលដែលបានទទួលសំណុំឯកសារ ពីរដ្ឋបាលសុំកូនអន្តរប្រទេសហើយមិនបានធ្វើការឆ្លើយតបក្នុងរយៈពេលកំណត់ខាងលើអ្នកសុំអាចដាក់ពាក្យសុំសាជាថ្មីបាន ហើយការសម្រេចអំពីការសុំអោយមានការផ្គូរផ្គងសារជាថ្មី ឬការទទួលពាក្យសុំសារជាថ្មី រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវពិចារណាអំពីមូលហេតុដែលអ្នកសុំខកខានមិនបានឆ្លើយតប ឬឆ្លើយតបថាមិនមានបំណងសុំកុមារដែលបានផ្គូរផ្គងលើកមិនចំណែកប្រាក់ចំណាយលើសោហ៊ុយ និងការវិភាគទានក្នុងការដាក់ពាក្យសុំមិនត្រូវបានផ្តល់ជូនអ្នកសុំវិញឡើយ[61]។

នៅពេលដែលមានការសម្រេចតាមការស្នើរសុំរបស់សាមីជន រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវរៀបបំអោយមានការជួបគ្នារវាងអ្នកសុំ និងកូនសុំកូនក្នុងរយៈពេល៦០ ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីកាលបរិច្ឆេទ ទទួលការយល់ព្រមពីអ្នកសុំ ប៉ុន្តែក្នុងករណីអ្នកសុំមិនបានមកតាមកាលបរិច្ឆេទខាងលើដោយគ្មានមូល ហេតុត្រឹមត្រូវរដ្ឋបាលសុំកូនអន្តរប្រទេសត្រូវចាត់ទុកថាអ្នកសុំបានបញ្ឈប់ពាក្យសុំរបស់ខ្លួន។ មុនមានការជួបគ្នារវាងអ្នកសុំនិងកូនសុំ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវធ្វើការសំភាសន៍អ្នកសុំ និងត្រូវធានាថា អ្នកសុំនិងកុមារបានរៀបចំខ្លួនជាស្រេចតាមរយៈការពិគ្រោះយោបល់ការផ្លាស់ប្តូរពត៌មានការផ្លាស់ប្តូរ រូបថត និងវិធានការណ៍ផ្សេងៗ ទៀតដើម្បីការជួបគ្នានេះ[62]។

រដ្ឋបាលសុំកូន អន្តរប្រទេសត្រួតពិនិត្យលើលក្ខណៈវិនិច័យ និងល័ក្ខខ័ណ្ឌនៃការសុំរបស់អ្នកសុំនិងកូនសុំ ហើយការសុំនោះពិតជាឆ្លើយតបទៅនឹងឧត្តមប្រយោជន៍របស់កុមារនោះក្នុងរយៈពេល៧ថ្ងៃ នៃថ្ងៃធ្វើការត្រូវផ្តល់មតិជាវិមានបន្ទាប់ពីការជួបគ្នា ។ហើយត្រូវដាក់សំនុំលិខិតទាំងនោះជូនរដ្ឋបមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីពិនិត្យនិងផ្តល់អនុសាសន៍លើដំណើរការសុំកូន [63]។ក្រោយពីបានពិនិត្យ និងផ្តល់អនុសាសន៍របស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចរួចមកអ្នកសុំត្រូវសហការជាមួយអាជ្ញាធរកណ្តាល នៃប្រទេសទទួលឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬទីភ្នាក់ងារសុំកូនអន្តរប្រទេសដាក់ពាក្យសុំកូនដែលបានផ្គូរផ្គងរួចតាមរយៈរដ្ឋបាលសុំកូនអន្តរប្រទេសទៅសាលាដំបូងរាជធានីភ្នំពេញ។ប៉ុន្តែក្នុងករណីអ្នកសុំទទួលបាននូវអនុសាសន៍ពីរដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច ហើយមិនបានដាក់ពាក្យសុំមកសាលាដំបូងរាជធានី

[61] មាត្រា ២៨ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

[62] មាត្រា ៣០ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

[63] មាត្រា ៣២ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

ភ្នំពេញក្នុងរយៈពេល៦០ (ហុកសិប) ថ្ងៃនៃថ្ងៃធ្វើការនោះត្រូវបាមចាត់ទុកថាអ្នកសុំបានបញ្ឈប់ពាក្យសុំដោយខ្លួនឯង[64]។

**កថាខណ្ឌទី២ ការស្នើសុំសេចក្តីសម្រេចបង្កើតសុំកូនអន្តរប្រទេស**

បន្ទាប់បានទទួលការយល់ព្រមលើការសុំកូនអន្តរប្រទេស តាមរយៈរដ្ឋបាលសុំកូនអន្តរប្រទេសត្រូវបញ្ជូនពាក្យសុំទៅសាលាដំបូងរាជធានីភ្នំពេញក្នុងរយៈ ៧ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីកាលបរិច្ឆេទទទួលពាក្យសុំរបស់អ្នកសុំ ដោយភ្ជាប់មកជាមួយសំណុំឯកសាររបស់កុមារ និងអ្នកសុំព្រមទាំងអនុសាសន៍របស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ចដើម្បីសុំដីការសម្រេចលើពាក្យសុំ [65]។

សុំកូនអន្តរប្រទេសអាចបង្កើតសុំកូនបានលុះត្រាការសុំកូនពេញលេញ ហើយកើតឡើងតាមសេចក្តីសម្រេចរបស់តុលាការ [66]។

**១.ស្ថាប័នអនុវត្ត**

សាលាដំបូងរាជធានីភ្នំពេញ មានយុត្តាធិការលើរឿងក្តីសុំកូនអន្តរប្រទេស [67]។

រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវជូនដំណឹងអំពីការប្រព្រឹត្តទៅនៃនីតិវិធីសុំកូន វិធានការដែលអាជ្ញាធរមានសមត្ថកិច្ចចាត់ការនិងការវិត្តន៍ នៃសុំកូននៅគ្រប់ដំណាក់កាលរបស់នីតិវិធីសុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាត[68]។

ក្រោយពីដីការចម្រេចរបស់តុលាការចូលជាស្ថាពរក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចត្រូវជូនដំណឹងទៅក្រសួងការបរទេស និងសហប្រតិបត្តិការអំពីដីការសម្រេចនេះ។

នៅពេលដែលនីតិវិធីសុំកូនអន្តរប្រទេស ត្រូវបានបញ្ចប់ដោយអនុលោមទៅតាមអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេសក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចត្រូវចេញលិខិតបញ្ជាក់អនុលោមតាមមាត្រា ២៣នៃអនុសញ្ញានេះ[69] ។

រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវរៀបចំពិធីប្រគល់កុមារ និងលិខិតបញ្ជាក់ស្តីពីការប្រគល់កូនជាផ្លូវការទៅអ្នកសុំ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវជួយសម្របសម្រួលជាមួយអាជ្ញាធរមានសមត្ថកិច្ចក្នុងការរៀបចំនិងការផ្តល់លិខិតឆ្លងដែន ទិដ្ឋាការ និងឯកសារចាំបាច់នានាដើម្បីអោយកុមារធ្វើ

[64] មាត្រា ៣៣ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

[65] មាត្រា ៣៣ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

[66] មាត្រា ១០០៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[67] មាត្រា ៣៤ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

[68] មាត្រា ៤៣ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

[69] មាត្រា ៤៤ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

ដំណើរចូលទៅប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំ។ ការធ្វើដំណើររបស់កុមារទៅកាន់ប្រទេសទទួលត្រូវអមដំណើរ។

រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវធានាថា ការបញ្ជូនកុមារទៅកាន់ប្រទេសទទួលត្រូវធានាថា ការបញ្ជូនកុមារទៅកាន់ប្រទេសទទួលប្រព្រឹត្តទៅក្នុងកាលៈទេសៈមានសុវត្ថិភាព ដោយមានការគិតគូរដល់សេចក្តីត្រូវការនានារបស់កុមារ។ ម្យ៉ាងវិញទៀតរដ្ឋបាលសុំកូនអន្តរប្រទេសត្រូវសម្របសម្រួលជាមួយអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ច ទទួលបន្ទុកសុំកូនអន្តរប្រទេស ឬទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃ ប្រទេសទទួលដើម្បីផ្តល់ឬសម្របសម្រួលដល់កុមារគ្រួសារចិញ្ចឹម មឹងគ្រួសារចិញ្ចឹមបង្កើតតាមការចាំបាច់[70]។

**២.ការពិនិត្យភស្តុតាង**

ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចត្រូវដាក់សំណុំឯកសារ និងរបាយការណ៍ជូនតុលាការ ដែលសារទាំងនោះ ជាភស្តុតាងនៃអង្គហេតុពិតទាក់ទងនឹងលក្ខណៈសម្បត្តិសុំកូនរបស់កុមារនិងភាពសមស្របសម្រាប់សុំកូនរបស់អ្នកសុំ។ ក្នុងករណីចាំបាច់តុលាការអាចបង្គាប់អោយតំណាងរដ្ឋបាលសុំកូនអន្តរប្រទេសមកបំភ្លឺបន្ថែមអំពីលទ្ធផលស្រាវជ្រាវ និងអនុសាសន៍របស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ចទាក់ទងនឹងសុំកូនអន្តរប្រទេសរួមទាំងឯកសាររបាយការណ៍ ការផ្សព្វផ្សាយសេចក្តីជូនដំណឹង និងភស្តុតាងជាឯកសារពាក់ព័ន្ធដែលគាំទ្រដល់លទ្ធផលនៃការស្រាវជ្រាវ[71]។

**តុលាការត្រូវពិនិត្យផ្ទៀងផ្ទាត់ថា៖**

- លក្ខណៈវិនិច្ឆ័យ ឬ លក្ខខណ្ឌទាំងអស់នៃសុំកូនអន្តរប្រទេសត្រូវបានបំពេញ។
- ការពិគ្រោះយោបល់ជាចាំបាច់ត្រូវបានធ្វើមុននឹងការផ្តល់យល់ព្រម។
- ការយល់ព្រមចាំបាច់នានាត្រូវបានផ្តល់ ដោយគោរពតាមខ្លឹមសារផ្នែកទី២ ជំពូកទី៤ នៃច្បាប់សុំកូនអន្តរប្រទេស។
- មានការពិចារនាត្រឹមត្រូវលើគ្រប់លទ្ធភាព ក្នុងការទុកដាក់កុមារក្នុងព្រះរាជាណាចក្រកម្ពុជា។
- អាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ច ឬទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលបានសុំការអនុញ្ញាតនៃប្រទេសទទួលយល់ព្រមលើការទុកដាក់របស់កុមារ។
- កុមារនឹងត្រូវអនុញ្ញាតអោយចូលទៅរស់នៅជាអចិន្ត្រៃយ៍នៅក្នុងប្រទេស។

[70] មាត្រា ៨៥ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

[71] មាត្រា ៣៦ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

- ស្មុំកូនអន្តរប្រទេស ពិតជាឧត្តមប្រយោជន៍របស់កុមារ[72]។

ក្នុងករណីមានភាពចាំបាច់ ដាច់ខាតត្រូវបំភ្លឺអង្គហេតុពាក់ព័ន្ធតុលាការអាចអញ្ជើញអ្នកសុំ ឬអ្នកមានអំណាចមេបាម្ខាង ឬអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ អ្នកតំណាងទីភ្នាក់ងារស្មុំកូនអន្តរប្រទេសពាក់ព័ន្ធនិងសាក្សីផ្សេងទៀត ដើម្បីផ្តល់ភស្តុតាងជាលាយលក្ខអក្សរឬដោយផ្ទាល់មាត់ទាក់ទងនឹងអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុ[73]។

បុគ្គលដែលមានសិទ្ធិ ឬផលប្រយោជន៍របស់ខ្លួនត្រូវបានបំពានដោយដីកាសម្រេចលើពាក្យស្មុំកូនអន្តរប្រទេសអាចប្តឹងជំទាស់ទៅសាលាឧទ្ធរណ៍ចំពោះដីកាសម្រេចនោះបាន។

ក្នុងករណីដែលបុគ្គលអាចប្តឹងជាទាស់ មិនជាជនដែលត្រូវទទួលបានការជូនដំណឹងពីដីកាសម្រេចខាងលើបណ្តឹងជំទាស់ត្រូវធ្វើឡើងក្នុងកំឡុងពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការគិតពីថ្ងៃដែលទទួលបានការជូនដំណឹងអំពីដីកាសម្រេច។

ក្នុងកំឡុងពេល ១៥ ថ្ងៃ នៃថ្ងៃធ្វើការដែលបានកំណត់ក្នុងកថាខណ្ឌទី២ និងទី៣ខាងលើមិនអាចពន្យាបានឡើយ។

សាលាឧទ្ធរណ៍លើកយកពាក្យបណ្តឹងជំទាស់នោះមកវិនិច្ឆ័យ និងចេញដីកាសម្រេចក្នុងរយះពេល៣០ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីទទួលបានពាក្យបណ្តឹងជំទាស់។

ដីកាសម្រេចរបស់សាលាឧទ្ធរណ៍លើបណ្តឹងជំទាស់ មិនអាចប្តឹងជំទាស់បានឡើយ[74]។

ដើម្បីទ្រទ្រង់សោហ៊ុយក្នុងការពិនិត្យភស្តុតាងអ្នកស្នើរសុំត្រូវបង់ប្រាក់ជាមុនសរុបចំនួន ១០០០០០០(មួយលានរៀល )រៀលតាមការបង្គាប់របស់តុលាការ។ ប៉ុន្តែបើសោហ៊ុយនោះចាំបាច់លើសពីទឹកប្រាក់ខាងលើ តុលាការអាចកំណត់ចំនួនសោហ៊ុយបន្ថែម និងបង្គាប់អោយអ្នកសុំបង់សោហ៊ុយបន្ថែមជាមុន ទឹកប្រាក់នេះមិនអាចបង្វិលជូនវិញបានទេ[75]។

### ៣. ដីកាសម្រេច

ការសម្រេចសេចក្តីស្តីពីការស្មុំកូនអន្តរប្រទេសរបស់តុលាការ មិនចាំបាច់ឆ្លងកាត់ការទាញហេតុផលផ្ទាល់មាត់ឡើយ។

ការចេញដីកាសម្រេចលើសំណុំរឿងស្មុំកូនអន្តរប្រទេស តុលាការត្រូវធ្វើការវិនិច្ឆ័យ និងចេញសេចក្តីសម្រេចក្នុងរយៈពេល ៣០(សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យសុំ

[72] មាត្រា ៣៧ នៃច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស ឆ្នាំ២០០៩

[73] មាត្រា ៣៨ នៃច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស ឆ្នាំ២០០៩

[74] មាត្រា ៤០ នៃច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស ឆ្នាំ២០០៩

[75] មាត្រា ៣៥ នៃច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស ឆ្នាំ២០០៩

និងត្រូវបញ្ជូនដីកាសម្រេចនោះទៅអ្នកសុំ អ្នកតំណាងដែលច្បាប់បានកំណត់របស់កូនសុំ និង ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច។

ដីកាសម្រេចមិនត្រូវបានចូលជាស្ថាពរ នៅមុនផុតអំឡុងពេលសម្រាប់ការប្តឹងជំទាស់ដែល បានកំណត់នៅក្នុងមាត្រា ៤០ នៃច្បាប់សុំកូនអន្តរប្រទេស។ ក្នុងករណីមានការប្តឹងជំទាស់ចំពោះ ដីកាសម្រេចនេះនិងមិនត្រូវចូលជាស្ថាពរដល់ពេលណាមានដីកាសម្រេចអំពីបណ្តឹងជំទាស់នោះ។

ដីកាសម្រេចរបស់តុលាការនឹងបើកផ្លូវឱ្យប្តឹងជំទាស់ទៅសាលាឧទ្ធរណ៍ ចំពោះបុគ្គលដែល មានសិទ្ធិនិងផលប្រយោជន៍របស់ខ្លួនត្រូវបានបំពានដីកាដោយដីកានោះក្នុងអំឡុងពេល ១៥ (ដប់ ប្រាំថ្ងៃ) នៃថ្ងៃធ្វើការគិតពីថ្ងៃដែលត្រូវទទួលបានដីកាសម្រេចនោះ។ ក្នុងករណីដែលបុគ្គលអាចប្តឹង ជំទាស់មិនមែនជាជនដែលត្រូវទទួលបានការជូនដំណឹងអំពីដីកាសម្រេចនោះ បណ្តឹងជំទាស់ត្រូវ ធ្វើឡើងក្នុងអំឡុងពេលដូចដែលបានកំណត់ខាងលើ បើគិតចាប់ពីថ្ងៃដែលអ្នកសុំបានទទួលដំណឹង អំពីដីកាសម្រេច។ នៅពេលទទួលបានពាក្យបណ្តឹងជំទាស់សាលាឧទ្ធរណ៍ត្រូវធ្វើការវិនិច្ឆ័យនឹង ចេញដីកាសម្រេចក្នុងរយៈពេល ៣០ ថ្ងៃ(សាមសិបថ្ងៃ) នៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលបណ្តឹង ជំទាស់ហើយដីកាសម្រេចរបស់សាលាឧទ្ធរណ៍ជាការសម្រេចបិទផ្លូវតវ៉ា[76]។

### ៤. សោហ៊ុយលើការសុំកូន

អ្នកសុំត្រូវបង់ប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានា ជូនរដ្ឋបាលសុំកូនអន្តរប្រទេស សម្រាប់ជួយឧបត្ថម្ភជំរើសនានា នៃការថែទាំជំនួស និងការជួយឧបត្ថម្ភទូទៅដល់មណ្ឌលកុមារកំព្រា របស់រដ្ឋទូទាំងប្រទេស និងកម្រៃសេវាចាំបាច់ផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេសដែលនឹង កំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុក វិស័យសង្គមកិច្ច។ ក្រៅពីនេះមិនត្រូវយកប្រាក់សោហ៊ុយសុំកូនពីអ្នកសុំ ឬទីភ្នាក់ងាររបស់អ្នកសុំកូន។ មិនអនុញ្ញាតឲ្យអ្នកសុំកូន ឬទីភ្នាក់ងាររបស់អ្នកសុំកូន បង់ថ្លៃសោហ៊ុយសុំកូនទៅតាមកុមារម្នាក់ៗ ឬទៅតាមសោហ៊ុយសុំកូនមួយដែលនឹងត្រូវបញ្ជូនទៅឲ្យមណ្ឌលកុមារកំព្រាណាមួយ ឬមិនអនុញ្ញាត ឲ្យ អ្នកសុំកូន ឬទីភ្នាក់ងាររបស់អ្នកសុំកូន ធ្វើការផ្តល់សោហ៊ុយ អំណោយ ឬការទូទាត់ទោះបី ក្នុងរូប ភាពណាក៏ដោយ ទៅឲ្យមណ្ឌលកុមារកំព្រាដែលកុមារ កំព្រានៅទីនោះត្រូវបានសុំយកទៅ ចិញ្ចឹម ឬទៅឲ្យបុគ្គលិក នាយក ឬសមាជិកនៃគណៈគ្រប់គ្រងទោះបីជាដោយផ្ទាល់ ឬដោយ ប្រយោលក្តី។

តុលាការត្រូវកំណត់ឲ្យអ្នកសុំបង់ប្រាក់ចំនួន ១.០០០.០០០ (មួយលាន)រៀល ដើម្បីទ្រទ្រង់ សោយហ៊ុយដាក់ពាក្យសុំការពិនិត្យភស្តុតាង ការចេញដីការសម្រេច ការបញ្ជូនឯកសារ ការផ្សព្វ ផ្សាយ សេចក្តីជូនដំណឹង ការស្រាវជ្រាវអង្គហេតុ និងសកម្មភាពខាងនីតិវិធីផ្សេងៗទៀត ដែល

---

[76] មាត្រា ៤០ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

ទាក់ទងនឹងកិច្ចការសុំកូនអន្តរប្រទេសនោះ ហើយតុលាការត្រូវបង្គាប់ ឲ្យអ្នកសុំបង់ចំនួនទឹកប្រាក់នោះជាមុន។ ក្នុងករណីដែលសោហ៊ុយចាំបាច់ ដែលបានកំណត់ខាងលើនេះលើសពី ១.០០០.០០០ (មួយលាន) រៀល តុលាការអាចកំណត់ចំនួនសោហ៊ុយបន្ថែម បង្គាប់ឲ្យអ្នកសុំបង់សោហ៊ុយបន្ថែម នោះមុន រីឯចំនួនទឹកប្រាក់នេះមិនបង្វិលជូនវិញទេ[77]។

**កថាខណ្ឌទី៣ កុមារក្រោយពេលទៅដល់ក្រៅប្រទេស**

ក្រោយពីកុមារត្រូវបានទទួលអនុញ្ញាតឱ្យធ្វើកូន នោះឪពុកម្តាយចិញ្ចឹមត្រូវផ្តល់របាយការណ៍អំពីស្ថានភាពវិវឌ្ឍន៍របស់កុមារ រដ្ឋបាលសុំកូនអន្តរប្រទេសជារៀងរាល់មួយខែម្តងក្នុងរយៈពេល៣ឆ្នាំ បន្ទាប់មកត្រូវផ្តល់ជារបាយការណ៍១ឆ្នាំ ម្តងរហូតដល់កុមារមានអាយុ១៨ ឆ្នាំ។

ឪពុកម្តាយចិញ្ចឹមត្រូវធ្វើរបាយការណ៍ជាលាយល័ក្ខអក្សរទៅរដ្ឋបាលសុំកូនអន្តរប្រទេសដោយផ្ទាល់ ឬតាមរយៈអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសឬទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាតនៃប្រទេស ឬប្រទេសជាលំនៅឋានអចិន្ត្រៃយ៍របស់ខ្លួនទៅតាមស្ថានភាពសមស្រប។

រដ្ឋបាលសុំកូនអន្តរប្រទេស និងសាលាដំបូងរាជធានីភ្នំពេញត្រូវសំណុំឯកសារសុំកូនអន្តរប្រទេសក្នុងរយៈពេល ៦០ ឆ្នាំ គិតពីកាលបរិច្ឆេទដែលដីកាសម្រេចសុំកូនអន្តរប្រទេសនោះចូលជាស្ថាពរ។

សំណុំឯកសារ និងកំណត់ហេតុទាំងអស់ទាក់ទងនឹងករណីសុំកូនអន្តរប្រទេសជាក់លាក់ណាមួយទោះជារក្សាទុកនៅតុលាការក៏ដោយរដ្ឋបាលសុំកូនអន្តរប្រទេស ទីភ្នាក់ងារសុំកូនអន្តរប្រទេស មណ្ឌលកុមារកំព្រា និងអ្នកជំនាញផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងនីតិវិធីសុំកូនអន្តរប្រទេសត្រូវរក្សាជាការសម្ងាត់។ ក៏ប៉ុន្តែសំណុំឯកសារនិងកំណត់ហេតុ ឬព័ត៌មានទាំងឡាយដែលមាននៅក្នុងសំណុំឯកសារអាចនឹងត្រូវបានបញ្ចេញទៅតាមការស្នើសុំ ការបង្គាប់ជាលាយល័ក្ខអក្សររបស់អាជ្ញាធរមានសមត្ថកិច្ចនៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជាក្នុងករណីមានតម្រូវការទាក់ទងនឹងករណី ឬនីតិវិធីតុលាការ ដែលកំពុងតែប្រព្រឹត្តទៅ ឬកាលៈទេសៈពិសេសដទៃទៀត

ឪពុកម្តាយចិញ្ចឹមអាចដាក់ពាក្យសុំទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីសុំច្បាប់ចម្លង នៃសំណុំលិខិត ដែលរួមមានអត្តសញ្ញាណរបស់ឪពុកម្តាយបង្កើតរបស់កូនសុំក្រោយពីដីកាសម្រេចសុំកូនរបស់តុលាការចូលជាស្ថាពរ។ នៅពេលដែលមានផលវិបាកនៃការដឹងអត្តសញ្ញាណកូនសុំដែលដល់អាយុដឹងខុសត្រូវគ្រប់គ្រាន់អាចត្រូវបានអនុញ្ញាតអោយមើល សំណុំលិខិតរបស់

[77] មាត្រា៣៥ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ២០០៩

ខ្លួនរួមទាំងអត្តសញ្ញាណរបស់ឪពុកម្តាយបង្កើតបាន ដោយធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរមក អាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជា។ កូនដែលឈានចូលអាយុនីតិភាពមានសិទ្ធមើល សំណុំឯកសារ និងកំណត់ហេតុទាក់ទងរបស់ខ្លួនដោយមានការពិគ្រោះយោបល់សមស្របមុននឹង មើលពតិមាននៅក្នុងសំណុំលិខិតរបស់ខ្លួន។

មានតែទីភ្នាក់ងារដែលបានទទួលការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច នៃព្រះ រាជាណាចក្រកម្ពុជា និងពីស្ថាប័នដែលមានសមត្ថកិច្ចនៃប្រទេសទទួលទើបមានសិទ្ធធ្វើប្រតិបត្តការ ក្នុងនីតិវិធីសុំកូនអន្តរប្រទេស ប៉ុន្តែចំនួនទីភ្នាក់ងារដែលមកពីប្រទេសទទួលនីមួយៗដែលអនុញ្ញាត អោយផ្តល់សេវានៅក្នុងប្រទេសកម្ពុជា ត្រូវកំណត់ដោយកិច្ចព្រមព្រៀងគ្នាមួយរវាងក្រសួងទទួល បន្ទុកវិស័យសង្គមកិច្ចនិងអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទទួល។

ប៉ុន្តែដើម្បីសុំការអនុញ្ញាត ធ្វើប្រតិបត្តិការណ៍សុំកូនអន្តរប្រទេសពីក្រសួងទទួលបន្ទុកវិស័យ សង្គមកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ទីភ្នាក់ងារត្រូវមានលក្ខណៈសម្បត្តិដូចតទៅ ៖

១-មានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសទទួល។

២-មានទិសដៅមិនស្វែងរកផលចំណេញ និងបានបំពេញនូវលក្ខខណ្ឌដែលមានចែងក្នុង បទបញ្ញត្តិ ច្បាប់ទាក់ទងនឹងនីតិបុគ្គលមិនយកចំណេញ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ឬ បទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតទាក់ទងនឹងលក្ខណៈនៃទីភ្នាក់ងារនោះ[78]។

## ផ្នែកទី៤៖ ផលវិជ្ជមាន និងអវិជ្ជមាននៃសុំកូនអន្តរប្រទេស

គ្រប់កិច្ចការដែលធ្វើឡើងដោយមនុស្ស ឬ សភាវៈដែលមានជីវិត សុទ្ធបង្កើតបាននូវគុណ សម្បត្តិ ដែលគេគ្រប់គ្នាត្រូវការ តែក៏បានបង្កើតជាមួយផងដែរនូវគុណវិបត្តិដែលនៅតែតោងទាម គុណសម្បត្តិនោះជាហូរហែរ ។ រីឯដំណើរការការសុំកូនអន្តរប្រទេស បានផ្តល់នូវប្រយោជន៍ជា ច្រើនដល់ភាគីទាំងសងខាង ( **កថាខណ្ឌទី១** ) តែមិនមែនមានន័យថា ទាមទារឲ្យឪពុកម្តាយគ្រប់ រូបលះបង់ទំនាក់ទំនងញាតិជាមួយកូនខ្លួន ដើម្បីទទួលបានផលប្រយោជន៍ទាំងនោះទេ ព្រោះវា បានភ្ជាប់មកជាមួយនូវគុណវិបត្តិផ្សេងៗ ( **កថាខណ្ឌទី២** ) ។ ភាគីទាំងសងខាងគឺពិតជាត្រូវការការ ប្រឹក្សាយ៉ាងច្បាស់លាស់ក្នុងការសម្រេចចិត្ត ជាពិសេសគឺឪពុកម្តាយបង្កើត ដូច្នេះក្នុងចំនុចដែលធ្វើ ការបកស្រាយអំពីគុណវិបត្តិ និង គុណសម្បត្តិនោះ គឺដើម្បីភាគីទាំងសងយកមូលដ្ឋានទាំងអស់ នេះទៅធ្វើការពិចារណាដើម្បី ទទួលបានការត្រៀមចិត្ត និងការសម្រេចចិត្តមួយ ដែលមិនខុសឆ្គង និងស្តាយក្រោយនូវការសម្រេចចិត្តរបស់ខ្លួន។

[78] មាត្រា ៤៨ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩

**កថាខណ្ឌទី១ ផលប្រយោជន៍នៃការសុំកូនអន្តរប្រទេស**

ស្មុំកូនអន្តរប្រទេសផ្តល់នូវផលវិជ្ជមាន អាចបញ្ជាក់នូវរាល់បញ្ហាដែលកើតមាន និងបំពេញនូវដោយគុណប្រយោជន៍ចំពោះអ្នកដែលជាប់ទាក់ទង។ លោកស្រី ប៉ែរណាឌែត អាប៊ីច្ចូ តំណាងមកពីការិយាល័យទីក្រុង ឡាអេ និងជាប្រធានខាងស្មុំកូនអន្តរប្រទេសមកពីហ្វីលីពីន បានលើកឡើងនូវ២ ចំណុចបន្ថែមទៀត ពាក់ព័ន្ធនឹងស្មុំកូនសាច់ញាតិ ដែលរស់នៅក្រៅប្រទេស និងមួយទៀតគឺការស្វែងរកគ្រួសារឲ្យកុមារ ដែលត្រូវការការថែទាំពិសេស សំដៅទៅលើកុមារដែលមានសុខភាពមិនប្រក្រតី កុមារពិការ កុមារដែលមានប្រវិត្តិមិនល្អ ឬជាកុមារដែលបានរងគ្រោះដោយការរំលោភបំពានជាដើម។ លោកស្រីក៏បានបញ្ជាក់ដែរថា គួរតែមានការកែសម្រួលខ្លះៗ ទៅលើប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្តាល និងរដ្ឋបាលស្មុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រ កម្ពុជាពីព្រោះក្នុងប្រកាសនេះមិនបានបរិយាកាសអំពីដំណើរការ ដែលពាក់ព័ន្ធទៅនឹងនីតិវិធីពិសេសចំណុចដែលលោកស្រីបានលើកឡើងនោះទេ។

ស្មុំកូនអន្តរប្រទេសអាចផ្តល់នូវគុណសម្បត្តិជាច្រើនចំពោះឪពុកម្តាយបង្កើត ១.១ រីឯផលប្រយោជន៍មួយចំនួនផ្សេងទៀតក៏អាចកើតមានលើកូនសុំនោះ ១.២ ចំពោះអ្នកសុំរិញថ្មីត្បិតបន្ថែមនូវភារកិច្ច ទទួលខុសត្រូវក៏ពិតមែន តែពួកគេក៏អាចទទួលផលប្រយោជន៍នៃស្មុំកូនអន្តរជាតិប្រទេសផងដែរ ១.៣ ។

**១. ផលប្រយោជន៍ចំពោះឪពុក និងម្តាយបង្កើត**

នាពេលដែលឪពុក ឬ និងម្តាយបង្កើត ឬអាណាព្យាបាលយល់ព្រមអនុញ្ញាត្តឲ្យកូនរបស់ខ្លួនឯងទៅជាកម្មវត្ថុនៃស្មុំកូនអន្តរប្រទេស ខ្លួននឹងទទួលបាននូវផលប្រយោជន៍មួយចំនួនទោះបីជាខ្លួនត្រូវបាត់បង់កូននោះក៏ដោយ ហើយផលប្រយោជន៍នោះមានដូចខាងក្រោម៖

- អាចជួយសម្រួលដល់ជីវភាពនៅក្នុងគ្រួសារ ៖ ព្រោះកូនអាចចាត់ទុកថា ជាសំពាធដល់គ្រួសារធ្ងន់សម្រាប់គ្រួសារដែលមានបញ្ហាជីវិភាព។ ការអនុញ្ញាតឲ្យមានស្មុំកូនអន្តរប្រទេសអាច ចាត់ទុកថា ឪពុកម្តាយបង្កើតនោះ គេចវេសនឹងការទទួលខុសត្រូវលើកាតព្វចិញ្ចឹមបីបាច់កូន ប៉ុន្តែបើគិតដល់សុទិដ្ឋិនិយមវិញ ការអនុញ្ញាតឲ្យកូនទៅអ្នកដទៃនោះ គឺសុទ្ធសឹងតែគិត ដល់ឧត្តមប្រយោជន៍របស់កុមារ ដើម្បីទទួលបានគុណប្រយោជន៍ល្អប្រសើរជាងមុន។
- មានឱកាសស្វែងរកគោលបំណងក្នុងសុបិនរបស់ខ្លួន ៖ ជួនកាលកូន គឺជាឧបសគ្គមួយដល់ស្ត្រី និង គ្រួសារមួយចំនួនដែលមិនអាចនឹងធ្វើបាននោះទេ ពោលគឺខ្លួនត្រូវព្យាយាមបង្កើនប្រាក់ចំណូល ដើម្បីផ្គត់ផ្គង់គ្រួសារ មានន័យថាខ្លួនត្រូវលុបចោលនូវផែនការនៃជីវិតឬ គម្រោងផ្សេងៗ ដូចជា ការសិក្សា ការធ្វើដំណើរ ឬចាប់

យកអាជីពជាក់លាក់ណាមួយ។ ដូច្នេះនាពេលដែលដឹងថាកូនរបស់ខ្លួនបានសុភមង្គលហើយ ខ្លួនក៏អាចបង្វែរគំនិតរបស់ខ្លួនបាន មករកអ្វីដែលជាសុបិននោះបាន។

- មានឱកាសបង្កើតអនាគតដ៏ល្អប្រសើរសម្រាប់កូនរបស់ខ្លួនដូចតាមបំណង៖ គ្មាននរណាម្នាក់ ដែលសុខចិត្តឲ្យកូនដែលចេញពីផ្ទៃរបស់ខ្លួនផ្ទាល់ទៅអ្នកដទៃនោះទេ ពោលគឺចង់ចិញ្ចឹមបីបាច់ដោយដៃរបស់ខ្លួនផ្ទាល់ ប៉ុន្តែដោយសារតែជីវិភាពខ្លួនមានតែបង្ខំចិត្តប្រគល់កូនរបស់ខ្លួនឲ្យទៅអ្នកដទៃ ដោយសង្ឃឹមថាកូននឹងទទួលបាននូវសុភមង្គលជីវភាពល្អប្រសើរទទួលបានការអប់រំ មានសមត្ថភាព។ល។
- មានសិទ្ធិដើម្បីជ្រើសរើសក្រុមគ្រួសារមួយ សម្រាប់កូនដោយផ្អែកលើចំណងចំណូលចិត្តរបស់ឪពុកម្ដាយបង្កើត និងឱកាសដើម្បីទទួលបានដំណឹងពីកូនរបស់ខ្លួន៖ ក្នុងន័យនេះឪពុកម្ដាយបង្កើតអាចស៊ើបទៅលើអ្នកសុំ ថាជាមនុស្សប្រភេទណាដែលអាចសម្រាប់ទីពឹងរបស់កូននោះបានឬទេ។ បើយល់ថាមានវិការៈណាមួយកើតឡើងឪពុក ឬនិងម្ដាយបង្កើតមានសិទ្ធិបញ្ឈប់នូវដំណើររបស់កុមារនោះទោះបីបានឃ្លាតទៅឆ្ងាយក៏ដោយ។
- មិនមានការចំណាយនោះទេក្នុងដំនើរការតាមផ្លូវច្បាប់ ៖ នៅក្នុងដំនើរការប្រព្រឹត្តទៅនៃសុំកូនអន្តរប្រទេស គ្រួសារ ឬអាណាព្យាបាលរបស់កុមារមិនចាំបាច់ធ្វើការបង់នូវប្រាប់ដើម្បីដំនើរការរបស់អាជ្ញាធរមានសមត្ថកិច្ច ទីភ្នាក់ងារ និងតុលាការនោះទេ តែអ្នកដែលត្រូវតែបង់ប្រាក់ក្នុងដំនើរការនោះវិញគឺអ្នកសុំ ។
- រួចផុតពីកាតព្វកិច្ចជាឪពុកម្ដាយ ៖ ក្នុងន័យនេះ ចង់សំដៅថាសុំកូនអន្តរប្រទេសគឺនាំមកនូវអានុភាពជាសុំកូនពេញលេញ គឺអ្នកសុំនឹងក្លាយទៅជា អាណាព្យាបាលលើកុមារ ស្របទៅតាមច្បាប់ ដែលមានកាតព្វកិច្ចបីបាច់ថែរក្សាកុមាររហូតក្លាយជានីតិជន ផ្ទុយទៅវិញ ឪពុក ឬនិងម្ដាយ ឬអាណាព្យាបាលនោះនឹងក្លាយទៅជាអ្នកដទៃ ព្រោះសុំកូននេះបានកាត់ផ្ដាច់នូវទំនាក់ទំនងញាតិទៅហើយ។
- មានសុភមង្គលនាពេលដែលដឹងថាកូនរបស់ខ្លួនបានសេចក្ដីសុខ៖ ឪពុក ឬនិងម្ដាយបង្កើតអាចទទួលបានអារម្មណ៍ថាល្អប្រសើរឡើង បន្ទាប់ពីមានអារម្មណ៍ពិបាកចិត្តពេលបាត់បង់សាច់ញាតិរបស់ខ្លួន ព្រោះបានដឹងថាកូនរបស់ខ្លួនត្រូវបានទទួលសេចក្ដីស្រលាញ់ និងការផ្គត់ផ្គង់ផ្សេងៗ ពីអ្នកសុំនោះ ។

## ២. ផលប្រយោជន៍ចំពោះកូនសុំ

នាពេលដែលបញ្ចប់នូវដំណើរការសុំកូនអន្តរប្រទេស ហើយតុលាការបានចេញនូវសាលក្រមស្ថាពរសម្រេចក្នុងការសុំកូននោះ កុមារដែលជាកម្មវត្ថុ អាចទទួលបានគុណសម្បត្តិក្នុងការលូតលាស់ផ្នែករាងកាយ និង ផ្លូវចិត្តផ្សេងៗដូចជា ៖

- ទទួលបានការស្រលាញ់ និងផ្គត់ផ្គង់ពីឪពុកម្ដាយចិញ្ចឹម៖ កុមារដែលត្រូវបានគេយកទៅចិញ្ចឹមគឺសុទ្ធតែអាចទទួលបានការថ្នាក់ថ្នម និងស្រលាញ់ពីអ្នកសុំ គឺត្រូវស្វែងរកកុមារណា ដែលខ្លួនយល់ថា អាចនៅចុះសម្រុងនឹងគ្នា ឬលក្ខណៈសម្បត្តិល្អប្រសើរនៅត្រង់ចំណុចណាមួយទើបធ្វើការសុំកុមារនោះ។ រីឯកុមារដែលត្រូវបានសុំនោះក៏អាចបន្ថែមនូវអ្នកស្រលាញ់ និងផ្គត់ផ្គង់ក្នុងការរស់រានមានជីវភាព ព្រមទាំងមានអនាគតល្អប្រសើរជាពិសេស គឺអាចនឹងមានឱកាសទទួលបានការអប់រំដែលមានគុណភាព ។
- កុមារទទួលបានគ្រួសារថ្មី ដែលមានបរិយាកាសល្អ៖ បរិយាកាសថ្មីសម្រាប់កុមារ គឺជាកត្តាចាំបាច់មួយចំពោះកុមារ ដើម្បីទទួលបានការអភិវឌ្ឍន៍ទាំងផ្នែករាងកាយ និង ផ្នែកស្មារតី។ កុមារមិនអាចរស់នៅក្នុងជីវភាព ដែលផ្ដល់ព្យសនកម្មដល់ការរៀនសូត្រនោះបានទេ ។ ជាពិសេស ពេលវេលាគ្រប់គ្រាន់ និង ទីកន្លែងស្ងប់ស្ងាត់ទើបអាចធ្វើឲ្យកុមារអាចមានស្មារតីសិក្សារៀនសូត្របាន។
- បន្ថែមឪពុកម្ដាយម្ខាងទៀតអាចផ្ដល់ឲ្យកុមារមានសាច់ញាតិ និងទំនាក់ទនងកាន់តែច្រើន៖ មនុស្សម្នាក់ៗ មិនអាចរស់នៅម្នាក់ឯងបាននោះទេ រីឯទំនាក់ទំនងនៅក្នុងសង្គមគឺចាំបាច់ត្រូវផ្ដល់ឲ្យកុមារ ជាពិសេសសេចក្ដីស្រលាញ់ ការការពារគឺជាអ្វីដែលកុមារត្រូវការចាំបាច់ព្រោះកុមារត្រូវបានចាត់ទុកជាជនរងគ្រោះ។
- មានឱកាសដ៏ល្អក្នុងការអប់រំ និងឱកាស ចូលក្នុងមហាវិទ្យាល័យល្អៗ៖ ផ្ដល់ការអប់រំដល់កុមារ គឺជាអ្វីដែលមិនអាចខ្វះបាន ប៉ុន្តែនៅក្នុងនោះដែរ គុណភាពនៃគ្រូបង្រៀនក្នុងសាលាល្អ គឺជារឿងដែលគួរពិចារណា។ មហាវិទ្យាល័យល្អៗ ដែលត្រូវបានគេទទួលស្គាល់គឺជាគោលដៅដែលអ្នកសិក្សាទាំងអស់ចង់បាន ដើម្បីអភិវឌ្ឍន៍ចំនេះវិជ្ជារបស់ខ្លួនឲ្យមានគុណភាព។ ប៉ុន្តែដើម្បីចូលសិក្សានោះ ក៏ត្រូវតែជាបុគ្គលមានសមត្ថភាពដែរ ក្នុងចំណុចនេះគឺមានតែឪពុកម្ដាយចិញ្ចឹម ដែលជាអ្នកនៅជិតជិតកូននោះបំផុត នឹងអាចផ្ដល់ឲ្យកុមារនូវមូលដ្ឋានគ្រឹះនៃដ៍មានគុណភាពជូនកុមារព្រោះអ្នកដែលអាចអនុញ្ញាតឲ្យសុំកូនបានគឺសុទ្ធសឹងតែជាអ្នកមានសមត្ថភាព និងជីវភាពល្អអាចចិញ្ចឹមទទួលកាតព្វកិច្ចជាឪពុកម្ដាយបាន។

- កុមារដែលនៅតំបន់ជនបទអាចទទួលបាននូវឪកាសនៃជីវិតថ្មី៖ កុមារដែលរស់នៅជនបទភាគច្រើនគឺមិនសូវទទួលបាននូវការលូតលាស់ និងចំពោះគ្រាប់គ្រាន់នោះទេ លើសពីនោះទៅទៀតថែមទាំងឆ្លងនូវជំងឺផ្សេងៗ។ ដោយសារកង្វះការថែទាំ និងបរិស្ថានកខ្វក់។ នាពេលដែលកុមារនៅតាមជនបទត្រូវបានសុំយកទៅចិញ្ចឹមនៅប្រទេសដទៃ គឺអាចធ្វើឲ្យកុមារមានឪកាសចាកចេញពីជីវភាពទាំងនោះ។
- កុមារអាចទទួលបាននូវគុណភាពនៃជីវិតមួយ ដែលឪពុកម្ដាយបង្កើតមិនអាចផ្ដល់ឲ្យបាន៖ ឪពុកម្ដាយគ្រប់រូប គឺមិនចង់បានបាត់បង់កូនរបស់ខ្លួននោះទេ តែដោយសារតែបញ្ហាជីវភាពទើបដាច់ប្រគល់កូននោះទៅអោយអ្នកដទៃ ព្រោះមិនអាចផ្ដល់តាមតម្រូវការរបស់កុមារនោះទេដូច្នេះមានតែអ្នកសុំដែលសមត្ថភាពប្រសើរជាងខ្លួន ទើបអាចផ្ដល់ឲ្យបានគ្រប់គ្រាន់តាមតំរូវការទាំងនោះ។

**៣. ផលប្រយោជន៍ចំពោះអ្នកសុំ**

កាលបើទទួលបានកូនដូចដែលខ្លួនប្រាថ្នាហើយ អ្នកសុំនោះនៅតែអាចទទួលបាននូវគុណប្រយោជន៍ផ្សេងទៀត ដែលមានដូចតទៅ៖

1. ទទួលបាននូវបទពិសោធន៍ដែលរីករាយ ក្នុងការមានសមាជិកបន្ថែមក្នុងគ្រួសាររបស់ខ្លួន៖ បន្ថែមនូវសមាជិកថ្មីក្នុងគ្រួសារគឺជាគោលបំណងរបស់អ្នកសុំ ដើម្បីទទួលបាននូវកូនស្របច្បាប់ដែលខ្លួនចង់បាន។
2. ទទួលបាននូវបទពិសោធន៍ក្នុងការយល់ដឹងអំពីការលូតលាស់របស់កុមារ៖ អ្នកដែសុំកុមារយកធ្វើជាកូនបង្កើតរបស់ខ្លួន អាចចាត់ទុកថាជាអ្នកដែលស្រលាញ់ និងចូលចិត្តក្មេងឬចង់បន្ថែមនូវសមាជិកថ្មី ហើយចង់យល់ពីជីវភាពនៃការចិញ្ចឹមកូនដូច្នេះពួកគេអាចយល់ដឹងអំពីការលូតលាស់របស់កុមារដោយការរស់នៅជិតស្និតជាមួយកុមារ។
3. មានឪកាសទទួលបានកុមារ ដែលជាកូនពេញលេញរបស់ខ្លួនទៅថ្ងៃអនាគតដោយមិនចាំបាច់មានលំហែរមាតុភាព៖ មានគ្រួសារភាគច្រើនចង់បង្កើតកូនដោយខ្លួនឯង និងចិញ្ចឹមបីបាច់ដោយផ្ទាល់ដៃ តែពួកគេមិនអាចធ្វើបានដោយសារតែ សហព័ទ្ធណាម្ខាងអសមត្ថភាពក្នុងកាតបង្កើតកូន ឬខាងប្រពន្ធមិនចង់ទទួលបានការឈឺចាប់ពីការមានគត៌ រីឯគ្រួសារដែលស្រលាញ់ភេទដូចគ្នាវិញ គឺពិតជាចង់ឲ្យគ្រួសារទូទៅ ផងដែរ។ក្នុងការបង្កើតគ្រួសារមួយដ៏ពេញលេញ ផ្ទុយទៅវិញពួកគេមិនអាចបង្កើតបាននោះទេ ។ ដូចគ្នាផងដែរ ចំពោះអ្នកដែលមិនមានបំណងចង់បានឬដៃគូ

ជីវិត ប៉ុន្តែពួកគេចង់បានកូនដែលជារបស់ខ្លួន ដូច្នេះសុំកូនអន្តរប្រទេសអាចជួយបាន្ទូវឲ្យពួកគេ មានឪកាសទទួលបានកូនដែលខ្លួនចង់បាន និងស្របច្បាប់។

4. កូនសុំនោះនឹងចាត់ទុកឪពុកម្តាយចិញ្ចឹមជាឪពុកម្តាយបង្កើតៈ កុមារដែលទទួលបានគុណភាពនៃការអប់រំគឺ ប្រាកដជាយល់ច្បាស់អំពីអ្វីដែលហៅថា កតវេទិតា និងមានសនសិការ ដឹងខុសត្រូវ តាមរយៈការផ្តល់មកវិញនូវចិត្តស្រលាញ់ ផ្គត់ផ្គង់និងសន្តិសុខជូនឪពុកម្តាយចិញ្ចឹម ទោះបីជាគេដឹងថាមិនមែនជាឪពុកម្តាយបង្កើតក៏ដោយ ក៏អនុស្សាវរីយ៍ និងភាពស្និតស្នាលដែលធ្លាប់មាន អាចភ្ជាប់បន្តនូវទំនាក់ទំនងនោះ។
5. ឪពុកម្តាយចិញ្ចឹមនឹងក្លាយជាអ្នកសប្បុរសដែលគេទទួលស្គាល់ ក្នុងការលះបង់កម្លាំងកាយចិត្ត និងថវិការដើម្បីផ្គត់ផ្គង់ដល់តម្រូវការជាចាំបាច់ដល់កុមារ ៖ គ្មាននរណាម្នាក់ ដែលសុខចិត្ត ទទួលចិញ្ចឹមកូនរបស់អ្នកដទៃ ដោយបានចំណាយនូវពេលវេលា កម្លាំងកាយ ចិត្តនិង ថវិកាផ្ទាល់ខ្លួនដើម្បីផ្គត់ផ្គង់នោះទេ ដូច្នេះអ្នកសុំអាចមានឪកាសក្លាយអ្នកដែលគេយកគំរូតាមបាន។ ឧទារណ៍: Angelina Jolie ដែលត្រូវបានគេចាត់ទុកជាសប្បុរសជនដែលបាន សុំកូន ពីកម្ពុជា និង ប្រទេសអាឌិស អាបាបា ដែលបានផ្តល់គ្រប់តំរូវការដល់កុមារ។
6. ផ្តល់ដល់អ្នកសុំអាចជ្រើសរើសមានកូនបែបណា ដែលពួកគេចង់បានដូចសេចក្តីប្រាថ្នាៈ ក្នុងចំនុចនេះ ចង់សំដៅទៅលើឪកាសរបស់កូនសុំ ដែលអាចស្វែងរកកុមារនៃជនជាតិណាដែលខ្លួនចង់បានក្នុងចំណោមប្រទេសជាសមាជិកនៃអនុសញ្ញាទីក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស។

**កថាខណ្ឌទី២ គុណវិបត្តិនៃសុំកូនអន្តរប្រទេស**

គ្មានអ្វីដែលកើតឡើងដោយល្អឥតខ្ចោះនោះទេ គឺត្រូវតែភ្ជាប់នូវគុណវិបត្តិដែលមិនអាចខ្វះបាន។ ក្រៅពីគុណសម្បត្តិខាងលើ ដែលភាគីទាំងសងខាងទទួលហើយ ក៏បន្ថែមមាននូវគុណវិបត្តិមួយចំនួននៅខាងក្រោយ ដែលមិនអាចខ្វះបាន។

**១. គុណវិបត្តិចំពោះឪពុក ឬនិងម្តាយបង្កើត**

ក្រៅពីគុណសម្បត្តិដែលមានខាងលើឪពុក ឬនិងម្តាយបង្កើត ត្រូវមានវិបត្តិមួយចំនួនដែលមិនអាចគេចផុតបានដូចជាៈ

- បោកប្រាស់សេចក្តីទុកចិត្តពីសំណាក់អ្នកសុំ ទំនាក់ទំនងដែលបង្កើតជាមួយឪពុកម្តាយចិញ្ចឹមរបស់កុមារ អាចជាហេតុនាំឲ្យមានការបោកប្រាស់សេចក្តីទុកចិត្ត ដែល

ប្រើការបោកបញ្ឆោតដោយសកម្មភាព។ ចំពោះអ្នកឱកាសនិយម មួយចំនួនបាន ឆ្លៀតពេលដែលឪពុកម្តាយមិនដឹងច្បាស់ ឬជឿទៅលើអ្នកសុំ ដែលមិនបានដើរតាម នីតិវិធីច្បាប់ហើយអត្តនោម័តដោយខ្លួនឯងអាចធ្វើឲ្យមានការខាតបង់ ដែលអាចធ្វើ ឲ្យកូនរបស់ខ្លួនក្លាយទៅជាកម្មវត្ថុនៃការជួយដូរទៅវិញ។

- មានសេចក្តីអស់សង្ឃឹមៈ ឪពុកម្តាយបង្កើតសុទ្ធតែសង្ឃឹមថាកូនរបស់ខ្លួននឹងទទួល បានអនាគតល្អ និងរស់នៅដោយ សុភមង្គល ទើបអនុញ្ញាតឲ្យកូនរបស់ខ្លួនទៅអ្នក ដទៃចិញ្ចឹមទៅវិញ ប៉ុន្តែឪពុកម្តាយបង្កើតអាចមានអារម្មណ៍អស់សង្ឃឹមនាពេល ដែលដឹង ថាកូនរបស់ខ្លួនមិនត្រូវបានយកចិត្តទុកដាក់ថែរក្សាដោយឪពុកម្តាយចិញ្ចឹ ម។
- អារម្មណ៍ដែលមិនបានបំពេញកាតព្វកិច្ចៈ ឪពុកម្តាយបង្កើតភាគច្រើនគឺប្រហែលជា មានអារម្មណ៍ទុក្ខព្រួយ ឬអាក់អន់ស្រពន់ចិត្ត និងនឹកដល់កូនរបស់ ពេលនោះ វិប្បដិសារីប្រាកដជាកើតឡើងដោយខ្លួនឯង ព្រោះខ្លួនជាឪពុកម្តាយបង្កើតបែរជា មិនអាចផ្គត់ផ្គង់តំរូវការរបស់កូនខ្លួនបានដូចគ្រួសារដទៃ។

**២.គុណវិបត្តិចំពោះកូនសុំ**

ការបើកឲ្យមានដំណើរការសុំកូនអន្តរប្រទេស គឺអាចធ្វើឲ្យមានការប្រែប្រួលចំពោះកូន សុំគ្រប់រូប។ ចំពោះកុមារដែលជាកម្មវត្ថុនៃសុំកូនអន្តរប្រទេស ទទួលបាននូវគុណវិបត្តិដូចជាៈ

- បាត់បង់នូវអារម្មណ៍ជាគ្រួសាររបស់ខ្លួនៈ ទោះបីជាមានការស្រលាញ់ និងឧបត្ថម្ភ ពីឪពុកម្តាយចិញ្ចឹមដូច ឬច្រើនជាងឪពុកម្តាយបង្កើតយ៉ាងណាក៏ដោយ ក្នុងទំនាក់ ទំនងនោះ កុមារភាគច្រើននៅតែមានអារម្មណ៍ថាមិនដូច ឬមិនស្មើនឹងឪពុកម្តាយ បង្កើតដដែល។
- កុមារមានអារម្មណ៍ថាខ្លួនត្រូវបានគេបោះបង់ចោលៈ ទោះបីជាស្ថិតក្នុងហេតុផល យ៉ាងណាក៏ដោយ ដើម្បីអនាគត និងផលប្រយោជន៍របស់កុមារផ្ទាល់ក៏ដោយ ក៏ កុមារនៅបន្តមានអារម្មណ៍ថាខ្លួនត្រូវឪពុកម្តាយបង្កើតបោះបង់ចោល បាត់បង់នូវ ភាពកក់ក្តៅពីសាច់ញាតិដែលកុមារគ្រប់រូបត្រូវការ។ នៅក្នុងស្ថានភាពបាត់បង់ ភាពម្ចាស់ការមួយចំនួន គេអាចកើតជាអារម្មណ៍ស្អប់ និងគុំគួនក្នុងចិត្ត។

**៣. គុណវិបត្តិចំពោះអ្នកសុំ**

ចំពោះអ្នកសុំវិញ ថ្វីត្បិតតែខ្លួនទទួលបាននូវកូនដូចបំណងប្រាថ្នាហើយ តែខ្លួននូវតែជៀស មិនផុតពីផលវិបាកជាច្រើនចំពោះខ្លួន ដែលជាកាតព្វត្រូវតែទទួលខុសត្រូវដូចជាៈ

- បន្ថែមនូវសម្ពាធៈ អ្នកសុំត្រូវតែព្យាយាមស្វែងរកចំនូលបន្ថែមដើម្បីសម្រួលដល់ជីវភាព។ថ្វីត្បិតតែខ្លួនឯងមានសមត្ថភាពគ្រប់គ្រាន់ខាងផ្នែកថវិកា ប៉ុន្តែកុមារ គឺមានតម្រូវការច្រើន ណាស់ក្នុងការអភិវឌ្ឍន៍ផ្នែករាងកាយ ក្រៅពីនេះគឺទៅលើសតិអារម្មណ៍ និងស្មារតីរបស់កុមារដែលទាមទារអ្នកសុំយកចិត្តទុកដាក់។
- ទំនាក់ទំនងមិនជាប់លាប់ ៖ ឪពុកម្ដាយចិញ្ចឹម និងកូនសុំគឺនៅជាមួយគ្នា ដែលបានបង្កើតនូវអនុស្សាវរីយ៍ក៏ដោយ ក៏អ្នកទាំងពីរនៅតែមានអារម្មណ៍ថាមិនស្និទស្នាល ព្រោះអ្នកទាំងពីរមិនមែនមានឈាមជ័រតែមួយ សូម្បីតែនិន្នាការ និងចំណង់ចំណូលចិត្តរបស់ពួកគេពេលខ្លះក៏អាចមានលក្ខណៈខុសគ្នា ហើយអ្វីដែលពិសេសនោះគឺអារម្មណ៍សាច់ញាតិ។ ក្នុងករណីដែល ឪពុកឬនិងម្ដាយបង្កើតមានភាពជិតដិតនឹងកូននោះ ហើយទិញទឹកចិត្តពីកូនដោយចង់យកកូននោះទៅវិញ ដែលជាវិបត្តិមួយអាចប៉ះពាល់ដល់គ្រួសារអ្នកសុំ។
- ព្យាយាមបង្ហាញចិត្តស្រលាញ់ទៅកូនសុំៈ ក្នុងករណីដែលកូននោះដឹងថា ខ្លួនត្រូវបានគេសុំបែបនេះ ខ្លួននឹងយល់ថាឯការ និងទាមទារចង់ជួបឪពុកម្ដាយបង្កើត ដូច្នេះអ្នកសុំត្រូវតែលួងលោម និងផ្ដល់ក្ដីស្រលាញ់ ដើម្បីឲ្យកូននោះ គិតថាខ្លួនមិនមែនជាកុមារកំព្រានោះទេ។
- មានទំនួលខុសត្រូវជាអាណាព្យាបាលៈ អ្នកសុំត្រូវតែបំពេញតួនាទី របស់ខ្លួនឲ្យខ្ជាប់ខ្ជួនគឺមានន័យថា ចាប់ពីថ្ងៃសុំដែលបញ្ជាក់ដោយសាលក្រមមក អ្នកសុំគឺឪពុកឬនិងម្ដាយ ស្របច្បាប់ ទោះបីជាកុមារនោះមានជំងឺតំណរពូជក៏ដោយ ក៏អ្នកសុំត្រូវតែទទួលខុសត្រូវស្វែងរកការព្យាបាលដល់កូននោះផងដែរ។ទទួលរងការឈឺចាប់ៈ កុមារនោះគឺជាឈាមជ័ររបស់អ្នកដទៃ ទោះបីជាយើងបានផ្លាស់ប្ដូរបរិស្ថានថ្មីដល់កូននោះ ដើម្បីឲ្យកុមារនោះសម្របតាមបរិស្ថាន តែ មិនប្រាកដកូននោះស្ថិតក្នុងបរិស្ថានដែលល្អប្រសើរនោះទេ ដូច្នេះកូនអាចទៅជា រឹងរូស មិនស្ដាប់បង្គាប់ខ្ជិលច្រអូស ហើយចុងក្រោយអ្នកដែលពិបាកចិត្តប្រាកដជាអ្នកសុំនោះហើយ ៕

### កថាខ័ណ្ឌទី៣ អានុភាពនៃសុំកូនអន្តរប្រទេស

ស៊ុំកូនអន្តរប្រទេស ត្រូវតែជាស៊ុំកូនពេញលេញ។ ស៊ុំកូនអន្តរប្រទេសមានអានុភាពបង្កើតនូវទំនាក់ទំនងញាតិរវាងឪពុកម្ដាយ និងកូនជាអចិន្ត្រៃយ៍ ដោយផ្ដល់ដល់កុមារនូវឋានៈ សិទ្ធិ និងកាតព្វកិច្ចដូចជាកូនបង្កើតរបស់ឪពុកម្ដាយចិញ្ចឹម ហើយវាបញ្ចប់ញាតិភាពរវាងកុមារ និងឪពុក ម្ដា

យបង្កើតរបស់ខ្លួន[79]។ ចំពោះអានុភាពផ្សេងទៀតនៃសុំកូនអន្តរប្រទេស ត្រូវគ្រប់គ្រងដោយ ច្បាប់ជាតិរបស់អ្នកសុំ ឬប្រសិនបើគ្មានច្បាប់រួមទេ ត្រូវគ្រប់គ្រងដោយច្បាប់ នៃប្រទេសលំនៅ អចិន្ត្រៃយ៍របស់អ្នកសុំ។

[79] មាត្រា ៩១ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ២០០៩

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការសិក្សាស្រាវជ្រាវដំណើរការនៃនីតិវិធីសុំកូនកន្លងមក ឃើញថា គ្រប់ល័ក្ខខ័ណ្ឌ និងក្នុងគោលបំណងមនុស្សធម៌។ កត្តានេះហើយ ដែលជំរុញឲ្យរាជរដ្ឋាភិបាលមានការបង្កើត ច្បាប់ អនុក្រឹត្យ ប្រកាស ឬសារាចរណ៍ណែនាំផ្សេងៗ និងសហការជាមួយក្រសួងដែលពាក់ព័ន្ធ មាន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការបរទេស អង្គការក្រៅរដ្ឋាភិបាលក្តី ដើម្បីធានាការពារសិទ្ធិជាមូលដ្ឋាន និងជាឧត្តមប្រយោជន៍កុមារជាធំ។

សុំកូនក្នុងប្រទេស ដែលយោងតាមក្រមរដ្ឋប្បវេណី ពុំសូវមានជាបញ្ហាចោទប៉ុន្មាននោះ ទេ ដោយសារនីតិវិធីមិនសូវតឹងរឹង ហើយកូនសុំត្រូវបានរស់នៅក្នុងប្រទេសកម្ពុជាដដែលគ្រាន់តែ ស្ថិតនៅក្រោយការគ្រប់គ្រង ឬអំណាចមេបារបស់ឪពុកម្តាយចិញ្ចឹមទាំងស្រុង។ ចំណែកឯវាល់ បទដ្ឋានគតិយុត្ត អនុក្រឹត្យ ប្រកាស និងរបាយការណ៍ទាំងនោះ គឺជាកិច្ចអន្តរាគមន៍ទៅលើវិស័យ សុំកុនពីព្រោះការសុំអន្តរប្រទេសមានលក្ខណៈស្មុគស្មាញ ដោយសារតែវាមិនអាស្រ័យលើច្បាប់ និងអាជ្ញាធរនៃប្រទេសតែមួយ។ ការរៀបចំបទដ្ឋានច្បាប់ និងនីតិវិធីថ្នាក់ជាតិត្រូវឲ្យត្រូវតាមស្តង់ ដារអន្តរជាតិ និងកិច្ចសហប្រតិបត្តិការវាងប្រទេសកំណើតរបស់កូនសុំ និងប្រទេសរបស់អ្នកសុំ គឺជារឿងចាំបាច់ ដើម្បីជៀសវាងបញ្ហា ដែលអាចប៉ះពាល់ដល់អនាគតរបស់កុមារ និងជាពិសេស ការជួញដូរកុមារ។

ផ្អែកតាមបទដ្ឋានអង្គការសហប្រជាជាតិ និងអនុសញ្ញាក្រុងឡាអេ តម្រូវឲ្យមានច្បាប់ ស្តីពីសុំកូនអន្តរប្រទេស ហើយច្បាប់នេះត្រូវបានចូលជាធរមាន នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៩។ ដោយរង់ចាំច្បាប់នេះក៏ពិតមែន ប៉ុន្តែដោយសារមានពត៌មាន ស្តីពីការជួញដូរកុមារ រួមនឹងសកម្មភាព ខុសច្បាប់របស់ទីភ្នាក់ងារបរទេសមួយចំនួននៅប្រទេសខ្លះ បានធ្វើឲ្យប្រទេសមួយចំនួនព្យួរដំណើរ ការសុំកូនអន្តរប្រទេសជាមួយកម្ពុជាដោយឯកតោភាគី។ ទន្ទឹមនឹងនេះ នៅមានប្រទេសជាច្រើន កំពុងបន្តការសុំកូនពីកម្ពុជា ដូច្នេះយើងមិនបានបិទទ្វារចំពោះប្រទេសណាមួយឡើយ ហើយស្វាគមន៍ ចំពោះកិច្ចសហ-ការលើការងារសុំកូនអន្តរប្រទេស ជាមួយប្រទេសទាំងអស់។ ច្បាប់នេះមិនតម្រូវ ចិត្តប្រទេសណាមួយទេ តែនេះជាតម្រូវការចាំបាច់នៃនីតិវិធីសុំកូនអន្តរប្រទេស និងដើម្បីឧត្តម ប្រយោជន៍នៃកុមារកម្ពុជា។

ដែនកំណត់នៃសារណានេះ គឺគិតចាប់តាំងពីកម្ពុជាមានអនុក្រឹត្យស្តីពីការសុំទារកកំព្រា ឬកុមារកំព្រាយកទៅចិញ្ចឹមនៅបរទេស (២០០១) ។សុំកូនបច្ចុប្បន្ន កម្ពុជាមានក្រមរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តឲ្យប្រើពីថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០០៧ ស្ថិតក្នុងផ្នែកទី២ ដែលបញ្ញត្តិអំពី សុំកូន

នេះ(សុំកូនពេញលេញ និង សុំកូនធម្មតា) ដែលគ្រប់គ្រងទៅលើវិស័យសុំកូនក្នុងស្រុក។ ដោយឡែក សុំកូនអន្តរប្រទេសកម្ពុជាមាន ច្បាប់ស្តីពីសុំកូនអន្តរប្រទេស (២០០៩) ដោយអនុលោមតាមរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា ៤៨ និង អនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ដែលព្រះរាជាណចក្រកម្ពុជា បានផ្តល់សច្ចាប័នកាលពីថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩២ ក្នុងមាត្រា២១ ៖ រដ្ឋជាភាគីទទួលស្គាល់និង ឬ អនុញ្ញាតនូវប្រព័ន្ធសុំកូនចិញ្ចឹម ត្រូវធានាថាផលប្រយោជន៍ដ៏ល្អបំផុតរបស់កុមារ គឺជាមូលដ្ឋានចម្បងនៅក្នុងបញ្ហានេះ និង អនុសញ្ញាស្តីពីការការពារកុមារ និង សហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស ដែលកម្ពុជាបានចូលជាភាគីកាលពីថ្ងៃទី ០១ ខែសីហា ឆ្នាំ ២០០៧។ ច្បាប់នេះត្រូវបាន ប្រកាសប្រើដោយព្រះរាជក្រមលេខ រដ្ឋជាភាគីទទួលស្គាល់និង ឬ អនុញ្ញាតនូវប្រព័ន្ធសុំកូនចិញ្ចឹម ត្រូវធានាថាផលប្រយោជន៍ដ៏ល្អបំផុតរបស់កុមារ គឺជាមូលដ្ឋានចម្បងនៅក្នុងបញ្ហានេះ និង អនុសញ្ញាស្តីពីការការពារកុមារ និង សហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស ដែលកម្ពុជាបានចូលជាភាគីកាលពីថ្ងៃទី ០១ ខែសីហា ឆ្នាំ ២០០៧។ ច្បាប់នេះត្រូវបាន ប្រកាសប្រើដោយព្រះរាជក្រមលេខ ៖ នស/រកម/១២០៩/០២៤ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ ២០០៩ (ប្រកាសជាប្រញាប់)។ ច្បាប់នេះ មានដែនសមត្ថកិច្ចទៅលើវិស័យសុំកូនអន្តរប្រទេស និង រួមទាំងប្រកាសនានារបស់ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និង យុទ្ធជន និង យុវនីតិសម្បទា។ ជារួម សុំកូន មានការយកចិត្តទុកដាក់យ៉ាងពីអ្នកដែលពាក់ព័ន្ធសំខាន់ៗ ដូចជា រាជរដ្ឋាភិបាល ស្ថានទូត និង អង្គការក្រៅរាជរដ្ឋាភិបាល។ពិសេស ក្រសួងសង្គមកិច្ចផ្ទាល់ ដែលជាស្ថាប័នសំខាន់ជាងគេក្នុងការទទួលបន្ទុកទៅលើវិស័យនេះ មួយវិញទៀត សុំកូនអាចប្រព្រឹត្តទៅបាន លុះត្រាតែមានសេចក្តីសម្រេចចេញពីតុលាការ។

គិតពីឆ្នាំ ១៩៩៨ រហូតដល់មានសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់សុំកូនអន្តរប្រទេស របស់ក្រសួងសង្គមកិច្ចអតីតជន យុវនីតិសម្បទា ត្រឹមថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ កុមារកំព្រា ចំនួន **២.៦៣៣**នាក់ ក្នុងនោះកុមារី **១.៤៥៧**នាក់ ត្រូវបានសុំយកទៅចិញ្ចឹមនៅបរទេស ដែលក្នុង នោះមាន អាមេរិក បារាំង កាណាដា អូស្ត្រាលី អង់គ្លេស អ៊ីតាលីជាដើម។ តួលេខចេញពី ក្រសួងសង្គមកិច្ចបង្ហាញថា មានកុមារ ៣៨០០នាក់ ត្រូវបានសុំយកទៅចិញ្ចឹម នៅបរទេសពីចន្លោះ ឆ្នាំ១៩៩៧ ដល់ ២០០៩ ។ ក្រោយមកកម្ពុជា បានផ្អាកសុំកូនអន្តរប្រទេសវិញ ចាប់តាំងពីឆ្នាំ ២០១១មក ដោយមើលឃើញថា កុមារកម្ពុជាមួយចំនួនរងគ្រោះ និងមានករណីជួញដូរកុមារ ដែលស្ថិតក្រោមស្លាកសុំកូនអន្តរប្រទេស។ គិតពីឆ្នាំ១៩៨៧ ដល់ខែមេសា ឆ្នាំ២០១១ កម្ពុជា បានរកគ្រួសារល្អឲ្យទារក និងកុមារកំព្រា ដែលត្រូវបានគេបោះបង់ចោលសរុបចំនួន ៣.៧២៨ នាក់។ ទោះបីជាយ៉ាងណាក្តី រាជរដ្ឋាភិបាលកាលនោះប្រកាសថា នឹងចាប់ផ្តើមបើកឲ្យមានការសុំកូនយក ទៅចិញ្ចឹមនៅបរទេសឡើងវិញ នៅដើមឆ្នាំ២០១៣ ក្រោយពីបានផ្អាកចាប់តាំងពីឆ្នាំ ២០០៩ និង ២០១១ មក ។

ទោះបីជានីតិវិធីនៃដំណើរការសុំកូនត្រូវបានបញ្ចប់ក៏ពិតមែន ប៉ុន្តែមិនមានន័យថា ចប់ បញ្ហាដែលទាក់ទងនឹងកូនសុំទាំងនោះបានទេ។ បន្ទាប់ពីចប់នីតិវិធីនៃសុំកូន កូនសុំត្រូវធានាថា ទទួលបានឋានៈ សិទ្ធិ និងករណីកិច្ចដូចគ្នានឹងកូនបង្កើតដែរ។ មានន័យថា កូនចិញ្ចឹមត្រូវបាន ឪពុកម្តាយចិញ្ចឹមទទួលស្គាល់ និងគិតគូរពីអនាគតដូចកូនបង្កើតរបស់ខ្លួន។ កូនសុំត្រូវទទួលបានសិទ្ធិ ថែទាំជាអចិន្ត្រៃយ៍ ទាំងផ្នែកសុខភាព អនាម័យ សម្លៀកបំពាក់ និងចំណីអាហារ ការអភិវឌ្ឍន៍ ផ្នែកសង្គម និងវប្បធម៌។ ពិសេស កូនសុំក៏ទទួលបានការសិក្សាអប់រំជាចំបង ការទូន្មាន ប្រៀនប្រដៅ និងភាពកក់ក្តៅពីឪពុកម្តាយចិញ្ចឹមគ្រប់ពេលវេលា។

# អនុសាសន៍

បើតាមការវិភាគរបស់យើងខ្ញុំផ្ទាល់ ការសុំកូនក្នុងប្រទេសមិនសូវមានបញ្ហាចោទនោះទេ ដោយឡែក សុំកូនអន្តរប្រទេសពិតជាមានលក្ខណៈស្មុគស្មាញនៅឡើយ ទោះបីកម្ពុជាមានច្បាប់ដោយឡែកមួយស្តីពីសុំកូនអន្តរប្រទេសក៏ដោយ ដោយសារតែការអនុវត្តនេះវាមិនអាស្រ័យលើច្បាប់ និងអាជ្ញាធរនៃប្រទេសតែមួយ ហេតុបែបនេះហើយបានជាដំណើរការ នៃនីតិវិធីមានលក្ខណៈមិន សូវស្របគ្នាខ្លះ។ វាពិតជាល្អណាស់ ប្រសិនបើការរៀបចំបទដ្ឋានច្បាប់ និងនីតិវិធីថ្នាក់ជាតិឲ្យត្រូវ តាមស្តង់ដារអន្តរជាតិ និងកិច្ចសហប្រតិបត្តិការគ្រប់គ្រាន់រវាងប្រទេសកំណើតរបស់កូនសុំ និងប្រទេស ទទួល ។

បន្ថែមលើនេះ រាជរដ្ឋាភិបាលត្រូវមានចំណាត់ការខ្ពស់ ដោយចាត់ទុកការងារសុំកូនអន្តរប្រទេស ជាគោលនយោបាយមួយក្នុងគោលដៅមនុស្សធម៌ ដោយផ្សារភ្ជាប់ការគោរពអនុវត្តសិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារ និងទប់ស្កាត់អំពើជួញដូរកុមារតាមរយៈសុំកូនអន្តរប្រទេស។ ពិសេស គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ គួររៀបចំសិក្ខាសាលាឲ្យបានញឹកញាប់ក្នុងគោលបំណង ដើម្បី ចែករំលែកពត៌មានអំពីស្ថានភាពសុំកូនអន្តរប្រទេស នៃព្រះរាជាណាចក្រកម្ពុជានាពេលបច្ចុប្បន្នជូនមជ្ឈដ្ឋានជាតិ និងអន្តរជាតិ បូករួមក្រសួងដែលពាក់ព័ន្ធ តំណាងស្ថានទូត និងទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលមានបំណងចង់ធ្វើប្រតិបត្តិការសុំកូននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មួយវិញទៀត យើងត្រូវដឹងថា កុមារនឹងទារកកំព្រាមិនអាចរស់នៅបានដោយសុខស្រួលទេ ប្រសិនបើមិនមានការថែទាំពីគ្រួសារ ប៉ុន្តែក្នុងករណីដែលមិនមែនគ្រួសារថែទាំពួកគេទេ សាច់ញាតិបន្ទាប់ គឺជាអ្នកមើលថែ ហើយប្រសិនជាមិនមានទៀត គឺនឹងមានការដាក់ឲ្យសុំកូននៅក្នុងប្រទេស ក្នុងករណីដែលមិនអាចទៅរួចទៀត គឺសុំកូនអន្តរប្រទេសត្រូវបានយកមកអនុវត្តដែល ជាជម្រើសចុងក្រោយ។

ជាការពិត ការសុំកូននៅក្នុងប្រទេស និងអន្តរប្រទេស គឺសុទ្ធតែពាក់ព័ន្ធទៅលើវិស័យ លើកស្ទួយឧត្តមប្រយោជន៍របស់កុមារ។ រាល់កុមារកំព្រា និងកុមារដែលត្រូវការនូវកិច្ចការពារ ពិសេស ជាកម្មវត្ថុចំបងមួយក្នុងការអភិវឌ្ឍន៍ធនធានមនុស្សសំរាប់បំរើប្រទេសជាតិ ។

# ឧបសម្ព័ន្ធ

# ច្បាប់

# ស្តីពី

# សុំកូនអន្តរប្រទេស

# ព្រះរាជក្រម

នស/រកម/១២០៩/០២៤

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីសុំកូនអន្តរប្រទេស ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៩ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៦ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ៖

# ច្បាប់

# ស្តីពី

# ស្ទុំភ្ជួនអន្តរប្រទេស



## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–**

ច្បាប់នេះ មានគោលដៅកំណត់ពីគោលការណ៍ លក្ខខណ្ឌ នីតិវិធី ទម្រង់បែបបទ និង អានុភាពនៃសុំកូនអន្តរប្រទេស ។

**មាត្រា ២.–**

ច្បាប់នេះ មានគោលបំណងធានាឧត្តមប្រយោជន៍ និង ការពារសិទ្ធិជាមូលដ្ឋានរបស់កុមារ ដែលជាកម្មវត្ថុនៃសុំកូនអន្តរប្រទេស ។

**មាត្រា ៣.–**

ច្បាប់នេះ មានវិសាលភាពលើការសុំកុមារសញ្ជាតិខ្មែរ ដែលមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយប្តីប្រពន្ធ ដែលមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងប្រទេសណាមួយផ្សេងទៀត ដើម្បីយកទៅចិញ្ចឹមជាកូន ដែលទទួលស្គាល់ដោយច្បាប់នៅប្រទេសនោះ ។

**មាត្រា ៤.–**

វាក្យស័ព្ទសំខាន់ៗ ដែលប្រើប្រាស់ក្នុងច្បាប់នេះ មាននិយមន័យដូចតទៅ :

- **ការថែទាំជំនួស** សំដៅដល់ការថែទាំ ដែលផ្តល់ទៅឱ្យកុមារកំព្រា និង កុមារងាយរងគ្រោះ ដែលមិនស្ថិតនៅក្រោមការថែទាំរបស់ឪពុកម្តាយបង្កើតនៃកុមារទាំងនោះ ។
- **កុមារដែលត្រូវការការថែទាំពិសេស** សំដៅដល់កុមារពិការផ្នែករាងកាយ សម្បទាផ្លូវកាយ ឬ ពិការផ្នែកស្មារតី ឬ កុមារដែលមានជំងឺរ៉ាំរ៉ៃ ។
- **កុមារដែលត្រូវបានបោះបង់ចោល** សំដៅដល់កុមារដែលអាជ្ញាធរមានសមត្ថកិច្ចរកឃើញ ឬ ត្រូវបានសាធារណជនរាយការណ៍ទៅអាជ្ញាធរមានសមត្ថកិច្ច និង ជាកុមារដែលមិនស្គាល់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ ជាកុមារដែលឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនបោះបង់ចោល ហើយ មិនអាចរកឃើញអ្នកទាំងនោះ យ៉ាងតិច ៥ (ប្រាំ) ខែជាប់គ្នា ។

- **ជនម្នាក់** សំដៅដល់ជនដែលគ្មានសហព័ទ្ធស្របច្បាប់ ។

- **ទីភ្នាក់ងារសុំកូនអន្តរប្រទេស** សំដៅដល់ទីភ្នាក់ងារដែលបានទទួលការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចនៃព្រះរាជាណាចក្រកម្ពុជា និង ពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសទទួលកូនសុំ ដើម្បីធ្វើប្រតិបត្តិការក្នុងនីតិវិធីសុំកូនអន្តរប្រទេស ។

- **បុគ្គលភាព** សំដៅដល់ខ្សែញាតិ ដែលទាក់ទងពីឪពុកម្តាយទៅកូនបង្កើតរបស់ខ្លួន ។

- **ប្រទេសដែលជនរស់នៅជាអចិន្ត្រៃយ៍** សំដៅដល់ប្រទេសដែលជនណាមួយកំពុងរស់នៅដោយមានបំណងយកប្រទេសនោះធ្វើជាលំនៅឋានអចិន្ត្រៃយ៍ ។ ជននោះត្រូវបានទទួលស្គាល់ដោយច្បាប់នៃប្រទេសដែលខ្លួនរស់នៅ ថាមានសិទ្ធិរស់នៅជាអចិន្ត្រៃយ៍នៅក្នុងប្រទេសនោះ ។

- **មណ្ឌលកុមារកំព្រា** សំដៅដល់មណ្ឌលរបស់រដ្ឋ ឬ របស់អង្គការមិនមែនរដ្ឋាភិបាល ដែលទទួលស្គាល់ដោយក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច សម្រាប់ចិញ្ចឹមថែទាំ និង ផ្តល់នូវតម្រូវការជាមូលដ្ឋានគ្រប់យ៉ាងក្នុងការអភិវឌ្ឍរបស់កុមារដែលគ្មានឪពុកម្តាយ ឬ គ្មានឪពុក ឬ គ្មានម្តាយ ឬ កុមារ ដែលត្រូវបោះបង់ចោល ឬ កុមារដែលឪពុកម្តាយ ឬ អ្នកអាណាព្យាបាលពុំមានលទ្ធភាពផ្តល់ការថែទាំគ្រប់គ្រាន់ ។

- **ប្តីប្រពន្ធ** សំដៅដល់បុរសម្នាក់ និង ស្ត្រីម្នាក់ដែលមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ ។

- **សុំកូនដោយសាច់ញាតិ** សំដៅដល់ការសុំកូនដោយអ្នកសុំនូវកុមារដែលត្រូវជាចៅរបស់ខ្លួន ចៅទួតរបស់ខ្លួន ក្មួយរបស់ខ្លួន ឬ កុមារដែលត្រូវជាកូន ចៅ ចៅទួត ឬ ក្មួយរបស់សហព័ទ្ធរបស់ខ្លួន ។

- **សុំកូនពេញលេញ** សំដៅដល់សុំកូនដែលមានអានុភាពបង្កើតនូវទំនាក់ទំនងអចិន្ត្រៃយ៍ ជាឪពុកម្តាយ និង កូនរវាងឪពុកម្តាយចិញ្ចឹម ឬ ឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹម និង កូនសុំ និង បញ្ចប់សិទ្ធិ និង កាតព្វកិច្ចរវាងកូនជាមួយឪពុកម្តាយបង្កើត ឬ អ្នកអាណាព្យាបាល ចំពោះកូនរបស់ខ្លួន ។

- **អ្នកសុំ** សំដៅដល់ប្តីប្រពន្ធដែលកំពុងស្វះស្វែងសុំកុមារយកទៅចិញ្ចឹម ។

- **ឪពុកម្តាយចិញ្ចឹម** សំដៅដល់ប្តីប្រពន្ធដែលបានទទួលសិទ្ធិជាផ្លូវការពី

តុលាការមានសមត្ថកិច្ច ឲ្យធ្វើជាឪពុកម្តាយថ្មីនៃកូនសុំស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងច្បាប់នេះ ។

## ជំពូកទី ២

## គោលការណ៍ទូទៅនៃសុំកូនអន្តរប្រទេស

មាត្រា ៥.-

សុំកូនអន្តរប្រទេសត្រូវអនុវត្តតាមគោលការណ៍ដូចតទៅ :

១- កុមារត្រូវចម្រើនធំធាត់នៅក្នុងបរិយាកាសគ្រួសារ បរិយាកាសសុភមង្គល សេចក្តីស្រឡាញ់ និង ការយោគយល់ ដើម្បីឲ្យមានការអភិវឌ្ឍពេញលេញ និង យ៉ាងសុខដុមនូវបុគ្គលិកលក្ខណៈរបស់ខ្លួន ។ សុំកូនអន្តរប្រទេស អាចអនុញ្ញាតបានក្រោយពីអស់លទ្ធភាពផ្តល់ការឧបត្ថម្ភគាំទ្រ ដើម្បីឲ្យកុមាររស់នៅក្នុងគ្រួសារកំណើត និង ក្រោយពីបានធ្វើការពិចារណា អំពីសុំកូននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- សុំកូនអន្តរប្រទេស អាចប្រព្រឹត្តទៅបានលុះត្រាតែជាសុំកូនពេញលេញដែលបង្កើតនូវទំនាក់ទំនងរវាងអ្នកសុំ និង កូនសុំជាអចិន្ត្រៃយ៍ និង ដែលផ្តល់ដល់កុមារនូវឋានៈ សិទ្ធិ និង ភារកិច្ចដូចជាកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹមនោះ ។

៣- កុមារទាំងឡាយណាដែលបំពេញបាននូវលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១០ អាចធ្វើជាកម្មវត្ថុនៃសុំកូនអន្តរប្រទេសបានដោយមិនមានការរើសអើងអំពីពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា មនោគមវិជ្ជានយោបាយ ដើមកំណើតជាតិកំណើត ឋានៈក្នុងសង្គម ធនធានពិការភាព ឬ ស្ថានភាពផ្សេងៗទៀតរបស់កុមារ ឬ របស់ឪពុកម្តាយ ឬ របស់ឪពុក ឬ របស់ម្តាយ ឬ របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ។

៤- រាល់ការសម្រេច និង សកម្មភាពទាក់ទងនឹងដំណើរការសុំកូនអន្តរប្រទេសត្រូវគិតគូរឲ្យបានច្រើនលើសលប់ដល់ឧត្តមប្រយោជន៍របស់កុមារ ។

៥- តុលាការ និង អាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធក្នុងដំណើរការសុំកូនអន្តរប្រទេសត្រូវធានាថា នៅពេលកំពុងដំណើរការនីតិវិធីសុំកូន កុមារដែលមានសមត្ថភាពអាចយល់ដឹងបាន ត្រូវបានពិគ្រោះយោបល់ និង ពន្យល់ណែនាំឲ្យបានត្រឹមត្រូវអំពីអានុភាព

នានា ដែលកើតចេញពីសុំកូននេះដោយគិតគូរដល់សេចក្តីប្រាថ្នា និង មតិរបស់កុមារ ដើម្បីឧត្តមប្រយោជន៍របស់កុមារ ។

២- ហាមការធ្វើអាជីវកម្ម ឬ ធ្វើសកម្មភាពយកផលកម្រៃពីសុំកូនអន្តរប្រទេស ។

អាជីវកម្ម ឬ សកម្មភាពយកផលកម្រៃពីសុំកូនអន្តរប្រទេសមាន ៖

- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ញុះញង់ដោយផ្ទាល់ដល់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឱ្យបោះបង់ទារកដែលកើតមកហើយ ឬ ដែលនឹងកើតដើម្បីឱ្យប្រគល់កូនតាមរយៈសុំកូនអន្តរប្រទេស
- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ធ្វើជាអន្តរការីរវាងប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និង ឪពុក ឬ ម្តាយដែលចង់បោះបង់កូនដែលកើតមកហើយ ឬ ដែលនឹងកើត និង
- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃធ្វើជាអន្តរការីរវាងប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និង ស្ត្រីម្នាក់យល់ព្រមពពោះដើម្បីនឹងប្រគល់កូននោះទៅឱ្យអ្នកសុំ ។

៣- អាជ្ញាធរមានសមត្ថកិច្ច ដែលពាក់ព័ន្ធក្នុងនីតិវិធីសុំកូនអន្តរប្រទេស ត្រូវធានាថាដំណើរការសុំកូនអន្តរប្រទេស មិនបណ្តាលឱ្យមានការទទួលផលកម្រៃផ្នែកហិរញ្ញវត្ថុដោយមិនស្របច្បាប់ និង ត្រូវបង្ការមិនឱ្យមានការចាប់ពង្រត់ ការលក់ និង ការជួញដូរកុមារក្នុងពេលកំពុងដំណើរការសុំកូនអន្តរប្រទេស ។ មានតែប្រាក់ចំណាយ សោហ៊ុយ និង វិភាគទាន ដែលកំណត់ដោយបទប្បញ្ញត្តិនៃច្បាប់នេះដែលត្រូវបង់ ។

## ជំពូកទី ៣
## អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស

**មាត្រា ៦.-**

ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច បំពេញតួនាទីជាអាជ្ញាធរកណ្តាលសុំកូនអន្តរ

ROYAUME DU CAMBODGE · LE MINISTÈRE DU PALAIS

មាត្រា ៧.–

អាជ្ញាធរកណ្ដាលសុំកូនអន្តរប្រទេសមានតួនាទី និង ភារកិច្ចដូចតទៅ ៖

១- រៀបចំ និង ត្រួតពិនិត្យការអនុវត្តគោលនយោបាយ ច្បាប់ បទបញ្ញត្តិ និង នីតិវិធីទាក់ទងនឹងការសម្រេចលើកិច្ចការសុំកូនអន្តរប្រទេស ។

២- ធ្វើសហប្រតិបត្តិការ និង ធ្វើការសម្របសម្រួលលើការប្រាស្រ័យទាក់ទងគ្នា ទាក់ទងនឹងកិច្ចការសុំកូនអន្តរប្រទេសជាមួយក្រសួង ស្ថាប័ន និង ទីភ្នាក់ងារដែលមានសមត្ថកិច្ចដោះស្រាយកិច្ចការសុំកូនអន្តរប្រទេស នៅក្នុងព្រះរាជាណាចក្រកម្ពុជា និង ជាមួយអាជ្ញាធរកណ្ដាល និង អាជ្ញាធរមានសមត្ថកិច្ច ទទួលបន្ទុកសុំកូនអន្តរប្រទេស នៃប្រទេសទទួល ។

៣- ចាត់វិធានការសមស្របដើម្បីបង្ការ និង ទប់ស្កាត់ ការទទួលផលកម្រៃផ្នែកហិរញ្ញវត្ថុដោយមិនសមស្រប ឬ ផលចំណេញផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេស ។

៤- រៀបចំបណ្ដុះបណ្ដាលជំនាញកិច្ចការសុំកូនអន្តរប្រទេសដល់មន្ត្រីពាក់ព័ន្ធ ។

៥- ពិនិត្យលើសំណើរបស់រដ្ឋបាលសុំកូនអន្តរប្រទេស ទាក់ទងនឹងករណីសុំកូនអន្តរប្រទេសនីមួយៗតាមការចាំបាច់ ។

៦- ធ្វើអធិការកិច្ចលើកិច្ចការពាក់ព័ន្ធសុំកូនអន្តរប្រទេស ។ គ្មានជនណាអាចរារាំង បង្អាក់ ឬ ជ្រៀតជ្រែកក្នុងការងារអធិការកិច្ចដែលបានធ្វើឡើងត្រឹមត្រូវតាមច្បាប់បានឡើយ ។

៧- បំពេញភារកិច្ចផ្សេងៗទៀតដែលក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច យល់ថាចាំបាច់សម្រាប់អនុវត្តកិច្ចការសុំកូនអន្តរប្រទេស ដោយអនុលោមទៅតាមច្បាប់ និង បទបញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៨.–

អាជ្ញាធរកណ្ដាលសុំកូនអន្តរប្រទេស មានរដ្ឋបាលសុំកូនអន្តរប្រទេសជាសេនាធិការ ។ មន្ត្រីបម្រើការក្នុងរដ្ឋបាលសុំកូនអន្តរប្រទេសរួមមាន អ្នកធ្វើការងារផ្នែកសង្គមកិច្ច [illegible] និង អ្នកជំនាញខាងច្បាប់បានទទួលការបណ្ដុះបណ្ដាលពិសេស ស្ដីពីសុំកូន

ការរៀបចំ និង ការប្រព្រឹត្តទៅរបស់រដ្ឋបាលស្មុំកូនអន្តរប្រទេស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

មាត្រា ៩.–

រដ្ឋបាលស្មុំកូនអន្តរប្រទេស មានតួនាទី និង ភារកិច្ចដូចតទៅ :

១-រៀបចំ ថែរក្សាបញ្ជីសម្គាល់ និង សំណុំឯកសាររបស់កុមារដែលមានលក្ខណ-សម្បត្តិសមស្របសម្រាប់ស្មុំកូនអន្តរប្រទេស ។

២-វាយតម្លៃស្ថានភាពកុមារទាំងអស់ ដែលមានឈ្មោះក្នុងបញ្ជីសម្គាល់ដើម្បីកំណត់ទម្រង់នៃការចិញ្ចឹមថែទាំសមស្របបំផុតសម្រាប់កុមារ និង ធានាថាកុមារទាំងនោះទទួលបានការចិញ្ចឹមថែទាំតាមតម្រូវការ ។

៣-ប្រឹងប្រែងរកដំណោះស្រាយឱ្យអស់លទ្ធភាពក្នុងប្រទេស ក្នុងការថែទាំជាអចិន្ត្រៃយ៍នៅតាមគ្រួសារ ឬ នៅជាមួយអ្នកអាណាព្យាបាល មុននឹងដំណើរការស្មុំកូនអន្តរប្រទេស ។

៤-ទទួលពិនិត្យ និង ចាត់ការពាក្យសុំកូនអន្តរប្រទេស និង ឯកសារពាក់ព័ន្ធផ្សេងៗទៀតរបស់អ្នកសុំ ។

៥-ផ្គូផ្គងអ្នកសុំជាមួយកុមារដែលមានលក្ខណសម្បត្តិសមស្របសម្រាប់ស្មុំកូនអន្តរប្រទេស និង ផ្តល់មតិយោបល់លើករណីស្មុំកូនអន្តរប្រទេស ជូនរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

៦-ផ្តល់ព័ត៌មានទៅអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ច ឬ ទីភ្នាក់ងារស្មុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាតពីប្រទេសទទួល អំពីនីតិវិធីស្មុំកូន និង ការវិវត្តនៃករណីស្មុំកូន ។

៧-សម្របសម្រួលការប្រគល់កុមារទៅឱ្យអ្នកសុំ និង រៀបចំឯកសារ ដើម្បីឱ្យកុមារធ្វើដំណើរចូលទៅប្រទេសរបស់អ្នកសុំ ។

៨-ផ្តល់ ឬ សម្របសម្រួលការផ្តល់សេវាក្រោយស្មុំកូនសមស្របដល់កុមារ [illegible] និង គ្រួសារបង្កើតតាមការចាំបាច់ ។

[illegible]ផ្តល់មតិយោបល់ទាក់ទងនឹងការផ្តល់ការអនុញ្ញាតឱ្យទីភ្នាក់ងារស្មុំកូនអន្តរ-

៩/៩៩-

ប្រទេស ធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេស ឬ ការដកហូតការអនុញ្ញាត ជូនអាជ្ញាធរកណ្ដាល ទទួលខុសត្រូវកិច្ចការសុំកូនអន្តរប្រទេស ។

១០- បំពេញការកិច្ចផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេសតាមការចាំបាច់ ដោយអនុលោមទៅតាមច្បាប់ និង បទបញ្ញា របស់ព្រះរាជាណាចក្រកម្ពុជា និង តាមការប្រគល់អំណាចរបស់អាជ្ញាធរកណ្ដាល ។

## ជំពូកទី ៤
## លក្ខខណ្ឌសម្រាប់សុំកូន
### ផ្នែកទី ១
### កូនសុំ

**មាត្រា១០...**

កុមារដែលអាចជាកម្មវត្ថុនៃសុំកូនអន្តរប្រទេសបាន ត្រូវឆ្លើយតបនឹងលក្ខខណ្ឌទាំងអស់ ដូចខាងក្រោម ៖

១- កុមារសញ្ជាតិខ្មែរដែលមានលំនៅឋានជាអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា ។

២-កុមារមានអាយុក្រោម៨ (ប្រាំបី) ឆ្នាំ គិតត្រឹមថ្ងៃទទួលពាក្យសុំ លើកលែងតែករណីកុមារត្រូវការនូវការថែទាំពិសេស ដែលអាចអនុញ្ញាតបានដល់អាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។ ក្នុងករណី កុមារមានបងប្អូនបង្កើតច្រើននាក់ ហើយម្នាក់មានអាយុក្រោម ៨ (ប្រាំបី) ឆ្នាំ អាចអនុញ្ញាតឱ្យសុំកុមារនោះរួមជាមួយនឹងបងប្អូនបង្កើតដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។

៣- កុមារកំពុងរស់នៅក្នុងមណ្ឌលកុមារកំព្រា ឬ រស់នៅក្រោមការទុកដាក់សមស្របផ្សេងទៀត ដែលត្រូវត្រួតពិនិត្យដោយក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

៤- កុមារទាំងនោះស្ថិតក្រោមអាណាព្យាបាលសម្រាប់អនីតិជន ឬ កុមារដែល[illegible]អំណាចមេបាដែលមានស្ថានភាពលំបាកបំផុត ។

៥- កុមារនោះត្រូវបានប្រកាសថាអាចសុំជាកូនចិញ្ចឹមបាន ដោយអនុលោមតាមមាត្រា ១[illegible] នៃច្បាប់នេះ ។

ក្នុងករណីស្នើសុំដោយសាច់ញាតិ ស្ថិតក្រោមអនុញ្ញាតបានចំពោះកុមារមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ដែលរស់នៅក្នុង ឬ ក្រៅមណ្ឌលកុមារកំព្រា ។

មាត្រា ១១.-

ករណីមានកុមារត្រូវបានរកឃើញ និង បញ្ជូនមកមណ្ឌលកុមារកំព្រា ហើយរកមិនឃើញឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ សាច់ញាតិ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ប្រធានមណ្ឌលកុមារកំព្រា ត្រូវជូនដំណឹងទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត អំពីវត្តមានរបស់កុមារ ដែលបានបញ្ជូនមកស្នាក់នៅក្នុងមណ្ឌល យ៉ាងយូរបំផុតរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីពេលដែលកុមារមកដល់មណ្ឌល ។ មន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ត្រូវជូនដំណឹងជាបន្ទាន់ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីបញ្ចូលឈ្មោះកុមារទៅក្នុងបញ្ជី ស្ដីពីកុមារដែលត្រូវបានរាយការណ៍ថាត្រូវបានគេបោះបង់ចោល ។

មន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ត្រូវប្រឹងប្រែងគ្រប់លទ្ធភាពដើម្បីស្វែងរកឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ សាច់ញាតិ និង អ្នកអាណាព្យាបាលសម្រាប់អនីតិជនមុន នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដោយប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសាធារណៈទៅតាមលទ្ធភាពជួចជា ទូរទស្សន៍ វិទ្យុ ឬ សារព័ត៌មាន និង រូបភាពរបស់កុមារនោះ ។ ជនណាដែលអះអាងថាខ្លួនជាឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ សាច់ញាតិ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ជននោះត្រូវបង្ហាញភស្តុតាងផ្សេងៗ ដែលបញ្ជាក់ថាខ្លួនមានជាប់ទាក់ទងជាសាច់ញាតិ ឬ អ្នកអាណាព្យាបាល សម្រាប់អនីតិជនជាមួយកុមារស្របទៅតាមបទប្បញ្ញត្តិជាធរមាន ។

បន្ទាប់ពីការផ្សព្វផ្សាយដំណឹងរយៈពេល ៥ (ប្រាំ) ខែ នៅតែរកមិនឃើញឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ សាច់ញាតិ និង អ្នកអាណាព្យាបាល សម្រាប់អនីតិជនមុននោះ មន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍ស្ដីពីការទិតទិស្រាវជ្រាវនេះ ហើយត្រូវផ្ញើមួយច្បាប់ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីចុះឈ្មោះកុមារទៅក្នុងបញ្ជីស្ដីពីកុមារដែលត្រូវបោះបង់ចោល ។

ចាប់ពីពេលដែលកុមារត្រូវបានរកឃើញ រហូតដល់តុលាការបានជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ប្រធានមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត គឺជាអ្នកអាណាព្យាបាលសម្រាប់អនីតិជនបណ្តោះអាសន្ន ។ បញ្ញត្តិស្តីពីអាណាព្យាបាលសម្រាប់អនីតិជនដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ត្រូវយកអនុវត្តផងដែរ ចំពោះអ្នកអាណាព្យាបាលសម្រាប់អនីតិជនបណ្តោះអាសន្ន ។ អ្នកអាណាព្យាបាលសម្រាប់អនីតិជនបណ្តោះអាសន្ន គ្មានសិទ្ធិផ្តល់ការយល់ព្រមលើសុំកូនទេ ។

ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវរៀបចំបញ្ជី និង បញ្ចូលព័ត៌មានថ្មីៗឱ្យបានទៀងទាត់ស្តីពីកុមារដែលត្រូវគេបោះបង់ចោល ។

ករណីកុមារដែលត្រូវគេបោះបង់ចោលពុំអាចរកឃើញឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ សាច់ញាតិ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ហើយពុំមានសំបុត្រអត្រានុកូលដ្ឋានកំណើត ប្រធានមណ្ឌលកុមារកំព្រា ត្រូវសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតកុមារនោះទៅតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ។

មាត្រា១២.-

ប្រសិនបើ អ្នកអនុវត្តអំណាចមេបាដែលស្ថិតនៅក្នុងស្ថានភាពលំបាកបំផុត បានធ្វើការទុកដាក់កុមារឱ្យនៅក្រោមការថែទាំរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចនោះ ត្រូវបញ្ចូលឈ្មោះកុមារទៅក្នុងសៀវភៅកត់ត្រាកុមារ ដែលត្រូវបានធ្វើការទុកដាក់ឱ្យនៅក្រោមការថែទាំរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចត្រូវរៀបចំបញ្ជី និង បញ្ចូលព័ត៌មានថ្មីៗឱ្យបានទៀងទាត់ស្តីពីកុមារដែលអ្នកអនុវត្តអំណាចមេបារបស់ខ្លួន បានធ្វើការទុកដាក់កុមារឱ្យនៅក្រោមការថែទាំរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

មាត្រា១៣.-

ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចត្រូវខិតខំឱ្យអស់លទ្ធភាពក្នុងការបញ្ជូនកុមារទៅគ្រួសារកំណើត ហើយបើមិនអាចធ្វើទៅបានទេ ត្រូវទុកដាក់កុមារតាមរយៈសុំកូនក្នុងព្រះរាជាណាចក្រកម្ពុជា មុននឹងពិនិត្យរកលក្ខណសម្បត្តិសុំកូនអន្តរប្រទេស

នៅពេលវិធានការតាមដាន ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ត្រូវបានបញ្ចប់ កុមារអាចនឹងត្រូវបានបញ្ចូលឈ្មោះទៅក្នុងបញ្ជីឈ្មោះកុមារដែលកំណត់ថាមានលក្ខណៈសម្បត្តិសមស្របសម្រាប់សុំកូនអន្តរប្រទេស ។

## ផ្នែកទី ២
## ការយល់ព្រមលើសុំកូន

**មាត្រា១៤.-**

ដំណើរការសុំកូនអាចប្រព្រឹត្តទៅបានលុះត្រាតែមានការយល់ព្រមរបស់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារតាមករណីដូចខាងក្រោមនេះ :

ក- ក្នុងករណីកុមារមានចំណងបុត្តភាពជាមួយឪពុក និង ម្តាយ ការយល់ព្រមត្រូវផ្តល់ដោយឪពុក និង ម្តាយរបស់កុមារនោះ ។

ខ- ក្នុងករណីដែលឪពុក ឬ ម្តាយណាមួយរបស់កុមារបានស្លាប់ ឬ ស្ថិតក្នុងស្ថានភាពដែលមិនអាចបង្ហាញឆន្ទៈបាន ឬ ត្រូវបានដកហូតអំណាចមេបា ការយល់ព្រមត្រូវផ្តល់ដោយឪពុក ឬ ម្តាយតែម្ខាងដែលមានអំណាចមេបាជាការគ្រប់គ្រាន់ ។

គ- ក្នុងករណីដែលឪពុកម្តាយរបស់កុមារបានស្លាប់ ឬ ស្ថិតនៅក្នុងស្ថានភាពដែលមិនអាចបង្ហាញឆន្ទៈបាន ឬ ត្រូវបានដកហូតអំណាចមេបា ការយល់ព្រមត្រូវផ្តល់ដោយអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារនោះ ។

**មាត្រា១៥.-**

ការយល់ព្រមខាងលើត្រូវផ្តល់ឱ្យដោយសេរី និង ច្បាស់លាស់ដោយមិនត្រូវមានវិការៈណាមួយដូចជា ការបង្ខិតបង្ខំ ការឆបោក ឬ ការបញ្ចុះបញ្ចូលតាមរយៈការផ្តល់ ឬ ការសន្យាផ្តល់ប្រាក់ រង្វាន់ សំណង ឬ ផលប្រយោជន៍ណាមួយឡើយ និង ដោយបាននឹង [illegible] វិបាកនៃការយល់ព្រមរបស់ខ្លួនចំពោះសុំកូនអន្តរប្រទេស ។

មាត្រា១៦.-

ឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ត្រូវទទួលនូវការពិគ្រោះយោបល់ពីភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ច ដែលបានទទួលការអនុញ្ញាតជាមុនសិន មុននឹងផ្ដល់ការយល់ព្រម ។ ភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ច ត្រូវប្រាប់យ៉ាងច្បាស់លាស់ ដល់អ្នកដែលត្រូវផ្ដល់ការយល់ព្រមអំពីអានុភាពនៃការយល់ព្រម ការបញ្ចប់នូវបុត្តភាព ព្រមទាំងការបញ្ចប់សិទ្ធិនិងភាតព្វកិច្ចជាអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន និង ត្រូវប្រាប់អំពីបែបបទ និង រយៈពេលបញ្ឈប់ការយល់ព្រមដូចមានចែងក្នុងមាត្រា ១៧ នៃច្បាប់នេះ ។ ភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ច ត្រូវធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ អំពីការសម្ភាសន៍របស់ខ្លួនជាមួយឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ។

ទោះក្នុងករណីណាក៏ដោយ ការយល់ព្រមត្រូវផ្ដល់សក្ខីកម្មជាលាយលក្ខណ៍អក្សរ នៅចំពោះមុខមេឃុំ ឬ ចៅសង្កាត់ខាងទីលំនៅរបស់ឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ។

មេឃុំ ឬ ចៅសង្កាត់ និងភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ចត្រូវធានាថា រាល់ការយល់ព្រមរបស់ឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ជាការយល់ព្រមដែលគោរពទៅតាមខ្លឹមសារនៃមាត្រា ១៥ នៃច្បាប់នេះ ។

មេឃុំ ឬ ចៅសង្កាត់ ត្រូវចាត់ចែងធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ អំពីការយល់ព្រមនេះ ក្រោយពីបានពិនិត្យថា ភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ចបានពិគ្រោះយោបល់ជាមុនជាមួយឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ និង បានប្រាប់យ៉ាងត្រឹមត្រូវអំពីអានុភាពនៃការយល់ព្រមនេះ ។

មាត្រា១៧.-

ឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារអាចបញ្ឈប់ការយល់ព្រមរបស់ខ្លួនវិញបាន រហូតដល់មុនពេលសេចក្ដីសម្រេចរបស់តុលាការស្ដីពីការ[illegible]ជាស្ថាពរ ។ ការបញ្ឈប់ការយល់ព្រមរបស់ឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននេះ អាចធ្វើជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់ នៅចំពោះមុខមេឃុំ ឬ ចៅសង្កាត់ខាងលំនៅឋានរបស់ខ្លួន ។ មេឃុំ ឬ ចៅសង្កាត់ខាង

លិខេរំហានរបស់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ត្រូវធ្វើកំណត់ហេតុពីកិច្ចការនេះ ហើយត្រូវបញ្ជូនកំណត់ហេតុនេះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ប្រធានមណ្ឌលកុមារកំព្រាដែលពាក់ព័ន្ធ និង ត្រូវប្រគល់កំណត់ហេតុចម្លងដែលមានសេចក្តីបញ្ជាក់នៅលើកំណត់ហេតុនោះ ទៅឱ្យឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ។

មាត្រា១៨.-

នីតិវិធីការសុំកូនអាចប្រព្រឹត្តទៅបាន លុះត្រាតែផុតកំណត់ពេល ៩០ (កៅសិប) ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយការយល់ព្រមរបស់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ។

មាត្រា១៩.-

ករណីឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារបដិសេធការយល់ព្រម ឬ បញ្ឈប់ការយល់ព្រមរបស់ខ្លួន ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អាចប្តឹងសុំឱ្យតុលាការប្រកាសដកហូតអំណាចមេបាពីឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ បញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ និងជ្រើសតាំងអ្នកអាណាព្យាបាលថ្មីសម្រាប់អនីតិជនរបស់កុមារ ក្នុងករណីពិនិត្យឃើញថា ការបដិសេធ ឬ ការបញ្ឈប់ការយល់ព្រមនេះ ធ្វើឱ្យខាតបង់ផលប្រយោជន៍របស់កុមារ ឬ បណ្តាលឱ្យប៉ះពាល់ដល់សុខភាព សុវត្ថិភាព ឬ សីលធម៌របស់កុមារ ។ ពាក្យបណ្តឹងទៅតុលាការត្រូវធ្វើក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ បដិសេធ ឬ បញ្ឈប់ការយល់ព្រមរបស់ខ្លួន ។

មាត្រា២០.-

ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ដែលយល់ថា ការយល់ព្រមរបស់ខ្លួនបានមកពីការបង្ហាញឆន្ទៈដែលមានវិការៈ ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ អាចបញ្ឈប់ ឬ លុបចោលការយល់ព្រមរបស់ខ្លួនបាន រហូតដល់មុនពីការសម្រេចរបស់តុលាការលើសុំកូនទទួល

## ផ្នែកទី ៣
## អ្នកសុំ

មាត្រា ២១.-

អ្នកសុំដែលអាចអនុញ្ញាតឱ្យសុំកុមារយកទៅចិញ្ចឹមជាកូនបាន ត្រូវឆ្លើយតបនឹងលក្ខខណ្ឌ ដូចតទៅ ៖

១-អ្នកសុំជាប្ដីប្រពន្ធត្រូវមានអាយុចាប់ពី ៣០ (សាមសិប) ឆ្នាំ និង មានអាយុលើសកូនសុំយ៉ាងតិច ២២ (ម្ភៃពីរ) ឆ្នាំ និង យ៉ាងច្រើនបំផុត ៤៥ (សែសិបប្រាំ) ឆ្នាំ គិតត្រឹមកាលបរិច្ឆេទដាក់ពាក្យសុំកូន ។

២-ក្នុងករណីដែលអ្នកសុំមិនបានបំពេញតាមចំណុច ១ ខាងលើ ហើយក្នុងករណីសុំកូនឆ្លើយតបនឹងឧត្តមប្រយោជន៍របស់កុមារ សុំកូនអាចអនុញ្ញាតឱ្យបាន ក្នុងស្ថានភាពដូចតទៅ ៖

ក-អ្នកសុំមានដើមកំណើតសញ្ជាតិខ្មែរ សុំកុមារដែលជាសាច់ញាតិរបស់ខ្លួន ឬ

ខ-អ្នកសុំជាសហព័ទ្ធដែលសុំកូននៃសហព័ទ្ធម្ខាងទៀត ឬ

គ-អ្នកសុំ សុំកុមារដែលត្រូវការការថែទាំពិសេស ឬ ស្ថានភាពផ្សេងទៀត ដែលបម្រើឧត្តមប្រយោជន៍របស់កុមារ ។

៣-ក្នុងករណីអ្នកសុំមានប្ដី ឬ ប្រពន្ធ ការសុំកូនត្រូវធ្វើដោយសហព័ទ្ធទាំងពីររួមគ្នា លើកលែងតែករណីដែលសហព័ទ្ធណាម្ខាង សុំកូនបង្កើតនៃសហព័ទ្ធម្ខាងទៀត ។

៤-ច្បាប់ជាតិរបស់អ្នកសុំនីមួយៗ និង ច្បាប់ប្រទេសនៃលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំបានទទួលស្គាល់ និង អនុញ្ញាតនូវបុត្តភាពនៃសុំកូនពេញលេញ ។

៥-ប្រទេសនៃសញ្ជាតិ ឬ ប្រទេសលំនៅឋានអចិន្ត្រៃយ៍នៃអ្នកសុំ ត្រូវតែជាប្រទេសដែលមានទំនាក់ទំនងការទូតជាមួយព្រះរាជាណាចក្រកម្ពុជា ។

៦-អ្នកសុំត្រូវមានលក្ខណសម្បត្តិ និង លក្ខខណ្ឌជាសារវន្តនានាសម្រាប់សុំកូនស្របតាមច្បាប់ប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់ខ្លួន ។

ROYAUME du CAMBODGE
LE MINISTRE du PALAIS ROYAL

៣- អ្នកសុំត្រូវតែជាជនពុំធ្លាប់ត្រូវបានផ្តន្ទាទោស ឬ កំពុងត្រូវបានប្តឹងអំពីកំហុសទាក់ទងទៅនឹងកិរិយាមារយាទ ឬ ការប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយនៅក្នុងប្រទេសនៃសញ្ជាតិរបស់ខ្លួន ឬ ប្រទេសលំនៅឋានអចិន្ត្រៃយ៍ ឬ ក្នុងប្រទេសណាមួយដែលខ្លួនបានស្នាក់នៅក្នុងក្រោយ ។

៤- អ្នកសុំត្រូវតែជាអ្នកមានសមត្ថភាពក្នុងការថែទាំសមស្រប និង ការគាំទ្រចាំបាច់ដល់កូនសុំ ។

៥- អ្នកសុំត្រូវបានអនុញ្ញាតឱ្យសុំកូនបាន លុះត្រាតែអ្នកសុំកូនគ្មានកូន ឬ មានកូនតែម្នាក់នៅក្នុងបន្ទុក ។ អ្នកសុំអាចសុំកូនបានតែម្នាក់ប៉ុណ្ណោះ លើកលែងតែកុមារដែលមានបងប្អូនបង្កើតអាចអនុញ្ញាតឱ្យសុំច្រើននាក់បាន ។

## ជំពូកទី ៥
## នីតិវិធីសុំកូន
### ផ្នែកទី ១
### នីតិវិធីរដ្ឋបាល

**មាត្រា ២២.-**

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវរៀបចំសំណុំឯកសារផ្ទាល់ខ្លួនរបស់កុមារម្នាក់ៗដែលមានលក្ខណៈសម្បត្តិសម្រាប់សុំកូនអន្តរប្រទេសរួមមាន ព័ត៌មានចាំបាច់អំពីអត្តសញ្ញាណរបស់កុមារ ភាពអាចសុំជាកូនចិញ្ចឹម សាវតារជាតិរបស់កុមារ បរិយាកាសសង្គមរបស់កុមារ ប្រវត្តិគ្រួសាររបស់កុមារ ប្រវត្តិសុខភាពរបស់កុមារ និង ប្រវត្តិសុខភាពគ្រួសាររបស់កុមារ និង សេចក្តីត្រូវការជាពិសេសណាមួយរបស់កុមារ ។

ក្នុងករណីកុមារត្រូវបានបោះបង់ចោល រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវធានាថា ការខិតខំប្រឹងប្រែងដើម្បីស្វះស្វែងរកឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ សាច់ញាតិ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារត្រូវបានធ្វើរួចហើយ ។

រដ្ឋបាលសុំកូនអន្តរប្រទេសក៏ត្រូវធានាផងដែរថា រាល់ការយល់ព្រមចាំបាច់ទាំងឡាយត្រូវបានធ្វើឡើងស្របទៅតាមបទប្បញ្ញត្តិនានានៃច្បាប់នេះ ។

សំណុំឯកសារផ្ទាល់ខ្លួនរបស់កុមារ រាប់បញ្ចូលទាំងភស្តុតាងបង្ហាញពីការយល់ព្រម និង/ឬ ការខិតខំប្រឹងប្រែងដើម្បីស្វះស្វែងរកឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ សាច់ញាតិ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារផងដែរ ។

មាត្រា ២៣.-

អ្នកសុំត្រូវដាក់ពាក្យសុំកូនទៅអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា ដោយភ្ជាប់មកជាមួយនូវឯកសារដូចមាន ៖

១-ភស្តុតាងដែលបញ្ជាក់ថា អាជ្ញាធរកណ្តាលនៃប្រទេសដើមរបស់ខ្លួន ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសលំនៅឋានអចិន្ត្រៃយ៍ចាត់ទុកថា អ្នកសុំមានលក្ខណសម្បត្តិ និង មានភាពសមស្របសម្រាប់សុំកូនដោយផ្អែកលើការវាយតំលៃលើជីវប្រវត្តិផ្ទាល់ខ្លួន ប្រវត្តិគ្រួសារ ប្រវត្តិសុខភាព បរិយាកាសគ្រួសារ បរិយាកាសសង្គម មូលហេតុសុំកូន និងលទ្ធភាពនៃការទទួលបន្ទុកភិបាលចំពោះសុំកូនអន្តរប្រទេស ។

២-ព័ត៌មានចាំបាច់ទាក់ទងនឹងការឆ្លើយតបទៅនឹងលក្ខខណ្ឌនានាដែលមានចែងក្នុងមាត្រា ២១ នៃច្បាប់នេះ ។

៣-ព័ត៌មានទាក់ទងនឹងអត្តសញ្ញាណរបស់អ្នកសុំ ដែលក្នុងនោះរួមមានឯកសារទាក់ទងនឹងអត្រានុកូលដ្ឋាន ។

៤-ព័ត៌មានទាក់ទងនឹងលក្ខណសម្បត្តិផ្សេងៗរបស់កុមារ ដែលអ្នកសុំអាចនឹងមានលក្ខណសម្បត្តិថែទាំបាន ។

៥-ភស្តុតាងទទួលបានពីអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទទួលដែលបញ្ជាក់ថា នៅពេលពាក្យសុំកូនរបស់ខ្លួនត្រូវបានយល់ព្រមហើយ កូនសុំនោះត្រូវបានអនុញ្ញាតឱ្យចូលទៅរស់នៅជាអចិន្ត្រៃយ៍ក្នុងប្រទេសទទួល ។

ឯកសារទាំងអស់ ត្រូវបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំ ។

ឯកសារច្បាប់ដើមទាំងអស់ត្រូវភ្ជាប់មកជាមួយនូវការបកប្រែជាភាសាអង់គ្លេស ឬ ភាសាបារាំង ដែលមានការបញ្ជាក់ត្រឹមត្រូវ ។

មាត្រា ២៤.-

ពាក្យសុំកូនមានចែងក្នុងមាត្រា ២៣ នៃច្បាប់នេះ ត្រូវបញ្ជូនមកក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ តាមរយៈអាជ្ញាធរកណ្ដាល ស្ថានទូត ឬ ស្ថានតំណាងនៃប្រទេសទទួលប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដែលបានបញ្ជាក់ពីភាពត្រឹមត្រូវនៃឯកសារទាំងនោះ ។ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ត្រូវពិនិត្យផ្ដល់យោបល់ និង ត្រូវបញ្ជូនសំណុំឯកសារសុំកូនអន្តរប្រទេស ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃបានទទួលពាក្យសុំ ។ ក្នុងរយៈពេលយ៉ាងយូរបំផុត ១៥ (ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃបានទទួលពាក្យសុំពីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរទៅអ្នកសុំ តាមរយៈអាជ្ញាធរកណ្ដាលនៃប្រទេសដើមរបស់អ្នកសុំ ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ តាមរយៈទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសលំនៅឋានអចិន្ត្រៃយ៍ ដោយបញ្ជាក់ថា ខ្លួនបានទទួលពាក្យសុំកូន ។

មាត្រា ២៥.-

អ្នកសុំត្រូវបង់ប្រាក់ចំណាយ សោហ៊ុយ និង វិភាគទាននានា សម្រាប់ជួយឧបត្ថម្ភដល់ជីវភាពនានានៃការថែទាំជូន និង ការជួយឧបត្ថម្ភទៅដល់មណ្ឌលកុមារកំព្រារបស់រដ្ឋទូទាំងប្រទេស និង កម្រៃសេវាចាំបាច់ផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេសដែលនឹងកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។ ក្រៅពីនេះ មិនត្រូវយកថ្លៃសោហ៊ុយសុំកូនពីអ្នកសុំកូន ឬ ទីភ្នាក់ងាររបស់អ្នកសុំកូន ។ មិនអនុញ្ញាតឱ្យអ្នកសុំកូន ឬ ទីភ្នាក់ងាររបស់អ្នកសុំកូនបង់ថ្លៃសោហ៊ុយសុំកូនទៅតាមកុមារម្នាក់ៗ ឬ ទៅតាមសោហ៊ុយសុំកូនមួយៗដែលនឹងត្រូវបញ្ជូនទៅឱ្យមណ្ឌលកុមារកំព្រាណាមួយ ឬ មិនអនុញ្ញាតឱ្យអ្នកសុំកូន ឬ ទីភ្នាក់ងាររបស់អ្នកសុំកូនធ្វើការផ្ដល់សោហ៊ុយ អំណោយ ឬ ការទូទាត់ ទោះក្នុងរូបភាពណាក៏ដោយឱ្យទៅមណ្ឌល[illegible]ដែលកុមារនៅទីនោះត្រូវបានសុំយកទៅចិញ្ចឹម ឬ ទៅឱ្យបុគ្គលិក នាយក ឬ [illegible]នៃគ្រឹះ[illegible]គ្រប់គ្រងនោះជាដោយផ្ទាល់ ឬ ដោយប្រយោលឡើយ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

មាត្រា ២៦.-

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវពិនិត្យសំណុំលិខិតសុំកូនក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃដែលក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចទទួលសំណុំលិខិតសុំកូន ដូចមានចែងក្នុងមាត្រា ២៣ នៃច្បាប់នេះ ។ ក្នុងករណីសំណុំលិខិតមានលក្ខណៈគ្រប់គ្រាន់ហើយ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវបញ្ជាក់ថា អ្នកសុំបានបំពេញលក្ខខណ្ឌត្រឹមត្រូវតាមច្បាប់នេះហើយ ។

ក្នុងករណីដែលសំណុំលិខិតដាក់ជូនរដ្ឋបាលសុំកូនអន្តរប្រទេស មិនទាន់គ្រប់គ្រាន់ ឬ មិនទាន់ត្រឹមត្រូវ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវជូនដំណឹងទៅអ្នកសុំជាលាយលក្ខណ៍អក្សរអំពីឯកសារដែលនៅខ្វះ ឬ មិនទាន់ត្រឹមត្រូវ តាមរយៈអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាតនៃប្រទេសទទួល ។ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវពិនិត្យសំណុំលិខិតសុំកូនក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលឯកសារដែលនៅខ្វះ ឬ កែតម្រូវរួច។

ក្នុងករណីអ្នកសុំខកខានមិនបានផ្តល់ឯកសារដែលនៅខ្វះ ឬ មិនទាន់ត្រឹមត្រូវក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃរដ្ឋបាលសុំកូនអន្តរប្រទេសបានជូនដំណឹងអំពីឯកសារដែលមិនទាន់គ្រប់គ្រាន់ ឬ មិនទាន់ត្រឹមត្រូវ នោះពាក្យសុំកូនអន្តរប្រទេសត្រូវទុកជាមោឃៈ ។

ក្នុងករណីបដិសេធពាក្យសុំ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវមានបញ្ជាក់អំពីមូលហេតុជាលាយលក្ខណ៍អក្សរ ។

មាត្រា ២៧.-

ក្នុងករណីសំណុំលិខិតមានលក្ខណៈគ្រប់គ្រាន់ និង ត្រឹមត្រូវ ហើយអ្នកសុំបានបំពេញទៅតាមលក្ខខណ្ឌនៃច្បាប់នេះ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវពិនិត្យពិចារណាទៅលើសំណុំឯកសារកុមារទាំងឡាយដែលមានលក្ខណសម្បត្តិសម្រាប់សុំកូនអន្តរប្រទេសបាន [illegible]លក្ខណសម្បត្តិរបស់អ្នកសុំណាដែលត្រូវគ្នាល្អបំផុតនឹងលក្ខណសម្បត្តិ[illegible] ។

ក្នុងការផ្តល់ដោយគិតគូរដល់ឧត្តមប្រយោជន៍របស់កុមារ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវពិចារណាឱ្យបានសមស្របទៅលើអត្ថប្រយោជន៍នៃការបន្តឱ្យមានការបីបាច់ ថែរក្សាកុមារ ដូចពេលកន្លងមក ព្រមទាំងពិចារណាទៅលើសាវតារសង្គម ជាតិពន្ធុ សាសនា និងវប្បធម៌របស់កុមារ ។

មាត្រា ២៨.-

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវផ្ញើសំណុំឯកសាររបស់កុមារដែលត្រូវបានផ្តល់ រួមទាំងភស្តុតាងដែលបង្ហាញថា រាល់ការយល់ព្រមចាំបាច់នានា ត្រូវបានទទួលរួចហើយ និងមូលហេតុដែលខ្លួនកំណត់ទុកដាក់កុមារជាមួយអ្នកសុំនោះទៅអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ច ទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ដើម្បីពិនិត្យនិងបញ្ជូនទៅអ្នកសុំដោយមិនចាំបាច់ផ្តល់ព័ត៌មានអំពីអត្តសញ្ញាណឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អតីតជនរបស់កុមារឡើយ លើកលែងតែករណីសុំកូនដោយសាច់ញាតិ ។

មាត្រា ២៩.-

អ្នកសុំត្រូវឆ្លើយតបទៅរដ្ឋបាលសុំកូនអន្តរប្រទេសជាលាយលក្ខណ៍អក្សរ អំពីការយល់ព្រមសុំកុមារ ដែលរដ្ឋបាលសុំកូនអន្តរប្រទេសបានផ្តល់ឱ្យតាមរយៈអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ។

ក្នុងករណីអ្នកសុំមិនបានឆ្លើយតបមករដ្ឋបាលសុំកូនអន្តរប្រទេសក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលរដ្ឋបាលសុំកូនអន្តរប្រទេសបានផ្ញើសំណុំឯកសាររបស់កុមារ រដ្ឋបាលសុំកូនអន្តរប្រទេសអាចចាត់ទុកថា អ្នកសុំបានបញ្ឈប់ពាក្យសុំរបស់ខ្លួន ហើយរដ្ឋបាលសុំកូនអន្តរប្រទេសអាចផ្តល់កុមារនោះឱ្យទៅអ្នកសុំផ្សេងទៀតបាន ។ ប្រាក់ចំណាយ សោហ៊ុយ និងវិភាគទានទាក់ទងនឹងការដាក់ពាក្យសុំមិនត្រូវបានសងត្រឡប់វិញឡើយ ។

ក្នុងករណីអ្នកសុំបានឆ្លើយតបថាមិនទទួលយកកុមារដែលបានផ្ដល់ឱ្យខ្លួននៅលើកទីមួយទេ អ្នកសុំនោះអាចស្នើសុំឱ្យលេខាធិការដ្ឋានសុំកូនអន្តរប្រទេសផ្ដល់កុមារជាលើកទីពីរបាន ។ ការផ្ដល់នេះមិនត្រូវអនុញ្ញាតឱ្យធ្វើជាលើកទីបីឡើយ ។

ចំពោះអ្នកសុំដែលមិនបានឆ្លើយតបក្នុងរយៈពេលកំណត់ដូចមានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រានេះ អ្នកសុំនោះអាចដាក់ពាក្យសុំកូនសាជាថ្មីស្របតាមនីតិវិធីនៃច្បាប់នេះ ។ ក្នុងការសម្រេចអំពីការសុំឱ្យមានការផ្ដល់សាជាថ្មី ឬ ការទទួលពាក្យសុំកូនសាជាថ្មី លេខាធិការដ្ឋានសុំកូនអន្តរប្រទេសត្រូវពិចារណាអំពីមូលហេតុដែលអ្នកសុំខកខានមិនបានឆ្លើយតប ឬ ឆ្លើយតបថា មិនមានបំណងសុំកុមារដែលបានផ្ដល់ពីលើកមុននាពេលកន្លងមក ។

មាត្រា ៣០.-

បន្ទាប់ពីអ្នកសុំ បានបញ្ជាក់ការយល់ព្រមរបស់ខ្លួនស្របតាមបទប្បញ្ញត្តិក្នុងមាត្រា ២៩ នៃច្បាប់នេះ ហើយអាជ្ញាធរកណ្ដាលនៃប្រទេសទទួល បានយល់ព្រមលើការសម្រេចនេះ លេខាធិការដ្ឋានសុំកូនអន្តរប្រទេសតាមរយៈអាជ្ញាធរកណ្ដាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ត្រូវរៀបចំឱ្យមានការជួបគ្នារវាងអ្នកសុំ និង កុមារដែលត្រូវបានផ្ដល់រួចហើយ ។

ការជួបគ្នានេះត្រូវប្រព្រឹត្តទៅតាមកាលបរិច្ឆេទមួយសមស្របសម្រាប់អ្នកសុំ និង លេខាធិការដ្ឋានសុំកូនអន្តរប្រទេស និង ត្រូវមានវត្តមានមន្ត្រីសង្គមកិច្ចមានសមត្ថកិច្ចម្នាក់រួមផង ។ ការជួបគ្នានេះ ត្រូវធ្វើក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទទទួលការយល់ព្រមពីអ្នកសុំ ។

មុនការជួបគ្នារវាងអ្នកសុំ និង កុមារ លេខាធិការដ្ឋានសុំកូនអន្តរប្រទេស ត្រូវធ្វើសម្ភាសន៍អ្នកសុំ និង ធានាថា អ្នកសុំ និង កុមារត្រូវបានរៀបចំខ្លួនជាស្រេចតាមរយៈការពិគ្រោះយោបល់ ការផ្លាស់ប្ដូរព័ត៌មាន ការផ្លាស់ប្ដូររូបថត និង វិធានការចាំបាច់ផ្សេងៗទៀត ដើម្បីឱ្យការជួបគ្នានេះ ។

ករណីមានសហព័ទ្ធ បើសហព័ទ្ធណាម្ខាងមិនអាចមកបាន សហព័ទ្ធនោះត្រូវធ្វើលិខិតប្រគល់សិទ្ធិឱ្យទៅសហព័ទ្ធម្ខាងទៀត ធ្វើជាអ្នកតំណាងរបស់ខ្លួន ដើម្បីធ្វើសកម្មភាពក្នុងការសុំកូនចិញ្ចឹមនេះ ។ លិខិតប្រគល់សិទ្ធិត្រូវមានការបញ្ជាក់ពីអាជ្ញាធរកណ្ដាល ឬ អាជ្ញាធរមានសមត្ថកិច្ចរបស់ប្រទេសទទួល ។

ក្នុងករណីអ្នកសុំមិនមកក្នុងរយៈពេលដូចបានកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើ ដោយគ្មានមូលហេតុត្រឹមត្រូវ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវចាត់ទុកថា អ្នកសុំបានបញ្ឈប់ពាក្យសុំរបស់ខ្លួន ។

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវសាកសួរយោបល់របស់កុមារដែលអាចដឹងខុសត្រូវបាន ព្រមទាំងប្រាប់កុមារឱ្យបានដឹងអំពីអានុភាពដែលកើតចេញពីសុំកូននេះ ហើយត្រូវស្តាប់កុមារបញ្ចេញមតិយោបល់របស់ខ្លួន ដោយគ្មានវត្តមានរបស់ភាគីផ្សេងទៀតឡើយ ។ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវយល់ដឹងឱ្យបានច្បាស់ អំពីទស្សនៈកុមារលើរាល់បញ្ហាដែលពាក់ព័ន្ធនឹងសុំកូន ក្នុងនោះមានជាអាទិ៍ ការជ្រើសរើសអ្នកសុំ ហើយមតិយោបល់របស់កុមារត្រូវយកទៅពិគ្រោះពិចារណាដោយផ្អែកទៅតាមវ័យ និង កម្រិតយល់ដឹងរបស់កុមារ ។ សំអាងស្តីពីការយល់ព្រមរបស់កុមារត្រូវធ្វើជាលាយលក្ខណ៍អក្សរ ។

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ អំពីការសម្ភាសន៍ និង ការជួបគ្នាខាងលើនេះ ។

មាត្រា ៣១.-

បទប្បញ្ញត្តិ ដែលមានចែងក្នុងជំពូកនេះត្រូវយកមកអនុវត្តផងដែរចំពោះសុំកូនដោយសាច់ញាតិ ។

មាត្រា ៣២.-

ក្នុងករណីរដ្ឋបាលសុំកូនអន្តរប្រទេសពិនិត្យឃើញថា អ្នកសុំ និង កុមារបំពេញបាននូវលក្ខណៈវិនិច្ឆ័យ និង លក្ខខណ្ឌសម្រាប់សុំកូនអន្តរប្រទេស ហើយសុំកូននេះពិតជាបានឆ្លើយតបទៅនឹងឧត្តមប្រយោជន៍របស់កុមារ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវផ្តល់មតិយោ-បល់ជាវិជ្ជមានក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីការជួបគ្នារវាងអ្នកសុំ និង កុមារ ។

រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវដាក់សំណុំលិខិតទាំងនេះ ជូនរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីសុំការពិនិត្យ និង ផ្តល់អនុសាសន៍លើសំណើការសុំកូន ។

មាត្រា ៣៣.–

ក្រោយពីទទួលអនុសាសន៍លើដំណើរការសុំកូនពីរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អ្នកសុំត្រូវសហការជាមួយអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ដាក់ពាក្យសុំកូនដែលបានផ្តល់ច្បាប់ តាមរយៈរដ្ឋបាលសុំកូនអន្តរប្រទេសទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីសុំដីកាសម្រេចសុំកូន ។ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវបញ្ជូនពាក្យសុំកូនទៅសាលាដំបូងរាជធានីភ្នំពេញដោយភ្ជាប់មកជាមួយនូវសំណុំឯកសាររបស់កុមារ និង អ្នកសុំ ព្រមទាំងអនុសាសន៍របស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ គិតពីកាលបរិច្ឆេទទទួលពាក្យសុំ ។ ឯកសារទាំងអស់ត្រូវបកប្រែជាភាសាខ្មែរ និង មានការបញ្ជាក់ពីរដ្ឋបាលសុំកូនអន្តរប្រទេស ។

ក្នុងករណីអ្នកសុំមិនបានដាក់ពាក្យសុំក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានអនុសាសន៍របស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវចាត់ទុកថាអ្នកសុំនោះបានបញ្ឈប់ពាក្យសុំរបស់ខ្លួន ។

## ផ្នែកទី ២
## នីតិវិធីតុលាការ

មាត្រា ៣៤.–

សាលាដំបូងរាជធានីភ្នំពេញ មានយុត្តាធិការលើរឿងក្តីសុំកូនអន្តរប្រទេស ។

តុលាការដែលមានយុត្តាធិការលើរឿងក្តីសុំកូនអន្តរប្រទេស ត្រូវយកបទប្បញ្ញត្តិស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង មកអនុវត្តចំពោះនីតិវិធីតុលាការទាក់ទងនឹងសុំកូនអន្តរប្រទេស លើកលែងតែមានបទប្បញ្ញត្តិពិសេសដូចមានចែងនៅក្នុងច្បាប់នេះ ។

មាត្រា ៣៥.–

អ្នកសុំត្រូវបង់ប្រាក់សរុបចំនួន ១.០០០.០០០ (មួយលាន) រៀល ដើម្បីទ្រទ្រង់សោហ៊ុយលើការដាក់ពាក្យសុំ ការពិនិត្យភស្តុតាង ការចេញដីកាសម្រេច ការបញ្ជូនឯកសារ ការផ្សព្វផ្សាយសេចក្តីជូនដំណឹង ការស្រាវជ្រាវអង្គហេតុ និង សកម្មភាពខាងនីតិវិធីផ្សេងៗទៀត

ដែលទាក់ទងនឹងកិច្ចការសុំកូនអន្តរប្រទេស ។ តុលាការត្រូវបង្គាប់ឱ្យអ្នកសុំបង់ចំនួនទឹកប្រាក់នោះជាមុន ។ ក្នុងករណីដែលសោហ៊ុយចាំបាច់ដែលបានកំណត់ខាងលើនេះ លើសពី ១.០០០.០០០ (មួយលាន) រៀល តុលាការអាចកំណត់ចំនួនសោហ៊ុយបន្ថែម និង បង្គាប់ឱ្យអ្នកសុំបង់សោហ៊ុយបន្ថែមនោះជាមុន ។ ចំនួនទឹកប្រាក់នេះមិនអាចបង្វិលសងវិញទេ ។

មាត្រា ៣៦.-

ជាគោលការណ៍ សំណុំឯកសារ និង របាយការណ៍ដែលផ្ញើមកតុលាការដោយក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវសន្មតជាភស្តុតាងនៃអង្គហេតុពិតទាក់ទងនឹងលក្ខណសម្បត្តិ សុំកូនរបស់កុមារ និង ភាពសមស្របសម្រាប់សុំកូនរបស់អ្នកសុំ លើកលែងតែមានភស្តុតាងថ្មីមកបញ្ជាក់ ។

ក្នុងករណីចាំបាច់ តុលាការអាចបង្គាប់ឱ្យអ្នកតំណាងរដ្ឋបាលសុំកូនអន្តរប្រទេស មកបំភ្លឺបន្ថែមអំពីលទ្ធផលនៃការស្រាវជ្រាវ និង អនុសាសន៍របស់មន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ទាក់ទងនឹងករណីសុំកូនអន្តរប្រទេសរួមទាំងឯកសារ របាយការណ៍ និង ភស្តុតាងជាឯកសារពាក់ព័ន្ធដែលគាំទ្រលទ្ធផលនៃការស្រាវជ្រាវខាងលើ ។

មាត្រា ៣៧.-

តុលាការត្រូវពិនិត្យផ្ទៀងផ្ទាត់ថា ៖

ក- លក្ខណវិនិច្ឆ័យ ឬ លក្ខខណ្ឌទាំងអស់នៃសុំកូនអន្តរប្រទេសត្រូវបានបំពេញ ។

ខ- ការពិគ្រោះយោបល់ជាចាំបាច់នានាត្រូវបានធ្វើមុននឹងផ្តល់ការយល់ព្រម ។

គ- ការយល់ព្រមចាំបាច់នានាត្រូវបានផ្តល់ ដោយគោរពតាមខ្លឹមសារផ្នែកទី ២ ជំពូកទី ៤ នៃច្បាប់នេះ ។

ឃ- មានការពិចារណាត្រឹមត្រូវលើគ្រប់លទ្ធភាពក្នុងការទុកដាក់កុមារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ង- អាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ច ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាតនៃប្រទេសទទួល យល់ព្រមលើការទុកដាក់កុមារ ។

ច- កុមារនឹងត្រូវបានអនុញ្ញាតឱ្យចូលទៅរស់នៅជាអចិន្ត្រៃយ៍នៅក្នុងប្រទេស

សុំកូនអន្តរប្រទេសនេះពិតជាឧត្តមប្រយោជន៍របស់កុមារ ។

មាត្រា ៣៨.-

តុលាការសម្រេចសេចក្តីអំពីរឿងក្តីដែលទាក់ទងនឹងសុំកូនអន្តរប្រទេស ដោយពុំចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ឡើយ ។

ក្នុងករណីមានភាពចាំបាច់ដើម្បីត្រូវពិនិត្យអង្គហេតុពាក់ព័ន្ធ តុលាការអាចអញ្ជើញអ្នកសុំ ឬ អ្នកតំណាង ឬ អ្នកមានអំណាចមេបាម្នាក់ ឬ ទាំងពីរ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ អ្នកតំណាងទីភ្នាក់ងារសុំកូនអន្តរប្រទេសពាក់ព័ន្ធ និងសាក្សីផ្សេងទៀត ដើម្បីផ្តល់ភស្តុតាងជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់ទាក់ទងនឹងអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុ ។

មាត្រា ៣៩.-

តុលាការត្រូវលើកយកសំណុំរឿងសុំកូនអន្តរប្រទេសមកវិនិច្ឆ័យ និងចេញដីកាសម្រេចក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យសុំកូន ។ តុលាការត្រូវបញ្ជូនដីកាសម្រេចនេះទៅអ្នកសុំ អ្នកតំណាងដែលច្បាប់បានកំណត់របស់កូនសុំ និងក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

ដីកាសម្រេចនេះមិនត្រូវចូលជាស្ថាពរនៅមុនពេលផុតកំណត់ពេលសម្រាប់ការប្តឹងជំទាស់ ដែលបានកំណត់នៅក្នុងមាត្រា៤០ នៃច្បាប់នេះ ។ ក្នុងករណីមានការប្តឹងជំទាស់ចំពោះដីកាសម្រេចនេះ ដីកាសម្រេចនេះមិនត្រូវចូលជាស្ថាពររហូតដល់ពេលមានដីកាសម្រេចអំពីបណ្តឹងជំទាស់នោះ ។

មាត្រា ៤០.-

បុគ្គលដែលមានសិទ្ធិ ឬ ផលប្រយោជន៍របស់ខ្លួនត្រូវបានប៉ះពាល់ដោយដីកាសម្រេចលើពាក្យសុំកូនអន្តរប្រទេស អាចប្តឹងជំទាស់ទៅសាលាឧទ្ធរណ៍ ចំពោះដីកាសម្រេចនោះបាន ។

ក្នុងករណីដែលបុគ្គលអាចប្តឹងជំទាស់ជាជនដែលត្រូវទទួលបានការជូនដំណឹងអំពីដីកាសម្រេចខាងលើ បណ្តឹងជំទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃដែលខ្លួនទទួលបានការជូនដំណឹងអំពីដីកាសម្រេច ។

ក្នុងករណីដែលបុគ្គលអាចប្តឹងជំទាស់ មិនមែនជាជនដែលត្រូវទទួលបានការជូនដំណឹងអំពីដីកាសម្រេចខាងលើ បណ្តឹងជំទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល ១៥ (ដប់ប្រាំ)

ថ្ងៃនៃថ្ងៃធ្វើការ គិតពីថ្ងៃដែលអ្នកសុំបានទទួលការជូនដំណឹងអំពីដីកាសម្រេច ។

អំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ ដែលកំណត់ក្នុងកថាខណ្ឌទី ២ និង ទី ៣ ខាងលើមិនអាចពន្យារបានឡើយ ។

សាលាឧទ្ធរណ៍ត្រូវលើកយកពាក្យបណ្ដឹងជំទាស់នោះមកវិនិច្ឆ័យ និង ចេញដីកាសម្រេចក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យបណ្ដឹងជំទាស់ ។

ដីកាសម្រេចរបស់សាលាឧទ្ធរណ៍លើបណ្ដឹងជំទាស់មិនអាចប្ដឹងជំទាស់ទៀតបានឡើយ ។

## ជំពូកទី ៦
## អានុភាពនៃសុំកូន

**មាត្រា ៤១.-**

សុំកូនអន្តរប្រទេសត្រូវតែជាសុំកូនពេញលេញ ។ សុំកូនអន្តរប្រទេសមានអានុភាពបង្កើតនូវទំនាក់ទំនងញាតិភាពរវាងឪពុកម្ដាយ និង កូនជាអចិន្ត្រៃយ៍ ដោយផ្ដល់ដល់កុមារនូវឋានៈ សិទ្ធិ និង កាតព្វកិច្ចដូចជាកូនបង្កើតរបស់ឪពុកម្ដាយថ្មី ហើយវាបញ្ចប់ញាតិភាពរវាងកុមារ និង ឪពុកម្ដាយបង្កើតរបស់ខ្លួន ។

**មាត្រា ៤២.-**

អានុភាពផ្សេងទៀតនៃសុំកូនអន្តរប្រទេស ត្រូវគ្រប់គ្រងដោយច្បាប់ជាតិរបស់អ្នកសុំ ឬ ប្រសិនបើគ្មានច្បាប់រួមមួយទេ ត្រូវគ្រប់គ្រងដោយច្បាប់នៃប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំ ។

## ជំពូកទី ៧
## ការជូនដំណឹងពីចំណាត់ការ និង នីតិវិធី បន្ទាប់ពីបញ្ចប់ដំណើរការសុំកូនអន្តរប្រទេស

...ពាក់ព័ន្ធ សុំកូនអន្តរប្រទេស ត្រូវជូនដំណឹងអំពីការប្រព្រឹត្តទៅនៃជីវិតនៃសុំកូន ...ដែល...អាជ្ញាធរមានសមត្ថកិច្ចបានចាត់ការ និង ការវិវត្តនៃការសុំកូនទៅគ្រប់

ចំណាត់ការរបស់នីតិវិធីស៊ុំកូនឱ្យបានទៀងទាត់ ទៅអ្នកស៊ុំតាមរយៈអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ច ឬ ទីភ្នាក់ងារស៊ុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាត ។

មាត្រា ៩៤.-

ក្រោយពីពីកាលប្រេចរបស់តុលាការចូលជាស្ថាពរ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវជូនដំណឹងទៅក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ អំពីពីកាលប្រេចនេះ ។

នៅពេលដែលនីតិវិធីស៊ុំកូនអន្តរប្រទេសត្រូវបានបញ្ចប់ ដោយអនុលោមទៅតាមអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និង សហប្រតិបត្តិការ ទាក់ទងនឹងស៊ុំកូនអន្តរ-ប្រទេស ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវចេញលិខិតបញ្ជាក់អនុលោមតាមមាត្រា ២៣ នៃអនុសញ្ញានេះ ។

រដ្ឋបាលស៊ុំកូនអន្តរប្រទេស ត្រូវរៀបចំពិធីប្រគល់កុមារ និង លិខិតបញ្ជាក់ស្តីពីការប្រគល់កូនជាផ្លូវការទៅអ្នកស៊ុំ ។ រដ្ឋបាលស៊ុំកូនអន្តរប្រទេសត្រូវជួយសម្របសម្រួលជាមួយអាជ្ញាធរមានសមត្ថកិច្ច ក្នុងការរៀបចំ និង ផ្តល់នូវលិខិតឆ្លងដែន ទិដ្ឋាការ និង ឯកសារចាំបាច់នានា ដើម្បីឱ្យកុមារធ្វើដំណើរចូលទៅប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់អ្នកស៊ុំ ។

ការធ្វើដំណើររបស់កុមារទៅកាន់ប្រទេសទទួល ត្រូវអមដំណើរដោយអ្នកស៊ុំ ។ រដ្ឋបាលស៊ុំកូនអន្តរប្រទេស ត្រូវធានាថាការផ្ទេរកុមារទៅកាន់ប្រទេសទទួល ប្រព្រឹត្តទៅក្នុងកាលៈទេសៈមានសុវត្ថិភាព ដោយមានការពិតចូលរួមលំសេចក្តីត្រូវការទាំងអស់របស់កុមារ ។

មាត្រា ៩៥.-

រដ្ឋបាលស៊ុំកូនអន្តរប្រទេសត្រូវសម្របសម្រួលជាមួយអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកស៊ុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារស៊ុំកូនអន្តរប្រទេសនៃប្រទេសទទួល ដើម្បីផ្តល់ ឬ សម្របសម្រួលសេវាក្រោយស៊ុំកូនសមស្របដល់កុមារ គ្រួសារចិញ្ចឹម និង គ្រួសារបង្កើតតាមការចាំបាច់ ។

ក្រោយពីកុមារត្រូវបានទទួលការអនុញ្ញាតឱ្យធ្វើជាកូន ឪពុកម្តាយចិញ្ចឹមត្រូវផ្តល់របាយការណ៍អំពីស្ថានភាពវិវឌ្ឍន៍របស់កុមារមករដ្ឋបាលស៊ុំកូនអន្តរប្រទេសជារៀងរាល់ប្រាំមួយខែម្តង ក្នុងរយៈពេល ៣ (បី) ឆ្នាំ បន្ទាប់មកត្រូវផ្តល់របាយការណ៍ ១ ឆ្នាំម្តង រហូតដល់កុមារមានអាយុ ១៨ ឆ្នាំ ។

ឪពុកម្តាយចិញ្ចឹមត្រូវផ្ញើរបាយការណ៍ជាលាយលក្ខណ៍អក្សរទៅរដ្ឋបាលសុំកូនអន្តរប្រទេសដោយផ្ទាល់ ឬ តាមរយៈអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេស ដែលបានទទួលការអនុញ្ញាតនៃប្រទេសទទួល ឬ ប្រទេសជាលំនៅឋានអចិន្ត្រៃយ៍របស់ខ្លួនទៅតាមស្ថានភាពសមស្រប ។

មាត្រា៤៦.-

រដ្ឋបាលសុំកូនអន្តរប្រទេស និង សាលាដំបូងរាជធានីភ្នំពេញ ត្រូវរក្សាទុកសំណុំឯកសារសុំកូនអន្តរប្រទេសក្នុងរយៈពេល ៦០ (ហុកសិប) ឆ្នាំ គិតពីកាលបរិច្ឆេទដែលដីកាសម្រេចសុំកូនអន្តរប្រទេសនោះចូលជាស្ថាពរ ។

សំណុំឯកសារ និង កំណត់ហេតុទាំងអស់ទាក់ទងនឹងករណីសុំកូនអន្តរប្រទេសជាក់លាក់ណាមួយ ទោះជារក្សាទុកនៅតុលាការ រដ្ឋបាលសុំកូនអន្តរប្រទេស ទីភ្នាក់ងារសុំកូនអន្តរប្រទេស មណ្ឌលកុមារកំព្រា និង អ្នកជំនាញផ្សេងៗទៀតដែលពាក់ព័ន្ធនឹងនីតិវិធីសុំកូនអន្តរប្រទេសត្រូវរក្សាទុកជាការសម្ងាត់ ។ ក៏ប៉ុន្តែសំណុំឯកសារនិងកំណត់ហេតុ ឬ ព័ត៌មានទាំងឡាយដែលមាននៅក្នុងសំណុំឯកសារ និង កំណត់ហេតុទាំងនោះអាចនឹងត្រូវបញ្ចេញទៅតាមការស្នើសុំ ឬ ការបង្គាប់ជាលាយលក្ខណ៍អក្សររបស់អាជ្ញាធរមានសមត្ថកិច្ច នៅក្នុង ឬ ក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងករណីមានតម្រូវការទាក់ទងនឹងករណី ឬ នីតិវិធីតុលាការដែលកំពុងតែប្រព្រឹត្តទៅ ឬ កាលៈទេសៈពិសេសផ្សេងទៀត ។

ឪពុកម្តាយចិញ្ចឹមអាចដាក់ពាក្យសុំទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីសុំច្បាប់ចម្លងនៃសំណុំលិខិត ដែលរួមមានអត្តសញ្ញាណរបស់ឪពុកម្តាយបង្កើតរបស់កូនសុំ ក្រោយពីដីកាសម្រេចសុំកូនរបស់តុលាការចូលជាស្ថាពរ ។ កូនសុំដែលដល់អាយុពេញវ័យ និងយល់ដឹងគ្រប់គ្រាន់អំពីផលវិបាកនៃការដឹងអត្តសញ្ញាណរបស់ខ្លួន អាចត្រូវបានអនុញ្ញាតឱ្យមើលសំណុំលិខិតរបស់ខ្លួនរួមទាំងអត្តសញ្ញាណរបស់ឪពុកម្តាយបង្កើតបាន ដោយធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរមកអាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជា ក្នុងករណីការមើលនេះជាឧត្តមប្រយោជន៍របស់កូនសុំ ។ កូនសុំដែលឈានចូលអាយុនីតិភាពមានសិទ្ធិមើលសំណុំឯកសារ និង កំណត់ហេតុទាក់ទងនឹងអត្តសញ្ញាណខ្លួន ។ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវធានាថា កូនសុំទទួលបានការពិគ្រោះយោបល់សមស្របមុននឹងមើល [illegible]សំណុំលិខិតរបស់ខ្លួន ។

## ជំពូកទី ៨
## ការផ្តល់ការអនុញ្ញាតដល់ទីភ្នាក់ងារ

**មាត្រា ៤៧.-**

មានតែទីភ្នាក់ងារដែលបានទទួលការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជា និង ពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសទទួល ស្របតាមមាត្រាជាបន្តបន្ទាប់ដូចខាងក្រោមប៉ុណ្ណោះ ដែលមានសិទ្ធិធ្វើប្រតិបត្តិការក្នុងនីតិវិធីសុំកូនអន្តរប្រទេស ។

ចំនួនទីភ្នាក់ងារមកពីប្រទេសទទួលនីមួយៗ ដែលអនុញ្ញាតឱ្យផ្តល់សេវានៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវកំណត់ដោយកិច្ចព្រមព្រៀងរួមគ្នាមួយរវាងក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច និង អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទទួល ។

**មាត្រា ៤៨.-**

ដើម្បីសុំការអនុញ្ញាតធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ទីភ្នាក់ងារត្រូវមានលក្ខណសម្បត្តិដូចតទៅ ៖

១- មានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសទទួល ។

២- មានទិសដៅមិនស្វែងរកផលចំណេញ និង បានបំពេញនូវលក្ខខណ្ឌដែលមានចែងក្នុងបទប្បញ្ញត្តិច្បាប់ទាក់ទងនឹងនីតិបុគ្គលមិនយកចំណេញ សមាគម ឬ អង្គការមិនមែនរដ្ឋាភិបាល ឬ បទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតទាក់ទងនឹងលក្ខណៈនៃទីភ្នាក់ងារនោះ ។

៣- មានអ្នកដឹកនាំនិងមានបុគ្គលិកដែលមានសមត្ថភាពប្រកបដោយគុណធម៌ និង សីលធម៌ ព្រមទាំងបានទទួលការបណ្តុះបណ្តាល និង មានបទពិសោធន៍ធ្វើការងារក្នុងវិស័យសុំកូនអន្តរប្រទេស ។

ទីភ្នាក់ងារដែលធ្វើប្រតិបត្តិការក្នុងដំណើរការសុំកូនអន្តរប្រទេស នៅក្នុងព្រះរាជាណាចក្រកម្ពុជា មិនត្រូវបានអនុញ្ញាតឱ្យបើក ឬ យកមណ្ឌលកុមារកំព្រា ជាប្រភពដើម្បីផ្គត់ផ្គង់ទារក និង កុមារកំព្រា នៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ ។

មាត្រា ៤៩.-

ទីភ្នាក់ងារនីមួយៗត្រូវបានចុះបញ្ជីតាមបទប្បញ្ញត្តិច្បាប់ជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា ទាក់ទងនឹងនីតិបុគ្គលមិនរកប្រាក់ចំណេញ សមាគម ឬ អង្គការមិនមែនរដ្ឋាភិបាល ឬ បទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗទៀត ទាក់ទងនឹងលក្ខណៈនៃទីភ្នាក់ងារនោះ មុនពេលដាក់ពាក្យសុំការអនុញ្ញាតធ្វើជាទីភ្នាក់ងារសុំកូនអន្តរប្រទេស ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច តាមរយៈរដ្ឋបាលសុំកូនអន្តរប្រទេស ។ ទីភ្នាក់ងារសុំកូនអន្តរប្រទេសត្រូវចុះកិច្ចសន្យាស្តីពីប្រតិបត្តិការសុំកូនអន្តរប្រទេស និង បំពេញបែបបទផ្សេងៗទៀត តាមការកំណត់របស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

មាត្រា ៥០.-

ពាក្យសុំការអនុញ្ញាតធ្វើជាទីភ្នាក់ងារសុំកូនអន្តរប្រទេស នៅព្រះរាជាណាចក្រកម្ពុជា ដែលដាក់ជូនរដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារដូចខាងក្រោម៖

១- ពាក្យសុំការអនុញ្ញាតដោយមានការយល់ព្រម និង ទទួលស្គាល់ពីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

២- ឯកសារសង្ខេបអំពីប្រវត្តិ និង សកម្មភាពរបស់ទីភ្នាក់ងារ ។

៣- ច្បាប់ចម្លងដែលមានបញ្ជាក់ត្រឹមត្រូវអំពីការអនុញ្ញាតឱ្យបើកទីភ្នាក់ងារពីប្រទេសទទួលរបស់ខ្លួន ចំពោះទីភ្នាក់ងារអន្តរជាតិ ។

៤- ច្បាប់ចម្លងលិខិតចុះបញ្ជីដែលមានបញ្ជាក់ត្រឹមត្រូវដូចមានចែងក្នុងមាត្រា ៤៩ នៃច្បាប់នេះ ។

៥- លក្ខន្តិកៈ និង បទបញ្ជាផ្ទៃក្នុងរបស់ទីភ្នាក់ងារ ។

៦- ជីវប្រវត្តិសង្ខេបនិងរូបថតរបស់សមាជិកក្រុមប្រឹក្សាភិបាល ឬ គណៈគ្រប់គ្រង ។

៧- ជីវប្រវត្តិសង្ខេបរបស់បុគ្គលដែលបានទទួលការអនុញ្ញាតឱ្យធ្វើជាអ្នកតំណាងទីភ្នាក់ងារចំពោះកិច្ចការសុំកូនអន្តរប្រទេស ។ អ្នកតំណាងទាំងនេះមិនត្រូវឱ្យជ្រើស [illegible] និងមិនមែនជានាយក នាយករង ឬ បុគ្គលិកនៃមណ្ឌលកុមារកំព្រាណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ ។

៨- ឯកសារភស្តុតាងនានាដែលបញ្ជាក់ថាអ្នកតំណាងដូចមានចែងក្នុងចំណុចទី ៧ ខាងលើ គ្មានជាប់ឈ្មោះក្នុងបញ្ជីថ្កោលទោសនៅប្រទេសដើមរបស់ខ្លួន និង នៅប្រទេសចុងក្រោយដែលខ្លួនរស់នៅ ក្នុងករណីប្រទេសខុសគ្នា ។

៩- កិច្ចព្រមព្រៀងទ្វេភាគីស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យសុំកូនអន្តរប្រទេស រវាងព្រះរាជាណាចក្រកម្ពុជា និង ប្រទេសរបស់ទីភ្នាក់ងារសុំកូនអន្តរប្រទេស ក្នុងករណីដែលប្រទេសនោះមិនមែនជារដ្ឋភាគីនៃអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និង សហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេសទេ ។

១០- របាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានធ្វើសវនកម្មឯករាជ្យ និង កិច្ចព្រមព្រៀងផ្តល់ជំនួយមនុស្សធម៌ ឬ ការជួយឧបត្ថម្ភដល់កុមារកំព្រានានា នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

១១- តម្រូវការផ្សេងៗទៀតដែលក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចយល់ថាចាំបាច់ ដើម្បីធានាឧត្តមប្រយោជន៍របស់កុមារ ដូចមានចែងនៅក្នុងនីតិវិធីទាក់ទងនឹងការផ្តល់ការអនុញ្ញាត ។

ច្បាប់ចម្លងចំនួនមួយច្បាប់នៃពាក្យសុំ និង សំណុំលិខិតសុំការអនុញ្ញាតធ្វើជាទីភ្នាក់ងារ ត្រូវផ្ញើជូនស្ថានទូត ឬ ស្ថានតំណាងនៃប្រទេសទទួល ដែលទីភ្នាក់ងារធ្វើប្រតិបត្តិការនៅទីនោះ ។

**មាត្រា ៥១.-**

ក្នុងកំឡុងពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យសុំការអនុញ្ញាតធ្វើជាទីភ្នាក់ងារសុំកូនអន្តរប្រទេស ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរទៅទីភ្នាក់ងារវិញអំពីការសម្រេចជាផ្លូវការរបស់ខ្លួន ។ ក្នុងករណីមានការបដិសេធ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ។

**មាត្រា ៥២.-**

មានតែអ្នកតំណាងដែលមានឈ្មោះក្នុងសំណុំឯកសារពាក្យសុំការអនុញ្ញាតតែប៉ុណ្ណោះដែលមានសិទ្ធិធ្វើជាអ្នកតំណាងទីភ្នាក់ងារនៅក្នុងដំណើរការសុំកូនអន្តរប្រទេស ។ ក្នុងករណីអ្នកតំណាងដែលបានទទួលការអនុញ្ញាត ត្រូវជំនួសដោយអ្នកផ្សេងនោះ ទីភ្នាក់

ងារត្រូវដាក់ពាក្យសុំទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីសុំការអនុញ្ញាតជាថ្មីឡើងវិញ។

**មាត្រា ៥៣.-**

ការអនុញ្ញាតឱ្យធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេស ត្រូវផ្តល់ឱ្យសម្រាប់រយៈពេល ២ (ពីរ) ឆ្នាំ ហើយអាចអនុញ្ញាតឱ្យបន្តទៀតបាន ដោយទីភ្នាក់ងារត្រូវដាក់ពាក្យសុំសាជាថ្មី និងត្រូវបំពេញតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៤៨ មាត្រា ៤៩ និង មាត្រា ៥០ នៃច្បាប់នេះ ផងរបាយការណ៍សកម្មភាពរបស់ទីភ្នាក់ងារសុំកូនអន្តរប្រទេស នៅតែចាំបាច់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៩
## ទោសប្បញ្ញត្តិ

**មាត្រា ៥៤.-**

ដោយមិនទាន់គិតដល់ទោសប្បញ្ញត្តិដែលមានចែងនៅក្នុងច្បាប់ជាធរមាន ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អាចព្យួរ ឬ ដកហូតការទទួលស្គាល់ ឬ បដិសេធការទទួលស្គាល់ ទីភ្នាក់ងារសុំកូនអន្តរប្រទេសសារជាថ្មី ប្រសិនបើមានភស្តុតាងបង្ហាញឱ្យឃើញថា ទីភ្នាក់ងារសុំកូនអន្តរប្រទេស ជាប់ពាក់ព័ន្ធនឹងអំពើណាមួយដូចតទៅ :

១- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ បញ្ចុះបញ្ចូលដោយផ្ទាល់ឱ្យឪពុកម្តាយ ឬ ឪពុក ឬ ម្តាយបោះបង់ទារកដែលកើតមកហើយ ឬ ដែលនឹងកើត ដើម្បីឱ្យប្រគល់កូនតាមរយៈសុំកូនអន្តរប្រទេស ។

២- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ធ្វើជាអន្តរការីរវាងប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និង ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយដែលចង់បោះបង់កូនដែលកើតមកហើយ ឬ ដែលនឹងកើត ។

៣- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ធ្វើជាអន្តរការីរវាងប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និង ស្ត្រីម្នាក់យល់ព្រមពពោះដើម្បីបង្កើតនិងប្រគល់កូននោះទៅឱ្យអ្នកសុំ ។

៤- អំពើក្លែងបន្លំ ឬ សមគំនិតក្លែងបន្លំក្នុងការពលិចាកបំផុត ដើម្បីទទួលបាន ការយល់ព្រមពីឪពុកម្តាយបង្កើត ឬ ឪពុកបង្កើត ឬ ម្តាយបង្កើត ឬ អ្នកអាណាព្យាបាល សម្រាប់អនីតិជនរបស់កុមារ ។

៥- អំពើរៀបចំឱ្យមានការយល់ព្រមរបស់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារដោយការបង្ខិតបង្ខំ ការគំរាមកំហែង ការឆបោក ឬ ការបញ្ចុះបញ្ចូលតាមរយៈការផ្តល់ ឬ សន្យាផ្តល់ប្រាក់ រង្វាន់ សំណង ឬ ផលប្រយោជន៍ណាមួយ ។

៦- ការបញ្ចេញសំណុំឯកសារ និង កំណត់ហេតុទាំងអស់ ឬ មួយផ្នែកទាក់ទង នឹងករណីសុំកូនអន្តរប្រទេសជាក់លាក់ណាមួយ ដោយគ្មានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ឬ តុលាការមានសមត្ថកិច្ច ។

៧- ការបង្គាប់ ឬ ការទទួលដោយផ្ទាល់ ឬ ដោយប្រយោល នូវថ្លៃប្រាក់កាស ទំនិញ ឬ សេវា ដោះដូរនឹងការបម្រុងទុកកុមារណាមួយសម្រាប់សុំកូន ។

៨- ការផ្តល់ប្រាក់កាស ទំនិញ ឬ សេវាទៅឱ្យមន្ត្រី ឬ អ្នកតំណាងណាមួយ នៃរដ្ឋបាលសុំកូនអន្តរប្រទេស ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អាជ្ញាធរកណ្តាលទទួលខុសត្រូវកិច្ចការសុំកូនអន្តរប្រទេស ឬ មន្ត្រីពាក់ព័ន្ធផ្សេងទៀត ដើម្បីឱ្យផ្តល់នូវសិទ្ធិជាអាទិ-ភាពនៅក្នុងនីតិវិធីសុំកូនអន្តរប្រទេសដល់អ្នកសុំ ។

៩- ការផ្សាយពាណិជ្ជកម្ម ឬ ការបោះពុម្ពផ្សាយនូវអត្តសញ្ញាណ ឬ រូបថត របស់កុមារណាមួយដែលជាកម្មវត្ថុសុំកូន ក្នុងគោលបំណងបញ្ចុះបញ្ចូលបុគ្គលណាមួយ ឱ្យដាក់ពាក្យសុំកូន ។

១០- ការតែងតាំង ឬ ចាត់តាំងអ្នកតំណាងណាមួយដោយមិនមានការឯកភាព ពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

១១- ការចូលរួមក្នុងការរៀបចំការផ្គូផ្គង ឬ ការទាក់ទងគ្នារវាងអ្នកសុំ និង ឪពុកម្តាយបង្កើត ឬ ឪពុកបង្កើត ឬ ម្តាយបង្កើត ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន របស់កុមារក្នុង គោលបំណងកំណត់ទុកជាមុននូវកុមារណាមួយដែលនឹងត្រូវសុំ ។

១២- ការរំលោភបំពានដល់បទប្បញ្ញត្តិនៃច្បាប់នេះ បទដ្ឋានអប្បបរមានៃ ការថែទាំចំពោះកុមារ និង បទប្បញ្ញត្តិផ្សេងទៀតជាធរមាននៃព្រះរាជាណាចក្រ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

34/152

Bl

**មាត្រា ៥៥.-**

ទីភ្នាក់ងារដែលធ្វើប្រតិបត្តិការជួយចាត់ចែងការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនអនុវត្តតាមកថាខណ្ឌទី ១ មាត្រា ៤៧ ឬ កថាខណ្ឌទី ២ មាត្រា ៤៨ នៃច្បាប់នេះ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។ ការដាក់ពិន័យអន្តរការណ៍ ជាសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។ ប្រាក់ពិន័យអន្តរការណ៍នេះត្រូវបង់ចូលទៅក្នុងមូលនិធិសម្រាប់ទ្រទ្រង់វិស័យសុខុមាលភាពកុមារ ។

ក្នុងករណីទីភ្នាក់ងារមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍នេះទេ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចអាចបញ្ជូនសំណុំរឿងទៅតុលាការ ។

**មាត្រា ៥៦.-**

បទល្មើសពាក់ព័ន្ធទៅនឹងច្បាប់ស្តីពីសុំកូនអន្តរប្រទេស ត្រូវផ្តន្ទាទោសដោយយោងតាមច្បាប់ និង បទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ១០

## អវសានប្បញ្ញត្តិ

**មាត្រា ៥៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥៨.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៩

នស/រកម/១២០៩/០១១

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ហត្ថលេខា

អ៊ិត សំហេង

លេខ ១០៥៩ ច.ល

ឆ្នាំ២០០៩

# អនុក្រឹត្យ

# ស្តីពីការសុំធារកកំព្រា

# ឬ កុមារកំព្រាយកទៅចិញ្ចឹមជា

# កូននៅបរទេស

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ ២៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការសុំទារកកំព្រា ឬ កុមារកំព្រាយកធ្វើជាកូនចិញ្ចឹមនៅបរទេស

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញក្រឹត្យ លេខ ៥៦ ក្រ ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋ នៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសញ្ជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីតាមសម័យប្រជុំ ថ្ងៃទី ០២ ខែមីនា ឆ្នាំ២០០១ ។

**ស ំ រេ ច**

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះ កំណត់សមត្ថកិច្ច លក្ខខណ្ឌ និងនីតិវិធី នៃការសុំទារកកំព្រា ឬកុមារកំព្រា យកទៅធ្វើជាកូនចិញ្ចឹមបង្កើតជាកូន នៅក្រៅប្រទេស ។

# ជំពូកទី ២

## សមត្ថកិច្ច លក្ខខណ្ឌ និងនីតិវិធីនៃការសុំទារកកំព្រា ឬកុមារកំព្រាយកទៅចិញ្ចឹមនៅបរទេស

២. –

ជនបរទេសជាសាមីអ្នកស្នើសុំទារកកំព្រា ឬកុមារកំព្រាយកទៅចិញ្ចឹមបីបាច់ជាកូននៅបរទេស ត្រូវបំពេញលក្ខខណ្ឌ និងនីតិវិធីដូចមានចែងក្នុងអនុក្រឹត្យនេះ ។

៣. –

សាមីអ្នកស្នើសុំជាប្តីប្រពន្ធត្រូវបានរៀបអាពាហ៍ពិពាហ៍ និងមានអាយុពី ២៥ ឆ្នាំ ដល់ ៥៥ ឆ្នាំ ។ ចំពោះអ្នកនៅលីវ អាចអនុញ្ញាតឱ្យសុំបានតែអ្នកនៅលីវដែលមានអាយុចាប់ពី ៤០ ឆ្នាំ ដល់ ៥០ ឆ្នាំ ។ ចំពោះសាមីអ្នកស្នើសុំមិនអាចសុំកូនយកទៅចិញ្ចឹមលើសពី ២ នាក់ បានឡើយ ។ ត្រូវបានអនុញ្ញាតឱ្យសុំកូនបាន លុះត្រាតែអ្នកស្នើសុំគ្មានកូន ឬមានកូនមិនលើសពី ២ នាក់ ។

៤. –

សាមីអ្នកស្នើសុំត្រូវសរសេរពាក្យសុំទៅក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា តាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដោយមានភ្ជាប់ឯកសារ ដូចខាងក្រោម :

- ទម្រង់ពាក្យសុំ
- លិខិតអនុញ្ញាតឱ្យសុំកូនចិញ្ចឹមពីអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសសាមីរបស់សាមីអ្នកស្នើសុំ
- របាយការណ៍ស្តីពីស្ថានភាពគ្រួសារ ដោយមានបញ្ជាក់ពីចំនួនសមាជិកគ្រួសារ ដែលធ្វើដោយភ្នាក់ងារមានជំនាញលើការងារនេះ ហើយមានការទទួលស្គាល់ពីក្រសួងមានសមត្ថកិច្ច នៃប្រទេសសាមី របស់សាមីអ្នកស្នើសុំ
- សេចក្តីចម្លងសំបុត្រកំណើត ឬវិញ្ញាបនបត្រកំណើតរបស់សាមីអ្នកស្នើសុំ
- សេចក្តីចម្លងលិខិតអាពាហ៍ពិពាហ៍ ឬលិខិតលែងលះគ្នា ឬលិខិតបញ្ជាក់ថានៅលីវ
- លិខិតបញ្ជាក់អំពីសុខភាពរបស់សាមីអ្នកស្នើសុំ
- របាយការណ៍ស្តីពីចិត្តវិទ្យាធ្វើឡើងដោយគ្រូពេទ្យចិត្តវិទ្យា ដែលទទួលស្គាល់ដោយរដ្ឋាភិបាលនៃប្រទេសសាមី របស់សាមីអ្នកស្នើសុំ
- លិខិតបញ្ជាក់ថាគ្មានទោស ចេញដោយអាជ្ញាធរក្នុងប្រទេសកំណើត ឬកន្លែងដែលសាមីអ្នកស្នើសុំបានរស់នៅ ឬ សំបុត្រថ្កោលទោសចេញដោយក្រសួងមានសមត្ថកិច្ច
- លិខិតបញ្ជាក់អំពីកិរិយាមារយាទ នៅក្នុងកន្លែងប្រកបការងារ និងនៅក្នុងសង្គមរស់នៅ ចេញដោយអាជ្ញាធរមានសមត្ថកិច្ច
- សេចក្តីបញ្ជាក់អំពីស្ថានភាពហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់សាមីអ្នកស្នើសុំ ចេញដោយអាជ្ញាធរមានសមត្ថកិច្ច
- កិច្ចសន្យាគោរពសិទ្ធិជាកូន និងផ្តល់ការសិក្សា ព្រមទាំងសិទ្ធិទទួលកេរ្តិ៍មរតក ដូចកូនបង្កើតប្រចាំខ្លួន

- រូបថតរបស់សាមីអ្នកស្នើសុំ យកក្នុងកំឡុងពេលពីរខែចុងក្រោយ
- កិច្ចសន្យារបស់សាមីអ្នកស្នើសុំ ស្តីពីការផ្តល់ពត៌មានលើការចិញ្ចឹមកូន ចាប់ពីពេលដែលយកកូនចិញ្ចឹមចេញពីប្រទេសកម្ពុជាមួយឆ្នាំម្តង១ រហូតដល់អាយុ ១៨ ឆ្នាំ មកក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ហើយរបាយការណ៍នោះត្រូវបានត្រួតពិនិត្យ និងបញ្ជាក់ពីភាពត្រឹមត្រូវ ដោយក្រសួងមានសមត្ថកិច្ចខាងការងារសុំកូនចិញ្ចឹម នៃប្រទេសរបស់សាមីអ្នកស្នើសុំ ហើយចម្លងជូនទៅស្ថានទូតខ្មែរដែលប្រចាំនៅប្រទេសសាមីអ្នកស្នើសុំ
- សេចក្តីថ្លែងលិខិតឆ្លងដែនរបស់សាមីអ្នកស្នើសុំ
- លិខិតបញ្ជាក់ពីស្ថានទូតនៃប្រទេសរបស់សាមីអ្នកស្នើសុំ ចំពោះឯកសារទាំងអស់ខាងលើពីភាពត្រឹមត្រូវ ។

ប្រការ ៥ .-

ទារកកំព្រា ឬកុមារកំព្រាដែលត្រូវបានអនុញ្ញាតឱ្យសុំយកទៅចិញ្ចឹម ត្រូវមានលក្ខណៈវិនិច្ឆ័យ និងសំណុំលិខិតដូចខាងក្រោមៈ

ក- មានអាយុក្រោម ៨ ឆ្នាំ

ខ- រស់នៅក្រោមការថែទាំរបស់មជ្ឈមណ្ឌលកុមារកំព្រារដ្ឋ ឬមណ្ឌលឯទៀតដែលគ្រប់គ្រងដោយ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

គ- រស់នៅក្នុងមណ្ឌលអស់រយៈពេល ៣ ខែ យ៉ាងតិចមុនពេលត្រូវបានស្នើសុំ

ឃ- ត្រូវមានសំបុត្រកំណើតដែលចេញឱ្យដោយមន្ត្រីអត្រានុកូលដ្ឋាន

ង- ត្រូវមានវិញ្ញាបនប័ត្របញ្ជាក់ពីសុខភាពកាយសម្បទា ដែលចេញដោយវេជ្ជបណ្ឌិតមានសមត្ថកិច្ច ធ្វើការក្នុងមន្ទីរពេទ្យរដ្ឋ ឬគ្លីនិកផ្សេងទៀតដែលរដ្ឋទទួលស្គាល់ ។

ប្រការ ៦.-

ការជ្រើសរើសកូនត្រូវធ្វើឡើងតាមបញ្ជីរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា បានរៀបចំ និងត្រូវបានការឯកភាពពីអ្នកសុំកូនយកទៅចិញ្ចឹម ។ អ្នកស្នើសុំមានសិទ្ធិទៅមើលទារកកំព្រា ឬកុមារកំព្រាក្នុងមណ្ឌល មុនពេលធ្វើការសំរេចចិត្តថា ទទួលយក ឬមិនទទួលយក ។

ប្រការ ៧.-

ឯកសារស្នើសុំកូនទាំងអស់ត្រូវផ្ញើមកក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ តាមរយៈស្ថានទូតនៃប្រទេសសាមីប្រចាំនៅកម្ពុជា ។ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវពិនិត្យលើសំណុំឯកសារទាំងអស់ដែលមានចែងក្នុងមាត្រា ៣ និងមាត្រា ៤ នៃអនុក្រឹត្យនេះ ក្នុងរយៈពេល ១៥ ថ្ងៃ ។ ប្រសិនបើសំណុំលិខិតរបស់សាមីអ្នកស្នើសុំមិនគ្រប់គ្រាន់ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចបដិសេធ ឬបញ្ជូនសំណុំឯកសារទៅឱ្យសាមីអ្នកស្នើសុំ ដើម្បីបំពេញសំណុំឯកសារឱ្យបានត្រឹមត្រូវឡើងវិញ ។ ក្រោយពីបានពិនិត្យរួចហើយ ត្រូវធ្វើលិខិតបញ្ជាក់យោបល់របស់ក្រសួង អមជាមួយសំណុំឯកសារពាក់ពន្ធ័ទាំងអស់ បញ្ជូនមកក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

មាត្រា ៨.-

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រូវពិនិត្យលើលក្ខខណ្ឌ និងបែបបទនានា ដែលសាមីអ្នកស្នើសុំបានបំពេញដូចមានចែងក្នុងមាត្រា ៥ នៃអនុក្រឹត្យនេះ ក្នុងរយៈពេល ២ ខែ ។ ក្រោយពីបានពិនិត្យសព្វគ្រប់ហើយ ត្រូវធ្វើលិខិតបញ្ជាក់អំពីយោបល់របស់ក្រសួង បញ្ជូនអមជាមួយសំណុំលិខិតពាក់ពន្ធ័ទាំងអស់ មកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីសុំសេចក្តីសម្រេចពីរាជរដ្ឋាភិបាល ។

មាត្រា ៩.-

ទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវពិនិត្យសំណុំលិខិត និងដាក់ជូនប្រមុខរាជរដ្ឋាភិបាលក្នុងរយៈពេល ១៥ ថ្ងៃ ហើយត្រូវបញ្ជូនលិខិតយល់ព្រម ទៅក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដើម្បីធ្វើលិខិតបញ្ជាក់ស្តីពីការសុំកូនចិញ្ចឹម និងជូនពត៌មានទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីអញ្ជើញសាមីអ្នកស្នើសុំមកកាន់ប្រទេសកម្ពុជា តាមរយៈស្ថានទូតនៃប្រទេសសាមីប្រចាំនៅកម្ពុជា ។ ការសំរេចជាវិជ្ជមាន ឬអវិជ្ជមាន ជាឆន្ទានុសិទ្ធិរបស់រាជរដ្ឋាភិបាល ។

មាត្រា ១០.-

ក្រោយពីបានទទួលសេចក្តីជូនដំណឹងស្តីពីការសំរេចយល់ព្រម ពីរាជរដ្ឋាភិបាល ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រូវចេញលិខិតបញ្ជាក់ស្តីពីការសុំកូនចិញ្ចឹម ជូនសាមីអ្នកស្នើសុំកូនចិញ្ចឹម ។

ការប្រគល់ទារកកំព្រា ឬកុមារកំព្រាជូនឪពុក និងឬ ម្តាយចិញ្ចឹម ត្រូវធ្វើជាផ្លូវការនៅចំពោះមុខមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ជាអ្នកសំរបសំរួល ។ ឪពុក និងឬម្តាយចិញ្ចឹម ត្រូវមានវត្តមាន ទទួលកូនដោយផ្ទាល់ក្នុងពេលនោះ ។ មិនអនុញ្ញាតឱ្យប្រគល់ទារកកំព្រា ឬកុមារកំព្រា តាមរយៈភ្នាក់ងារកណ្តាលណាមួយឡើយ ។

មាត្រា ១១.-

ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រូវបន្តតាមដានពត៌មានជុំវិញកូនចិញ្ចឹមសញ្ជាតិដើមកម្ពុជា រហូតដល់កុមារកំព្រារូបនោះ មានអាយុ ១៨ ឆ្នាំ ។

## ជំពូកទី ៣

## អំពីបន្ទុករបស់សាមីអ្នកស្នើសុំកូន

មាត្រា ១២.-

សាមីអ្នកស្នើសុំកូនចិញ្ចឹមទាំងអស់ ត្រូវមានបន្ទុកចំណាយដូចតទៅ :

- ធ្វើលិខិតឆ្លងដែនសំរាប់ទារកកំព្រា ឬកុមារកំព្រា ដែលសាមីខ្លួនបានស្នើសុំ
- រ៉ាប់រងការចំណាយទាំងអស់ក្នុងការចាកចេញរបស់ទារកកំព្រា ឬកុមារកំព្រា ។

មាត្រា ១៣.-

សាមីអ្នកស្នើសុំកូនអាចរួមចំណែកភាគទានសប្បុរសធម៌ តាមការស្ម័គ្រចិត្ត ជូនក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សំរាប់ជាផលប្រយោជន៍របស់ទារកកំព្រា ឬកុមារកំព្រា ។

/

មាត្រា ១៤.-

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មានភារកិច្ចគ្រប់គ្រង ប្រើប្រាស់ថវិកា វិភាគទានសប្បុរសធម៌នេះ តាមបទប្បញ្ញត្តិជាធរមាន និងដោយតម្លាភាព ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

មាត្រា ១៥.-

បទប្បញ្ញត្តិទាំងឡាយ ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៦.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការ ក្រសួង ស្ថាប័នពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ឆ្នាំ២០០១

សែន

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

អ៊ិត សំហេង

កន្លែងទទួល :

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រសួងព្រះបរមរាជវាំង
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលាខេត្ត-ក្រុង
- ដូចមាត្រា ១៦
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
លេខ ០០២ ស.អ.យ

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៣

# របាយការណ៍
# ស្ដីពី
# ការងារសុំកូនអន្តរប្រទេសនៅព្រះរាជាណាចក្រកម្ពុជា

## I-ស្ថានភាពការណ៍ការងារសុំកូនចិញ្ចឹមអន្តរប្រទេស

### ១-ស្ថានភាពការណ៍រួម

រាជរដ្ឋាភិបាលកម្ពុជា អនុវត្តគោលនយោបាយការពារសិទ្ធិកុមារ ស្របតាមអនុសញ្ញារបស់អង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារ ដែលបានដាក់បញ្ចូលក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

តាមការវាយតម្លៃនៃរបាយការណ៍ជាតិលើកទី២ លើកទី៣ ដែលមានការទទួលស្គាល់ពីគណៈកម្មការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ ការអនុវត្តអនុសញ្ញារបស់អង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារនៅកម្ពុជាសម្រេចបានគោលដៅជាច្រើននៃគោលដៅអភិវឌ្ឍសហសវត្ស ដែលពាក់ព័ន្ធនឹងវិស័យសុខុមាលភាពកុមារ។

រាជរដ្ឋាភិបាលកម្ពុជា ចាត់ទុកការងារសុំកូនអន្តរប្រទេស ជាគោលនយោបាយមួយក្នុងគោលដៅមនុស្សធម៌ ផ្សារភ្ជាប់ការគោរព អនុវត្តសិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារ និងទប់ស្កាត់អំពើជួញដូរកុមារតាមរយៈសុំកូនអន្តរប្រទេស។

នៅកម្ពុជាដំណើរការសុំកូនអន្តរប្រទេស បានអនុវត្តចាប់តាំងពីឆ្នាំ១៩៨៧ រហូតមកដល់ខែមេសា ឆ្នាំ២០១១។

មុនដំបូងបានចាប់ផ្ដើមអនុវត្តការផ្ដល់កូនសុំជូនដល់បុគ្គលិកបរទេសរបស់អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលដែលមកបំពេញបេសកកម្មនៅកម្ពុជា ហើយបន្ទាប់មកបានអនុវត្តចំពោះប្រជាពលរដ្ឋបរទេសដែលបានមកទំនាក់ទំនងសុំកូនពីកម្ពុជា។

កុមារដែលបានផ្ដល់ជាកូនសុំកន្លងមកគឺជាទារក ឬកុមារកំព្រាត្រូវបានបោះបង់ចោលនៅតាមមណ្ឌលកុមារកំព្រាទាំងរបស់រដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាល។

ប្រទេសដែលមានសហប្រតិបត្តិការសុំកូនជាមួយកម្ពុជាកន្លងមក រួមមាន៖ ប្រទេសបារាំង សហរដ្ឋអាមេរិក បែលហ្ស៊ិក កាណាដា អ៊ីតាលី អង់គ្លេស សាន់លូស៊ីយ៉ា ប៉ូឡូញ ស៊ុយអែត ម៉ាល់តា ហ្វាំងឡង់ អេស្ប៉ាញ ក្រិក អាហ្វ្រិកខាងត្បូង អាហ្សង់ទីន អាល្លឺម៉ង់ ហូល្លង់ អូស្ត្រាលី ស្វីស ន័រវេស អៀកឡង់ ស៊ីង្ហបុរី ស៊ុយអែត ទ្រីនីដេត អូទ្រីស ហ្វីលីពីន ដាណឺម៉ាក់ និងប័រមុយដា ។

ចំនួនកុមារដែលត្រូវបានផ្តល់ជាកូនចិញ្ចឹមសរុបមានចំនួន ៣,៧២៨ នាក់ ប្រុស ១,៨៧០ នាក់ ស្រី ១,៨៥៨ នាក់ គិតមកដល់ខែមេសា ឆ្នាំ២០១១ ។

**២- អំពីកិច្ចសហប្រតិបត្តិការសុំកូនអន្តរប្រទេសកម្ពុជា-អាមេរិក**

កម្ពុជា និងសហរដ្ឋអាមេរិក មានទំនាក់ទំនងលើការងារសុំកូនអន្តរប្រទេស តាំងពីចុងទស្សវត្ស ៩០។ កុមារកម្ពុជាដែលបានផ្តល់ជាកូនសុំទៅសហរដ្ឋអាមេរិកមានចំនួន ១,៤៨៦ នាក់ ប្រុសចំនួន ៦៨៥ នាក់ ស្រីចំនួន ៨០១ នាក់។

នៅដើមខែមីនា ឆ្នាំ២០០២ រដ្ឋាភិបាលអាមេរិកបានផ្អាកកិច្ចសហប្រតិបត្តិការសុំកូន ជាមួយកម្ពុជា ដោយយកហេតុផលថាមានការជួញដូរកុមារ ពិសេសយោងហេតុផលលើករណីបទល្មើសដែលរកឃើញចំពោះប្រធានអង្គការអាមេរិកម្នាក់ឈ្មោះ Laryn Galindo ដែលបានឆបោកចំពោះពលរដ្ឋអាមេរិក ហើយត្រូវអាជ្ញាធរអាមេរិកចាប់ខ្លួន ករណីនេះកម្ពុជាក៏បានផ្តល់កិច្ចសហការយ៉ាងពេញលេញជាមួយសហរដ្ឋអាមេរិក។

ក្នុងអំឡុងពេលផ្អាកនេះ សហរដ្ឋអាមេរិកបានស្នើឲ្យភាគីកម្ពុជាជួយសម្រួលសំណុំលិខិតសុំកូនដែលនៅសេសសល់ចំនួន៣លើក លើកទី១ ចំនួន១២៩ លើកទី២ ចំនួន ៧៧ និងលើកទី៣ ចំនួន ៧០ សរុបទាំងអស់ចំនួន ២៧៦ ករណី។ ភាគីកម្ពុជាបានសម្រួលតាមសំណើរបស់ភាគីអាមេរិក។

បន្ទាប់ពីដោះស្រាយករណីខាងលើ សហរដ្ឋអាមេរិក និងកម្ពុជា បានបន្តកិច្ចសហប្រតិបត្តិការដោយផ្តោតទៅលើ ការជួយពង្រឹងប្រព័ន្ធសុំកូនអន្តរប្រទេសរបស់កម្ពុជា ជួយបង្កលក្ខណៈឲ្យកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស គាំទ្រកម្ពុជាក្នុងការរៀបចំច្បាប់ស្តីពីសុំកូនអន្តរប្រទេស គាំទ្រកម្ពុជាក្នុងការរៀបចំនីតិវិធីអនុវត្តច្បាប់ ការកសាងសមត្ថភាពស្ថាប័ន ។ល។

សហរដ្ឋអាមេរិក បានតាមដានដោយយកចិត្តទុកដាក់នូវការរីកចម្រើនរបស់កម្ពុជា ហើយបានវាយតម្លៃខ្ពស់ចំពោះការខិតខំរបស់ភាគីកម្ពុជា។ បានស្នើឲ្យភាគីកម្ពុជាពន្យាពេលនៃការដាក់ឲ្យដំណើរការសុំកូនអន្តរប្រទេសចំនួន ២ លើក លើកទី ១ ឆ្នាំ២០១១ លើកទី២ ឆ្នាំ២០១២ ហើយលោកជំទាវ Susan Jacobs ឧមកាវីក្រសួងការបរទេសបច្ចុប្បន្នជាអគ្គរដ្ឋទូត ទីប្រឹក្សាពិសេសផ្នែកបញ្ហាកុមារ បានចូលជួបសម្តែងការគួរសម និងពិភាក្សាការងារដែលទាក់ទងនឹងសុំកូនអន្តរប្រទេស ជាមួយឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សន្យាថាការពន្យាឆ្នាំ២០១២ គឺជាលើកចុងក្រោយ។

រាជរដ្ឋាភិបាលកម្ពុជាបានយល់ព្រមពន្យាតាមសំណូមពររហូតដល់ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៣។ ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ក្រសួងការបរទេសសហរដ្ឋអាមេរិក បានផ្ញើលិខិតកោតសរសើរ និងលើកទឹកចិត្តឲ្យខិតខំបណ្តុះបណ្តាលបុគ្គលិកពាក់ព័ន្ធ និងគ្រប់គ្រងកុមារដែលជាកូនសុំឲ្យបានល្អ។

ជាការឆ្លើយតបភាគីកម្ពុជា ស្វាគមន៍ការយល់ឃើញរបស់ភាគីអាមេរិក ហើយរង់ចាំកិច្ចសហប្រតិបត្តិការជាមួយអាមេរិក។

ក្នុងរយៈពេលនេះ ក៏មានភ្នាក់ងារសុំកូនអន្តរប្រទេសអាមេរិកមួយចំនួន បានស្នើសុំការគាំទ្រពីភាគីកម្ពុជា និងផ្តល់ការឧបត្ថម្ភគាំទ្រដល់អាជ្ញាធរកម្ពុជា។

-សេចក្តីប្រកាសស្តីពីសុំកូនចំពោះកុមារដែលមានតម្រូវការពិសេស។

ខ-បានសហការជាមួយអង្គការយូនីសេហ្វ និងអ្នកជំនាញការផ្នែកច្បាប់នៃការិយាល័យអចិន្ត្រៃយ៍អនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស ក្នុងការរៀបចំកសាងលិខិតបទដ្ឋាន ក្នុងការបើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីជំនាញជាច្រើនវគ្គ និងបានឯកភាពលើផែនការ និងកម្មវិធីសកម្មភាពការងារសុំកូនអន្តរប្រទេស។

II-<u>និសនវៅ</u>

១.ដំណើរការនីតិវិធីសុំកូនអន្តរប្រទេស ពីតិចទៅច្រើន តាមលទ្ធភាពជាក់ស្តែង ដោយចាប់ដំណើរការចំពោះកុមារនៅខេត្ត៥ រួមមាន រាជធានីភ្នំពេញ បាត់ដំបង បន្ទាយមានជ័យ សៀមរាប ខេត្តព្រះសីហនុ ។ ផ្តល់អាទិភាពដល់កុមារដែលមានអាយុច្រើនពី ៦ ទៅ ៨ ឆ្នាំមុន និងកុមារដែលមានតម្រូវការពិសេស ក្នុងនោះមានកុមារពិការ កុមារត្រូវគេលោភបំពាន និងសុំកូនដោយសាច់ញាតិ។ល។

២-ស្វាគមន៍ប្រទេសនានាដែលមានសំណើចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការលើវិស័យសុំកូនជាមួយកម្ពុជាដើម្បីកំណត់ចំនួនទីភ្នាក់ងារ និងបើកដំណើរការទីភ្នាក់ងារនៅកម្ពុជា។

៣-បន្តរៀបចំបង្កើយលិខិតបទដ្ឋានដែលនៅសេសសល់ និងបណ្តុះបណ្តាលមន្ត្រីពាក់ព័ន្ធគ្រប់ផ្នែក។

៤-ពង្រឹងប្រព័ន្ធសុខុមាលភាពកុមារ នៅរាជធានី ខេត្តអាទិភាព ៥ រាជធានីភ្នំពេញ បាត់ដំបង បន្ទាយមានជ័យ សៀមរាប ខេត្តព្រះសីហនុ ដើម្បីគ្រប់គ្រងករណីកុមារដែលជាមុខសញ្ញានៃសុំកូនអន្តរប្រទេស។

៥-បន្តសហការជាមួយប្រទេស និងភ្នាក់ងារនៃប្រទេសដែលបានចុះកិច្ចព្រមព្រៀងរួចហើយ។

<u>III-សេចក្តីសន្និដ្ឋាន</u>

ព្រះរាជាណាចក្រកម្ពុជា បានរៀបចំនីតិវិធីសុំកូនអន្តរប្រទេស បានល្អប្រសើរ ស្របតាមអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស។ ពិតមែននៅសល់ការងារខ្លះកំពុងបន្តបង្ហើយ តែអាចដំណើរការការងារសុំកូនអន្តរប្រទេសបានតាមកាលបរិច្ឆេទដែលបានកំណត់ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៣។ កម្ពុជាត្រៀមខ្លួនជាស្រេចដើម្បីស្វាគមន៍ប្រទេសជាដៃគូរនានា ធ្វើកិច្ចព្រមព្រៀងសហប្រតិបត្តិការស្របតាមច្បាប់ជាធរមានរបស់កម្ពុជា។ ទោះជាមានការព្រមព្រៀងនៅពេលនេះការអនុវត្តសុំកូនជាក់ស្តែង ត្រូវចំណាយពេលយ៉ាងហោចមួយឆ្នាំទៀត តាមនីតិវិធីដែលមានចែងក្នុងច្បាប់ជាធរមាន។

សេចក្តីដូចបានគោរពជូនខាងលើនេះ សូមសម្តេចតេជោ នាយករដ្ឋមន្ត្រី មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់ដោយអនុគ្រោះ ។

សូម សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

រដ្ឋមន្ត្រី

អ៊ិត សំហេង

# ប្រកាស

## នានារបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

0 2 12.09.05

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣ ✽ ៣

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន
និងយុវនីតិសម្បទា

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ[illegible] ឆ្នាំ ២០០៥

# សេចក្តីថ្លែងហេតុ
# នៃ សេចក្តីព្រាងច្បាប់ស្តីពីសុំកូនអន្តរប្រទេស

សេចក្តីព្រាងច្បាប់នេះ បានរៀបចំតាក់តែងឡើងដោយអនុលោមតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា ៤៨ បានចែង ជាអាទិ៍ថា ៖ រដ្ឋធានាការពារសិទ្ធិកុមារដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ........។ អនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីសិទ្ធិកុមារ ក្នុងមាត្រា ២១ បានចែងថា រដ្ឋជាភាគីទទួលស្គាល់ និង/ឬ អនុញ្ញាតនូវប្រព័ន្ធសុំកូនចិញ្ចឹម ត្រូវធានាថា ផលប្រយោជន៍ដ៏ល្អបំផុតរបស់កុមារ គឺជាមូលដ្ឋានចំបងនៅក្នុងបញ្ហានេះ ។

ទន្ទឹមនេះដែរ ផ្អែកតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា សំរាប់នីតិកាលទី ៣ នៃរដ្ឋសភាបានចែងជាអាទិ៍ថា *រាជរដ្ឋាភិបាលប្តេជ្ញាដាក់ចេញនូវវិធានការគ្រប់បែបយ៉ាង ដើម្បីទប់ស្កាត់អំពើគាបសង្កត់ អំពើពេស្យាចារលើកុមារ ការជួញដូរកុមារ ការពង្រឹងការអនុវត្តន៍ច្បាប់ ការកែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ។*

## ១.ភាពចាំបាច់តម្រូវអោយមានច្បាប់ស្តីពីសុំកូនអន្តរប្រទេស ៖

*ក . ចំណុចចាប់ផ្តើម និង ការវិវត្តន៍នៃនីតិវិធី បែបបទសុំកូននៅកម្ពុជា*

- ការងារសុំទារកកំព្រា ឬកុមារកំព្រានៅប្រទេសកម្ពុជាយើង ត្រូវបានអនុវត្តចាប់តាំង ពីឆ្នាំ ១៩៨៧ តាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី លេខ ៧៩ សសរ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៨៧ ។ ចំពោះអ្នកស្នើសុំកុមារកម្ពុជាពេលនោះ ភាគច្រើនគឺជាបុគ្គលិករបស់អង្គការអន្តរជាតិ ឬ អង្គការមិនមែនរដ្ឋាភិបាល ដែលបំពេញបេសកកម្មនៅក្នុងប្រទេសកម្ពុជា មានចិត្តអាណិតស្រឡាញ់ទារក ឬកុមារកំព្រាកម្ពុជា ហើយនៅពេលចប់បេសកកម្ម ត្រឡប់ទៅស្រុកវិញ គេបានសុំទារកកំព្រា ឬ កុមារកំព្រាយកទៅចិញ្ចឹមជាកូន ដោយអនុវត្តនីតិវិធីជាធរមាន ។

- នៅថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៨៩ ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ត្រូវបានរដ្ឋសភានៃរដ្ឋកម្ពុជាអនុម័ត និង ដាក់ឱ្យប្រើប្រាស់ ។ រដ្ឋាភិបាល បានចេញសេចក្តីណែនាំលេខ ៥៤៩ សជណ ផក ចុះថ្ងៃទី ២៥ ខែមិនា ឆ្នាំ ១៩៩១ ស្តីពី នីតិវិធីការងារសុំកូនចិញ្ចឹម តាមច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ។

-ឆ្នាំ១៩៩៧-២០០០ ការងារសុំកូនចិញ្ចឹមពីកម្ពុជា ត្រូវបានទទួលការចាប់អារម្មណ៍កាន់តែច្រើនឡើង ។ ពីពលរដ្ឋនៃប្រទេសនានាមួយចំនួន រួមមាន អាមេរិក បារាំង កាណាដា អូស្ត្រាលី អាល្លឺម៉ង់ អ៊ីតាលី ......។ល។

-រាជរដ្ឋាភិបាល បានពង្រឹងនីតិវិធីសុំកូន ក្នុងគោលដៅមនុស្សធម៌សុទ្ធសាធ [illegible]ភ្ជាប់ការគោរព អនុវត្តសិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារ និង[illegible]ស្កាត់ភាពអសកម្ម ។ គិតពីឆ្នាំ ១៩៩៨ [illegible]ច្ចុប្បន្ននេះ កុមារកំព្រាសរុប

12.09.05

ដំបូងរបស់ប្រទេសកម្ពុជា ដែលហៅថា " **សេចក្តីសង្កេតចុងក្រោយ** " លើកទឹកចិត្តប្រទេសកម្ពុជា ឱ្យបន្តតាក់តែងច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឱ្យបានឆាប់ ។

២-ជាការធានាទូវសិទ្ធិ និង ឧត្តមប្រយោជន៍របស់កុមារកំព្រា ត្រូវបោះបង់ចោល និង តាមរយៈការផ្តល់ឱកាស តាមសុំកូនអន្តរប្រទេស ដោយមានការធានាត្រឹមត្រូវ ដោយច្បាប់នេះ និងអនុសញ្ញាអន្តរជាតិពាក់ព័ន្ធ ។

៣-ធានាឱ្យឧត្តមប្រយោជន៍របស់កុមារកម្ពុជា ដែលត្រូវបានគេសុំយកទៅចិញ្ចឹមនៅបរទេស និង ដើម្បីការពារកុមារកម្ពុជា គេចផុតពីការជួញដូរ តាមរូបភាពសុំកូនអន្តរប្រទេស ។

៤-បង្កើតច្រកចេញចូលតែមួយ ប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងយន្តការសុំកូនអន្តរប្រទេស នៃព្រះរាជាណាចក្រកម្ពុជា ក្រោមអាណាព្យាបាលរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ច្បាប់នេះ នឹងរួមចំណែកពង្រឹងកិច្ចសហប្រតិបត្តិការល្អ ជាមួយប្រទេសទាំងអស់ និង ស្ថាប័នអន្តរជាតិ ក្នុងការអនុវត្តបទដ្ឋានអន្តរជាតិស្តីពីសិទ្ធិកុមារ និង សុំកូនអន្តរប្រទេស ។ នីតិវិធី ដែលចែងក្នុងសេចក្តីព្រាងច្បាប់នេះ បានដកស្រង់ពិសោធន៍ពីប្រទេសអាស៊ាន និង ប្រទេសមួយចំនួនក្នុងតំបន់ ដែលបានអនុវត្តដោយជោគជ័យ ។

## ២.ខ្លឹមសារជាសារវ័ន្តនៃសេចក្តីព្រាងច្បាប់

អនុវត្តតាមអនុសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានបង្កើតក្រុមការងាររបស់ក្រសួង ដឹកនាំដោយឯកឧត្តមរដ្ឋលេខាធិការ **នឹម ថូត** រួមជាមួយអ្នកឯកទេស ខាងច្បាប់របស់យូនីសេហ្វ រៀបចំតាក់តែងអត្ថបទ សេចក្តីព្រាងច្បាប់សុំកូនអន្តរប្រទេស ដែលចាប់ដំណើរការ ពីថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០២ រហូតដល់ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៥ ។ អត្ថបទសេចក្តីព្រាងច្បាប់នេះ បានឆ្លងការពិភាក្សាក្នុងក្រុមការងារ ចំនួន ២៨ លើក សិក្ខាសាលា ចំនួន ០២ លើក ឆ្លងអង្គប្រជុំថ្នាក់ដឹកនាំក្រសួងចំនួន ៦ លើក ។ តំណាងស្ថានទូតនៃប្រទេសពាក់ព័ន្ធសំខាន់ៗ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និង ក្រសួងស្ថាប័នពាក់ព័ន្ធ សុទ្ធតែបានផ្តល់យោបល់ ហើយរាល់យោបល់ទាំងនោះ បានបញ្ចូលក្នុងខ្លឹមសារ នៃអត្ថបទសេចក្តីព្រាងច្បាប់នេះ ។

*សេចក្តីព្រាងច្បាប់នេះមាន ៨ ជំពូក និង ៥០ មាត្រាដែលមានខ្លឹមសារសង្ខេប ដូចតទៅ :*

**ជំពូកទី១** : ស្តីពីបទប្បញ្ញត្តិទូទៅ មាន ៣ មាត្រា បញ្ញត្តិអំពីកម្មវត្ថុ និយមន័យ និង គោលការណ៍គ្រឹះ សំរាប់ការងារសុំកូនអន្តរប្រទេស

**ជំពូកទី២** : ស្តីពី លក្ខខណ្ឌសំរាប់សុំកូន ចែកជា ៣ ផ្នែក និង ១២ មាត្រា

ផ្នែកទី ១ មាន ៣ មាត្រា បញ្ញត្តិអំពីលក្ខខណ្ឌនានា សំរាប់កុមារដែលជាកម្មវត្ថុនៃសុំកូន

ផ្នែកទី ២ មាន ៨ មាត្រា បញ្ញត្តិអំពីនីតិវិធីនៃការយល់ព្រមលើសុំកូន និង អសុពលភាពនៃសុំកូន

ផ្នែកទី ៣ មាន ១ មាត្រា បញ្ញត្តិអំពីលក្ខណសម្បត្តិរបស់បេក្ខជនសុំកូន

**ជំពូកទី៣** : មាន ២ មាត្រា បញ្ញត្តិអំពីអានុភាពនៃសុំកូន

**ជំពូកទី៤** : មាន ១៩ មាត្រា បញ្ញត្តិអំពីនីតិវិធីនៃកិច្ចដំណើរការ តាំងពីពាក្យសុំកូនរហូតដល់កុមារចេញផុតពីប្រទេសកម្ពុជាទៅកាន់ប្រទេសទទួល ... តាមដានកិច្ចនៃការធ្វើរបាយការណ៍របស់ឪពុកម្តាយចិញ្ចឹម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
លេខ ១៩៦៤ ស.អ.យ.

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែ[illegible] ឆ្នាំ២០១៣

# ប្រកាស
## ស្ដីពី
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្ដាល ស្នុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា

---

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១០៥ / ០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុសញ្ញាស្ដីពីសិទ្ធិកុមារដែលក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា បានសុំចូលជាភាគីនៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២
- បានឃើញព្រះរាជក្រម នស / រកម / ០១០៧ / ០០៣ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេ ស្ដីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងស្នុំកូនអន្តរប្រទេស
- បានឃើញព្រះរាជក្រមលេខ នស / រកម / ១២០៩ / ០២៤ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីស្នុំកូនអន្តរប្រទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញការចាំបាច់របស់ក្រសួង

## សម្រេច

### ប្រការ ១.–

ប្រកាសនេះកំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្ដាលស្នុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា មានអក្សរកាត់ថា " អ . ក . ស . អ " ជាភាសាអង់គ្លេស " Central Authority for Inter-country Adoption (C . A . I . A)។

**ប្រការ ២.-**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បំពេញតួនាទីជាអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជាស្របតាមមាត្រា ៦ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស។

**ប្រការ ៣.-**

អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជាមានភារកិច្ចដូចតទៅ៖

១- រៀបចំ និងត្រួតពិនិត្យការអនុវត្តគោលនយោបាយ ច្បាប់ បទបញ្ញា និងនីតិវិធីទាក់ទងនឹងការសម្រេចលើកិច្ចការសុំកូនអន្តរប្រទេស។

២- ធ្វើសហប្រតិបត្តិការ និងសម្របសម្រួលលើការប្រាស្រ័យទាក់ទងគ្នាទៅនឹងកិច្ចការសុំកូនអន្តរប្រទេសជាមួយក្រសួង ស្ថាប័ន និងទីភ្នាក់ងារដែលមានសមត្ថកិច្ចដោះស្រាយកិច្ចការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជានិងជាមួយអាជ្ញាធរកណ្តាល និងអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសទទួល។

៣- ចាត់វិធានការសមស្របដើម្បីបង្ការ និងទប់ស្កាត់ការទទួលផលកម្រៃផ្នែកហិរញ្ញវត្ថុដោយមិនសមស្រប ឬផលចំណេញផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេស។

៤- រៀបចំបណ្តុះបណ្តាលជំនាញកិច្ចការសុំកូនអន្តរប្រទេសដល់មន្ត្រីពាក់ព័ន្ធ។

៥- ពិនិត្យលើសំណើរបស់រដ្ឋបាលសុំកូនអន្តរប្រទេស ទាក់ទងនឹងករណីសុំកូនអន្តរប្រទេសនីមួយៗតាមការចាំបាច់។

៦- ធ្វើអធិការកិច្ចលើការងារទាំងឡាយដែលពាក់ព័ន្ធជាមួយសុំកូនអន្តរប្រទេស។ គ្មានជនណាអាចរារាំង បង្អាក់ ឬ ជ្រៀតជ្រែកក្នុងការងារអធិការកិច្ចដែលបានធ្វើឡើងត្រឹមត្រូវតាមច្បាប់បានឡើយ។

៧- ចាត់វិធានការដ៏សមស្របដើម្បីប្រមូល រក្សាការពារ និងផ្លាស់ប្តូរព័ត៌មានអំពីស្ថានភាពរបស់កុមារ និងរក្សាទុកព័ត៌មានទាក់ទងនឹងប្រភពកំណើតរបស់កុមារ អត្តសញ្ញាណរបស់កុមារ ឪពុកម្តាយកុមារ និងប្រវត្តិសុខភាពកុមារ។

៨- រក្សា និងផ្តល់ស្ថិតិទាក់ទងនឹងសុំកូនអន្តរប្រទេសដល់ប្រទេសនានាតាមសំណើ។

៩- ទទួលប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានាពីអ្នកសុំកូនត្រូវបង់តាមរយៈទីភ្នាក់ងារសុំកូនអន្តរប្រទេស ឬអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសទទួល។

១០- ទទួលខុសត្រូវក្នុងការកត់ត្រា តាមដានប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានាដែលប្រមូលបាន និងបង់ប្រាក់ចូលក្នុងគណនីប្រាក់បញ្ញើរបស់គណៈកម្មាធិការគ្រប់គ្រង និងចាត់ចែងប្រាក់វិភាគទានមនុស្សធម៌នៅធនាគារជាតិ។

១១- ធ្វើរបាយការណ៍ស្តីពីស្ថានភាពប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានាដែលប្រមូលបាន និងបង់ប្រាក់ចូលក្នុងគណនីប្រាក់បញ្ញើនៅធនាគារជាតិជារៀងរាល់ខែ ត្រីមាស និងប្រចាំឆ្នាំជូនគណៈកម្មាធិការគ្រប់គ្រង និងចាត់ចែងប្រាក់វិភាគទានមនុស្សធម៌។

១២- ពិនិត្យ ផ្តល់អនុសាសន៍ និងបញ្ជូនសំណុំឯកសារសុំកូនអន្តរប្រទេសនីមួយៗទៅតុលាការ។

១៣- បំពេញភារកិច្ចផ្សេងៗទៀតដែលក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា យល់ថាចាំបាច់សម្រាប់អនុវត្តកិច្ចការសុំកូនអន្តរប្រទេស ដោយអនុលោមទៅតាមច្បាប់ និងលិខិតបទបញ្ញាជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

## ប្រការ ៤.–

អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយគណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស។

## ប្រការ ៥.–

គណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស មានសមាសភាពដូចតទៅ៖

| | |
|---|---|
| ១- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ប្រធាន |
| ២- រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ទទួលបន្ទុកវិស័យសុខុមាលភាពកុមារ | អនុប្រធាន |
| ៣- អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៤- អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និង ហិរញ្ញវត្ថុ | សមាជិក |
| ៥- នាយកខុទ្ទកាល័យរដ្ឋមន្ត្រី | សមាជិក |
| ៦- តំណាងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ | សមាជិក |
| ៧- អ្នកជំនាញការជាតិលើវិស័យសុខុមាលភាពកុមារ | សមាជិក |
| ៨- ប្រធាននាយកដ្ឋានសុខុមាលភាពកុមារ | សមាជិក |
| ៩- ប្រធានរដ្ឋបាលសុំកូនអន្តរប្រទេស | អគ្គលេខាធិការ |

ការតែងតាំងសមាសភាពគណៈកម្មាធិការអាជ្ញាធរកណ្តាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

## ប្រការ ៦.–

គណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

១- ពិនិត្យ និងសម្រេចចុងក្រោយពាក់ព័ន្ធនិងនីតិវិធីសុំកូនអន្តរប្រទេស។

២- ពិនិត្យ និងផ្តល់អនុសាសន៍តាមការចាំបាច់លើគោលនយោបាយ ច្បាប់ បទបញ្ញា និងនីតិវិធីទាក់ទងនឹងកិច្ចការសុំកូនអន្តរប្រទេស។ តាមដាន ត្រួតពិនិត្យការអនុវត្តគោលនយោបាយ ច្បាប់ បទបញ្ញា និងនីតិវិធីទាក់ទងនឹងសុំកូនអន្តរប្រទេស។

៣- ធ្វើសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន និងទីភ្នាក់ងារដែលមានសមត្ថកិច្ចដោះស្រាយកិច្ចការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងជាមួយអាជ្ញាធរកណ្តាល និងអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសទទួល។

៤- ចាត់វិធានការសមស្របដើម្បីបង្ការ ទប់ស្កាត់ការទទួលផលកម្រៃផ្នែកហិរញ្ញវត្ថុដោយមិនសមស្រប ឬផលចំណេញផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេស។

៥- ពិនិត្យ និងផ្តល់អនុសាសន៍លើសកម្មភាពបណ្តុះបណ្តាលជំនាញដល់មន្ត្រីពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធផ្សេងទៀតលើការងារសុំកូនអន្តរប្រទេស។

៦ ពិនិត្យ សម្រេចលើសំណើផ្គូផ្គងកុមារនឹងអ្នកសុំដែលស្នើឡើងដោយរដ្ឋបាលសុំកូនអន្តរប្រទេស និងផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

៧-ពិនិត្យ និងអនុម័តគម្រោងថវិកា ប្រាក់ចំណាយ សោហ៊ុយ ស្របតាមច្បាប់ស្តីពីសុំកូនអន្តរប្រទេស និងសុំការសម្រេចពីរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

៨-ទាក់ទង និងធ្វើសហប្រតិបត្តិការជាមួយការិយាល័យអចិន្ត្រៃយ៍នៃសន្និសីទក្រុងឡាអេ ស្តីពីច្បាប់អន្តរជាតិឯកជនពាក់ព័ន្ធនឹងការងារសុំកូនអន្តរប្រទេស អង្គការអន្តរជាតិពាក់ព័ន្ធ និងប្រទេសដែលមានទំនាក់ទំនងសហប្រតិបត្តិការលើវិស័យសុំកូនអន្តរប្រទេស ជាមួយព្រះរាជាណាចក្រកម្ពុជា។

៩-អនុវត្តភារកិច្ចផ្សេងៗទៀតដែលរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាប្រគល់ជូន។

## ប្រការ ៧.-

ត្រូវបានបង្កើតគណៈកម្មាធិការគ្រប់គ្រង ចាត់ចែងវិភាគទានមនុស្សធម៌នៃអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស ដែលរួមមានសមាសភាពគណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស បន្ថែមតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១រូប។ សមាសភាពតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកំណត់ដោយលិខិតរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ប្រការ ៨.-

របៀបរបបធ្វើការរបស់គណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស៖

-គណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសបើកសម័យប្រជុំ ដើម្បីពិនិត្យឲ្យយោបល់លើករណីសុំកូននីមួយៗ និងពិនិត្យឲ្យយោបល់ក្នុងការរៀបចំត្រួតពិនិត្យការអនុវត្តគោលនយោបាយ ច្បាប់ បទបញ្ញា និងនីតិវិធីទាំងឡាយទាក់ទងនឹងសុំកូនអន្តរប្រទេស និងអនុវត្តភារកិច្ចដូចមានចែងក្នុងប្រការ ៦ នៃប្រកាសនេះ។

-ការប្រជុំ និងការសម្រេចរបស់គណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសអាចយកជាការបានលុះត្រាតែមានសមាជិកចូលរួមយ៉ាងតិច ៥០% + ១ នៃសមាជិកគណៈកម្មាធិការទាំងអស់។

-ការប្រជុំត្រូវដឹកនាំដោយប្រធានគណៈកម្មាធិការ ក្នុងករណីប្រធានអវត្តមាន អាចប្រគល់សិទ្ធិឲ្យអនុប្រធានដឹកនាំជំនួស។

-ការសម្រេចរបស់អង្គប្រជុំទាំងអស់ត្រូវអនុម័តដោយសំឡេងភាគច្រើននៃសមាជិកអង្គប្រជុំ ករណីមានសំឡេងស្មើគ្នា សំឡេងប្រធានមានឧត្តមានុភាព។

-ផ្អែកលើសារៈសំខាន់នៃបញ្ហានីមួយៗ ប្រធានគណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសអាចអញ្ជើញតំណាងក្រសួង ស្ថាប័ន អង្គការ និងជនពាក់ព័ន្ធដទៃទៀតឲ្យចូលរួមយោបល់តាមការចាំបាច់។

-គណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស ត្រូវប្រជុំមួយខែម្តង ឬញឹកញាប់ជាងនេះទៅតាមការចាំបាច់។

## ប្រការ ៩.-

ត្រូវបានបង្កើតរដ្ឋបាលសុំកូនអន្តរប្រទេស មានអក្សរកាត់ថា " រ.ស.អ. " ជាភាសាអង់គ្លេស " Inter- country Adoption Administration ( I. C. A.A ) " ដើម្បីធ្វើជាលេខាធិការរបស់អាជ្ញាធរកណ្តាលសុំកូនអន្តរ[illegible]ស។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
លេខ ១៤៣០ ស.អ.យ

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០១៤

# ប្រកាស
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលសុំកូនអន្តរប្រទេស

---

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុសញ្ញាស្តីពីសិទ្ធិកុមារដែលក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា បានចុះហត្ថលេខាថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ១៩៩២ និងបានផ្តល់សច្ចាប័ននៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២
- បានឃើញព្រះរាជក្រម នស/រកម/០១០៧/០០៣ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៤ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសុំកូនអន្តរប្រទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញប្រកាសលេខ ១៩៥ សអយ ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញការចាំបាច់របស់ក្រសួង

## សម្រេច

### ប្រការ១.-

ប្រកាសនេះកំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលសុំកូនអន្តរប្រទេស មានអក្សរកាត់ជា "រ.ស.អ." ជាភាសាអង់គ្លេស "Inter-Country Adoption Administration (I.C.A.A)"

១៤-គ្រប់គ្រងថវិកាចំណាយរបស់រដ្ឋបាលសុំកូនអន្តរប្រទេស រៀបចំធ្វើផែនការចំណាយ និងធ្វើរបាយការណ៍ហិរញ្ញវត្ថុស្តីពីស្ថានភាពប្រើប្រាស់ថវិកាជារៀងរាល់ខែ ត្រីមាស និងប្រចាំឆ្នាំជូនអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស។

១៥-រៀបចំផែនការ កម្មវិធី និងសកម្មភាពបណ្តុះបណ្តាលជំនាញដល់មន្ត្រីធ្វើការងារសុំកូនអន្តរប្រទេស និងអ្នកពាក់ព័ន្ធផ្សេងទៀត។

១៦-ចាត់វិធានការសមស្របក្នុងការប្រមូល ថែរក្សា និងផ្លាស់ប្តូរព័ត៌មានស្តីពីស្ថានភាពកុមារ ព័ត៌មានដើមកំណើតកុមារ អត្តសញ្ញាណឪពុកម្តាយ និងប្រវត្តិសុខភាពកុមារ ។

១៧-បំពេញភារកិច្ចចាំបាច់ផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេស ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិផ្សេងៗទៀត តាមការប្រគល់ភារកិច្ចរបស់គណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស។

## ប្រការ៣.-

រដ្ឋបាលសុំកូនអន្តរប្រទេស ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

## ប្រការ៤.-

រដ្ឋបាលសុំកូនអន្តរប្រទេសមានរចនាសម្ព័ន្ធដូចខាងក្រោម៖

១-ការិយាល័យ រដ្ឋបាល និងហិរញ្ញវត្ថុ

២-ការិយាល័យ គ្រប់គ្រងទិន្នន័យ និងតម្កល់ឯកសារ

៣-ការិយាល័យ អនុវត្តនីតិវិធីសុំកូនអន្តរប្រទេស

៤-ការិយាល័យ អភិវឌ្ឍ គ្រប់គ្រងទីភ្នាក់ងារ និងអធិការកិច្ច

៥-ការិយាល័យ សហប្រតិបត្តិការអន្តរជាតិ

ប្រធានការិយាល័យនីមួយៗមានឋានៈស្មើប្រធានការិយាល័យថ្នាក់ក្រសួង។

អង្គការលេខរបស់រដ្ឋបាលសុំកូនអន្តរប្រទេសមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

## ប្រការ៥.-

សមាសភាពថ្នាក់ដឹកនាំ និងមន្ត្រីបម្រើការងារនៅរដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវមានលក្ខណសម្បត្តិដូចខាងក្រោមនេះ៖

-មានបទពិសោធន៍លើការងារសង្គមកិច្ច ផ្នែកចិត្តសាស្ត្រ ជាពិសេសការងារសុខុមាលភាពកុមារ

-បានទទួលការបណ្តុះបណ្តាលវគ្គសេវាសង្គមកិច្ច

-មានចំណេះដឹងជាមូលដ្ឋានលើផ្នែកច្បាប់ ជាពិសេសច្បាប់ស្តីពីសុំកូនអន្តរប្រទេស និងអនុសញ្ញាអន្តរជាតិនានាដែលពាក់ព័ន្ធនឹងសុំកូនអន្តរប្រទេស

-មានសមត្ថភាពខាងផ្នែកព័ត៌មានវិទ្យា និងភាសាបរទេសជាពិសេសភាសាអង់គ្លេស

-ជាមន្ត្រីក្របខណ្ឌរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬជាមន្ត្រីជាប់កិច្ចសន្យា

-រដ្ឋបាលសុំកូនអន្តរប្រទេសអាចប្រើប្រាស់ទីប្រឹក្សាតាមការចាំបាច់។

## ៣-ការិយាល័យអនុវត្តនីតិវិធីសុំកូនអន្តរប្រទេស

ក-ការងារគ្រប់គ្រងអត្តសញ្ញាណកុមារដែលជាកម្មវត្ថុសុំកូនអន្តរប្រទេសៈ

-រៀបចំបញ្ជីត្រួតពិនិត្យឯកសារ ព័ត៌មានផ្សេងៗតាមដំណាក់កាល និងពេលវេលាសម្រាប់សំណុំឯកសារទាំងអស់

-រៀបចំសំណុំឯកសារផ្ទាល់ខ្លួនរបស់កុមារម្នាក់ៗ ដែលមានលក្ខណសម្បត្តិសម្រាប់សុំកូនអន្តរប្រទេសរួមមានព័ត៌មានចាំបាច់អំពីអត្តសញ្ញាណរបស់កុមារ ភាពអាចសុំជាកូនចិញ្ចឹមបាន សាវតារជាតិរបស់កុមារ បរិយាកាសសង្គម ប្រវត្តិគ្រួសារ ប្រវត្តិសុខភាពផ្ទាល់ខ្លួន ប្រវត្តិសុខភាពគ្រួសារកុមារ និងសេចក្តីត្រូវការពិសេសរបស់កុមារ

-ពិនិត្យមើលឲ្យបានត្រឹមត្រូវ គ្រប់គ្រាន់អំពីឯកសារទាំងឡាយស្តីពីការស្វះស្វែងទុកដាក់កុមារតាមរយៈការថែទាំជំនួសនៅក្នុងស្រុកដោយអស់លទ្ធភាព ពិសេសតាមរយៈសុំកូនក្នុងស្រុក

-ករណីកុមារត្រូវបានបោះបង់ចោល ត្រូវមានឯកសារបញ្ជាក់អំពីការស្វះស្វែងរកឪពុកម្តាយ ឬឪពុក ឬម្តាយ ឬសាច់ញាតិ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារស្របតាមបទប្បញ្ញត្តិជាធរមាន

-រៀបចំលិខិតបទដ្ឋាន និងពិនិត្យសំណុំឯកសារដើម្បីអនុវត្តនីតិវិធីសុំកូនអន្តរប្រទេសដោយសាច់ញាតិ និងកុមារដែលមានតម្រូវការពិសេស

-ពិនិត្យលិខិតយល់ព្រមលើសុំកូនដែលត្រូវមានជាចាំបាច់ ហើយធ្វើឡើងស្របទៅតាមបទប្បញ្ញត្តិច្បាប់ស្តីពីសុំកូនអន្តរប្រទេស

-ពិនិត្យផ្ទៀងផ្ទាត់សំណុំឯកសារទាំងអស់របស់កុមារអំពីភាពត្រឹមត្រូវ និងស្របច្បាប់ ក្នុងករណីមានភាពមិនប្រក្រតី ត្រូវបញ្ជូនសំណុំឯកសារទៅផ្នែកអធិការកិច្ចដើម្បីធ្វើការស៊ើបអង្កេតឲ្យបានច្បាស់លាស់ និងធ្វើរបាយការណ៍អំពីលទ្ធផលនៃការស៊ើបអង្កេត

-អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានរដ្ឋបាលសុំកូនអន្តរប្រទេសប្រគល់ជូន។

ខ-ការងារពិនិត្យពាក្យសុំរបស់អ្នកសុំកូនៈ

-ទទួលពាក្យសុំកូនដែលបញ្ជូនមកពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិព្រមទាំងសំណុំឯកសារភស្តុតាងរបស់អ្នកសុំកូនដែលបានភ្ជាប់មកជាមួយ និងធ្វើលិខិតឆ្លើយតបទៅអ្នកសុំឲ្យស្របទៅតាមនីតិវិធី និងបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់ស្តីពីសុំកូនអន្តរប្រទេស

-ណែនាំអ្នកតំណាងទីភ្នាក់ងារសុំកូនអន្តរប្រទេសឲ្យបង់ប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានាជំនួសឲ្យអ្នកសុំតាមគោលការណ៍កំណត់ ក្រៅពីនេះមិនត្រូវបង់ប្រាក់អ្វីផ្សេងទៀតឡើយ

-ណែនាំទីភ្នាក់ងារសុំកូនអន្តរប្រទេស ឬអ្នកតំណាង ឬរបស់អ្នកសុំកូនមិនឲ្យបង់ប្រាក់ចំណាយ សោហ៊ុយ វិភាគទាន ឬការទូទាត់ដោយផ្ទាល់ ឬដោយប្រយោលក្តី ទោះក្នុងរូបភាពណាក៏ដោយទៅឲ្យមណ្ឌលកុមារកំព្រា ឬនាយក នាយករង សមាជិកគណៈគ្រប់គ្រង និងបុគ្គលិកមណ្ឌលកុមារកំព្រាឡើយ

-ចាត់ចែងឲ្យបកប្រែសំណុំឯកសារដើមរបស់អ្នកសុំទាំងអស់មកជាភាសាខ្មែរ ដោយមានបញ្ជាក់អំពីភាពត្រឹមត្រូវពីស្ថាប័នមានសមត្ថកិច្ច

-ពិនិត្យសំណុំឯកសាររបស់អ្នកសុំឲ្យបានត្រឹមត្រូវគ្រប់គ្រាន់ទៅតាមបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់ស្តីពីសុំកូនអន្តរប្រទេស ករណីសំណុំឯកសារមិនទាន់ត្រឹមត្រូវ ឬមិនទាន់គ្រប់គ្រាន់

- ធ្វើលិខិតរបស់ក្រសួងជូនដំណឹងទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិអំពីការសម្រេចរបស់តុលាការ
- ធ្វើលិខិតបញ្ជាក់ស្មុំកូនដាក់ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចុះហត្ថលេខា
- រៀបចំពិធីប្រគល់កុមារ ជូនលិខិតបញ្ជាក់ស្មុំកូន និងធ្វើកំណត់ហេតុអំពីពិធីប្រគល់កុមារ
- សហការជួយសម្របសម្រួលជាមួយ ស្ថាប័នមានសមត្ថកិច្ចក្នុងការធ្វើលិខិតឆ្លងដែន និងទិដ្ឋាការឲ្យកុមារបានធ្វើដំណើរទៅកាន់ប្រទេសទទួលដោយសុវត្ថិភាព និងស្របតាមនីតិវិធីច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានរដ្ឋបាលស្មុំកូនអន្តរប្រទេសប្រគល់ជូន។

**៤-ការិយាល័យអភិវឌ្ឍ គ្រប់គ្រងទីភ្នាក់ងារ និងរដ្ឋបាលកិច្ច**

ក-ការងារអភិវឌ្ឍ:

- រៀបចំតាក់តែងសេចក្តីព្រាងគោលនយោបាយ ច្បាប់ បទបញ្ជា និងនីតិវិធីថ្មីៗតាមការចាំបាច់ដើម្បីធ្វើឲ្យប្រសើរឡើងចំពោះការងារស្មុំកូនអន្តរប្រទេស
- ពិនិត្យ និងផ្តល់យោបល់ជូនគណៈកម្មាធិការអាជ្ញាធរកណ្តាលស្មុំកូនអន្តរប្រទេស អំពីការអនុវត្តគោលនយោបាយ ច្បាប់ បទបញ្ជា និងនីតិវិធីទាក់ទងនឹងស្មុំកូនអន្តរប្រទេស ព្រមទាំងអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារនិង សហប្រតិបត្តិការទាក់ទងនឹងស្មុំកូនអន្តរប្រទេស
- ធ្វើសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន ដែលមានសមត្ថកិច្ចលើកិច្ចការស្មុំកូនអន្តរប្រទេស និងទីភ្នាក់ងារស្មុំកូនអន្តរប្រទេសដែលធ្វើប្រតិបត្តិការស្មុំកូននៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ទប់ស្កាត់សកម្មភាពទាំងឡាយដែលបំពានច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស អនុសញ្ញាស្តីពីសិទ្ធិកុមារ អនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងស្មុំកូនអន្តរប្រទេស
- រៀបចំបើកវគ្គផ្សព្វផ្សាយច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស លិខិតបទដ្ឋានជាតិ និងអន្តរជាតិពាក់ព័ន្ធនឹងស្មុំកូនអន្តរប្រទេសដល់មន្ត្រីរបស់ក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋានជាពិសេស ឃុំ សង្កាត់
- រៀបចំកម្មវិធីបណ្តុះបណ្តាលសម្រាប់មន្ត្រីពាក់ព័ន្ធការងារស្មុំកូនអន្តរប្រទេស និងអ្នកពាក់ព័ន្ធផ្សេងទៀត
- តាមដាន វាយតម្លៃលទ្ធផលនៃការបណ្តុះបណ្តាល
- រៀបចំបោះពុម្ពសៀវភៅច្បាប់ស្មុំកូនអន្តរប្រទេស អនុសញ្ញាអន្តរជាតិ និងឯកសារពាក់ព័ន្ធផ្សេងៗទៀត
- រៀបចំតាក់តែង និងបោះពុម្ពសៀវភៅផ្នត់ ស្តីពីនីតិវិធីស្មុំកូនអន្តរប្រទេស
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានរដ្ឋបាលស្មុំកូនអន្តរប្រទេសប្រគល់ជូន។

ខ-ការងារគ្រប់គ្រងទីភ្នាក់ងារ:

- ពិនិត្យ និងផ្តល់យោបល់ ក្នុងការអនុញ្ញាតឲ្យទីភ្នាក់ងារស្មុំកូនអន្តរប្រទេសធ្វើប្រតិបត្តិការស្មុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- រៀបចំកិច្ចសន្យារវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាមួយទីភ្នាក់ងារស្មុំកូនអន្តរប្រទេសដែលធ្វើប្រតិបត្តិការស្មុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា

- បំពេញបែបបទ និងផ្តល់ព័ត៌មានទៅការិយាល័យអចិន្ត្រៃយ៍នៃសន្និសីទក្រុងឡាអេស្តីពីច្បាប់អន្តរជាតិ ឯកជន ភារកិច្ចស្រាវការ និងកាតព្វកិច្ចនៃប្រទេសជាភាគីនៃអនុសញ្ញានេះ
- ទំនាក់ទំនង និងសហការជាមួយការិយាល័យអចិន្ត្រៃយ៍នៃសន្និសីទក្រុងឡាអេ ស្តីពីច្បាប់អន្តរជាតិ ឯកជន រដ្ឋជាភាគីអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារនិងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស អង្គការជាតិ អង្គការអន្តរជាតិពាក់ព័ន្ធ ដៃគូអភិវឌ្ឍ និងប្រទេសជាមិត្តនានាដើម្បីទាក់ទាញការជួយឧបត្ថម្ភគាំទ្រផ្នែកបច្ចេកទេស និងសម្ភារៈចំពោះការងារសុំកូនអន្តរប្រទេសនៅកម្ពុជា
- រៀបចំកិច្ចព្រមព្រៀងនានារវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាមួយអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទទួលទាំងអស់ដែលពាក់ព័ន្ធលើការងារសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានរដ្ឋបាលសុំកូនអន្តរប្រទេសប្រគល់ជូន។

## ប្រការ៧.-

រដ្ឋបាលសុំកូនអន្តរប្រទេសមានសិទ្ធិប្រើប្រាស់ត្រាដោយឡែកសម្រាប់ប្រតិបត្តិការមុខងាររបស់ខ្លួន។

## ប្រការ៨ .-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

## ប្រការ៩.-

នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ប្រធាននាយកដ្ឋានសេវាកម្មផ្ទៃក្នុង ប្រធាននាយកដ្ឋានសុខុមាលភាពកុមារ ប្រធានរដ្ឋបាលសុំកូនអន្តរប្រទេស ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានីខេត្ត និងអង្គភាពពាក់ព័ន្ធមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

<u>ចម្លងជូន:</u>
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ **សម្តេចតេជោ នាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យឯកឧត្តម **សាត ឈាំ** ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងមុខងារសាធារណៈ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ ៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៣

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

លេខ ១៩៥៤ (ស.អ.យ.

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែសីហា ឆ្នាំ ២០១៤

# ប្រកាស
## ស្តីពី
## នីតិវិធីផ្តល់ការអនុញ្ញាតដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេស

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៣ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៤ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសុំកូនអន្តរប្រទេស
- បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ជាអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីកំណត់ចំនួនទីភ្នាក់ងារ ដែលអនុញ្ញាតឲ្យធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយចំនួននេះ កំណត់ឲ្យមានត្រឹម ០១ (មួយ) ឬ ០២ (ពីរ) លើកលែងតែក្នុងករណីចាំបាច់ដើម្បីឧត្តមប្រយោជន៍ កុមារអាចអនុញ្ញាតឲ្យមានលើសពីនេះ។

**ប្រការ ៤ .-**

ដើម្បីសុំការអនុញ្ញាតធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ទីភ្នាក់ងារត្រូវមានលក្ខណសម្បត្តិដូចតទៅ៖

១ - មានការបញ្ជាក់ទទួលស្គាល់គុណវុឌ្ឍិពីអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសរបស់ទីភ្នាក់ងារ។

២ - មានការអនុញ្ញាតពីអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសរបស់ទីភ្នាក់ងារ ឲ្យធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៣ -មានទិសដៅមិនស្វែងរកផលចំណេញ និងបានបំពេញនូវលក្ខខណ្ឌដែលមានចែងក្នុងបទប្បញ្ញត្តិច្បាប់ទាក់ទងនឹងនីតិបុគ្គលមិនយកចំណេញ សមាគម ឬ អង្គការមិនមែនរដ្ឋាភិបាល ឬ បទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតទាក់ទងនឹងលក្ខណៈនៃទីភ្នាក់ងារ។

៤ - មានអ្នកដឹកនាំ និងមានបុគ្គលិកដែលមានសមត្ថភាពប្រកបដោយគុណធម៌ និងសីលធម៌ បញ្ជាក់ដោយអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសរបស់ប្រទេសទីភ្នាក់ងារ បានទទួលការបណ្តុះបណ្តាលអំពីច្បាប់ ស្តីពីសុំកូនអន្តរប្រទេសរបស់ព្រះរាជាណាចក្រកម្ពុជា លិខិតបទដ្ឋានជាតិ និងអន្តរជាតិពាក់ព័ន្ធនឹងការងារសុំកូនអន្តរប្រទេស រៀបចំដោយអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស (រដ្ឋបាលសុំកូនអន្តរប្រទេស) និងមានបទពិសោធធ្វើការងារក្នុងវិស័យសុំកូនអន្តរប្រទេស។

**ប្រការ ៥ .-**

ទីភ្នាក់ងារដែលអនុញ្ញាតឲ្យធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេស នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវឆ្លើយតបនឹងលក្ខខណ្ឌដូចតទៅ៖

១ - មិនមានបើកមណ្ឌលកុមារកំព្រា ឬ ប្រើប្រាស់មណ្ឌលកុមារកំព្រា ដើម្បីជាប្រភពផ្តល់ទារក និងកុមារកំព្រាសម្រាប់សុំកូនអន្តរប្រទេស។

២ - ប្រទេសរបស់ទីភ្នាក់ងារជាប្រទេសដែលមានទំនាក់ទំនងការទូតជាមួយព្រះរាជាណាចក្រកម្ពុជា។

១០ - ឯកសារភស្តុតាងនានាដែលបញ្ជាក់ថាអ្នកតំណាងដូចមានចែងក្នុងចំណុច ៩ ខាងលើ គ្មានជាប់ឈ្មោះក្នុងបញ្ជីផ្តន្ទាទោសនៅប្រទេសដើមរបស់ខ្លួន និងនៅប្រទេសចុងក្រោយដែលខ្លួនកំពុងរស់នៅ ប្រសិនបើប្រទេសខុសគ្នា។

១១ - ច្បាប់ចម្លងឯកសារកិច្ចព្រមព្រៀងពីអតីតកាល ឬ បច្ចុប្បន្នកាលជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការផ្តល់ជំនួយមនុស្សធម៌ ឬ ការជួយឧបត្ថម្ភដល់កុមារកំព្រានានា នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

១២ - ច្បាប់ចម្លងកិច្ចព្រមព្រៀងទ្វេភាគី ស្តីពីកិច្ចសហប្រតិបត្តិការសុំកូនអន្តរប្រទេសរវាងព្រះរាជាណាចក្រកម្ពុជា (ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ) និងប្រទេសរបស់ទីភ្នាក់ងារ ប្រសិនបើប្រទេសនេះមិនមែនជាប្រទេសភាគីអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស។

១៣ - ឯកសារផ្សេងៗទៀតដែលក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា យល់ថាចាំបាច់ដើម្បីឧត្តមប្រយោជន៍កុមារ និងដើម្បីមានមូលដ្ឋានវាយតម្លៃពាក្យសុំឲ្យបានសមស្រប។

ពាក្យសុំ និងសំណុំឯកសារទាំងអស់ត្រូវបញ្ជូនតាមរយៈស្ថានទូត ឬ ស្ថានតំណាងនៃប្រទេសរបស់ទីភ្នាក់ងារប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ពិនិត្យ និងបញ្ជូនបន្តមកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

សំណុំឯកសារទាំងអស់នេះ ត្រូវមានជាភាសាអង់គ្លេស ឬ ភាសាបារាំង ហើយត្រូវបកប្រែជាភាសាខ្មែរ។

**ប្រការ ៧ .** –

នៅពេលពាក្យស្នើសុំ និងសំណុំឯកសារទាំងអស់មកដល់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវទំនាក់ទំនងអញ្ជើញសាមីទីភ្នាក់ងារមកបង់ប្រាក់តម្លៃសេវារដ្ឋបាលពិនិត្យឯកសារចំនួន ២០០០ ០០០ (ពីរលាន) រៀល យោងតាមប្រកាសរួមលេខ ១០០៧ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

ចំនួនទឹកប្រាក់នេះមិនអាចបង្វិលជូនវិញទេ។

**ប្រការ ៨ .** –

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានឹងផ្តល់ចម្លើយជាលាយលក្ខណ៍អក្សរទៅទីភ្នាក់ងារ វិញអំពីការសម្រេចរបស់ក្រសួង ក្នុងកំឡុងពេល៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ

កិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ពិនិត្យឃើញថា សេវារបស់ទីភ្នាក់ងារសុំកូនអន្តរប្រទេសនោះនៅតែចាំបាច់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ទីភ្នាក់ងារត្រូវដាក់ពាក្យស្នើសុំសាជាថ្មីទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រយៈពេល៩០ (កៅសិប) ថ្ងៃ នៃថ្ងៃធ្វើការ មុនអាជ្ញាប័ណ្ណរបស់ទីភ្នាក់ងារអស់សុពលភាព ដើម្បីសុំបន្តការអនុញ្ញាតធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជាតទៅទៀត ហើយត្រូវចម្លងពាក្យស្នើសុំនេះ ជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិដើម្បីជ្រាប។ ឯកសារនៅក្នុងប្រការ ៦ នៃប្រកាសនេះ ហើយអស់សុពលភាព ទីភ្នាក់ងារត្រូវរៀបចំបំពេញសារជាថ្មី។ ត្រូវបង់ប្រាក់តម្លៃសេវារដ្ឋបាលពិនិត្យឯកសារ និងផ្តល់អាជ្ញាប័ណ្ណ ចំនួន ២ ០០០ ០០០ (ពីរលាន) រៀល យោងតាមប្រកាសរួមលេខ ១០០៧ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ទឹកប្រាក់នេះមិនអាចបង្វិលជូនវិញទេ។

មុនផ្តល់ការអនុញ្ញាតសារជាថ្មី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អាចចាត់តាំងមន្ត្រី អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសឲ្យទៅពិនិត្យវាយតម្លៃសកម្មភាពការងាររបស់ទីភ្នាក់ងារ ហើយក្នុងករណីចាំបាច់អាចទៅធ្វើទស្សនកិច្ចពិនិត្យវាយតម្លៃអំពីស្ថានភាពរស់នៅរបស់កុមារកម្ពុជា ដែលត្រូវបានសុំយកទៅចិញ្ចឹមនៅប្រទេសរបស់ទីភ្នាក់ងារនោះ។ ទីភ្នាក់ងារសុំកូនអន្តរប្រទេសសាមីត្រូវសម្របសម្រួលជាមួយអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់ខ្លួនដើម្បីបង្កលក្ខណៈងាយស្រួលដល់ការពិនិត្យវាយតម្លៃនេះ។

**ប្រការ ១១ .-**

ទីភ្នាក់ងារសុំកូនអន្តរប្រទេស ដែលមានបំណងឈប់ធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវធ្វើលិខិតជូនដំណឹងជាផ្លូវការជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងរយៈពេល៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ មុនកាលបរិច្ឆេទឈប់ធ្វើប្រតិបត្តិការ។ លិខិតជូនដំណឹងនេះត្រូវចម្លង ជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ ក្នុងករណីនេះ អាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសសាមីរបស់ទីភ្នាក់ងារអាចបញ្ជូនទីភ្នាក់ងារថ្មីមកជំនួសទីភ្នាក់ងារដែលបានបញ្ចប់សកម្មភាព។ ទីភ្នាក់ងារថ្មីត្រូវបំពេញបែបបទស្នើសុំការអនុញ្ញាតតាមបទប្បញ្ញត្តិនៃប្រកាសនេះ។

**ប្រការ ១២ .-**

ទីភ្នាក់ងារសុំកូនអន្តរប្រទេសត្រូវបង់ប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានាជំនួសឲ្យអ្នកសុំទៅតាមចំនួនកូនសុំ។ បរិមាណទឹកប្រាក់មានកំណត់ក្នុងប្រកាសរួមលេខ ៨៨៨ សហវ.

៤ - អំពើក្លែងបន្លំ ឬ សមគំនិតក្លែងបន្លំស្ថានភាពលំបាកបំផុត ដើម្បីទទួលបានការយល់ព្រមពីឪពុកម្តាយបង្កើត ឬ ឪពុកបង្កើត ឬ ម្តាយបង្កើត ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ។

៥ - អំពើរៀបចំឲ្យមានការយល់ព្រមរបស់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ដោយការបង្ខិតបង្ខំ ការគំរាមកំហែង ការឆបោក ឬ ការបញ្ចុះបញ្ចូលតាមរយៈការផ្តល់ ឬ សន្យាផ្តល់ប្រាក់រង្វាន់សំណង ឬ ផលប្រយោជន៍ណាមួយ។

៦ - ការបញ្ចេញសំណុំឯកសារ និងកំណត់ហេតុទាំងអស់ ឬ មួយផ្នែកទាក់ទងនឹងករណីសុំកូនអន្តរប្រទេសជាក់លាក់ណាមួយ ដោយគ្មានការអនុញ្ញាតពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬ ពីតុលាការមានសមត្ថកិច្ច។

៧ - ការបង្អាប់ ឬ ការទទួលដោយផ្ទាល់ ឬ ដោយប្រយោលនូវថ្នូរប្រាក់កាស ទំនិញ ឬ សេវាដោះដូរ និងការបម្រុងទុកកុមារណាមួយសម្រាប់សុំកូន។

៨ - ការថ្លែងមិនពិត ឬ លាក់បាំងព័ត៌មានសំខាន់ណាមួយដែលតម្រូវដោយច្បាប់ទាក់ទងនឹងសុំកូនអន្តរប្រទេស ការបង្កើត និងការប្រព្រឹត្តទៅនៃអង្គការមិនស្វែងរកផលចំណេញ ឬ លក្ខខណ្ឌតម្រូវនានានៃប្រកាសនេះ។

៩ - ការផ្តល់ប្រាក់កាស ទំនិញ ឬ សេវាទៅឲ្យមន្ត្រី ឬ អ្នកតំណាងណាមួយនៃរដ្ឋបាលសុំកូនអន្តរទេសក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស ឬ មន្ត្រីពាក់ព័ន្ធផ្សេងទៀត ដើម្បីឲ្យផ្តល់សិទ្ធិជាអាទិភាពក្នុងនីតិវិធីសុំកូនអន្តរប្រទេសដល់អ្នកសុំ។ ត្រូវហាមឃាត់ផងដែរការទទួលប្រាក់ ទំនិញ ឬ សេវាសម្រាប់គោលបំណងនេះដែរ។

១០- ការផ្សាយពាណិជ្ជកម្ម ឬ ការបោះពុម្ពផ្សាយនូវអត្តសញ្ញាណ ឬ រូបថតរបស់កុមារណាមួយដែលជាកម្មវត្ថុសុំកូនអន្តរប្រទេស ក្នុងគោលបំណងបញ្ចុះបញ្ចូលបុគ្គលណាមួយឲ្យដាក់ពាក្យសុំកូន។

១១- ការធ្វើអំពើណាមួយ ដែលមិនគោរពទៅតាមច្បាប់ ស្តីពីសុំកូនអន្តរប្រទេស ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គការមិនស្វែងរកផលចំណេញ ឬ លក្ខខណ្ឌតម្រូវនានានៃប្រកាសនេះ។

១២- ការតែងតាំង ឬ ចាត់តាំងអ្នកតំណាងណាមួយដោយមិនមានការអនុញ្ញាតទទួលស្គាល់ពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

រយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីកាលបរិច្ឆេទដែលបានទទួលការឆ្លើយបំភ្លឺ ឬ ការខកខានមិនបានឆ្លើយតប ឬ ឆ្លើយបំភ្លឺពីសំណាក់ទីភ្នាក់ងារក្នុងរយៈពេលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ នៃប្រការនេះ រដ្ឋបាលស្នំកូនអន្តរប្រទេសត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរជូនរដ្ឋមន្ត្រីក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីសុំការសម្រេច។

**ប្រការ ១៨ .–**

អាស្រ័យលើស្ថានទម្ងន់នៃការរំលោភបំពានច្បាប់ ឬ ករណីទីភ្នាក់ងារខកខានមិនបានផ្តល់ការឆ្លើយតប ឬ ឆ្លើយបំភ្លឺ ហើយបើចាំបាច់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អាចព្យួរជាបណ្តោះអាសន្នមិនឲ្យទីភ្នាក់ងារពាក់ព័ន្ធនោះធ្វើសកម្មភាពរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ ជាអតិបរិមា។ ប្រសិនបើមានភ័ស្តុតាងបង្ហាញថា ទីភ្នាក់ងារ ឬ អ្នកតំណាងទីភ្នាក់ងារបានរំលោភបំពានច្បាប់យ៉ាងធ្ងន់ធ្ងរ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អាចបញ្ឈប់ទីភ្នាក់ងារនោះជាបន្ទាន់មិនអនុញ្ញាត ឲ្យធ្វើប្រតិបត្តិការស្នំកូនអន្តរប្រទេសតទៅទៀត ហើយត្រូវមានវិធានការដើម្បីធានាថា ការបញ្ឈប់សកម្មភាពរបស់ទីភ្នាក់ងារនោះពុំមានកុមារណាមួយទទួលរងគ្រោះអំពីការព្យួរ ឬ ការបញ្ឈប់ការអនុញ្ញាតឲ្យធ្វើប្រតិបត្តិការរបស់ទីភ្នាក់ងារនោះឡើយ។

**ប្រការ ១៩ .–**

ក្នុងករណីចាំបាច់ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អាចស្នើសុំតាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ទៅអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកស្នំកូនអន្តរប្រទេសនៃប្រទេសរបស់ទីភ្នាក់ងារ ដើម្បីទៅធ្វើអធិការកិច្ចទីភ្នាក់ងារស្នំកូនអន្តរប្រទេសនៅប្រទេសសាមីទីភ្នាក់ងារនោះ។ គ្មានជនណាអាចរារាំង បង្អាក់ ឬ ជ្រៀតជ្រែកក្នុងការងារអធិការកិច្ចដែលបានធ្វើឡើងត្រឹមត្រូវតាមច្បាប់នោះឡើយ។

ផ្អែកតាមលទ្ធផលនៃការធ្វើអធិការកិច្ច ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អាចសម្រេចព្យួរ ឬ ដកហូតការអនុញ្ញាត ឬ បដិសេធការបន្តការអនុញ្ញាតសាជាថ្មីទៅតាមស្ថានទម្ងន់ ឬ ភ័ស្តុតាងបង្ហាញពីការរំលោភបំពាន ហើយត្រូវធ្វើលិខិតជូនដំណឹងអំពីការសម្រេចនេះទៅឲ្យទីភ្នាក់ងារសាមី អាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកស្នំកូនអន្តរប្រទេសនៃប្រទេសរបស់ទីភ្នាក់ងារ និងចម្លងជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

**ប្រការ ២០ .–**

ការទទួលពាក្យស្នើសុំ ការអនុញ្ញាតដល់ទីភ្នាក់ងារស្នំកូនអន្តរប្រទេសនៃប្រទេសទទួលនឹងចាប់ផ្តើមអនុវត្តបន្ទាប់ពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

# សេចក្តីជូនដំណឹង
# អំពី
# ស្ថានភាពសុំកូនអន្តរប្រទេសនៅកម្ពុជា

អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដល់សាធារណមតិជាតិ និងអន្តរជាតិ អំពីស្ថានភាពនៃការងារសុំកូនអន្តរប្រទេសដូចតទៅ៖

ច្បាប់ស្តីពីសុំកូនអន្តរប្រទេស នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានចូលជាធរមាននៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៩ ដោយអនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា៤៨ និងអនុលោមទៅតាមអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស ដែលត្រូវបានផ្តល់សច្ចាប័ននៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៧ ព្រមទាំងពិធីសារបន្ថែមចំនួនពីរ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលត្រូវបានផ្តល់សច្ចាប័ននៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០២។ បន្ទាប់ពីកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញា និងពិធីសារបន្ថែមខាងលើនោះមក រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍នានា ក្នុងការធានាឱ្យមានដំណើរការសុំកូនអន្តរប្រទេសស្របតាមច្បាប់ជាតិ អន្តរជាតិ ប្រកបដោយក្រមសីលធម៌ និងតម្លាភាព ដើម្បីការពារឧត្តមប្រយោជន៍របស់កុមារដែលជាកម្មវត្ថុសុំកូនអន្តរប្រទេស។

ក្នុងដំណាក់កាលនៃការរៀបចំលិខិតបទដ្ឋានគតិយុត្តចាំបាច់ដូចបានបញ្ជាក់ជូនខាងលើ កម្ពុជាបានសម្រេចផ្អាកការសុំកូនអន្តរប្រទេសចាប់តាំងពីឆ្នាំ ២០១១ មក។ លិខិតបទដ្ឋានគតិយុត្តដែលបាននិងកំពុងរៀបចំរួមមាន៖ ១. នីតិវិធីស្តីពីសុំកូនក្នុងស្រុក ២. ស្តង់ដារគ្រប់គ្រងករណី និងការបង្រួបបង្រួមគ្រួសារ ដើម្បីធ្វើសមាហរណកម្មកុមារដែលកំពុងរស់នៅក្នុងមណ្ឌលរដ្ឋ និងមណ្ឌលអង្គការមិនមែនរដ្ឋាភិបាល។

ផ្អែកតាមយន្តការខាងលើអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា ចាប់ផ្តើមទទួលស្វាគមន៍បណ្តាប្រទេស ដែលមានបំណងធ្វើកិច្ចសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេសជាមួយកម្ពុជា តាមរយៈកិច្ចព្រមព្រៀងទ្វេភាគី ស្តីពីការកំណត់ចំនួនទីភ្នាក់ងារ និងអនុញ្ញាតឱ្យទីភ្នាក់ងារសុំកូនដែលបានចុះបញ្ជីត្រឹមត្រូវនៅក្នុងបណ្តាប្រទេសជាដៃគូ អាចដាក់ពាក្យស្នើសុំដើម្បីទទួលការអនុញ្ញាតឱ្យធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ឧបសម្ព័ន្ធនៃប្រកាសលេខ ១២៣០ ស.អ.យ. ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០១៤

**អង្គភាពលេខារដ្ឋបាលសុំកូនអន្តរប្រទេស**



# ប្រកាស

# ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលស្រុក ក្នុងអន្តរប្រទេស

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៚

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

លេខ ២៥០ ស.អ.យ.

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៣

# ប្រកាស

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលសុំកូនអន្តរប្រទេស

---

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១០៥ / ០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុសញ្ញាស្តីពីសិទ្ធិកុមារដែលក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា បានសុំចូលជាភាគីនៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២
- បានឃើញព្រះរាជក្រម នស / រកម / ០១០៧ / ០០៣ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស
- បានឃើញព្រះរាជក្រមលេខ នស / រកម / ១២០៩ / ០២៨ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសុំកូនអន្តរប្រទេស
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញប្រកាសលេខ ២៩៥ សអយ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញការចាំបាច់របស់ក្រសួង

## សម្រេច

### ប្រការ ១.-

ប្រកាសនេះកំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលសុំកូនអន្តរប្រទេស មានអក្សរកាត់ថា " រ.ស.អ. " ជាភាសាអង់គ្លេស " Inter- country Adoption Administration (I.C.A.A) "។

## ប្រការ ២.-

រដ្ឋបាលសុំកូនអន្តរប្រទេសមានភារកិច្ចដូចខាងក្រោម៖

១.រៀបចំ ថែរក្សា និងធ្វើបច្ចុប្បន្នភាពបញ្ជីសម្គាល់ និងសំណុំឯកសាររបស់កុមារដែលមានលក្ខណសម្បត្តិសមស្របសម្រាប់សុំកូនអន្តរប្រទេស។

២.ធ្វើការថ្លឹងថ្លែងប្រមាណស្ថានភាពកុមារទាំងអស់ដែលមានឈ្មោះក្នុងបញ្ជីសម្គាល់ ដើម្បីកំណត់ទម្រង់នៃការចិញ្ចឹមថែទាំសមស្របបំផុតសម្រាប់កុមារ និងធានាថាកុមារទាំងនោះទទួលបានការចិញ្ចឹមថែទាំតាមតម្រូវការ។

៣.ធ្វើការផ្ទៀងផ្ទាត់អំពីការខិតខំប្រឹងប្រែងដោយអស់លទ្ធភាពក្នុងដំណោះស្រាយនៅក្នុងប្រទេស តាមរយៈការថែទាំជាអចិន្ត្រៃយ៍នៅតាមគ្រួសារ ឬជាមួយអ្នកអាណាព្យាបាលមុនដាក់ដំណើរការសុំកូនអន្តរប្រទេស។

៤.ទទួលពិនិត្យ និងចាត់ការពាក្យសុំកូនអន្តរប្រទេស និងឯកសារពាក់ព័ន្ធផ្សេងៗទៀតរបស់អ្នកសុំ។

៥.ផ្គូផ្គងកុមារដែលមានលក្ខណសម្បត្តិសមស្របសម្រាប់សុំកូនអន្តរប្រទេសជាមួយអ្នកសុំដែលអាចបំពេញតម្រូវការដ៏ល្អបំផុតរបស់កុមារ ស្របតាមគោលការណ៍នៃឧត្តមប្រយោជន៍របស់កុមារ ហើយលើកយោបល់ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាពិនិត្យសម្រេច។

៦.ជូនដំណឹងអំពីនីតិវិធីសុំកូន និងការវិវឌ្ឍនៃករណីសុំកូនទៅអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទទួល ឬទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាតពីប្រទេសទទួល។

៧.រៀបចំពិធីប្រគល់កុមារឲ្យទៅអ្នកសុំ និងរៀបចំឯកសារដើម្បីឲ្យកុមារធ្វើដំណើរចូលទៅប្រទេសរបស់អ្នកសុំ។

៨.ផ្តល់ ឬសម្របសម្រួលការផ្តល់សេវាក្រោយសុំកូនសមស្របដល់កុមារ គ្រួសារអ្នកសុំ និងគ្រួសារបង្កើតតាមការចាំបាច់។

៩.ផ្តល់យោបល់ជូនគណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស ទាក់ទងនឹងការអនុញ្ញាត ឬដកហូតការអនុញ្ញាតដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

១០.អនុវត្តគោលការណ៍ណែនាំរបស់គណៈកម្មាធិការអាជ្ញាធរកណ្តាល ដើម្បីធ្វើអធិការកិច្ចលើកិច្ចការសុំកូនអន្តរប្រទេស។ គ្មានជនណាអាចរារាំង បង្អាក់ បំភិតបំភ័យ ឬជ្រៀតជ្រែកក្នុងការងារអធិការកិច្ចដែលបានធ្វើឡើងត្រឹមត្រូវតាមច្បាប់បានឡើយ។

១១.លើកសំណើសុំការសម្រេចពីគណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស ដើម្បីចាត់វិធានការព្រមាន ដាក់កំហិត ឬដាកពិន័យចំពោះបុគ្គល ឬអង្គភាពដែលប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីសុំកូនអន្តរប្រទេស ព្រមទាំងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមានផ្សេងៗទៀត។

១២.ពិនិត្យឯកសារទាក់ទងនឹងសុំកូនអន្តរប្រទេស និងផ្តល់យោបល់សមស្របជូនប្រធានគណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស និងជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីពិនិត្យសម្រេច ។

១៣-រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុរាល់ការប្រជុំរបស់គណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស។

១៤.គ្រប់គ្រងថវិកាចំណាយរបស់រដ្ឋបាលសុំកូនអន្តរប្រទេស រៀបចំធ្វើផែនការចំណាយ និងធ្វើរបាយការណ៍ហិរញ្ញវត្ថុស្តីពីស្ថានភាពប្រើប្រាស់ថវិកាការប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំជូនអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស។

១៥.រៀបចំផែនការ កម្មវិធី និងសកម្មភាពបណ្តុះបណ្តាលជំនាញដល់មន្ត្រីធ្វើការងារសុំកូនអន្តរប្រទេស និងអ្នកពាក់ព័ន្ធផ្សេងទៀត។

១៦.ដាក់វិធានការសមស្របក្នុងការប្រមូល ថែរក្សា និងផ្លាស់ប្តូរព័ត៌មានស្តីពីស្ថានភាពកុមារ ព័ត៌មានដើមកំណើតកុមារ អត្តសញ្ញាណឪពុកម្តាយ និងប្រវត្តិសុខភាពកុមារ ។

១៧.បំពេញភារកិច្ចចាំបាច់ផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេស ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិផ្សេងៗទៀត តាមការប្រគល់ភារកិច្ចរបស់គណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស។

## ប្រការ ៣.–

រដ្ឋបាលសុំកូនអន្តរប្រទេស ដឹកនាំដោយប្រធានមួយរូប ដែលមានឋានៈស្មើអនុប្រធាននាយកដ្ឋាន និងមានអនុប្រធានមួយចំនួន មានឋានៈស្មើអនុប្រធាននាយកដ្ឋាន ។

## ប្រការ ៤.–

រដ្ឋបាលសុំកូនអន្តរប្រទេសមានរចនាសម្ព័ន្ធដូចខាងក្រោម៖

១.ការិយាល័យរដ្ឋបាល ហិរញ្ញវត្ថុ និងតម្កល់ឯកសារ

២.ការិយាល័យអនុវត្តនីតិវិធីសុំកូនអន្តរប្រទេស

៣.ការិយាល័យអភិវឌ្ឍ គ្រប់គ្រងទីភ្នាក់ងារ អធិការកិច្ច និងសហប្រតិបត្តិការអន្តរជាតិ

ប្រធានការិយាល័យនីមួយៗមានឋានៈស្មើប្រធានការិយាល័យថ្នាក់ក្រសួង។

អង្គការលេខរបស់រដ្ឋបាលសុំកូនអន្តរប្រទេសមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

## ប្រការ ៥.–

សមាសភាពថ្នាក់ដឹកនាំ និងមន្ត្រីបម្រើការងារនៅរដ្ឋបាលសុំកូនអន្តរប្រទេសត្រូវមានលក្ខណសម្បត្តិដូចខាងក្រោមនេះ៖

-មានបទពិសោធន៍លើការងារសង្គមកិច្ច ផ្នែកចិត្តសាស្ត្រ ជាពិសេសការងារសុខុមាលភាពកុមារ។

-បានទទួលការបណ្តុះបណ្តាលវគ្គសេវាសង្គមកិច្ច។

-មានចំណេះដឹងជាមូលដ្ឋានលើផ្នែកច្បាប់ ជាពិសេសច្បាប់ស្តីពីសុំកូនអន្តរប្រទេស និងអនុសញ្ញាអន្តរជាតិនានាដែលពាក់ព័ន្ធនឹងសុំកូនអន្តរប្រទេស។

-មានសមត្ថភាពខាងផ្នែកព័ត៌មានវិទ្យា និងភាសាបរទេសជាពិសេសភាសាអង់គ្លេស ។

-ជាមន្ត្រីក្របខណ្ឌរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬជាមន្ត្រីជាប់កិច្ចសន្យា។

-រដ្ឋបាលសុំកូនអន្តរប្រទេសអាចប្រើប្រាស់ទីប្រឹក្សាតាមការចាំបាច់។

## ប្រការ ៦.–

ការិយាល័យនីមួយៗមានភារកិច្ចដូចតទៅ៖

**១.ការិយាល័យរដ្ឋបាល ហិរញ្ញវត្ថុ និងតម្កល់ឯកសារ**

ក.ការងាររដ្ឋបាល បុគ្គលិក:

-គ្រប់គ្រងបុគ្គលិក។

-ទទួលគ្រប់គ្រង ធ្វើការទាក់ទងជាមួយស្ថាប័ន អង្គភាព អាជ្ញាធរមូលដ្ឋាន ក្នុងការផ្ញើ ទទួល បែងចែក សារាចរ លិខិត ឯកសារ។

-គ្រប់គ្រងបញ្ជីសារពើភ័ណ្ឌ សម្ភារៈ និងគ្រឿងបរិក្ខារ។

-ផ្សព្វផ្សាយបទបញ្ជា សារាចរ សេចក្តីសម្រេច សេចក្តីជូនដំណឹងផ្សេងៗរបស់ថ្នាក់ដឹកនាំ។

-រៀបចំកិច្ចប្រជុំ ធ្វើកំណត់ហេតុអង្គប្រជុំ រៀបចំលិខិតស្នាមផ្សេងៗទៀតតាមស្មារតីអង្គប្រជុំរបស់គណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស។

-ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំរបស់រដ្ឋបាលសុំកូនអន្តរប្រទេស។

-អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានរដ្ឋបាលសុំកូនអន្តរប្រទេសប្រគល់ជូន។

ខ.ការងារហិរញ្ញវត្ថុ:

-ជំនួយឲ្យអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស ក្នុងការអនុវត្តនីតិវិធី ទទួល គ្រប់គ្រងថវិកាជាប្រាក់ចំណាយសេវាហើយ និងវិភាគទានសុំកូនអន្តរប្រទេស ស្របតាមការកំណត់នៃប្រកាសរួមរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-ទទួលគ្រប់គ្រងថវិកាចំណូលរបស់រដ្ឋបាលសុំកូនអន្តរប្រទេស រៀបចំធ្វើផែនការចំណាយ និងលើកសំណើប្រើប្រាស់ថវិកាដែលមានតាមភារកិច្ចរបស់រដ្ឋបាលសុំកូនអន្តរប្រទេស។

-ធ្វើរបាយការណ៍ពីចំណូល និងចំណាយរបស់អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស និងរដ្ឋបាលសុំកូនអន្តរប្រទេសរៀងរាល់ខែ ត្រីមាស និងប្រចាំឆ្នាំ។

-អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានរដ្ឋបាលសុំកូនអន្តរប្រទេសប្រគល់ជូន។

គ-ការងារតម្កល់ឯកសារ:

-រៀបចំតម្កល់រក្សាទុកសំណុំឯកសាររបស់កុមារឲ្យបានគង់វង្សល្អក្នុងរយៈពេល ៦០ (ហុកសិប) ឆ្នាំ។

-រក្សាការសម្ងាត់ចំពោះព័ត៌មានទាំងអស់ដែលមានសរសេរនៅក្នុងសំណុំឯកសារ។

-ណែនាំឪពុកម្តាយចិញ្ចឹម និងកូនសុំដែលដល់អាយុពេញវ័យឲ្យដាក់ពាក្យសុំមកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប្រសិនបើចង់មើល ឬចង់ចម្លងសំណុំឯកសារ។

-ពិគ្រោះយោបល់ជាមួយកូនសុំឲ្យបានសមស្រប មុនឲ្យមើលព័ត៌មានផ្សេងៗនៅក្នុងសំណុំឯកសារ។

-អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានរដ្ឋបាលសុំកូនអន្តរប្រទេសប្រគល់ជូន។

**២.ការិយាល័យអនុវត្តនីតិវិធីសុំកូនអន្តរប្រទេស**

ក-ការងារគ្រប់គ្រងអត្តសញ្ញាណកុមារដែលជាកម្មវត្ថុសុំកូនអន្តរប្រទេស:

-រៀបចំបញ្ជីត្រួតពិនិត្យឯកសារ ព័ត៌មានផ្សេងៗតាមដំណាក់កាល និងពេលវេលាសម្រាប់សំណុំឯកសារទាំងអស់។

-រៀបចំសំណុំឯកសារផ្ទាល់ខ្លួនរបស់កុមារម្នាក់ៗ ដែលមានលក្ខណសម្បត្តិសម្រាប់សុំកូនអន្តរប្រទេសរួមមានព័ត៌មានចាំបាច់អំពីអត្តសញ្ញាណរបស់កុមារ ភាពអាចសុំជាកូនចិញ្ចឹមបាន សាវតាជាតិរបស់កុមារ បរិយាកាសសង្គម ប្រវត្តិគ្រួសារ ប្រវត្តិសុខភាពផ្ទាល់ខ្លួន ប្រវត្តិសុខភាពគ្រួសារកុមារ និងសេចក្តីត្រូវការពិសេសរបស់កុមារ។

-ពិនិត្យមើលឲ្យបានត្រឹមត្រូវ គ្រប់គ្រាន់អំពីឯកសារទាំងឡាយស្តីពីការស្វះស្វែងទុកដាក់កុមារតាមរយៈការថែទាំជំនួសនៅក្នុងស្រុកដោយអស់លទ្ធភាព ពិសេសតាមរយៈសុំកូនក្នុងស្រុក។

-ករណីកុមារត្រូវបានបោះបង់ចោល ត្រូវមានឯកសារបញ្ជាក់អំពីការស្វះស្វែងរកឪពុកម្ដាយ ឬឪពុក ឬម្ដាយ ឬសាច់ញាតិ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារស្របតាមបទប្បញ្ញត្តិជាធរមាន។

-រៀបចំលិខិតបទដ្ឋាន និងពិនិត្យសំណុំឯកសារដើម្បីអនុវត្តនីតិវិធីសុំកូនអន្តរប្រទេសដោយសាច់ញាតិ និងកុមារដែលមានតម្រូវការពិសេស។

-ពិនិត្យលិខិតយល់ព្រមលើសុំកូនដែលត្រូវមានជាចាំបាច់ ហើយធ្វើឡើងស្របទៅតាមបទប្បញ្ញត្តិច្បាប់ស្ដីពីសុំកូនអន្តរប្រទេស។

-ពិនិត្យផ្ទៀងផ្ទាត់សំណុំឯកសារទាំងអស់របស់កុមារអំពីភាពត្រឹមត្រូវ និងស្របច្បាប់ ក្នុងករណីមានភាពមិនប្រក្រតី ត្រូវបញ្ជូនសំណុំឯកសារទៅផ្នែករដ្ឋបាលកិច្ចដើម្បីធ្វើការស៊ើបអង្កេតឲ្យបានច្បាស់លាស់ និងធ្វើរបាយការណ៍អំពីលទ្ធផលនៃការស៊ើបអង្កេត។

-អនុវត្តភារកិច្ចផ្សេងៗទៀតដែលអាជ្ញាធរកណ្ដាលសុំកូនអន្តរប្រទេសប្រគល់ឲ្យ។

ខ-ការងារពិនិត្យពាក្យសុំរបស់អ្នកសុំកូនៈ

-ទទួលពាក្យសុំកូនដែលបញ្ជូនមកពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិព្រមទាំងសំណុំឯកសារភស្តុតាងរបស់អ្នកសុំកូនដែលបានភ្ជាប់មកជាមួយ និងធ្វើលិខិតឆ្លើយតបទៅអ្នកសុំឲ្យស្របទៅតាមនីតិវិធី និងបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់ស្ដីពីសុំកូនអន្តរប្រទេស។

-ណែនាំអ្នកតំណាងទីភ្នាក់ងារសុំកូនអន្តរប្រទេសឲ្យបង់ប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានាជំនួសឲ្យអ្នកសុំតាមគោលការណ៍កំណត់ ក្រៅពីនេះមិនត្រូវបង់ប្រាក់អ្វីផ្សេងទៀតឡើយ។

-ណែនាំទីភ្នាក់ងារសុំកូនអន្តរប្រទេស ឬអ្នកតំណាង ឬរបស់អ្នកសុំកូនមិនឲ្យបង់ប្រាក់ចំណាយ សោហ៊ុយ វិភាគទាន ឬការទូទាត់ដោយផ្ទាល់ ឬដោយប្រយោលក្ដី ទោះក្នុងរូបភាពណាក៏ដោយទៅឲ្យមណ្ឌលកុមារកំព្រា ឬនាយក នាយករង សមាជិកគណៈគ្រប់គ្រង និងបុគ្គលិកមណ្ឌលកុមារកំព្រាឡើយ។

-ចាត់ចែងឲ្យបកប្រែសំណុំឯកសារដើមរបស់អ្នកសុំទាំងអស់មកជាភាសាខ្មែរ ដោយមានបញ្ជាក់អំពីភាពត្រឹមត្រូវពីស្ថាប័នមានសមត្ថកិច្ច។

-ពិនិត្យសំណុំឯកសាររបស់អ្នកសុំឲ្យបានត្រឹមត្រូវគ្រប់គ្រាន់ទៅតាមបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់ស្ដីពីសុំកូនអន្តរប្រទេស ករណីសំណុំឯកសារមិនទាន់ត្រឹមត្រូវ ឬមិនទាន់គ្រប់គ្រាន់ ត្រូវធ្វើលិខិតជូនដំណឹងទៅទីភ្នាក់ងារសុំកូនអន្តរប្រទេស ដើម្បីឲ្យអ្នកសុំបំពេញឯកសារដែលខ្វះ ឬកែតម្រូវឲ្យបានត្រឹមត្រូវឡើងវិញ។

-ធ្វើលិខិតឆ្លើយតបទៅអ្នកសុំដោយបញ្ជាក់ពីមូលហេតុឲ្យបានច្បាស់លាស់ ក្នុងករណីបដិសេធពាក្យសុំកូន។

-អនុវត្តភារកិច្ចផ្សេងៗទៀតដែលអាជ្ញាធរកណ្ដាលសុំកូនអន្តរប្រទេសប្រគល់ឲ្យ។

គ-ការងារផ្គូផ្គងកុមារៈ

-ពិនិត្យ និងពិចារណាលើសំណុំឯកសាររបស់កុមារដែលមានឈ្មោះនៅក្នុងបញ្ជីកុមារជាកម្មវត្ថុសម្រាប់សុំកូនអន្តរប្រទេស រួចហើយត្រូវផ្គូផ្គងជាមួយអ្នកសុំណាដែលមានលក្ខណសម្បត្តិត្រូវសមគ្នាល្អបំផុតស្របតាមបទប្បញ្ញត្តិ ដែលមានចែងក្នុងច្បាប់ស្ដីពីសុំកូនអន្តរប្រទេស និងក៏គិតគូដល់ឧត្តមប្រយោជន៍របស់កុមារផងដែរ។

- រៀបចំធ្វើលិខិតផ្ញើទៅអ្នកសុំ និងភ្ជាប់សំណុំឯកសារពាក់ព័ន្ធរបស់កុមារដែលត្រូវបានផ្តល់ផ្គូផ្គងឲ្យលើកលែងតែករណីសុំកូនដោយសាច់ញាតិ។
- ពិនិត្យខ្លឹមសារលិខិតឆ្លើយតបរបស់អ្នកសុំដែលយល់ព្រមទទួលយកកុមារ ឬមិនទទួលយក ករណីបដិសេធត្រូវពិនិត្យឈ្មោះកុមារផ្សេងទៀតផ្គូផ្គងឲ្យជាលើកទីពីរ ហើយមិនអនុញ្ញាតឲ្យមានការផ្គូផ្គងជាលើកទីបីទៀយ។
- បន្ទាប់ពីអ្នកសុំឆ្លើយតបយល់ព្រម ត្រូវរៀបចំឲ្យមានការជួបគ្នារវាងអ្នកសុំជាមួយកុមារដែលត្រូវបានផ្គូផ្គងរួចហើយតាមកាលបរិច្ឆេទមួយសមស្របត្រឹមត្រូវតាមបែបបទ នីតិវិធី និងបទប្បញ្ញត្តិ ដែលមានកំណត់ក្នុងច្បាប់ស្តីពីសុំកូនអន្តរប្រទេស។
- រៀបចំធ្វើសម្ភាសន៍អ្នកសុំមុនការជួបគ្នាជាមួយកុមារ ហើយកុមារក៏ត្រូវបានពិគ្រោះយោបល់ជាមុនផងដែរ។
- ចាត់ចែងធ្វើកំណត់ហេតុអំពីការធ្វើសម្ភាសន៍ និងការជួបគ្នារវាងអ្នកសុំជាមួយកុមារ។
- ធ្វើកំណត់បង្ហាញ ផ្តល់យោបល់ ដាក់សំណុំលិខិតទាំងអស់ជូនគណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសសុំការពិនិត្យ និងផ្តល់អនុសាសន៍លើដំណើរការសុំកូន។
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសប្រគល់ឲ្យ។

ឃ-ការងារបន្តនីតិវិធីទៅតុលាការ:

- សហការជាមួយទីភ្នាក់ងារសុំកូនអន្តរប្រទេស ដើម្បីឲ្យអ្នកសុំរៀបចំដាក់ពាក្យសុំកូនទៅសាលាដំបូងរាជធានីភ្នំពេញតាមរយៈរដ្ឋបាលសុំកូនអន្តរប្រទេស។
- ពិនិត្យផ្ទៀងផ្ទាត់ឡើងវិញឲ្យបានត្រឹមត្រូវនូវសំណុំលិខិតទាំងអស់របស់កុមារ និងរបស់អ្នកសុំ រួចហើយបញ្ជូនពាក្យសុំកូន និងសំណុំលិខិតទាំងអស់នេះទៅសាលាដំបូងរាជធានីភ្នំពេញដើម្បីសុំដីកាសម្រេច។
- សហការជាមួយមន្ត្រីគ្រប់គ្រងសំណុំលិខិតអត្តសញ្ញាណកុមារ និងពិនិត្យឯកសារឡើងវិញឲ្យបានគ្រប់គ្រាន់ ច្បាស់លាស់ដើម្បីត្រៀមឡើងបំភ្លឺតុលាការក្នុងករណីចាំបាច់ និងអាចរកមេធាវីជួយការពារក្តីផង។
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសប្រគល់ឲ្យ។

ង-ការងារទាក់ទងជូនដំណឹងពីចំណាត់ការ និងនីតិវិធីបន្ទាប់ពីបញ្ចប់ដំណើរការសុំកូន:

- ជូនដំណឹងឲ្យបានទៀងទាត់ទៅអ្នកសុំអំពីចំណាត់ការ និងការវិវត្តនៃនីតិវិធីសុំកូន តាមមាត្រា ៤៣ ក្នុងច្បាប់ស្តីពីសុំកូនអន្តរប្រទេស។
- ធ្វើលិខិតរបស់ក្រសួងជូនដំណឹងទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិអំពីការសម្រេចរបស់តុលាការ។
- ធ្វើលិខិតបញ្ជាក់សុំកូនដាក់ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាចុះហត្ថលេខា។
- រៀបចំពិធីប្រគល់កុមារ ជូនលិខិតបញ្ជាក់សុំកូន និងធ្វើកំណត់ហេតុអំពីពិធីប្រគល់កុមារ។
- សហការជួយសម្របសម្រួលជាមួយស្ថាប័នមានសមត្ថកិច្ចក្នុងការធ្វើលិខិតឆ្លងដែន និងទិដ្ឋាការឲ្យកុមារបានធ្វើដំណើរទៅកាន់ប្រទេសទទួលដោយសុវត្ថិភាព និងស្របតាមនីតិវិធីច្បាប់ស្តីពីសុំកូនអន្តរប្រទេស។
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសប្រគល់ឲ្យ។

**៣.ការិយាល័យអភិវឌ្ឍ គ្រប់គ្រងទីភ្នាក់ងារ រដ្ឋបាលកិច្ច និងសហប្រតិបត្តិការអន្តរជាតិ**

ក.ការងារអភិវឌ្ឍ:

- រៀបចំតាក់តែងសេចក្តីព្រាងគោលនយោបាយ ច្បាប់ បទបញ្ញា និងនីតិវិធីថ្មីៗតាមការចាំបាច់ដើម្បីធ្វើឲ្យប្រសើរឡើងចំពោះការងារសុំកូនអន្តរប្រទេស។
- ពិនិត្យ និងផ្តល់យោបល់ជូនគណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស អំពីការអនុវត្តគោលនយោបាយ ច្បាប់ បទបញ្ញា និងនីតិវិធីទាក់ទងនឹងសុំកូនអន្តរប្រទេស ព្រមទាំងអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស។
- ធ្វើសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន ដែលមានសមត្ថកិច្ចលើកិច្ចការសុំកូនអន្តរប្រទេស និងទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលធ្វើប្រតិបត្តិការសុំកូននៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- ទប់ស្កាត់សកម្មភាពទាំងឡាយដែលបំពានច្បាប់ស្តីពីសុំកូនអន្តរប្រទេស អនុសញ្ញាស្តីពីសិទ្ធិកុមារ អនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស។
- រៀបចំបើកវគ្គផ្សព្វផ្សាយច្បាប់ស្តីពីសុំកូនអន្តរប្រទេស លិខិតបទដ្ឋានជាតិ និងអន្តរជាតិពាក់ព័ន្ធនឹងសុំកូនអន្តរប្រទេសដល់មន្ត្រីរបស់ក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋានជាពិសេស ឃុំ សង្កាត់។
- រៀបចំកម្មវិធីបណ្តុះបណ្តាលសម្រាប់មន្ត្រីពាក់ពន្ធ័ការងារសុំកូនអន្តរប្រទេស និងអ្នកពាក់ពន្ធ័ផ្សេងទៀត។
- តាមដាន វាយតម្លៃលទ្ធផលនៃការបណ្តុះបណ្តាល។
- រៀបចំបោះពុម្ពសៀវភៅច្បាប់សុំកូនអន្តរប្រទេស អនុសញ្ញាអន្តរជាតិ និងឯកសារពាក់ព័ន្ធផ្សេងៗទៀត។
- រៀបចំតាក់តែង និងបោះពុម្ពសៀវភៅផ្នត់ ស្តីពីនីតិវិធីសុំកូនអន្តរប្រទេស។
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានរដ្ឋបាលសុំកូនអន្តរប្រទេសប្រគល់ជូន។

ខ-ការងារគ្រប់គ្រងទីភ្នាក់ងារ:

- ពិនិត្យ និងផ្តល់យោបល់ ក្នុងការអនុញ្ញាតឲ្យទីភ្នាក់ងារសុំកូនអន្តរប្រទេសធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- រៀបចំកិច្ចសន្យារវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាមួយទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- ពិនិត្យ និងផ្តល់យោបល់លើកិច្ចព្រមព្រៀងរវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាមួយទីភ្នាក់ងារសុំកូនអន្តរប្រទេស ស្តីពីការផ្តល់ជំនួយមនុស្សធម៌ ការជួយឧបត្ថម្ភដល់កុមារកំព្រានិង កុមាររងគ្រោះដទៃទៀតដែលមិនពាក់ព័ន្ធជាមួយការងារសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានរដ្ឋបាលសុំកូនអន្តរប្រទេសប្រគល់ជូន។

គ.ការងារអធិការកិច្ច:

- ចុះធ្វើការស្រាវជ្រាវលើសំណុំឯកសារអត្តសញ្ញាណកុមារជាមុខសញ្ញាសុំកូនអន្តរប្រទេសដែលមានឈ្មោះក្នុងបញ្ជីកុមារជាកម្មវត្ថុនៃសុំកូនអន្តរប្រទេសក្នុងករណីចាំបាច់។

- ធ្វើអធិការកិច្ចចំពោះទីភ្នាក់ងារសុំកូនអន្តរប្រទេស និងអ្នកតំណាងទាំងអស់ដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការធ្វើអធិការកិច្ច។
- រៀបចំដាក់ពិន័យអន្តរការណ៍ចំពោះទីភ្នាក់ងារ តាមការសម្រេចរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្របតាមច្បាប់ស្តីពីសុំកូនអន្តរប្រទេស។
- រៀបចំឯកសារបញ្ជូនទៅតុលាការ ករណីទីភ្នាក់ងារមិនព្រមបង់ពិន័យអន្តរការណ៍។
- សម្របសម្រួលជាមួយអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួលដើម្បីផ្តល់ ឬសម្របសម្រួលសេវាក្រោយសុំកូនសមស្របដល់កុមារ គ្រួសារចិញ្ចឹម និងគ្រួសារបង្កើតតាមការចាំបាច់ដូចមានចែងក្នុងមាត្រា ៩៥ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស។
- ណែនាំអ្នកសុំកូនឲ្យធ្វើរបាយការណ៍អំពីស្ថានភាពវិវឌ្ឍរបស់កុមារមករដ្ឋបាលសុំកូនអន្តរប្រទេសឲ្យបានទៀងទាត់តាមការកំណត់ក្នុងច្បាប់ស្តីពីសុំកូនអន្តរប្រទេស។
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសប្រគល់ឲ្យ។

ឃ.ការងារសហប្រតិបត្តិការអន្តរជាតិ:

ជំនួយការឲ្យប្រធានរដ្ឋបាលសុំកូនអន្តរប្រទេសក្នុងការងារ:

- ទំនាក់ទំនងនិងសហប្រតិបត្តិការជាមួយអាជ្ញាធរកណ្តាល និងអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសទទួល រដ្ឋជាភាគីអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារនិងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស និងប្រទេសដទៃទៀតដែលមានកិច្ចសហប្រតិបត្តិការសុំកូនអន្តរប្រទេសជាមួយប្រទេសកម្ពុជា។
- ជំរុញកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីទប់ស្កាត់សកម្មភាពទាំងឡាយដែលពាក់ព័ន្ធនឹងការជួញដូរកុមារតាមរយៈសុំកូនអន្តរប្រទេស ស្របតាមច្បាប់ស្តីពីសុំកូនអន្តរប្រទេស និងអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស។
- បំពេញបែបបទ និងផ្តល់ព័ត៌មានទៅការិយាល័យអចិន្ត្រៃយ៍នៃសន្និសីទក្រុងឡាអេស្តីពីច្បាប់អន្តរជាតិ ឯកជន តាមតម្រូវការ និងកាតព្វកិច្ចនៃប្រទេសជាភាគីនៃអនុសញ្ញានេះ។
- ទំនាក់ទំនង និងសហការជាមួយការិយាល័យអចិន្ត្រៃយ៍នៃសន្និសីទក្រុងឡាអេស្តីពីច្បាប់អន្តរជាតិ ឯកជន រដ្ឋជាភាគីអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារនិងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស អង្គការជាតិ អង្គការអន្តរជាតិពាក់ព័ន្ធ ដៃគូអភិវឌ្ឍ និងប្រទេសជាមិត្តនានាដើម្បីទាក់ទាញការជួយឧបត្ថម្ភគាំទ្រផ្នែកបច្ចេកទេស និងសម្ភារៈចំពោះការងារសុំកូនអន្តរប្រទេសនៅកម្ពុជា។
- រៀបចំកិច្ចព្រមព្រៀងនានារវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាមួយអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទទួលទាំងអស់ដែលពាក់ព័ន្ធលើការងារសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានរដ្ឋបាលសុំកូនអន្តរប្រទេសប្រគល់ជូន។

**ប្រការ ៧.–**

រដ្ឋបាលសុំកូនអន្តរប្រទេសមានសិទ្ធិប្រើប្រាស់ត្រាដោយឡែកសម្រាប់ប្រតិបត្តិការមុខងាររបស់ខ្លួន។

## ប្រការ ៨.-

នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធាននាយកដ្ឋានសុខុមាលភាពកុមារ ប្រធានរដ្ឋបាលស្នងកូនអន្តរប្រទេស ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានីខេត្ត និងអង្គភាពពាក់ព័ន្ធមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

អ៊ិត សំហេង

<u>ចម្លងជូន:</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យ **សម្តេចតេជោ នាយករដ្ឋមន្ត្រី**
-ខុទ្ទកាល័យលោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ
-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
-ក្រសួងយុត្តិធម៌
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួង ស្ថាប័នពាក់ព័ន្ធ
-ដូចប្រការ ៨
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

# ប្រកាស

## ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ
## របស់អាជ្ញាធរកណ្តាលសុំកូនអន្តរ
## ប្រទេសនៃព្រះរាជាណាចក្រកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

លេខ ២៤៩ ស.អ.យ.

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែមករា ឆ្នាំ ២០១៣

# ប្រកាស
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្តាលស្មុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា

---

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុសញ្ញាស្តីពីសិទ្ធិកុមារដែលក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា បានសុំចូលជាភាគីនៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២
- បានឃើញព្រះរាជក្រម នស/រកម/០១០៧/០០៣ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងស្មុំកូនអន្តរប្រទេស
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៨ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស
- បានឃើញអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញការចាំបាច់របស់ក្រសួង

## សម្រេច

### ប្រការ ១.-

ប្រកាសនេះកំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្តាលស្មុំកូនអន្តរប្រទេសនៃ ៈរាជាណាចក្រកម្ពុជា មានអក្សរកាត់ថា "អ.ក.ស.អ" ជាភាសាអង់គ្លេស "Central Authority for ter-country Adoption (C.A.I.A)។



ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ. ទូរស័ព្ទ/ទូរសារៈ (៨៥៥) ២៣ ៧២ ៦១ ៨៣

## ប្រការ ២.-

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បំពេញតួនាទីជាអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជាស្របតាមមាត្រា ៦ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស។

## ប្រការ ៣.-

អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជាមានភារកិច្ចដូចតទៅ៖

១.រៀបចំ និងត្រួតពិនិត្យការអនុវត្តគោលនយោបាយ ច្បាប់ បទបញ្ញា និងនីតិវិធីទាក់ទងនឹងការសម្រេចលើកិច្ចការសុំកូនអន្តរប្រទេស។

២.ធ្វើសហប្រតិបត្តិការ និងសម្របសម្រួលលើការប្រាស្រ័យទាក់ទងគ្នាទៅនឹងកិច្ចការសុំកូនអន្តរប្រទេសជាមួយក្រសួង ស្ថាប័ន និងទីភ្នាក់ងារដែលមានសមត្ថកិច្ចដោះស្រាយកិច្ចការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងជាមួយអាជ្ញាធរកណ្តាល និងអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសទទួល។

៣.ចាត់វិធានការសមស្របដើម្បីបង្ការ និងទប់ស្កាត់ការទទួលផលកម្រៃផ្នែកហិរញ្ញវត្ថុដោយមិនសមស្រប ឬផលចំណេញផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេស។

៤.រៀបចំបណ្តុះបណ្តាលជំនាញកិច្ចការសុំកូនអន្តរប្រទេសដល់មន្ត្រីពាក់ព័ន្ធ។

៥.ពិនិត្យលើសំណើរបស់រដ្ឋបាលសុំកូនអន្តរប្រទេស ទាក់ទងនឹងករណីសុំកូនអន្តរប្រទេសនីមួយៗតាមការចាំបាច់។

៦.ធ្វើអធិការកិច្ចលើការងារទាំងឡាយដែលពាក់ព័ន្ធជាមួយសុំកូនអន្តរប្រទេស។គ្មានជនណាអាចរារាំង បង្អាក់ ឬជ្រៀតជ្រែកក្នុងការងារអធិការកិច្ចដែលបានធ្វើឡើងត្រឹមត្រូវតាមច្បាប់បានឡើយ។

៧.ចាត់វិធានការដ៏សមស្របដើម្បីប្រមូល រក្សាការពារ និងផ្លាស់ប្តូរព័ត៌មានអំពីស្ថានភាពរបស់កុមារ និងរក្សាទុកព័ត៌មានទាក់ទងនឹងប្រភពកំណើតរបស់កុមារ អត្តសញ្ញាណរបស់កុមារ ឪពុកម្តាយកុមារ និងប្រវត្តិសុខភាពកុមារ។

៨.រក្សា និងផ្តល់ស្ថិតិទាក់ទងនឹងសុំកូនអន្តរប្រទេសដល់ប្រទេសនានាតាមសំណើ។

៩.ទទួលប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានាពីអ្នកសុំកូនត្រូវបង់តាមរយៈទីភ្នាក់ងារសុំកូនអន្តរប្រទេស ឬអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសទទួល។

១០.ទទួលខុសត្រូវក្នុងការកត់ត្រា តាមដានប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានាដែលប្រមូលបាន និងបង់ប្រាក់ចូលក្នុងគណនីប្រាក់បញ្ញើរបស់គណៈកម្មាធិការគ្រប់គ្រង និងចាត់ចែងប្រាក់វិភាគទានមនុស្សធម៌នៅធនាគារជាតិ។

១១.ធ្វើរបាយការណ៍ស្តីពីស្ថានភាពប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានាដែលប្រមូលបាន និងបង់ប្រាក់ចូលក្នុងគណនីប្រាក់បញ្ញើនៅធនាគារជាតិជាទៀងរាល់ខែ ត្រីមាស និងប្រចាំឆ្នាំជូនគណៈកម្មាធិការគ្រប់គ្រង និងចាត់ចែងប្រាក់វិភាគទានមនុស្សធម៌។

១២.ពិនិត្យ ផ្តល់អនុសាសន៍ និងបញ្ជូនសំណុំឯកសារសុំកូនអន្តរប្រទេសនីមួយៗទៅតុលាការ។

១៣.បំពេញភារកិច្ចផ្សេងៗទៀតដែលក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា យល់ថាចាំបាច់សម្រាប់អនុវត្តកិច្ចការសុំកូនអន្តរប្រទេសដោយអនុលោមទៅតាមច្បាប់ និងបទបញ្ញាជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

## ប្រការ ៤.-

អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយគណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស។

## ប្រការ ៥.-

គណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស មានសមាសភាពដូចតទៅ៖

| | |
|---|---|
| ១.រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ប្រធាន |
| ២.រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ទទួលបន្ទុកវិស័យសុខុមាលភាពកុមារ | អនុប្រធាន |
| ៣.អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៤.ឥស្សរជនមានបទពិសោធន៍លើវិស័យសុខុមាលភាពកុមារ | សមាជិក |
| ៥.អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស | សមាជិក |
| ៦.អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និង ហិរញ្ញវត្ថុ | សមាជិក |
| ៧.អគ្គាធិការនៃអគ្គាធិការដ្ឋាន | សមាជិក |
| ៨.អគ្គលេខាធិការក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ | សមាជិក |
| ៩.អ្នកជំនាញការជាតិលើវិស័យសុខុមាលភាពកុមារ | សមាជិក |
| ១០.ប្រធាននាយកដ្ឋានសុខុមាលភាពកុមារ | សមាជិក |
| ១១.ប្រធានរដ្ឋបាលសុំកូនអន្តរប្រទេស | អគ្គលេខាធិការ |

ការតែងតាំងសមាសភាពគណៈកម្មាធិការអាជ្ញាធរកណ្តាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

## ប្រការ ៦.-

គណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

១.ពិនិត្យ និងសម្រេចចុងក្រោយពាក់ព័ន្ធនិងនីតិវិធីសុំកូនអន្តរប្រទេស។

២.ពិនិត្យ និងផ្តល់អនុសាសន៍តាមការចាំបាច់លើគោលនយោបាយ ច្បាប់ បទបញ្ញា និងនីតិវិធីទាក់ទងនឹងកិច្ចការសុំកូនអន្តរប្រទេស។ តាមដាន ត្រួតពិនិត្យការអនុវត្តគោលនយោបាយ ច្បាប់ បទបញ្ញា និងនីតិវិធីទាក់ទងនឹងសុំកូនអន្តរប្រទេស។

៣.ធ្វើសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន និងទីភ្នាក់ងារដែលមានសមត្ថកិច្ចដោះស្រាយកិច្ចការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងជាមួយអាជ្ញាធរកណ្តាល និងអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសទទួល។

៤.ចាត់វិធានការសមស្របដើម្បីបង្ការ ទប់ស្កាត់ការទទួលផលកម្រៃផ្នែកហិរញ្ញវត្ថុដោយមិនសមស្រប ឬផលចំណេញផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេស។

៥.ពិនិត្យ និងផ្តល់អនុសាសន៍លើសកម្មភាពបណ្តុះបណ្តាលជំនាញដល់មន្ត្រីពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធផ្សេងទៀតលើការងារសុំកូនអន្តរប្រទេស។

៦.ពិនិត្យ សម្រេចលើសំណើផ្គូផ្គងកុមារនឹងអ្នកសុំដែលស្នើឡើងដោយរដ្ឋបាលសុំកូនអន្តរប្រទេស និងផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលសុំកូនអន្តរប្រទេស កំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**ប្រការ ១០.–**

ប្រកាសលេខ ១៩៨០ ស.អ.យ. ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្តាល និងរដ្ឋបាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ ១១.–**

នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធាននាយកដ្ឋានសុខុមាលភាពកុមារ ប្រធានរដ្ឋបាលសុំកូនអន្តរប្រទេស ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី.ខេត្ត និងអង្គភាពពាក់ព័ន្ធមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**អ៊ិត សំហេង**

<u>ចម្លងជូន:</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យ **សម្តេចតេជោ នាយករដ្ឋមន្ត្រី**
-ខុទ្ទកាល័យលោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ
-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
-ក្រសួងយុត្តិធម៌
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួង ស្ថាប័នពាក់ព័ន្ធ
-ដូចប្រការ ១១
-រាជកិច្ច
- ឯកសារ. កាលប្បវត្តិ